**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

*រាជរដ្ឋាភិបាលកម្ពុជា*

# របាយការណ៍វឌ្ឍនភាពឆ្នាំ២០១៩

## នៃការសម្រេចបាន

## គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា (គ.អ.ច.ក.)

## ២០១៦-២០៣០



រាជធានីភ្នំពេញ ខែសីហា ឆ្នាំ២០២០

# តារាងមាតិកា


តារាងមាតិកា .................................................................................... i

បញ្ជីតារាង .................................................................................... iv

បញ្ជីរូបភាព .................................................................................... v

ពាក្យបំប្រួញ .................................................................................... vi

សេចក្តីសង្ខេប .................................................................................... viii

**ជំពូកទី១៖ សេចក្តីផ្តើម**.................................................................................... ១

១.១ បរិការណ៍នៃប្រទេសកម្ពុជា .................................................................................... ១

១.២ ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការធ្វើឱ្យសម្រេចបាន គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា .................................................................................... ៥

១.៣ ដំណើរការមូលដ្ឋាននីយកម្មនិងសមាហរណកម្ម .................................................................................... ៥

១.៤ មូលហេតុនៃការរៀបចំរបាយការណ៍វឌ្ឍនភាពឆ្នាំ២០១៩ នៃការសម្រេចបាន គ.អ.ច.ក.... ៦

**ជំពូកទី២៖ វិធីសាស្រ្តនិងដំណើរការសម្រាប់ការតាមដានត្រួតពិនិត្យនិងវាយតម្លៃការសម្រេចបាន គ.អ.ច.ក. ២០១៦-២០៣០** .................................................................................... ៩

២.១ សេចក្តីផ្តើម .................................................................................... ៩

២.២ វិធីសាស្រ្ត និង ប្រភពព័ត៌មាន .................................................................................... ៩

២.៣ ដំណើរការនៃការរៀបចំសេចក្តីព្រាងរបាយការណ៍វឌ្ឍនភាពឆ្នាំ២០១៩ នៃការសម្រេចបាន គ.អ.ច.ក. .................................................................................... ១០

**ជំពូកទី៣៖ បរិយាកាសនយោបាយដែលអំណោយផលសម្រាប់ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ការសម្រេចបាន គ.អ.ច.ក. ២០១៦-២០៣០** .................................................................................... ១២

៣.១ ការបង្កើតភាពជាម្ចាស់លើការរៀបចំនិងអនុវត្តគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា ១២

៣.២ ការធ្វើសមាហរណកម្ម គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា ទៅក្នុងក្របខ័ណ្ឌនៃការរៀបចំផែនការនិងគោលនយោបាយជាតិ .................................................................................... ១៣

៣.៣ ការបន្សុីគ្នារវាងសមាសភាពទាំងបីនៃការអភិវឌ្ឍប្រកបដោយចីរភាពនិងបរិយាប័ន្ន ទៅក្នុងយុទ្ធសាស្រ្តនៃការអភិវឌ្ឍកម្ពុជា .................................................................................... ១៤

៣.៤ ការអភិវឌ្ឍសេដ្ឋកិច្ច ចីរភាព និង បរិយាប័ន្ន .................................................................................... ១៦

៣.៥ មិនមាននរណាម្នាក់ត្រូវបានទុកឱ្យនៅឯកោ .................................................................................... ១៧

៣.៦ ការធានាឱ្យមានចីរភាពបរិស្ថាន .................................................................................... ១៨

**ជំពូកទី៤៖ វឌ្ឍនភាពតាមសូចនាករ និងចំណុចដៅ ក្នុងគោលដៅនីមួយៗ** .................................................................................... ២០

៤.១ សេចក្តីផ្តើម ........................................................................ ២០

៤.២ ការវាយតម្លៃសូចនាករ និងចំណុចដៅ តាមគោលដៅនីមួយៗ ................................ ២១

គោលដៅទី១៖ បញ្ចប់ភាពក្រីក្រគ្រប់ទម្រង់នៅគ្រប់ទីកន្លែង ........................................ ២២

គោលដៅទី២៖ បញ្ចប់ភាពអត់ឃ្លាន សម្រេចឱ្យបានសន្តិសុខស្បៀង ធ្វើឱ្យប្រសើរឡើងស្ថានភាពអាហារូបត្ថម្ភ និងលើកកម្ពស់កសិកម្មប្រកបដោយចីរភាព ................ ២៥

គោលដៅទី៣៖ ធានាជីវភាពរស់នៅរបស់ប្រជាជនប្រកបដោយសុខភាពល្អ និងលើកកម្ពស់សុខុមាលភាពរបស់មនុស្សគ្រប់រូប និងគ្រប់វិស័យ ................................ ៣០

គោលដៅទី៤៖ ធានាការអប់រំប្រកបដោយគុណភាព បរិយាប័ន្ន និងសមធម៌ និង លើកកម្ពស់កាលានុវត្តភាពសិក្សាមួយជីវិត សម្រាប់ប្រជាជនគ្រប់រូប ........................ ៣៥

គោលដៅទី៥៖ សម្រេចឱ្យបានសមភាពយេនឌ័រ និងពង្រឹងភាពអង់អាចរបស់ស្ត្រី និងកុមារីគ្រប់រូប ........................................................................ ៤០

គោលដៅទី៦៖ ធានាឱ្យមានទឹក និងអនាម័យ និង ការគ្រប់គ្រងទឹក និងអនាម័យប្រកបដោយចីរភាពសម្រាប់ប្រជាជនគ្រប់រូប ........................................ ៤៧

គោលដៅទី៧៖ ធានាឱ្យទទួលបានថាមពលដែលមានលក្ខណៈបច្ចេកទេសទំនើប ប្រកប ដោយចីរភាព អាចជឿជាក់បាន និងមានតម្លៃសមរម្យ សម្រាប់ប្រជាជនគ្រប់រូប ........ ៥១

គោលដៅទី៨៖ ធានាកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពនិងបរិយាប័ន្ន មានមុខរបរពេញលេញនិងផលិតភាព និងមានការងារសមរម្យសម្រាប់ប្រជាជនគ្រប់រូប ........ ៥៧

គោលដៅទី៩៖ កសាងហេដ្ឋារចនាសម្ព័ន្ធដែលធន់នឹងការប្រែប្រួលអាកាសធាតុ លើកកម្ពស់ឧស្សាហូនីយកម្មប្រកបដោយចីរភាពនិងបរិយាប័ន្ននិងលើកកម្ពស់នវានុវត្តន៍. ៦១

គោលដៅទី១០៖ កាត់បន្ថយវិសមភាពនៅក្នុងប្រទេសនិងក្នុងចំណោមបណ្តាប្រទេសនានា ..... ៦៥

គោលដៅទី១១៖ ធ្វើឱ្យទីក្រុងនិងកន្លែងតាំងលំនៅថ្មីៗសម្រាប់ប្រជាជន មានលក្ខណៈបរិយាប័ន្ន សុវត្ថិភាព ធន់នឹងការប្រែប្រួលអាកាសធាតុ និងចីរភាព ........................ ៦៨

គោលដៅទី១២៖ ធានាឱ្យមានចីរភាពក្នុងទម្រង់នៃការប្រើប្រាស់និងផលិតកម្មវឌ្ឍនភាព ........ ៧១

គោលដៅទី១៣៖ ចាត់វិធានការជាបន្ទាន់ ដើម្បីប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់ ........................................................................ ៧៤

គោលដៅទី១៤៖ អភិរក្សនិងប្រើប្រាស់ប្រកបដោយចីរភាពនូវមហាសមុទ្រ សមុទ្រ និងធនធានសមុទ្រ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ........................................ ៧៨

គោលដៅទី១៥៖ ការពារ ស្តារ និងជំរុញការប្រើប្រាស់ប្រកបដោយចីរភាពនូវ ប្រព័ន្ធអេកូឡូស៊ីលើដែនគោក គ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព ប្រយុទ្ធប្រឆាំងនឹងឱនភាពដី បញ្ឈប់និងបង្វែរទិសនៃការសឹករេចរិលគុណភាពដី និងបញ្ឈប់កុំឱ្យបាត់បង់ជីជាតិដីនិងជីវៈចម្រុះ ........................................................................ ៨២

គោលដៅទី១៦៖ លើកកម្ពស់សង្គមដែលមានសន្តិភាពប្រកបដោយបរិយាប័ន្ន ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព ផ្តល់នូវការទទួលបានយុត្តិធម៌សម្រាប់ប្រជាជនគ្រប់រូប និងកសាងស្ថាប័នដែលមានប្រសិទ្ធភាព គណនេយ្យភាព និងបរិយាប័ន្ន នៅគ្រប់កម្រិត ........ ៨៦

គោលដៅទី១៧៖ ពង្រឹងមធ្យោបាយអនុវត្តនានា និងបង្កើតភាពរស់រវើកនៃភាពជាដៃគូសាកលសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព........ ៩៣

គោលដៅទី១៨៖ បញ្ចប់ផលប៉ះពាល់ជាវិជ្ជមានរបស់មីន/សំណល់ជាតិផ្ទុះពីសង្គ្រាម និងជំរុញការសង្គ្រោះជនរងគ្រោះ ........ ៩៨

**ជំពូកទី៥៖ មធ្យោបាយនិងការអនុវត្តបន្ត សម្រាប់ការសម្រេចបាន គ.អ.ច.ក. ២០១៦-២០៣០ ........ ១០២**

៥.១ ការធ្វើសមាហរណកម្ម គ.អ.ច.ក. ទៅក្នុងប្រព័ន្ធផែនការនិងគោលនយោបាយជាតិ ........ ១០២

៥.២ ការផ្តល់ធនធាន និងការធ្វើឱ្យសម្រេចបានគោលដៅ ........ ១០៥

៥.៣ ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ និងមតិយោបល់គោលនយោបាយ ........ ១០៩

៥.៤ ការលើកកម្ពស់ចំណេះដឹង ........ ១១១

៥.៥ ការកសាងសមត្ថភាព ........ ១១២

៥.៦ ការលើកកម្ពស់ភាពជាដៃគូពហុភាគី ........ ១១៣

**ជំពូកទី៦៖ សេចក្តីសន្និដ្ឋាន ........ ១១៥**

**ឧបសម្ព័ន្ធ ........ ១១៩**

ឧបសម្ព័ន្ធ ១៖ ឯកសារយោង ........ ១១៩

ឧបសម្ព័ន្ធ ២៖ បញ្ជីប្រភពទិន្នន័យសម្រាប់ចំណុចដៅ គ.អ.ច.ក. ........ ១២១

# បញ្ជីតារាង


តារាង ១.១៖ សង្ខេបពីលទ្ធផលនៃការអនុវត្ត គ.អ.ស.ក. ........ ៣
តារាង ៤.១៖ វឌ្ឍនភាពគោលដៅទី១ នៃ គ.អ.ច.ក. ........ ២២
តារាង ៤.២៖ វឌ្ឍនភាពគោលដៅទី២ នៃ គ.អ.ច.ក. ........ ២៨
តារាង ៤.៣៖ វឌ្ឍនភាពគោលដៅទី៣ នៃ គ.អ.ច.ក........ ៣១
តារាង ៤.៤៖ វឌ្ឍនភាពគោលដៅទី៤ នៃ គ.អ.ច.ក. ........ ៣៦
តារាង ៤.៥៖ វឌ្ឍនភាពគោលដៅទី៥ នៃ គ.អ.ច.ក. ........ ៤៤
តារាង ៤.៦៖ វឌ្ឍនភាពគោលដៅទី៦ នៃ គ.អ.ច.ក. ........ ៤៩
តារាង ៤.៧៖ វឌ្ឍនភាពគោលដៅទី៧ នៃ គ.អ.ច.ក. ........ ៥៣
តារាង ៤.៧.១៖ សូចនាករសមិទ្ធផលសំខាន់ៗ ក្នុងវិស័យរ៉ែ និង ថាមពល. ........ ៥៤
តារាង ៤.៨៖ វឌ្ឍនភាពគោលដៅទី៨ នៃ គ.អ.ច.ក. ........ ៥៨
តារាង៤.៩៖ វឌ្ឍនភាពគោលដៅទី៩ នៃ គ.អ.ច.ក. ........ ៦២
តារាង ៤.១០៖ វឌ្ឍនភាពគោលដៅទី១០ នៃ គ.អ.ច.ក. ........ ៦៦
តារាង ៤.១១៖ វឌ្ឍនភាពគោលដៅទី១១ នៃ គ.អ.ច.ក. ........ ៦៩
តារាង ៤.១២៖ វឌ្ឍនភាពគោលដៅទី១២ នៃ គ.អ.ច.ក........ ៧៣
តារាង ៤.១៣៖ វឌ្ឍនភាពគោលដៅទី១៣ នៃ គ.អ.ច.ក. ........ ៧៥
តារាង ៤.១៤៖ វឌ្ឍនភាពគោលដៅទី១៤ នៃ គ.អ.ច.ក. ........ ៨០
តារាង ៤.១៥៖ វឌ្ឍនភាពគោលដៅទី១៥ នៃ គ.អ.ច.ក. ........ ៨៣
តារាង ៤.១៦៖ វឌ្ឍនភាពគោលដៅទី១៦ នៃ គ.អ.ច.ក. ........ ៨៧
តារាង៤.១៧៖ វឌ្ឍនភាពគោលដៅទី១៧ នៃ គ.អ.ច.ក. ........ ៩៥
តារាង ៤.១៨៖ វឌ្ឍនភាពគោលដៅទី១៨ នៃ គ.អ.ច.ក. ........ ៩៩

# បញ្ជីរូបភាព


រូបភាព ១.១៖ និន្នាការវិសមភាពនៃការប្រើប្រាស់ ២០០៧-២០១៤ ........................ ១

រូបភាព ១.២៖ សន្ទស្សន៍អភិវឌ្ឍធនធានមនុស្ស ពីឆ្នាំ១៩៩០ ដល់២០១៥ .................... ២

រូបភាព ២.១៖ ការរៀបចំរបាយការណ៍វឌ្ឍនភាពឆ្នាំ២០១៩ នៃការសម្រេចបាន គ.អ.ច.ក. និងប្រភពព័ត៌មាន ........................................................... ១០

រូបភាព ៣.១៖ អាណត្តិកាលរបស់ គ.អ.ច.ក. និង ផែនការជាតិ ............................ ១៤

រូបភាព ៣.២៖ យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ ........................................ ១៦

រូបភាព ៤.១៖ លទ្ធផលនៃការអនុវត្តគោលដៅនៃ គ.អ.ច.ក. ................................. ២១

រូបភាព ៤.២៖ គោលដៅជាយុទ្ធសាស្ត្រ ទាំង ៧ នៃវិស័យសុខាភិបាល ...................... ៣៣

រូបភាព ៥.១៖ ចំណុចផ្សារភ្ជាប់រវាង ក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា និងដំណើរការនៃការរៀបចំផែនការនិងថវិកា ...................................... ១០៣

រូបភាព ៥.២៖ ចំណោលលំហូរហិរញ្ញវត្ថុ ដល់ឆ្នាំ២០២៥ (សេណារីយ៉ូកម្រិតទាបនិងខ្ពស់) ១០៧

# ពាក្យបំប្រួញ

| | |
|---|---|
| ក.ក.ន. | ក្រសួងកិច្ចការនារី |
| ក.ក.រ.ន. | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ក.ជ.អ.ច. | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព |
| ក.ទ.ច. | ក្រសួងទេសចរណ៍ |
| ក.ទ.រ.ព.អ. | ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច |
| ក.ប.ទ. | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ |
| ក.ប.ស. | ក្រសួងបរិស្ថាន |
| ក.ផ.ក. | ក្រសួងផែនការ |
| ក.ព.ក. | ក្រសួងពាណិជ្ជកម្ម |
| ក.ម.ផ. | ក្រសួងមហាផ្ទៃ |
| ក.ម.ស. | ក្រសួងមុខងារសាធារណៈ |
| ក.រ.ថ. | ក្រសួងរ៉ែនិងថាមពល |
| ក.ស.ដ. | ក្រសួងសាធារណៈការនិងដឹកជញ្ជូន |
| ក.ស.ហ. | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| ក.ស.អ.យ. | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| ក.វ.ស | កម្មវិធីវិនិយោគសាធារណៈ |
| ក.ស.ភ. | ក្រសួងសុខាភិបាល |
| ក.អ.ក. | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| ក.អ.ជ. | ក្រសួងអភិវឌ្ឍន៍ជនបទ |
| ក.អ.យ.ក. | ក្រសួងអប់រំ យុវជន និងកីឡា |
| ក.ឧ.ស. | ក្រសួងឧស្សាហកម្ម |
| គ.ជ.អ.ប. | គណៈកម្មាធិការជាតិសម្រាប់ការអនុវត្តតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| គ.អ.ច. | គោលដៅអភិវឌ្ឍប្រកបដោយចីរភាព |
| គ.អ.ច.ក. | គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា |
| គ.អ.ស. | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ |
| គ.អ.ស.ក. | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា |
| គ.អ.ឧ. | គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម |
| គ.ជ.នា. | គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា |

| | |
|---|---|
| ស.ផ.ស. | សំណល់ជាតិផ្ទុះពីសង្គ្រាម |
| ផ.យ.អ.ជ. | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| ផ.ស.ស. | ផលិតផលក្នុងស្រុកសរុប |
| វ.ជ.ស. | វិទ្យាស្ថានជាតិស្ថិតិ |
| អ.ច.ស. | អាកាសចរណ៍ស៊ីវិល |
| អ.ធ.ម. | អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីននិងសង្គ្រោះជនពិការដោយសារមីន |
| អ.ល.-ក.ជ.វ.ប. | អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា |
| អ.ល.អ.ច. | អគ្គលេខាធិការនៃក្រុមប្រឹក្សាអភិវឌ្ឍន៍ដោយចីរភាព |

# សេចក្ដីសង្ខេប

ក្រោមបាវចនា ជាតិ សាសនា ព្រះមហាក្សត្រ រាជរដ្ឋាភិបាលកម្ពុជា បានប្ដេជ្ញាចិត្តចូលរួមអនុវត្ត ដើម្បីឱ្យសម្រេចបាន របៀបវារៈអភិវឌ្ឍន៍ឆ្នាំ២០៣០ របស់អង្គការសហប្រជាជាតិ។ ក្នុងរយៈពេល ៤០ ឆ្នាំចុងក្រោយនេះ កម្ពុជាបានបង្ហាញឱ្យឃើញពីការផ្លាស់ប្ដូរដ៏ធំធេង ដោយបានប្ដូរពីស្ថានភាពនៃរបប មួយដែលបានអូសបន្លាយជម្លោះផ្ទៃក្នុងដ៏យូរអង្វែង និងឆ្លងកាត់របបប្រល័យពូជសាសន៍ មកជាប្រទេស ដែលមានការអភិវឌ្ឍគ្រប់វិស័យ មានការអភិវឌ្ឍយ៉ាងឆាប់រហ័ស ទាំងវិស័យសេដ្ឋកិច្ច សង្គមកិច្ច មាន ការអភិវឌ្ឍ ពង្រឹងនិងពង្រីកធនធានមនុស្ស ដែលជាមូលដ្ឋានយ៉ាងសំខាន់សម្រាប់ការអភិវឌ្ឍ ការស្ដារ និងកសាងហេដ្ឋារចនាសម្ព័ន្ធគ្រប់វិស័យ និង បានលើកកម្ពស់ផងដែរ សិទ្ធិសេរីភាព និងលទ្ធិប្រជាធិប តេយ្យនៅទូទាំងប្រទេស។

សមិទ្ធផលទាំងនេះ គឺជាលទ្ធផលដែលកម្ពុជា បានអនុវត្តយ៉ាងមានប្រសិទ្ធភាពនូវ គោលដៅ អភិវឌ្ឍសហស្សវត្សរ៍កម្ពុជា (គ.អ.ស.ក.) ក៏ដូចជា ការចូលរួមចំណែកធ្វើឱ្យសម្រេចបាន គោលដៅ អភិវឌ្ឍសហស្សវត្សរ៍ (គ.អ.ស.) សាកល ដែលកម្ពុជា បានទទួលស្គាល់ជាប្រទេសមួយក្នុងចំណោម ប្រទេសនានា ដែលសម្រេចបានគោលដៅច្រើនជាងគេ នៃ គ.អ.ស. នៅពេលដែលបញ្ចប់អាណត្តិឆ្នាំ ២០១៥។

ក្នុងគោលបំណងបន្តកំណត់ត្រានៃភាពជោគជ័យនេះ កម្ពុជាគាំទ្របានគាំទ្រយ៉ាងខ្លាំងដល់ របៀបវារៈឆ្នាំ២០៣០ ទោះបីជាកម្ពុជាមិនទទួលយកចំណុចដៅ និងសូចនាករ ទាំងអស់ពីគោលដៅ ទាំង១៧ នៃ គ.អ.ច. សាកលក៏ដោយ។ ជាមួយគ្នានេះ កម្ពុជាក៏បានបន្ថែមគោលដៅជាតិមួយទៀត ជាមួយនឹងគ្នានឹងការបន្ថែមនូវចំណុចដៅ និងសូចនាករជាតិមួយចំនួន ដែលអាចនិយាយបានថា ជា យុទ្ធសាស្ត្រ ឈ្នះ-ឈ្នះ ដោយអាចអនុវត្តសម្រាប់ការអភិវឌ្ឍនៅក្នុងបរិការណ៍កម្ពុជាផង និងក៏អាចចូល រួមចំណែកធ្វើឱ្យសម្រេចបាន គ.អ.ច. សាកលផងដែរ។

## វឌ្ឍនភាពរហូតមកដល់ពេលបច្ចុប្បន្ន (ឆ្នាំ២០១៩)

បន្ទាប់ពីគោលដៅអភិវឌ្ឍប្រកបដោយចីរភាពសាកល ទទួលបានការអនុមតិជាផ្លូវការ ពីអង្គ ការសហប្រជាជាតិ កាលពីចុងឆ្នាំ២០១៥ មក រាជរដ្ឋាភិបាលកម្ពុជា បានធ្វើការអនុមតិគោលដៅទាំងនោះ ដាក់ក្នុងបរិការណ៍កម្ពុជា និងបានធ្វើមូលដ្ឋាននីយកម្ម ដោយបង្កើតក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកប ដោយចីរភាពកម្ពុជា។ បន្ថែមលើគោលដៅ១៧ ដែលជាគោលដៅសាកល កម្ពុជានៅតែត្រូវការគោលដៅ មួយបន្ថែមទៀត គឺគោលដៅទី១៨ ពាក់ព័ន្ធនឹងការលុបបំបាត់គ្រាប់មីននិងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះពីសង្គ្រាម ដូចនេះ ក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា មានគោលដៅចំនួន១៨ ចំណុច ដៅចំនួន

៨៨ និងសូចនាករចំនួន១៤៨។ ចំនួនគោលដៅ ចំណុចដៅ និងសូចនាករទាំងនេះ បានបង្ហាញច្បាស់ពីការប្តេជ្ញាចិត្តចូលរួមធ្វើឱ្យសម្រេចបាន គោលដៅអភិវឌ្ឍប្រកបដោយចីរភាព(គ.អ.ច.ក.)។

បន្ទាប់ពីការអនុមតិលើក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា កាលពីថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨ មក កម្ពុជាបានចុះឈ្មោះដើម្បីរៀបចំរបាយការណ៍ត្រួតពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្ត ដើម្បីបង្ហាញពីវឌ្ឍនភាពនៃការអនុវត្ត គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា (គ.អ.ច.ក.) ត្រឹមឆ្នាំ២០១៩ ដល់សាធារណៈទាំងក្នុងនិងក្រៅប្រទេស និងបានធ្វើបទបង្ហាញនៅវេទិកានយោបាយកម្រិតខ្ពស់ស្តីពីគោលដៅអភិវឌ្ឍប្រកបដោយចីរភាព របស់អង្គការសហប្រជាជាតិ នៅបូរីញូយ៉ក កាលពីថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៩។

ទោះជាដូចនេះក្តី ដោយពិនិត្យឃើញថា របាយការណ៍ត្រួតពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្ត នៅមានចំណុចខ្វះចន្លោះមួយចំនួន ជាពិសេស ការខ្វះខាតទិន្នន័យសម្រាប់វាយតម្លៃពីវឌ្ឍនភាព ក្រសួងផែនការក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា បានសម្រេចចិត្តរៀបចំរបាយការណ៍មួយដែលនឹងបង្ហាញពីវឌ្ឍនភាពពេញលេញ នៃការសម្រេចបាន គ.អ.ច.ក. ត្រឹមឆ្នាំ២០១៩ ដែលមានឈ្មោះថា *របាយការណ៍វឌ្ឍនភាពឆ្នាំ២០១៩ នៃការសម្រេចបានគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា* ដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធពីក្រសួង ស្ថាប័ន និងភាគីដែលមានចំណែកពាក់ព័ន្ធនានា។ ការរៀបចំរបាយការណ៍វឌ្ឍនភាពនេះត្រូវបានរៀបចំឡើង ផ្អែកលើរបាយការណ៍ត្រួតពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្ត ឆ្នាំ២០១៩ ដោយធ្វើការបំពេញចន្លោះខ្វះខាតទិន្នន័យ នៅតាមសូចនាករ និងចំណុចដៅ ក្នុងគោលដៅទាំង១៨ ជាពិសេស តួលេខឆ្នាំ២០១៩។ ក្រសួង ស្ថាប័ន តាមវិស័យ នឹងត្រូវស្នើសុំឱ្យផ្តល់តួលេខ និងព័ត៌មានពាក់ព័ន្ធនឹងសូចនាករ ចំណុចដៅ ដែលខ្លួនទទួលខុសត្រូវក្នុងការអនុវត្តឱ្យសម្រេចបាន។ ជាមួយគ្នានេះ ក្រសួង ស្ថាប័នផ្សេងទៀត និងភាគីដែលមានចំណែកពាក់ព័ន្ធនានា ត្រូវបានស្នើសុំឱ្យសហការផ្តល់ទិន្នន័យ និងព័ត៌មាន សម្រាប់ការវាយតម្លៃ ក៏ដូចជាការរៀបចំរបាយការណ៍វឌ្ឍនភាពនេះផងដែរ។

ជាទូទៅ របាយការណ៍វឌ្ឍនភាពនេះ ត្រូវបានកំណត់យកលទ្ធផលនៃការសម្រេចបាន ត្រឹមចុងឆ្នាំ២០១៩ ចំពោះសូចនាករ ចំណុចដៅ និងគោលដៅទាំងអស់នៃ គ.អ.ច.ក.។ ក្នុងរបាយការណ៍នេះ ក៏បានពិនិត្យមើលផងដែរ នូវសូចនាករនានា ដែលពុំមានទិន្នន័យ និងព័ត៌មានគាំទ្រសម្រាប់ការព្យាយាមស្វែងរកប្រភពសម្រាប់គាំទ្រឬពិចារណាដកចេញពីបញ្ជីសូចនាករ និងអាចជាគំនិតផ្តួចផ្តើមលើកឡើងនូវសូចនាករមួយចំនួនដែលមានតម្រូវការចាំបាច់សម្រាប់ការអភិវឌ្ឍនៅកម្ពុជា និងដែលអាចរួមចំណែកក្នុងធ្វើឱ្យសម្រេចបាន គ.អ.ច. សាកល។ ក្នុងបរិការណ៍នេះ ក្រសួងផែនការនឹងដឹកនាំការងារមួយផ្សេងទៀតដើម្បីកែសម្រួលបញ្ជីសូចនាករនៃ គ.អ.ច.ក. នាពេលឆាប់ៗខាងមុខនេះ។

វឌ្ឍនភាពនៃការសម្រេចបាននេះ ត្រូវបានពិនិត្យមើលនិងវាយតម្លៃ ទៅលើសូចនាករនិងចំណុចដៅ ក្នុងគោលដៅនីមួយៗ។ ជាការពិតណាស់ របាយការណ៍នេះ ក៏ជាផ្នែកមួយយ៉ាងសំខាន់

សម្រាប់ពិនិត្យមើលភាពជឿនលឿននៃការអភិវឌ្ឍសង្គមសេដ្ឋកិច្ចកម្ពុជាក្នុងរយៈពេលដូចគ្នា និងជាឯកសារមួយយ៉ាងសំខាន់ សម្រាប់ពិនិត្យមើលពីវឌ្ឍនភាពនៃអនុវត្ត *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤* និង *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ (ផ.យ.អ.ជ.) ២០១៩-២០២៣*។ ការវាយតម្លៃទៅលើលទ្ធផលនៃការសម្រេចបាន ត្រូវបានកំណត់ជា៣ ប្រភេទគឺ *(១)* លើសចំណុចដៅ គឺជាលទ្ធផលល្អប្រសើរ ដែលជាការកំណត់បង្ហាញឱ្យឃើញពីលទ្ធផលនៃការអនុវត្តបានលើសពី១០% នៃតម្លៃចំណុចដៅដែលបានកំណត់នៅក្នុងឆ្នាំអនុវត្តនីមួយៗ *(២)* ស្ថិតលើគន្លងទៅសម្រេចបាន គឺជាលទ្ធផលល្អ ដែលជាការកំណត់បង្ហាញឱ្យឃើញពីលទ្ធផលនៃការអនុវត្តបាននៅចន្លោះពី ក្រោមចំណុចដៅត្រឹម១០% និងលើសចំណុចដៅត្រឹម១០% នៃចំណុចដៅដែលបានកំណត់នៅក្នុងឆ្នាំអនុវត្តនីមួយៗ។ *(៣)* ទាបជាងចំណុចដៅ គឺជាលទ្ធផល ដែលជាការកំណត់បង្ហាញឱ្យឃើញពីលទ្ធផលនៃការអនុវត្តបាន មានកម្រិតទាបជាងតម្លៃដែលបានកំណត់ លើសពី១០%។ ចំពោះសូចនាករ ឬចំណុចដៅណាដែលពុំមានទិន្នន័យគាំទ្រសម្រាប់ការវាយតម្លៃពីលទ្ធផលនៃការអនុវត្តឬសម្រេចបាន នៅក្នុងអាណត្តិកាលនៃការរៀបចំរបាយការណ៍វឌ្ឍនភាពនេះ នឹងត្រូវកំណត់ថា **គ្មានទិន្នន័យ** ។ រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ថា ការរៀបចំរបាយការណ៍វឌ្ឍនភាពនេះ គឺជាផ្នែកមួយនៃការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ដែលទាមទារឱ្យមានការគ្រប់គ្រងឱ្យបានល្អប្រសើរ នូវធនធាន និងទិន្នន័យសម្រាប់គាំទ្រ។

- **លើសចំណុចដៅ៖** គឺជាការបង្ហាញឱ្យឃើញពីលទ្ធផលល្អប្រសើរ ដែលជាការអនុវត្តបានលើសតម្លៃចំណុចដៅដែលបានកំណត់១០% នៅក្នុងឆ្នាំអនុវត្តនីមួយៗ។
- **ស្ថិតលើគន្លងទៅសម្រេចបាន៖** គឺជាលទ្ធផលល្អ ដែលជាការកំណត់បង្ហាញតម្លៃនៃលទ្ធផលអនុវត្តនៅចន្លោះរវាងក្រោមតម្លៃចំណុចដៅដែលបានកំណត់ត្រឹម១០% និងលើសតម្លៃចំណុចដៅដែលបានកំណត់ត្រឹម១០%។
- **ទាបជាងចំណុចដៅ៖** គឺជាការបង្ហាញឱ្យឃើញពីលទ្ធផលនៃការអនុវត្តបាន មានកម្រិតទាបជាងតម្លៃចំណុចដៅដែលបានកំណត់លើសពី១០%។

## កាលានុវត្តភាព និង បញ្ហាប្រឈម

នៅក្នុងការអនុវត្តក្របខ័ណ្ឌ គ.អ.ច.ក. កម្ពុជាបាននិងកំពុងជួបប្រទះជាមួយ ផ្នែកទាំងពីរគឺកាលានុវត្តភាព និង បញ្ហាប្រឈម។ ដោយផ្អែកលើ*យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤* និង *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣* កម្ពុជាមានបញ្ហាចម្បងៗចំនួន៣ ដែលត្រូវដោះស្រាយគឺ៖

**ទី១៖** ធនធានសម្រាប់គាំទ្រដល់ការអនុវត្តឱ្យសម្រេចបាន គ.អ.ច.ក. ក្នុងរយៈពេលខ្លី មធ្យម និងវែង។ សេដ្ឋកិច្ចកម្ពុជា នៅតែមានសន្ទុះខ្លាំង ដែលស្តែងចេញតាមរយៈ កំណើនសេដ្ឋកិច្ចខ្ពស់ ការវិនិយោគក្នុងវិស័យឯកជនបន្តកើនឡើង និង ចំណូលសាធារណៈមានកម្រិតខ្ពស់និងបន្តកើនឡើង

ដែលផ្ដល់នូវមូលដ្ឋានរឹងមាំសម្រាប់ការអភិវឌ្ឍ។ តាមរយៈនិន្នាការនេះ នឹងធ្វើឱ្យរចនាសម្ព័ន្ធសេដ្ឋកិច្ចកម្ពុជាមានការផ្លាស់ប្ដូរទៅរកសកម្មភាពដែលមានតម្លៃបន្ថែមខ្ពស់ ស្របជាមួយគ្នានឹងប្រជាជនមានលក្ខណៈវ័យក្មេង និងនិចលភាពប្រជាសាស្ត្រ។ ទោះជាដូចនេះក្ដី កម្ពុជាក៏ប្រឈមជាមួយនឹងការផ្ដល់ហិរញ្ញប្បទានដល់មហិច្ឆតានៃការសម្រេចបាន គ.អ.ច.ក. និងការបង្កើនគុណភាពនៃសេវាសាធារណៈ ទន្ទឹមនឹងហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍ មាននិន្នាការថយចុះ។

**ទី២៖** បញ្ហាការប្រែប្រួលអាកាសធាតុ គឺជាការរាំងស្ទះដល់វឌ្ឍនភាពនៃការសម្រេចបានគោលដៅជាច្រើននៃ គ.អ.ច.ក.។ ស្របពេលដែលរាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការជាច្រើន ដើម្បីកាត់បន្ថយនិងសម្របខ្លួនទៅនឹងសម្ពាធដែលមានលក្ខណៈជាសាកលមួយនេះ ប្រទេសកម្ពុជានៅតែទទួលរងនូវឥទ្ធិពលអវិជ្ជមានជាច្រើននៃព្រឹត្តិការណ៍ការប្រែប្រួលអាកាសធាតុ និងការកើនឡើងកំដៅនៃភពផែនដី។ ការចាត់វិធានការនានា ដើម្បីទប់ស្កាត់ភាពរេចរិលធម្មជាតិនិងបរិស្ថាន គឺជាតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីរួមចំណែកជំរុញកម្ពុជាឆ្ពោះទៅរកប្រទេសដែលមានស្ថានភាពចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ២០៣០។

**ទី៣៖** មានសំណួរជាច្រើន ត្រូវបានលើកឡើងពាក់ព័ន្ធនឹងគោលដៅនៃទិដ្ឋភាពអភិបាលកិច្ច។ ខណៈពេលដែលប្រទេសកម្ពុជាបានធ្វើការវិនិយោគគួរឱ្យកត់សម្គាល់ លើកំណែទម្រង់ និងការពង្រឹងប្រព័ន្ធគ្រប់គ្រងវិស័យសាធារណៈ បញ្ហាខ្វះខាតនៅតែមាន ជាពិសេស ពាក់ព័ន្ធនឹងការតាមដានត្រួតពិនិត្យនិងវាយតម្លៃ និងទិន្នន័យសម្រាប់គាំទ្រការងារនេះ។ តាមរយៈឧបករណ៍ផ្សេងៗជាច្រើន ដូចជាកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ យុទ្ធសាស្ត្រជាតិសម្រាប់ការអភិវឌ្ឍស្ថិតិ និងផែនការការងារដែលពាក់ព័ន្ធ រាជរដ្ឋាភិបាលបាននិងកំពុងខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការបង្កើតឧបករណ៍ប្រកបដោយប្រសិទ្ធភាព សម្រាប់ការងារត្រួតពិនិត្យនិងនិងវាយតម្លៃ លើការសម្រេចបានគោលដៅខាងលើ។ បន្ថែមលើនេះ ការធ្វើឱ្យសម្រេចបាន គ.អ.ច.ក. ទាមទារឱ្យមានការរួមចំណែកពីបណ្ដាភាគីពាក់ព័ន្ធទាំងអស់ ទាំងនៅក្នុងនិងក្រៅរាជរដ្ឋាភិបាល ជាពិសេស សង្គមស៊ីវិលនិងផ្នែកឯកជន។

## សារសំខាន់ និងជំហានត្រូវអនុវត្តបន្ត

ជាគោលការណ៍ចម្បង រាជរដ្ឋាភិបាលកម្ពុជា បានផ្ដល់ការប្ដេជ្ញាចិត្តគាំទ្រយ៉ាងពេញទំហឹងជាថ្មី ដល់ការធ្វើឱ្យសម្រេចបាន គ.អ.ច.ក. ក៏ដូចជាការរួមចំណែកធ្វើឱ្យសម្រេចបាន គ.អ.ច. សាកល ដើម្បីថែរក្សានិងបង្កើនល្បឿននៃការអភិវឌ្ឍ តាមរយៈការអនុវត្តនូវវិធានការ និងកំណែទម្រង់ចាំបាច់នានា។ ក្របខ័ណ្ឌ គ.អ.ច.ក. បានផ្ដល់នូវចំណុចចាប់ផ្ដើមដ៏រឹងមាំមួយ ដែលផ្ដល់នូវក្របខ័ណ្ឌជាតិមួយយ៉ាងពេញលេញ ហើយអនុមតិទទួលយកនូវចំណុចដៅនានា តម្លៃគ្រាដើម ចំណុចដៅតាមឆ្នាំ និងចំណុចដៅចុងក្រោយ និង បានកំណត់នូវស្ថាប័នដែលទទួលខុសត្រូវក្នុងការធ្វើឱ្យសម្រេចបាននៅ

កម្រិតវិស័យ។ រាជរដ្ឋាភិបាលកម្ពុជា បានសន្យានិងពិចារណាក្នុងការកែសម្រួលនូវចំណុចដៅ និងបញ្ជីសូចនាករ ទៅតាមតម្រូវការនិងស្ថានភាពជាក់ស្តែងនៅក្នុងបរិការណ៍កម្ពុជា។

ភាពជោគជ័យរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (គ.អ.ស.ក.) និងមហិច្ឆតាក្នុងការធ្វើឱ្យសម្រេចបាន គ.អ.ច.ក. គឺស្របគ្នាទៅនឹងប្រវត្តិនៃការអភិវឌ្ឍនៅកម្ពុជា បន្ទាប់ពីការរួចចាកចេញពីរបបប្រល័យពូជសាសន៍ ការកាត់បន្ថយភាពក្រីក្រលឿន និងមានកំណើនសេដ្ឋកិច្ចយ៉ាងខ្ពស់ និង ការចាកចេញពីស្ថានភាពនៃប្រទេសដែលមានចំណូលទាបមកជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប។ គោលដៅអភិវឌ្ឍប្រកបដោយចីរភាព (គ.អ.ច.) មានភាពស្របគ្នាជាមួយ គោលនយោបាយ យុទ្ធសាស្ត្រ និងផែនការរយៈពេលមធ្យមរបស់រាជរដ្ឋាភិបាលកម្ពុជា ដូចបានកំណត់នៅក្នុង*យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤* និង *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.) ២០១៩-២០២៣*។ ភាពស្របគ្នានេះ នឹងធ្វើឱ្យកម្ពុជាមានការវិវឌ្ឍទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ និងជាបន្ទាប់ ជាប្រទេសដែលមានចំណូលខ្ពស់ ដោយឈរលើមូលដ្ឋានបរិយាប័ន្នកំណើនសេដ្ឋកិច្ចនិងចីរភាពបរិស្ថាន។ ភាពចាំបាច់នៃការធានាឱ្យមានការអភិវឌ្ឍប្រកបដោយសមធម៌និងមិនទុកអ្នកណាម្នាក់ឱ្យនៅឯកោ ការអភិរក្សធនធានធម្មជាតិរបស់ប្រទេស ទន្ទឹមនឹងការដោះស្រាយការគំរាមកំហែង ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ ត្រូវបានបញ្ចូលយ៉ាងពេញលេញនៅក្នុងជំហរគោលនយោបាយ។

គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា (គ.អ.ច.ក.) ត្រូវបានដាក់បញ្ចូលពេញលេញទៅក្នុងគោលនយោបាយនិងផែនការ។ ការដាក់បញ្ចូលនេះ គឺធ្វើឡើងតាមរយៈការបញ្ចូលទៅក្នុងក្របខ័ណ្ឌនៃការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដែលក្នុងនោះប្រមាណ៤០% ជាសូចនាកររបស់ គ.អ.ច.ក. និងតាមរយៈ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យដែល គ.អ.ច.ក. នឹងផ្តល់នូវមធ្យោបាយវាស់វែងលទ្ធផលនៃការអនុវត្តថវិកា។ ចុងក្រោយ គឺអនុវត្តតាមរយៈកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេស នវានុវត្តន៍ ការតភ្ជាប់ជាក់ស្តែងរវាង គ.អ.ច.ក. និងការរៀបចំថវិកាសាធារណៈ នៅកម្ពុជា។

រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ថា ទោះបីជាកម្ពុជាបានធ្វើឱ្យមានវឌ្ឍនភាពគួរជាទីមោទនក៏ដោយ ក៏នៅមានការងារជាច្រើនទៀត ដែលត្រូវធ្វើ ដើម្បីសម្រេចឱ្យបានទៅតាមមហិច្ឆតា នៃ គ.អ.ច.ក. និងចូលរួមសម្រេច គ.អ.ច. សាកល។

# ជំពូកទី១

# សេចក្តីផ្តើម

## ១.១ បរិការណ៍នៃប្រទេសកម្ពុជា

ក្នុងរយៈពេល ២ទសវត្សរ៍ចុងក្រោយនេះ កម្ពុជាបានបង្ហាញឱ្យឃើញពីភាពខ្លាំងនៃការអនុវត្តសេដ្ឋកិច្ច ដែលបោះជំហានយ៉ាងស្វាហាប់ឆ្ពោះទៅរកការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាពនិងឆាប់រហ័ស។ កម្ពុជាបានរក្សាអត្រាកំណើនផលិតផលក្នុងស្រុកសរុបប្រមាណ៧% ក្នុងមួយឆ្នាំ ដោយមានគោលនយោបាយធានានូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងការបើកទូលាយសេដ្ឋកិច្ច។ នេះគឺជាលទ្ធផលដែលទទួលបានពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការស្វែងរកការងារធ្វើដល់ប្រជាជន ធ្វើឱ្យចំណូលមធ្យមរបស់ប្រជាជនម្នាក់ៗកើនឡើងខ្ពស់ នាំឱ្យកម្រិតជីវភាពរបស់ប្រជាជនកម្ពុជាមានការកើនឡើង និងធ្វើឱ្យអត្រានៃភាពក្រីក្រឱ្យថយចុះយ៉ាងគំហុក (រូបភាព ១.១)។ នៅក្នុងអំឡុងពេលដែលកម្ពុជា ត្រូវបានចាត់ថ្នាក់ជាប្រទេសដែលមានការអភិវឌ្ឍតិចតួច កំណើនសេដ្ឋកិច្ចដ៏រឹងមាំរបស់កម្ពុជា ត្រូវបានបង្ហាញឱ្យឃើញតាមរយៈការប្រែក្លាយជាប្រទេសដែលមានស្ថានភាពចំណូលមធ្យមកម្រិតទាប នៅឆ្នាំ២០១៦។ ទស្សនទានកម្ពុជា ឆ្នាំ២០៥០ បានកំណត់ថា កម្ពុជានឹងក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ២០៣០ និងក្លាយជាប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០ និងផ្អែកលើមូលដ្ឋាននៃបរិយាប័ន្នសេដ្ឋកិច្ច និងចីរភាពបរិស្ថាន។

**រូបភាព ១.១៖ និន្នាការវិសមភាពនៃការប្រើប្រាស់ ២០០៧-២០១៤**




*ប្រភព៖ ការប៉ាន់ស្មានរបស់ធនាគារពិភពលោក ពី អ.ស.ស.ក. ២០១៧-២០១៤*

វិស័យកម្មន្តសាលដែលកំពុងមានសន្ទុះខ្លាំងនៅកម្ពុជា ដូចជាវិស័យកាត់ដេរនិងស្បែកជើង បាននិងកំពុងបន្តកើនឡើង ដែលបានជួយឱ្យមានការផ្លាស់ប្តូរជាវិជ្ជមាន និងធ្វើឱ្យមានការកើនឡើងនូវតម្លៃបន្ថែម។ នៅក្នុងវិស័យឧស្សាហកម្ម ក៏មានការធ្វើពិពិធកម្មជាមូលដ្ឋានផងដែរ ដូចជា រោងចក្រផលិត

គ្រឿងបន្លាស់រថយន្ត និងគ្រឿងអេឡិចត្រូនិច។ វិស័យសេវាកម្ម ក៏ត្រូវបានបង្ហាញពីកំណើនប្រចាំឆ្នាំខ្លាំងផងដែរ ជាពិសេស តាមរយៈការអនុវត្តពាណិជ្ជកម្មនិងការដឹកជញ្ជូនក្នុងប្រទេស។ ទោះជាដូចនេះក្តី ការប្រឈមបានកើតមានឡើងនៅក្នុងរយៈពេលថ្មីៗនេះ ដោយសារអត្រាកំណើនកម្រិតទាបក្នុងវិស័យទេសចរណ៍ និងអចលនទ្រព្យ ដែលជាវិស័យមួយមានការរួមចំណែកខ្លាំងក្នុងវិស័យសេវាកម្ម និងផ្តល់ការងារធ្វើនិងផលិតផលយ៉ាងច្រើនក្នុងសេដ្ឋកិច្ច។

វឌ្ឍនភាពនៃសូចនាករក្នុងវិស័យសង្គមកិច្ច ត្រូវបានកត់សម្គាល់ឃើញក្នុងវិស័យអប់រំ និងសុខាភិបាល ជាពិសេស ក្នុងរយៈពេល ២ទសវត្សរ៍ចុងក្រោយនេះ។ ក្នុងពេលបច្ចុប្បន្ននេះ សង្គមកម្ពុជាកំពុងឆ្លងកាត់ការផ្លាស់ប្តូរដ៏សំខាន់ តាមរយៈ អន្តរកាលប្រជាសាស្ត្រ និងការរីកចម្រើននៃការធ្វើនគរូបនីយកម្ម និងឧស្សាហូបនីយកម្ម។

ទន្ទឹមនឹងកំណើនសេដ្ឋកិច្ចដ៏រឹងមាំកំពុងបន្តកើតមាន និន្នាការរបស់សូចនាករសង្គម ក៏មានលក្ខណៈវិជ្ជមានដែរ។ រូបភាពខាងក្រោមបង្ហាញពីគន្លងនៃសន្ទស្សន៍អភិវឌ្ឍន៍មនុស្សនៅកម្ពុជា[1] ដែលគូសបញ្ជាក់ពីការប្រែប្រួលក្នុងកម្រិតមួយល្អប្រសើរ ក្នុងចំណោមប្រទេសចំនួន១០ ក្នុងសាកលលោក។

**រូបភាព ១.២÷ សន្ទស្សន៍អភិវឌ្ឍន៍ធនធានមនុស្ស ពីឆ្នាំ១៩៩០ ដល់២០១៥**




*ប្រភព÷ ការគណនាដោយផ្អែកលើទិន្នន័យរបស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ*

លទ្ធផលដ៏ល្អប្រសើរនេះ ត្រូវបានជំរុញដោយវឌ្ឍនភាពនៃការសម្រេចបាន គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (គ.អ.ស.ក.) ដែលកម្ពុជាសម្រេចបានចំណុចដៅភាគច្រើន និងមុនកាលកំណត់។

[1] *HDI គឺជាតារាងម៉ាទ្រីសរួមបញ្ចូលគ្នានៃ ចំណូលជាតិសរុបសម្រាប់មនុស្សម្នាក់ អាយុកាលសង្ឃឹមរស់ និងការសិក្សា (គេហទំព័រ UNDP HD* http://hdr.undp.org/en/data)

តារាងខាងក្រោម បង្ហាញពីលទ្ធផលនៃការសម្រេចបាន គ.អ.ស.ក. និងជាមូលដ្ឋានសម្រាប់អនុវត្ត គ.អ.ច.ក. នាពេលអនាគត។

**តារាង ១.១៖ សង្ខេបពីលទ្ធផលនៃការអនុវត្ត គ.អ.ស.ក.**

| គោលដៅ | ចំណុចដៅ | ការអនុវត្ត |
|---|---|---|
| ១. លុបបំបាត់ភាពក្រីក្រ និងភាពអត់ឃ្លានធ្ងន់ធ្ងរ | (១a) កាត់បន្ថយឱ្យបានពាក់កណ្ដាលសមាមាត្រនៃប្រជាជនរស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្ររបស់ជាតិ | សម្រេចបាន |
| | (១b) កាត់បន្ថយសមាមាត្រប្រជាជនដែលទទួលរងនូវភាពអត់ឃ្លាន | សម្រេចបាន |
| | (១c) បង្កើនចំណែកនៃចំណូលរបស់ប្រជាជនក្របំផុត២០% | មិនទាន់សម្រេចបាន |
| | (១d) លើកកម្ពស់អាហារូបត្ថម្ភនិងលុបបំបាត់ភាពក្រិន | មិនទាន់សម្រេចបាន |
| ២. សម្រេចឱ្យបានសកលកម្មអក្ខរកម្មនិងការអប់រំបឋមសិក្សា | (២a) សម្រេចឱ្យបាន១០០% ការសិក្សាពិតនៅកម្រិតបឋមសិក្សា | ហៀបនឹងសម្រេចបាន |
| | (២b) សម្រេចឱ្យបាន១០០% អត្រាបញ្ចប់ការសិក្សានៅកម្រិតសិក្សាបឋមភូមិ | មិនទាន់សម្រេចបាន |
| | (២c) សម្រេចឱ្យបានសកលកម្មអក្ខរកម្ម ក្នុងចំណោមប្រជាជនអាយុ ពី ១៥-២៥ ឆ្នាំ | ហៀបនឹងសម្រេចបាន |
| | (២d) សម្រេចឱ្យបាននូវសមភាពយេនឌ័រ នៅកម្រិតបឋមសិក្សា | សម្រេចបាន |
| ៣. លើកកម្ពស់សមភាពយេនឌ័រនិងការផ្ដល់សិទ្ធិអំណាចដល់ស្ត្រី | (៣a) សម្រេចឱ្យបានសមភាពយេនឌ័រក្នុងវិស័យអប់រំនិងអក្ខរកម្ម | សម្រេចបាន |
| | (៣b) ផ្ដល់សិទ្ធិអំណាចដល់ស្ត្រីក្នុងការងារទទួលបានប្រាក់ឈ្នួល | មិនទាន់សម្រេចបាន |
| | (៣c) ផ្ដល់សិទ្ធិអំណាចដល់ស្ត្រីក្នុងការធ្វើសេចក្ដីសម្រេចចិត្ត | មិនទាន់សម្រេចបាន |
| | (៣d) បញ្ចប់អំពើហិង្សាលើយេនឌ័រ | មិនមានចំណុចដៅ |
| ៤. កាត់បន្ថយអត្រាមរណភាពកុមារ | (៤a) កាត់បន្ថយអត្រាមរណភាពទារក | សម្រេចបាន |
| | (៤b) កាត់បន្ថយអត្រាមរណភាពកុមារក្រោមអាយុ៥ឆ្នាំ | សម្រេចបាន |
| ៥. លើកកម្ពស់សុខភាពមាតា | (៥a) កាត់បន្ថយអត្រាមរណភាពមាតា | សម្រេចបាន |
| | (៥b) បង្កើនអត្រាសម្រាលកូនដោយបុគ្គលិកសុខាភិបាលមានជំនាញ | សម្រេចបាន |
| ៦. ការប្រយុទ្ធប្រឆាំងមេរោគអេដស៍ ជំងឺអេដស៍ ជំងឺគ្រុនចាញ់ និងជំងឺផ្សេង ៗទៀត | (៦a) កាត់បន្ថយអត្រាប្រេវ៉ាឡង់មេរោគអេដស៍ក្នុងចំណោមប្រជាជនទូទៅ | សម្រេចបាន |
| | (៦b) កាត់បន្ថយ អត្រាស្លាប់ដោយជំងឺរបេងនិងអត្រាប្រេវ៉ាឡង់ | សម្រេចបាន |
| | (៦c) កាត់បន្ថយអត្រាស្លាប់ដោយជំងឺគ្រុនចាញ់ | សម្រេចបាន |
| ៧. ធានាចីរភាពបរិស្ថាន | (៧a) បញ្ចូលគោលការណ៍អភិវឌ្ឍប្រកបដោយចីរភាពនិងការថយចុះនៃធនធានធម្មជាតិ | មិនមានចំណុចដៅ |
| | (៧b) សម្រេចឱ្យបានការទទួលបានទឹកសុវត្ថិភាពបរិភោគ និងអនាម័យ នៅតំបន់ជនបទនិងតំបន់ទីប្រជុំជន | សម្រេចបាន |
| | (៧c) កាត់បន្ថយ ការពឹងផ្អែករបស់គ្រួសារកម្ពុជា លើអុសសម្រាប់ប្រើជាថាមពល | មិនទាន់សម្រេចបាន |
| | (៧d) បង្កើនសមាមាត្រប្រជាជនកាន់កាប់ដីធ្លីប្រកបដោយចីរភាព | សម្រេចបាន |
| ៨. បង្កើតភាពជាដៃគូជាសាកលសម្រាប់កិច្ចអភិវឌ្ឍ | មិនមានចំណុចដៅ | មិនមានចំណុចដៅ |
| ៩. ការបោសសម្អាតមីនសំណល់ជាតិផ្ទុះពីសង្គ្រាម និងការសង្គ្រោះជនពិការដោយសារមីន | (៩a) កាត់បន្ថយចំនួនប្រជាជនដែលរងគ្រោះដោយសារមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម | សម្រេចបាន |
| | (៩b) ផ្ទៃដីដែលបានបោសសម្អាតមីននិងយុទ្ធភណ្ឌមិនទាន់ផ្ទុះពីសង្គ្រាម | សម្រេចបាន |

*ប្រភព៖ ក្រសួងផែនការ ក្របខ័ណ្ឌ គ.អ.ច.ក. (២០១៨)*

ខណៈពេលដែលកំណើនសេដ្ឋកិច្ចកម្ពុជាបានទទួលជោគជ័យ ក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ បញ្ហាប្រឈមមួយ ក្នុងចំណោមបញ្ហាប្រឈមចម្បងៗដែលបានជួបប្រទះនៅក្នុងដំណើរការអភិវឌ្ឍនៅកម្ពុជា គឺហានិភ័យរបស់ប្រទេស។ កម្ពុជាត្រូវបានចាត់ថ្នាក់ជាប្រទេសមួយក្នុងចំណោមប្រទេសចំនួន១០ ក្នុងសាកលលោក និងជាប្រទេសមួយក្នុងចំណោមប្រទេសចំនួន៣ ក្នុងតំបន់អាស៊ីដែលមានហានិភ័យខ្ពស់ជាងគេពីការប្រែប្រួលអាកាសធាតុ។ ដូចនេះ ដើម្បីទទួលបានស្ថិរភាពបរិស្ថាន និងទ្រទ្រង់មាគ៌ាឆ្ពោះទៅរកការអភិវឌ្ឍប្រកបដោយចីរភាព រាជរដ្ឋាភិបាលកម្ពុជា បានផ្តួចផ្តើមធ្វើកំណែទម្រង់អភិបាលកិច្ចបរិស្ថានដែលមានលក្ខណៈទូលំទូលាយ។

ព្រះរាជក្រមស្តីពីបរិស្ថាននិងធនធានធម្មជាតិ និងផែនការយុទ្ធសាស្ត្រនិងសកម្មភាពជាតិបរិស្ថាន ដែលត្រូវបានរៀបចំក្នុងឆ្នាំ២០១៦ បានបង្កើតឡើងនូវបរិយាកាសច្បាប់និងគោលនយោបាយដែលអាចជួយសម្រួលដល់ការសម្រេចបាននូវការការពារបរិស្ថាន ជាមួយគ្នានឹងការគាំទ្រដល់ការអភិវឌ្ឍប្រកបដោយចីរភាព។ ព្រះរាជក្រមនេះ ត្រូវឱ្យមានបទប្បញ្ញត្តិច្បាប់ ដើម្បីពង្រឹងការអភិរក្សធនធានធម្មជាតិនិងសត្វព្រៃ ការកសាងភាពធន់នឹងអាកាសធាតុ ការជំរុញការប្រើប្រាស់ថាមពលកកើតឡើងវិញនិងបរិស្ថានស្អាត និងការកសាងទីក្រុងប្រកបដោយចីរភាព ដែលមានសមត្ថភាពដោះស្រាយការបំពុលអាកាសធាតុនិងសំរាម។

ជាមួយនឹងគោលនយោបាយនិងច្បាប់បរិស្ថានដែលមាន ចាំបាច់ត្រូវធ្វើការគ្រប់គ្រងធនធានធម្មជាតិឱ្យមានប្រសិទ្ធភាព តាមរយៈការប្រើប្រាស់ចំណេះដឹងវិទ្យាសាស្ត្រត្រឹមត្រូវ និងការបង្កើតប្រព័ន្ធតាមដានត្រួតពិនិត្យគ្រប់គ្រាន់។ ការអនុវត្តគោលនយោបាយនិងច្បាប់បរិស្ថានប្រកបដោយប្រសិទ្ធភាពគឺអាស្រ័យលើការអភិវឌ្ឍជំនាញបច្ចេកទេសនិងផ្តល់ធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ សម្រាប់ស្ថាប័នដែលមានការពាក់ព័ន្ធ។ ជាមួយគ្នានេះដែរ ចាំបាច់ត្រូវពង្រឹងរចនាសម្ព័ន្ធក្នុងការគាំទ្រដល់ការការពារបរិស្ថានប្រកបដោយចីរភាព ដូចជា ក្នុងករណីដែលមានគ្រោះទឹកជំនន់ក៏ដូចជាភាពរាំងស្ងួត ស្ថានីយ៍អាកាសធាតុ និងប្រព័ន្ធប្រកាសអាសន្ន នឹងអាចផ្តល់ព័ត៌មានទាន់ពេលវេលាដល់ភ្នាក់ងាររាជរដ្ឋាភិបាលនិងសហគមន៍មូលដ្ឋាន។

ទោះជាដូចនេះក្តី តម្រូវការចាំបាច់សម្រាប់ធ្វើឱ្យអភិបាលកិច្ចបរិស្ថានទទួលបានជោគជ័យ គឺការធ្វើឱ្យមានការចាប់អារម្មណ៍ និងការចូលរួមយ៉ាងសកម្មពីប្រជាជន ក្នុងការដោះស្រាយបញ្ហាបរិស្ថាននេះ។ ប្រជាជនកម្ពុជាដែលរស់នៅតាមតំបន់ជនបទនិងតំបន់ទីប្រជុំជន មានចំណេះដឹងពីរបៀបដែលពួកគេរងផលប៉ះពាល់ពីបរិស្ថានដែលមានសភាពអាក្រក់។ បទពិសោធន៍ឬចំណេះដឹងនេះ ត្រូវតែប្រើប្រាស់យ៉ាងសកម្ម សម្រាប់ជាផ្នែកមួយនៃការឆ្លើយតប ការបង្ការ និងទប់ទល់នឹងផលប៉ះពាល់នៃបរិស្ថាននេះ។ ដូចនេះ ស្ថាប័ននានារបស់រាជរដ្ឋាភិបាលកម្ពុជា និងភាគីដែលមានចំណែកពាក់ព័ន្ធ ត្រូវតែជាសមាសភាគដ៏សំខាន់ នៅក្នុងការធ្វើឱ្យមានវឌ្ឍនភាពឆ្ពោះទៅរកការគ្រប់គ្រងបរិស្ថានប្រកបដោយចីរភាព។

## ១.២ ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការធ្វើឱ្យសម្រេចបានគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជាបានទទួលយករបៀបវារៈ ឆ្នាំ២០៣០ របស់អង្គការសហប្រជាជាតិសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និងគោលដៅនៃគោលដៅអភិវឌ្ឍប្រកបដោយចីរភាព (គ.អ.ច.) ចំនួន ១៧ ដែលជាការប្តេជ្ញាចិត្តខ្ពស់ចំពោះការធ្វើឱ្យសម្រេចបានសមិទ្ធផលនេះ។ ក្រសួងផែនការត្រូវបានទទួលសិទ្ធិប្រទានក្នុងការដឹកនាំសម្របសម្រួលធ្វើមូលដ្ឋាននីយកម្ម គ.អ.ច. មកក្នុងបរិការណ៍កម្ពុជា។ ក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា បានទទួលយកគោលដៅសាកលទាំង ១៧ និងបន្ថែមគោលដៅជាតិមួយទៀតពាក់ព័ន្ធនឹងការដោះមីននិងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះពីសង្គ្រាម ដើម្បីឆ្លើយតបនឹងអាទិភាពរបស់ជាតិ ក្នុងការបំបាត់ឱ្យអស់គ្រាប់មីននិងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះពីសង្គ្រាមពីទឹកដីកម្ពុជា។ លទ្ធផលចុងក្រោយដែលបង្ហាញក្នុងក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា រួមមាន គោលដៅចំនួន១៨ ចំណុចដៅចំនួន៨៨ រួមទាំងចំណុចដៅជាតិនិងសាកល និងសូចនាករចំនួន១៤៨ ដែលរួមបញ្ចូលទាំងសូចនាករជាតិចំនួន៩៦។ ដំណើរការនៃការរៀបចំក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា រួមបញ្ចូលទាំងកិច្ចប្រជុំពិភាក្សាជាមួយអ្នកដែលមានចំណែកពាក់ព័ន្ធ ដែលរួមមាន អ្នកធ្វើសេចក្តីសម្រេចចិត្តគោលនយោបាយ ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ និងអង្គការសង្គមស៊ីវិល។ ដំណើរការនេះ រួមបញ្ចូលទាំង ការសម្រេចចិត្តក្នុងការបញ្ជ្រាបបណ្តាគោលដៅនានា ទៅក្នុងប្រព័ន្ធផែនការ និងគោលនយោបាយ ដើម្បីអនុវត្ត។

## ១.៣ ដំណើរការមូលដ្ឋាននីយកម្មនិងសមាហរណកម្ម

ដំណើរការនៃការធ្វើមូលដ្ឋាននីយកម្ម គ.អ.ច. នៅកម្ពុជា បានចាប់ផ្តើមពីវាយតម្លៃលទ្ធផលនៃការសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (គ.អ.ស.ក.) និងពិនិត្យមើលផងដែរពីបណ្តាគោលដៅ ចំណុចដៅ និងសូចនាករនានាដែលមិនទាន់សម្រេចបាន នៅក្នុងអាណត្តិកាលពីឆ្នាំ ២០០៣-២០១៥ របស់ គ.អ.ស.ក. ដើម្បីពិចារណាដាក់បញ្ចូលទៅក្នុងគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា។ អាទិភាពនៃការរៀបចំ ត្រូវបានផ្តល់ចំពោះការសម្របសម្រួលរវាងការរៀបចំនិងការអនុវត្តគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា ដោយផ្សារភ្ជាប់ជាមួយប្រព័ន្ធផែនការ។

រាជរដ្ឋាភិបាលកម្ពុជា ដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធពីអង្គការសហប្រជាជាតិ បានធ្វើការវាយតម្លៃពីស្ថានភាពពាក់ព័ន្ធនឹង គ.អ.ច. ចំនួនពីរគឺ ការវាយតម្លៃរួមធាប់រហ័ស ដែលធ្វើឡើងក្នុងឆ្នាំ ២០១៦ និង ការវាយតម្លៃលើសូចនាករនិងប្រភពទិន្នន័យ ដែលធ្វើឡើងក្នុងឆ្នាំ២០១៧។ ការវាយតម្លៃរួមធាប់រហ័ស ផ្តោតជាសំខាន់លើភាពស៊ីគ្នារវាង គោលដៅ ចំណុចដៅ របស់ គ.អ.ច. ជាមួយនឹង គោលនយោបាយ និងយុទ្ធសាស្ត្រនានារបស់កម្ពុជាដែលមានស្រាប់ ជាពិសេស ផ.យ.អ.ជ. និង យុទ្ធសាស្ត្រតាមវិស័យនិងអន្តរវិស័យ។ សម្រាប់ការវាយតម្លៃលើសូចនាករនិងប្រភពទិន្នន័យ ចែកចេញជា ៣ផ្នែក គឺ

ទិន្នន័យដែលមានស្រាប់ឬអាចផលិតបានដោយងាយ ទិន្នន័យដែលអាចធ្វើបានដោយតម្រូវឱ្យមានកិច្ចខិតខំប្រឹងប្រែង និង ទិន្នន័យដែលមិនអាចផលិតបាន។ រាជរដ្ឋាភិបាលកម្ពុជាបានអនុមតិនូវគោលដៅអភិវឌ្ឍប្រកបដោយចីរភាពដែលស្របគ្នានឹងបរិការណ៍កម្ពុជា ដែលរួមទាំង តម្រូវការជាក់ស្តែងរបស់ជាតិ និងបញ្ហាប្រឈមដែលរំពឹងថា នឹងអាចជួបប្រទះនៅក្នុងដំណាក់នៃការអនុវត្ត។ គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា បានបញ្ចូលរួចហើយទៅក្នុងប្រព័ន្ធផែនការជាតិ ជាក់ស្តែង បានបញ្ចូលទៅក្នុង *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.)* ដែលបានដាក់បញ្ចូលសូចនាកររបស់ គ.អ.ច.ក. ទៅក្នុងសូចនាករស្នូលសម្រាប់ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ប្រមាណជាង៤០% ការណែនាំឱ្យក្រសួង ស្ថាប័ននានាដាក់បញ្ចូល គ.អ.ច.ក. ទៅក្នុងផែនការយុទ្ធសាស្ត្រវិស័យនានា ចំពោះគោលដៅណាដែលពាក់ព័ន្ធនឹងវិស័យនោះ និង ការណែនាំឱ្យស្ថាប័ននៅថ្នាក់ក្រោមជាតិ បញ្ជ្រាប គ.អ.ច.ក. ទៅក្នុងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់។

## ១.៤ មូលហេតុនៃការរៀបចំរបាយការណ៍វឌ្ឍនភាពឆ្នាំ២០១៩ នៃការសម្រេចបាន គ.អ.ច.ក.

បន្ទាប់ពីបានបញ្ចប់ជាស្ថាពរនិងអនុមតិដាក់ឱ្យអនុវត្ត នូវឯកសារក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា ២០១៦-២០៣០ រួចមក រាជរដ្ឋាភិបាលកម្ពុជាបានចុះឈ្មោះនៅអង្គការសហប្រជាជាតិ ក្នុងការរៀបចំរបាយការណ៍វាយតម្លៃថ្នាក់ជាតិដោយស្ម័គ្រចិត្ត ឆ្នាំ២០១៩ ដែលជារបាយការណ៍ត្រូវបានរៀបចំនៅក្នុងតំបន់ បន្ទាប់ពីប្រទេសថៃដែលបានរៀបចំធ្វើនៅឆ្នាំ២០១៧ និងប្រទេសឡាវ បានរៀបចំធ្វើនៅឆ្នាំ២០១៨។ ដំណើរការនៃការរៀបចំរបាយការណ៍ត្រួតពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្តនេះ ត្រូវបានដឹកនាំនិងសម្របសម្រួលដោយក្រសួងផែនការ និងដោយមានការគាំទ្រដោយ កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិនៅកម្ពុជា។ គោលបំណងនៃការរៀបចំរបាយការណ៍នេះ គឺដើម្បីបង្ហាញពីវឌ្ឍនភាពនៃការសម្រេចបាន គ.អ.ច.ក. ទៅដល់សាធារណៈទាំងក្នុងនិងក្រៅប្រទេស ជាពិសេសបង្ហាញដល់សាកលលោក តាមរយៈវេទិកានយោបាយកម្រិតខ្ពស់ស្តីពីគោលដៅអភិវឌ្ឍប្រកបដោយចីរភាព របស់អង្គការសហប្រជាជាតិ នៅញុំយ៉ក កាលពីថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៩ និង បង្កើតចេញនូវវិធានការនិងពង្រឹកយន្តការស្ថាប័ន ក៏ដូចជា លើកទឹកចិត្តឱ្យមានការចូលរួមកាន់តែច្រើនថែមទៀត ពីភាគីដែលមានចំណែកពាក់ព័ន្ធ ក្នុងការអនុវត្តនិងឈានឆ្ពោះទៅសម្រេចបាន គ.អ.ច.ក.។ ជាមួយគ្នានេះ កម្ពុជានឹងមានឱកាសក្នុងការផ្លាស់ប្តូរបទពិសោធន៍ ជាមួយបណ្តាប្រទេសនានាក្នុងតំបន់និងក្នុងពិភពលោក ក្នុងគោលដៅកែលម្អដំណើរការនៃការអនុវត្តនិងការសម្រេចបាន គ.អ.ច.ក. ក៏ដូចជា ការចូលរួមធ្វើឱ្យសម្រេចបាន គ.អ.ច.ក.។

ទោះជាដូចនេះក្តី របាយការណ៍ត្រួតពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្ត ឆ្នាំ២០១៩ មិនទាន់មានលក្ខណៈពេញលេញទេ ដោយសារតែរបាយការណ៍នេះ ត្រូវបានរៀបចំឡើងដោយបន្ទាន់ពេក គឺ

ចាប់ផ្តើមរៀបចំនៅដើមឆ្នាំ២០១៩ ក្នុងពេលដែល*ក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា ២០១៦-២០៣០* ត្រូវបានអនុមតិនៅចុងឆ្នាំ២០១៨។ ដោយសារតែលក្ខណៈបន្ទាន់ដូចនេះហើយ ទើបធ្វើឱ្យទិន្នន័យភាគច្រើននៃចំណុចដៅក្នុងរបាយការណ៍នេះ មានភាពខ្វះខាតច្រើន គឺរហូតដល់៤៣,២% នៃចំណុចដៅរបស់ គ.អ.ច.ក. មិនមានទិន្នន័យសម្រាប់វាយតម្លៃពីលទ្ធផលនៃការអនុវត្ត ជាពិសេសទិន្នន័យសម្រាប់ឆ្នាំ២០១៩ ចំពោះគ្រប់ចំណុចដៅទាំងអស់។

ដើម្បីបំពេញបន្ថែមលើរបាយការណ៍ត្រួតពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្ត ឆ្នាំ២០១៩ និងបង្ហាញចេញនូវលទ្ធផលពេញលេញស្តីពីការសម្រេចបាន គ.អ.ច.ក. ត្រឹមឆ្នាំ២០១៩ ទើបក្រសួងផែនការបានផ្តួចផ្តើមរៀបចំ*របាយការណ៍វឌ្ឍនភាពឆ្នាំ២០១៩ នៃការសម្រេចបាន គ.អ.ច.ក.* នេះឡើង។ ការរៀបចំនេះទាមទារឱ្យមានការសហការពីក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានអនុវត្តដោយផ្ទាល់នូវបណ្តាសកម្មភាពនានាសម្រាប់ធ្វើឱ្យសម្រេចបានបណ្តាគោលដៅនានា ស្ថាប័នដែលទទួលបន្ទុកប្រមូលទិន្នន័យ និងភាគីដែលមានចំណែកពាក់ព័ន្ធនានា ក្នុងការផ្តល់នូវព័ត៌មាននិងទិន្នន័យ សម្រាប់វាយតម្លៃនិងរៀបចំរបាយការណ៍នេះ។

គោលបំណងនៃការរៀបចំ*របាយការណ៍វឌ្ឍនភាព ឆ្នាំ២០១៩ នៃការសម្រេចបានគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា* នេះ គឺដើម្បីបង្ហាញចេញនូវរបាយការណ៍ពេញលេញមួយនៃការអនុវត្ត គ.អ.ច.ក. ត្រឹមឆ្នាំ២០១៩ ដោយពិនិត្យមើលបណ្តាចំណុចដៅនានារបស់សូចនាករ ដែលបានកំណត់នៅក្នុងក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា ធៀបនឹងលទ្ធផលជាក់ស្តែងដែលសម្រេចបាន នៅក្នុងឆ្នាំ២០១៩ និងសម្រាប់ជាមូលដ្ឋាននៃការកំណត់នូវសេចក្តីសម្រេចចិត្តនានា សម្រាប់អនុវត្តបន្ត និងឈានទៅសម្រេចបាន គ.អ.ស.ក. បន្តរហូតដល់ឆ្នាំ២០៣០។ ជាការពិត លទ្ធផលនៃការសម្រេចបាននៃសូចនាករទាំងអស់ក្នុងចំណុចដៅនីមួយៗ នឹងបង្ហាញឱ្យឃើញលទ្ធផលនៃការសម្រេចបាននៃចំណុចដៅនោះ។ ដូចគ្នាដែរ លទ្ធផលនៃការសម្រេចបានរបស់ចំណុចដៅទាំងអស់ក្នុងគោលដៅនីមួយៗ នឹងបង្ហាញច្បាស់ពីលទ្ធផលរបស់គោលដៅនោះ។

ដូចគ្នានឹងរបាយការណ៍ត្រួតពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្ត ឆ្នាំ២០១៩ ដែរ ការរៀបចំ*របាយការណ៍វឌ្ឍនភាពឆ្នាំ២០១៩ នៃការសម្រេចបាន គ.អ.ច.ក.* នេះ នឹងត្រូវរាយការណ៍ពីវឌ្ឍនភាពគ្រប់គោលដៅទាំងអស់ ប៉ុន្តែត្រូវរាយការណ៍តាមលេខរៀងនៃគោលដៅ ពីគោលដៅទី១ រហូតដល់គោលដៅទី១៨។ របាយការណ៍វឌ្ឍនភាពនេះ នឹងត្រូវទទួលបានការអនុមតិពីរាជរដ្ឋាភិបាលកម្ពុជា និងត្រូវធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយ ទន្ទឹមគ្នានឹងការផ្សព្វផ្សាយរបាយការណ៍ត្រួតពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្ត ឆ្នាំ២០១៩ ដើម្បីជាការប្រៀបធៀបគ្នា។

របាយការណ៍នេះ ចែកចេញជា ចំនួន៦ជំពូក និងមានឧបសម្ព័ន្ធភ្ជាប់ចំនួន២ គឺ

ជំពូកទី២៖ វិធីសាស្ត្រនិងដំណើរការសម្រាប់ការតាមដានត្រួតពិនិត្យនិងវាយតម្លៃការសម្រេចបាន គ.អ.ច.ក. ២០១៦-២០៣០។

ជំពូកទី៣៖ បរិយាកាសនយោបាយដែលអំណោយផលសម្រាប់ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ការសម្រេចបាន គ.អ.ច.ក. ២០១៦-២០៣០។

ជំពូកទី៤៖ វឌ្ឍនភាពតាមសូចនាករនិងចំណុចដៅ ក្នុងគោលដៅនីមួយៗ។

ជំពូកទី៥៖ មធ្យោបាយនិងការអនុវត្តបន្ត សម្រាប់ការសម្រេចបាន គ.អ.ច.ក. ២០១៦-២០៣០។

ជំពូកទី៦៖ សេចក្តីសន្និដ្ឋាន។

# ជំពូកទី២

# វិធីសាស្ត្រនិងដំណើរការសម្រាប់ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ការសម្រេចបាន គ.អ.ច.ក. ២០១៦-២០៣០

## ២.១ សេចក្តីផ្តើម

ជំពូកទីពីរនេះ កំណត់បង្ហាញពីវិធីសាស្ត្រទូទៅសម្រាប់ការរៀបចំ*របាយការណ៍វឌ្ឍនភាព ឆ្នាំ២០១៩ នៃការសម្រេចបានគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា* នេះ។ ជំពូកនេះ មានបីផ្នែក ដែលផ្នែកទី២ នឹងពិភាក្សាពីវិធីសាស្ត្រសម្រាប់រៀបចំរបាយការណ៍ និងបង្ហាញពីប្រភពទិន្នន័យនិងព័ត៌មាន សម្រាប់វាយតម្លៃលទ្ធផលនៃការសម្រេចបាន គ.អ.ច.ក. និងរៀបចំរបាយការណ៍នេះ និងផ្នែកទីបី គឺជាដំណើរការនៃការរៀបចំសេចក្តីព្រាង*របាយការណ៍វឌ្ឍនភាព ឆ្នាំ២០១៩ នៃការសម្រេចបាន គ.អ.ច.ក.*។

## ២.២ វិធីសាស្ត្រ និង ប្រភពព័ត៌មាន

ការពិភាក្សានិងការវិភាគនៅក្នុងរបាយការណ៍នេះ គឺផ្អែកលើ វិធីសាស្ត្រស្រាវជ្រាវចម្រុះ ដែលស្របគ្នានឹងស្ថានភាពជាក់ស្តែងនាពេលបច្ចុប្បន្ន ការស្រាវជ្រាវឯកសារគោលនយោបាយថ្មីៗរបស់រាជរដ្ឋាភិបាលកម្ពុជា និងការសម្ភាសន៍ដោយផ្ទាល់ជាមួយអ្នកដែលមានចំណែកពាក់ព័ន្ធនានា ដើម្បីវាយតម្លៃពីវឌ្ឍនភាពនៃលទ្ធផលដែលទទួលបាន បញ្ហាប្រឈម និងការកំណត់គោលនយោបាយសំខាន់ៗ សម្រាប់ជំរុញការអនុវត្តឱ្យសម្រេចបាន គ.អ.ច.ក.។ ឯកសារសំខាន់ៗដែលត្រូវបានពិនិត្យមើល រួមមាន *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ ក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា ២០១៦-២០៣០ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.) ២០១៩-២០២៣* ផែនការយុទ្ធសាស្ត្រតាមវិស័យ និងឯកសារគោលនយោបាយពាក់ព័ន្ធនានា។ ដូចបានបញ្ជាក់ពីខាងដើម ការពិភាក្សា និងការវិភាគទាំងនេះ គឺក្នុងគោលបំណងដើម្បីទទួលបាននិងបង្ហាញឱ្យឃើញច្បាស់ពីវឌ្ឍនភាពពេញលេញដែលទទួលបាន និងបញ្ហាប្រឈម តាមសូចនាករ និងចំណុចដៅនីមួយៗ តាមគោលដៅនៃ គ.អ.ច.ក. ត្រឹមឆ្នាំ២០១៩។

បន្ថែមលើនេះទៀត របាយការណ៍នេះ បានបើកទូលាយឱ្យមានការចូលរួមពីគ្រប់ផ្នែក និងទទួលយកនូវបណ្តាព័ត៌មានទាំងបរិមាណនិងគុណភាព ពីភាគីដែលមានចំណែកពាក់ព័ន្ធ ទាំងស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជា និងពីស្ថាប័នមួយចំនួនដែលមិននៅក្នុងរាជរដ្ឋាភិបាល។ រូបភាពខាងក្រោមបង្ហាញពីប្រភពនិងលំហូរព័ត៌មាននិងទិន្នន័យសម្រាប់រៀបចំ*របាយការណ៍វឌ្ឍនភាពឆ្នាំ២០១៩ នៃការសម្រេចបាន គ.អ.ច.ក.*។

## រូបភាព ២.១៖ ការរៀបចំរបាយការណ៍វឌ្ឍនភាពឆ្នាំ២០១៩ នៃការសម្រេចបាន គ.អ.ច.ក. និងប្រភពព័ត៌មាន




ទម្រង់នៃការប្រមូលទិន្នន័យពីភាគីដែលមានចំណែកពាក់ព័ន្ធសំខាន់ៗ សម្រាប់វាយតម្លៃពីវឌ្ឍភាពនៃការសម្រេចបាន គ.អ.ច.ក. នេះ ត្រូវបានរៀបចំឡើង ដើម្បីសម្របសម្រួលនិងធ្វើឱ្យមានស្តង់ដាក្នុងដំណើរការនៃការប្រមូលទិន្នន័យ និងទម្រង់នៃទិន្នន័យ។ ទិន្នន័យដែលទទួលបានពីប្រភពផ្សេងៗ ត្រូវបានប្រើប្រាស់សម្រាប់ធ្វើការវិភាគពីនិន្នាការរបស់សូចនាករនីមួយៗរបស់ គ.អ.ច.ក. មុននឹងត្រូវបានពិភាក្សាជាមួយភាគីដែលមានចំណែកពាក់ព័ន្ធ។ ជំហាននេះត្រូវបានចែកចេញជាពីរផ្នែក គឺ**ទី១** ផ្តល់ឱ្យដោយអ្នកដែលមានចំណែកពាក់ព័ន្ធយល់ដឹងពីទិន្នន័យ និងប្រភពទិន្នន័យ សម្រាប់ គ.អ.ច.ក. ដែលមានការពាក់ព័ន្ធនឹងសកម្មភាពរបស់ពួកគេ និងធ្វើការកំណត់ពីព័ត៌មានទាំងនោះ និង **ទីពីរ** គឺ ព័ត៌មានដែលប្រមូលបាននេះ មានសារសំខាន់ណាស់សម្រាប់ក្រសួងផែនការ ដែលជាស្ថាប័នសម្របសម្រួលការងារ គ.អ.ច.ក. និងសម្រាប់ភាគីដែលមានចំណែកពាក់ព័ន្ធនានា សម្រាប់កំណត់និងវាយតម្លៃគោលដៅនៃ គ.អ.ច.ក. ដែលខ្វះព័ត៌មាននិងទិន្នន័យ។

## ២.៣ ដំណើរការនៃការរៀបចំសេចក្តីព្រាងរបាយការណ៍វឌ្ឍនភាពឆ្នាំ២០១៩ នៃការសម្រេចបាន គ.អ.ច.ក.

ការរៀបចំ*របាយការណ៍វឌ្ឍនភាពឆ្នាំ២០១៩ នៃការសម្រេចបាន គ.អ.ច.ក.* បានចាប់ផ្តើមបន្ទាប់ពីការទទួលបានធាតុចូលជាព័ត៌មាននិងទិន្នន័យពីក្រសួង ស្ថាប័ននានា និងភាគីដែលមានចំណែកពាក់ព័ន្ធ។ នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៩ ក្រសួងផែនការបានរៀបចំកិច្ចប្រជុំអន្តរក្រសួងមួយ និងដោយមានការចូលរួមពីភាគីដែលមានចំណែកពាក់ព័ន្ធផ្សេងទៀត ដើម្បីណែនាំពីការរៀបចំធាតុចូល

សម្រាប់ក្រសួងផែនការរៀបចំរបាយការណ៍វឌ្ឍនភាពពេញលេញ សម្រាប់ឆ្នាំ២០១៩ នៃការសម្រេចបាន គោលដៅអភិវឌ្ឍប្រកបដោយចីរភាព។ ជាតុចូលដែលស្នើសុំឱ្យផ្ដល់ឱ្យដោយក្រសួង ស្ថាប័ន ផ្ដោតជាសំខាន់លើទិន្នន័យដែលខ្វះខាតនៅក្នុងរបាយការណ៍ត្រួតពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្ត ជាពិសេសទិន្ន័យសម្រាប់សូចនាករមួយចំនួនពីឆ្នាំ២០១៦ ដល់ឆ្នាំ២០១៨ និងទិន្នន័យដែលជាលទ្ធផលនៃការអនុវត្ត គ.អ.ច.ក. ក្នុងឆ្នាំ២០១៩ សម្រាប់សូចនាករទាំងអស់។

អនុសាសន៍នានា និងការស្នើសុំការកែសម្រួលលើសេចក្ដីព្រាងរបាយការណ៍ត្រូវបានទទួលតាមរយៈ កិច្ចប្រជុំពិភាក្សាអន្តរក្រសួងបន្តបន្ទាប់ និងការផ្ញើនូវសេចក្ដីព្រាងរបាយការណ៍នេះ ទៅក្រសួង ស្ថាប័ន និងភាគីដែលមានចំណែកពាក់ព័ន្ធ ដើម្បីផ្ដល់អនុសាសន៍។ ដៃគូអភិវឌ្ឍនានា ត្រូវបានលើកទឹកចិត្តឱ្យធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រសួង ស្ថាប័នតាមវិស័យ ក្នុងការផ្ដល់ជាតុចូលនិងផ្ដល់អនុសាសន៍សម្រាប់កែសម្រួលនិងបញ្ចប់ការរៀបចំរបាយការណ៍វឌ្ឍនភាពនេះ។ ដូចគ្នាដែរ ភាគីដែលមានចំណែកពាក់ព័ន្ធផ្សេងទៀត ក៏ត្រូវបានផ្ដល់ឱកាសក្នុងការផ្ដល់ជាតុចូល ក៏ដូចជាផ្ដល់អនុសាសន៍នានា លើសេចក្ដីព្រាងដែលបានរៀបចំផងដែរ។

*របាយការណ៍វឌ្ឍនភាពឆ្នាំ២០១៩ នៃការសម្រេចបាន គ.អ.ច.ក.* ត្រូវបានបញ្ចប់ និងទទួលការឯកភាពក្នុងពីខែសីហា ឆ្នាំ២០២០។ របាយការណ៍នេះ នឹងត្រូវបានបោះពុម្ពនិងផ្សព្វផ្សាយយ៉ាងទូលំទូលាយ ដល់គ្រប់ភាគីទាំងអស់ ទាំងក្នុងរាជរដ្ឋាភិបាលកម្ពុជា និងស្ថាប័នមិនមែនរដ្ឋាភិបាលទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

# ជំពូកទី៣

# បរិយាកាសនយោបាយអំណោយផលសម្រាប់ ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ការសម្រេចបាន គោលដៅ អភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា (គ.អ.ច.ក.) ២០១៦-២០៣០

## ៣.១ ការបង្កើតភាពជាម្ចាស់ លើការរៀបចំនិងអនុវត្តគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា

គោលដៅអភិវឌ្ឍប្រកបដោយចីរភាព (គ.អ.ច.) ចង្អុលបង្ហាញពីវិសាលភាពនៃរបៀបវារៈឆ្នាំ២០៣០ ដែលត្រូវបានអនុមតិដោយមហាសន្និបាទរបស់អង្គការសហប្រជាជាតិ កាលពីឆ្នាំ២០១៥ បានបង្ហាញពីអាទិភាពថ្មីនិងការគិតគូពីតម្រូវការនៃការអភិវឌ្ឍ និងទិសដៅនាពេលអនាគត របស់សាកលលោក។ សំខាន់ជាងនេះទៀត របៀបវារៈឆ្នាំ២០៣០ ទទួលស្គាល់អាទិភាពចំនួនពីរគឺ ការធ្វើឱ្យមានចីរភាពបរិស្ថាន (ជាពិសេស កាត់បន្ថយការគំរាមកំហែងដែលបង្កឡើងដោយការប្រែប្រួលអាកាសធាតុ) និងការបន្តលុបបំបាត់ភាពក្រីក្រ ដោយផ្តោតការយកចិត្តទុកដាក់លើការធានានូវសមធម៌ ក្រោមបាវចនា *មិនទុកចោលអ្នកណាម្នាក់នៅឯកកោ*។

ផ្ទុយនឹងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ (គ.អ.ស.) ដែលបានផ្តោតភាគច្រើនលើលទ្ធផលនៃគោលនយោបាយសង្គមនិងយកចិត្តទុកដាក់មួយចំនួនលើបរិស្ថាន *គោលដៅអភិវឌ្ឍប្រកបដោយចីរភាព (គ.អ.ច.)* ផ្តោតលើទិដ្ឋភាពទាំងអស់ឱ្យមានលក្ខណៈចីរភាពនិងបរិយាប័ន្ន និង យកចិត្តទុកដាក់ពេញលេញលើសមាសភាព សេដ្ឋកិច្ច សង្គម អភិបាលកិច្ច និងបរិស្ថាន។ របៀបវារៈនេះ ក៏បានពង្រីកគោលដៅរហូតដល់ចំនួន១៧ និងចំណុចដៅដល់ចំនួន១៦៩ ដែលធៀបនឹង គ.អ.ស. ដែលមានគោលដៅតែចំនួន៨ និងចំណុចដៅតែចំនួន៤៨ ប៉ុណ្ណោះ ដែលតាមរយៈនេះ បានបង្ហាញនូវមហិច្ឆតាធំធេងដោយព្យាយាមកាត់បន្ថយវិសមភាពក្នុងសង្គមឱ្យបានជាអតិបរមា ជាមួយគ្នានឹងការព្យាយាមជំរុញការបង្កើនកំណើនសេដ្ឋកិច្ច។ បន្ថែមលើនេះទៀត គ.អ.ច. បានបញ្ចូលនូវលទ្ធផលទាំងពីរនៃការអភិវឌ្ឍ គឺការលុបបំបាត់ភាពក្រីក្រនិងគម្លាតយេនឌ័រ ក៏ដូចជា ការណែនាំពីគោលដៅនានា ដូចជា ការទទួលបានការងារសមរម្យ ការជំរុញកំណើនសេដ្ឋកិច្ច និងការផលិតនិងប្រើប្រាស់ផលិតផលដោយការទទួលខុសត្រូវ ។ល។ ការរួមបញ្ចូលគ្នាជាមួយនឹងកម្រិតនៃមហិច្ឆតានេះ អាចធានាថា គ.អ.ច. នឹងផ្តល់នូវក្របខ័ណ្ឌផែនការមួយដែលមានលក្ខណៈទូលំទូលាយ មានការរួមបញ្ចូលគ្រប់ផ្នែក និងមានការតាមដានត្រួតពិនិត្យជាប្រចាំ។

កម្ពុជាបានចាប់ផ្ដើមដំណើរការធ្វើមូលដ្ឋាននីយកម្ម គ.អ.ច. នៅចុងឆ្នាំ២០១៥ ដោយធ្វើការពិនិត្យមើល បណ្ដាគោលដៅនិងចំណុចដៅសាកល ដើម្បីជ្រើសរើសដាក់បញ្ចូលក្នុងអាទិភាពជាតិ។ ទោះបីជាដំណើរការនេះ ជាការទទួលខុសត្រូវរបស់ក្រសួងផែនការក្ដី កិច្ចប្រជុំពិភាក្សាជាច្រើនស្ដីពីការរៀបចំសូចនាករ ត្រូវបានរៀបចំឡើងដោយមានការចូលរួមពីតំណាងក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជា ដៃគូអភិវឌ្ឍ និងភាគីដែលមានចំណែកពាក់ព័ន្ធនានា។ សេចក្ដីព្រាងចុងក្រោយនៃក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា ត្រូវបានទទួលការអនុមតិ ក្នុងខែវិច្ឆិកា ឆ្នាំ២០១៨ ដែលមានគោលដៅសរុបចំនួន១៨ ចំណុចដៅចំនួន៨៨ និងសូចនាករចំនួន១៤៨។

## ៣.២ ការធ្វើសមាហរណកម្ម គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា នៅក្នុងក្របខ័ណ្ឌនៃការរៀបចំផែនការនិងគោលនយោបាយជាតិ

ក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា រួមជាមួយនឹងរបៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានកំណត់នៅក្នុង*យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤* បានផ្ដល់នូវមូលដ្ឋានគ្រឹះសម្រាប់រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដែលមានអាណត្តិ ឆ្នាំ២០១៩-២០២៣។ រាជរដ្ឋាភិបាលកម្ពុជា បានរៀបចំនិងអនុមតិ*យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤* បន្ទាប់ពីការបោះឆ្នោតជាសាកល ខែកក្កដា ឆ្នាំ២០១៨។ គួរកត់សម្គាល់ផងដែរថា ដោយស្របតាមគោលដៅនានារបស់សាកល ក្របខ័ណ្ឌពេលវេលានៃ គ.អ.ច.ក. បាននឹងកំពុងបំពេញបន្ថែមនូវទស្សនវិស័យកម្ពុជា ឆ្នាំ២០៥០ ត្រឹមឆ្នាំ២០៣០ ជាមួយនឹងវដ្ដនៃការរៀបចំផែនការច្រើន ដែលជាទូទៅចំនួន៣វដ្ដផែនការ (រូបភាព ៣.១)។

គ.អ.ច.ក. ក៏បានផ្ដោតការយកចិត្តទុកដាក់ខ្ពស់លើ*ការមិនទុកចោលអ្នកណាម្នាក់នៅឯកោ* ដូចនេះ គ្រប់ប្រជាជនកម្ពុជាទាំងអស់ត្រូវរួមចំណែកនៅក្នុងការអភិវឌ្ឍនិងវិបុលភាពរបស់កម្ពុជា។ ការផ្ដោតការយកចិត្តទុកដាក់នេះ ស្របគ្នានឹងការប្ដេជ្ញាចិត្តក្នុងការធ្វើឱ្យមានចីរភាពនៃការអភិវឌ្ឍ ជាមួយគ្នានឹងការការពារធនធានធម្មជាតិរបស់ជាតិដ៏ណំបែប សម្រាប់ប្រជាជនជំនាន់បច្ចុប្បន្ននិងអនាគត និងជាមូលដ្ឋានដ៏មានប្រសិទ្ធភាពសម្រាប់ការប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ។

ក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា មានគោលបំណងជាក់លាក់ចំនួន៤ គឺ៖

- បង្ហាញពីសូចនាករ ចំណុចដៅ និងគោលដៅ ជាតិ ផ្អែកលើអាទិភាពជាតិ ដោយពិនិត្យមើលផងដែរលើ សូចនាករ ចំណុចដៅ និងគោលដៅសាកល។

- កំណត់ការទទួលខុសត្រូវរបស់ ក្រសួង ស្ថាប័ន ក្នុងការបង្កើតសកម្មភាពនានា សម្រាប់អនុវត្តដើម្បីធ្វើឱ្យសម្រេចបានបណ្តាចំណុចដៅដែលបានកំណត់ និងតាមដានត្រួតពិនិត្យនិងវាយតម្លៃ តាមកម្មវិធីកំណត់។
- កំណត់ប្រភពទិន្នន័យសម្រាប់សូចនាករនីមួយៗ និងវដ្តនៃទិន្នន័យនោះ ជាមួយនឹងការផ្តល់នូវនិយមន័យ និងវិធីសាស្រ្តសម្រាប់គណនាតម្លៃចំណុចដៅនៃសូចនាករនោះឱ្យបានច្បាស់លាស់។
- បង្ហាញពីការតម្រង់ទិសសម្រាប់ឆ្ពោះទៅធ្វើឱ្យសម្រេចបានចំណុចដៅ ការកំណត់តម្លៃគ្រាដើម (ឆ្នាំ២០១៥) ការកំណត់តម្លៃចំណុចដៅប្រចាំឆ្នាំ (ឬតាមវដ្តនៃទិន្នន័យ) និងការអនុវត្តនៅថ្នាក់វិស័យនិងថ្នាក់ក្រោមជាតិ។

**រូបភាព ៣.១៖ អាណត្តិកាលរបស់ គ.អ.ច.ក. និង ផែនការជាតិ**




*ប្រភព÷ ក្របខ័ណ្ឌ គ.អ.ច.ក. ២០១៦-២០៣០*

ក្របខ័ណ្ឌនេះ មិនមែនជាផែនការសកម្មភាពសម្រាប់អនុវត្តធ្វើឱ្យសម្រេចបានគោលដៅទេ ប៉ុន្តែវាបានផ្តល់នូវមូលដ្ឋានសម្រាប់ធ្វើសមាហរណកម្ម គ.អ.ច.ក. ទៅក្នុងប្រព័ន្ធផែនការជាតិ និងតាមដានត្រួតពិនិត្យពីលទ្ធផលនៃការសម្រេចបានគោលដៅនេះ តាមរយៈសកម្មភាពនិងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ដៃគូអភិវឌ្ឍ ផ្នែកឯកជន សង្គមស៊ីវិល និងភាគីដែលមានចំណែកពាក់ព័ន្ធផ្សេងទៀត។

## ៣.៣ ការបង្កើតស្ពានរវាងសមាសភាពទាំងបីនៃការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាប័ន្ន នៅក្នុងយុទ្ធសាស្ត្រនៃការអភិវឌ្ឍកម្ពុជា

ការធ្វើសមាហរណកម្មសមាសភាពសង្គម សេដ្ឋកិច្ច និងបរិស្ថាន គឺជាលក្ខខណ្ឌគន្លឹះសម្រាប់ធ្វើឱ្យសម្រេចបានការអភិវឌ្ឍប្រកបដោយចីរភាព។ រាជរដ្ឋាភិបាលកម្ពុជាបានយល់ពីភាពចាំបាច់ក្នុងការធ្វើសមាហរណកម្មសមាសភាពទាំងបីនេះ ប៉ុន្តែ នៅមានសំណួរចោទសួរថា តើធ្វើដូចម្តេច ដើម្បី

ឱ្យការធ្វើសមាហរណកម្មនេះទទួលបានជោគជ័យ។  កម្ពុជាបានដំណើរការយ៉ាងល្អប្រសើរក្នុងការងារនេះ។ សមាសភាពទាំងបីនេះ ត្រូវបានបញ្ជ្រាបទៅក្នុងផែនការអភិវឌ្ឍន៍ ទាំងនៅថ្នាក់ជាតិ វិស័យនិងថ្នាក់ក្រោមជាតិ។ នៅថ្នាក់ជាតិ ក្របខ័ណ្ឌស្នូលនៃ*យុទ្ធសាស្រ្តចតុកោណ ដំណាក់កាលទី៤* ដែលត្រូវបានអនុមតិក្នុងខែកក្កដា ឆ្នាំ២០១៨ បានផ្តោតលើចតុកោណចំនួន៤ គឺ *(១) ការអភិវឌ្ឍធនធានមនុស្ស (២) ការធ្វើពិពិធកម្មសេដ្ឋកិច្ច (៣) ការអភិវឌ្ឍផ្នែកឯកជននិងការងារ និង (៤) ការអភិវឌ្ឍដោយចីរភាពនិងបរិយាប័ន្ន*។ គោលនយោបាយនេះ ត្រូវបានកំណត់នៅក្នុងរូបភាព ៣.២ ខាងក្រោម។ យុទ្ធសាស្រ្តចតុកោណ ត្រូវបានដាក់ឱ្យអនុវត្តតាមរយៈ ផ.យអ.ជ. ដែលក្នុងនោះ បានកំណត់បែងចែកការងារនិងវិភាជថវិកាទៅតាមវិស័យ។ រាជរដ្ឋាភិបាលកម្ពុជាជឿជាក់ថា គ.អ.ច.ក. ត្រូវបានធ្វើសមាហរណកម្មយ៉ាងល្អ ទៅក្នុងផែនការថ្នាក់ជាតិ តាមរយៈ ការសំយោគទៅក្នុង ផ.យ.អ.ជ.។

នៅថ្នាក់វិស័យ គឺជាការតម្រូវឱ្យវិស័យនីមួយៗ ដែលជាទូទៅអាចមានក្រសួង ស្ថាប័នមួយឬច្រើនតាមវិស័យ  រៀបចំផែនការយុទ្ធសាស្រ្តតាមវិស័យរៀងខ្លួន  ដើម្បីរួមចំណែកអនុវត្តបណ្តាគោលនយោបាយអាទិភាពតាមវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា និងបញ្ជ្រាបបណ្តាគោលដៅ ចំណុចដៅ និងសូចនាកររបស់ គ.អ.ច.ក. ដែលពាក់ព័ន្ធនឹងវិស័យនោះ ដើម្បីអនុវត្តនិងធ្វើឱ្យសម្រេចបានតាមការគ្រោងទុក។ បណ្តាសកម្មភាពត្រូវបានលើកទឹកចិត្តឱ្យរៀបចំឡើងដើម្បីអនុវត្ត ទៅតាមសូចនាករ ចំណុចដៅនិងគោលដៅ។ ការកំណត់តម្លៃចំណុចដៅសូចនាករតាមឆ្នាំនីមួយៗ ត្រូវបានប្រើប្រាស់សម្រាប់ការតាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្ត។

នៅថ្នាក់ក្រោមជាតិ អនុក្រឹត្យស្តីពីការរៀបចំផែនការអភិវឌ្ឍន៍ ៥ឆ្នាំ និងកម្មវិធីវិនិយោគ ៣ឆ្នាំរំកិល នៅរាជធានី ខេត្ត ត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់ ក្នុងឆ្នាំ២០០៩។ ផែនការអភិវឌ្ឍន៍រាជធានីខេត្ត រយៈពេល៥ឆ្នាំ ត្រូវបានរៀបចំ និងត្រូវបានអនុមតិដោយក្រុមប្រឹក្សារាជធានី ខេត្ត។ ការរៀបចំផែនការអភិវឌ្ឍន៍ទាំងនេះ  គឺដើម្បីគាំទ្រនិងអនុវត្តយុទ្ធសាស្រ្តចតុកោណ  តាមរយៈ  ការកំណត់តំបន់អាទិភាពសូចនាករ  ការកំណត់ពេលវេលាសម្រាប់អនុវត្តផែនការនេះ  ការរៀបចំយន្តការសម្រាប់ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ការទទួលខុសត្រូវនិងអនុវត្តរបស់ស្ថាប័ន និងអ្នកដែលមានចំណែកពាក់ព័ន្ធ ក្រោមក្របខ័ណ្ឌរដ្ឋបាលរាជធានី  ខេត្ត។  ដំណើរការនៃការរៀបចំផែនការ  ត្រូវបានបញ្ចូលនូវការដោះស្រាយបញ្ហាប្រឈមចំនួន៤  តាមស្ថានភាពជាក់ស្តែងរបស់រាជធានី  ខេត្តនីមួយៗគឺ  (១)  សេដ្ឋកិច្ច  (២)អភិវឌ្ឍសង្គម (៣) ធនធានធម្មជាតិ បរិស្ថាន និង បន្សាំការប្រែប្រួលអាកាសធាតុ និង (៤) សន្តិសុខ។ រាជរដ្ឋាភិបាលកម្ពុជា បានទទួលស្គាល់ថា គ.អ.ច.ក. ត្រូវការបំបែកនិងធ្វើសមាហរណកម្មទៅក្នុងផែនការថ្នាក់ក្រោមជាតិ ដែលបានចាប់ផ្តើមអាណត្តិកាលថ្មីក្នុងឆ្នាំ២០១៩ កន្លងទៅ។

## រូបភាព ៣.២÷ យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤




*ប្រភព÷ រាជរដ្ឋាភិបាលកម្ពុជា ២០១៨*

## ៣.៤ ការអភិវឌ្ឍសេដ្ឋកិច្ច ចីរភាព និង បរិយាប័ន្ន

ការអភិវឌ្ឍសេដ្ឋកិច្ច គឺជាគន្លឹះនៃការអភិវឌ្ឍនៅកម្ពុជា ហើយការងារនេះនឹងនៅតែជាកត្តានាំមុខគេសម្រាប់បង្កើតការងារ និងវិបុលភាពដល់ប្រជាជនកម្ពុជា។ ក្នុងបរិការណ៍នេះ កម្ពុជាកំពុងអភិវឌ្ឍលើគ្រប់វិស័យ ជាមួយនឹងការផ្តោតការយកចិត្តទុកដាក់លើសមាសភាពពីរផ្សេងទៀត (សង្គម និងបរិស្ថាន) ដូចបានកំណត់នៅក្នុង*យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤*។ ដូចគ្នានេះដែរ រាជរដ្ឋាភិបាលកម្ពុជាក៏បានយល់ស្របផងដែរថា គោលដៅបរិយាប័ន្នសង្គម និងបរិស្ថាន មិនអាចសម្រេចនិងរក្សាបានទេ ប្រសិនបើការងារមិនមានសុខដុមនីយកម្មជាមួយការអភិវឌ្ឍសេដ្ឋកិច្ច។

បន្ថែមលើនេះទៀត គោលដៅជាច្រើនរបស់ គ.អ.ច.ក. ដែលមិនមានការពាក់ព័ន្ធជាមួយសកម្មភាពសេដ្ឋកិច្ច ដូចជា គោលដៅសង្គមនិងសាធារណៈ ដែលទាមទារឱ្យមានការវិភាជថវិកាសម្រាប់ធ្វើឱ្យសម្រេចបាន ហើយប្រភពថវិកាទាំងនេះ ត្រូវតែបង្កើតចេញពីផលិតកម្មនៃសកម្មភាពសេដ្ឋកិច្ច។ ដូចនេះ ស្ថិរភាពកំណើនសេដ្ឋកិច្ចខ្ពស់គឺជាចំណុចស្នូលដែលធ្វើឱ្យសម្រេចបាន គ.អ.ច.ក.។ រាជរដ្ឋាភិបាលកម្ពុជា នឹងអនុមតិគោលនយោបាយសេដ្ឋកិច្ចមួយដែលមានឫសគល់ចម្រុះសម្រាប់កំណើនជាអតិបរមា និងជំរុញការផ្លាស់ប្តូររចនាសម្ព័ន្ធ ទន្ទឹមនឹងការលើកកម្ពស់និរន្តរភាពនិងបរិយាប័ន្ន។

ទោះជាដូចនេះក្ដី នៅក្នុងរយៈពេលមធ្យម កម្ពុជាមានគោលដៅក្លាយជាប្រទេសដែលអាចពឹងផ្អែកភាគច្រើនលើសេដ្ឋកិច្ចខ្លួនឯង និងកាត់បន្ថយឱ្យនៅកាន់តែតិចទៅៗ នូវការពឹងផ្អែកលើជំនួយបច្ចេកទេសនិងហិរញ្ញវត្ថុរបស់បរទេស ជាមួយនឹងសេដ្ឋកិច្ចជាតិមានសមត្ថភាពបង្កើតការងារ។ គោលដៅនេះ ពឹងផ្អែកលើការអភិវឌ្ឍដោយមានប្រសិទ្ធភាពក្នុងវិស័យឧស្សាហកម្ម និងសកម្មភាពថ្មីនានាដែលផ្ដល់នូវតម្លៃបន្ថែមនិងផលប្រយោជន៍ខ្ពស់។

គ្រប់ចំណុចដែលបានពិចារណាលើកឡើងនេះ គឺជាតម្រូវការសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាពនិងបរិយាប័ន្ន។ ដូចនេះ នៅក្នុងឆ្នាំបន្តបន្ទាប់ រាជរដ្ឋាភិបាលកម្ពុជានឹងបង្កើនកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីសម្រេចឱ្យបានការអភិវឌ្ឍសេដ្ឋកិច្ច ជាមួយគ្នានឹង ការគិតគូរដល់ការបន្សាំនឹងបរិស្ថាន និងបរិយាប័ន្នក្នុងសង្គម។

## ៣.៥ មិនមាននរណាម្នាក់ត្រូវបានទុកឱ្យនៅឯកោ

បរិយាប័ន្នជាចំណុចមួយដ៏សំខាន់ នៅក្នុងទស្សនវិស័យឆ្នាំ២០៥០ របស់កម្ពុជា។ ចំណុចគន្លឹះនេះ បានកំណត់ការអភិវឌ្ឍគោលនយោបាយគន្លឹះចំនួន៣ នៅក្នុងចតុកោណទី១ (ការអភិវឌ្ឍធនធានមនុស្ស) នៃយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤គឺ៖

**ទី១៖** ការរៀបចំ ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ ផែនការយុទ្ធសាស្ត្រដើម្បីធានាសុវត្ថិភាពចំណូល និងការកាត់បន្ថយហានិភ័យហិរញ្ញវត្ថុនិងសេដ្ឋកិច្ចរបស់ប្រជាជន។ រាជរដ្ឋាភិបាលកម្ពុជាមានគោលបំណងបង្កើនកម្រិតសុខុមាលភាពរបស់ប្រជាជន បង្កើតភាពបន្សាំទៅនឹងហានីភ័យផ្សេងៗ ជំរុញការសាមគ្គីភាពសង្គម និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនឱ្យបានជាអតិបរមា។ ជារួម ក្របខ័ណ្ឌគោលនយោបាយនេះ បានបន្សុី និងធ្វើឱ្យប្រសើរឡើងកម្មវិធីគាំពារសង្គមដែលមានស្រាប់ និងលើកកម្ពស់ ប្រសិទ្ធភាព សមភាព តម្លាភាព និងសង្គតិភាព នៃប្រព័ន្ធគាំពារសង្គម។ ប្រព័ន្ធគាំពារសង្គមនេះ នឹងមានការរីកចម្រើន អាស្រ័យដោយកម្រិតនិងគោលបំណងនៃការពង្រីកវិសាលភាពដែលកំពុងគ្របដណ្ដប់នាពេលបច្ចុប្បន្ន ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាជននៅគ្រប់ផ្នែកទាំងអស់។ ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ នឹងដើរតួនាទីយ៉ាងសំខាន់ ក្នុងការបង្កើនលទ្ធភាពទទួលបានសេវាគាំពារសង្គម និងជំនួយសង្គម របស់ប្រជាជនជាសាធារណៈ និងរបស់ផ្នែកផ្លូវការនិងមិនផ្លូវការ នៃផ្នែកឯកជន។ ដើម្បីធ្វើឱ្យសម្រេចបានទស្សនទានថ្មីសម្រាប់ប្រព័ន្ធគាំពារសង្គមរបស់កម្ពុជា រាជរដ្ឋាភិបាលកម្ពុជានឹងរៀបចំនូវយន្តការនិងកម្មវិធីចាំបាច់នានា ជាជំហានៗ។ ជាមួយគ្នានេះ ក៏នឹងត្រូវធ្វើការកែទម្រង់ប្រព័ន្ធនេះ ដើម្បីផ្ដោតការយកចិត្តទុកដាក់លើការការពារប្រជាជនក្រីក្រនិងក្រុមជនងាយរងគ្រោះ និងបង្កើតនូវហេដ្ឋារចនាសម្ព័ន្ធចាំបាច់ ដើម្បីធានាប្រសិទ្ធភាព និងនិរន្តរភាព។ បន្ថែមលើនេះ នៅក្នុងពេលអនាគត ក្របខ័ណ្ឌស្ដីពីអភិបាលកិច្ចនិងបញ្ហាអន្តរវិស័យ នឹងត្រូវបានរៀបចំឡើងដើម្បីធានានូវប្រសិទ្ធភាពរបស់ប្រព័ន្ធ និងផលប៉ះពាល់របស់ថវិកា។

**ទី២៖** គឺជាបញ្ហាការថែទាំសុខភាព ជាពិសេស ការទទួលបាននូវសេវាដែលមានគុណភាពនិងថ្លៃសមរម្យ។ មូលនិធិសមធម៌សុខភាពកម្ពុជា ត្រូវបានបង្កើតឡើងដោយក្រសួងសុខាភិបាល ផ្តល់នូវសេវាថែទាំសុខភាពដោយមិនគិតថ្លៃ ដល់ប្រជាជនទាំងអស់ដែលត្រូវបានកំណត់ថាក្រ (ដោយកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ)។

**ទី៣៖** ការប្រែប្រួលក្នុងផ្នែកប្រជាសាស្ត្រ គឺជាបញ្ហាដែលមិនអាចជៀសវាងបាន ជាពិសេស គឺការទទួលស្គាល់ពីការកើនឡើងនៃសមាមាត្រប្រជាជនវ័យចាស់ ដែលមិនត្រឹមតែមានផលលំបាកដល់ប្រជាជនវ័យចាស់ខ្លួនឯងទេ ប៉ុន្តែ នឹងមានផលប៉ះពាល់ដល់ផ្នែកទាំងអស់នៃសង្គម និងសេដ្ឋកិច្ច។ រាជរដ្ឋាភិបាលកម្ពុជា បានកែសម្រួលគោលនយោបាយមនុស្សចាស់ឆ្នាំ២០០៣ និងបានដូរឈ្មោះជា "*គោលនយោបាយជាតិសម្រាប់មនុស្សចាស់ ២០១៧-២០៣០*"។ គោលនយោបាយនេះ មានគោលបំណងដើម្បីបញ្ជ្រាបបញ្ហាមនុស្សចាស់ ទៅក្នុងដំណើរការនៃការរៀបចំផែនការ ដោយផ្អែកលើគោលគំនិតជាមូលដ្ឋានចំនួន៣ គឺ៖

១. លុបបំបាត់ការរើសអើងលើមូលដ្ឋានអាយុ ដូចនេះ មនុស្សចាស់ត្រូវបានធានាទទួលបានសិទ្ធិស្មើគ្នាដូចមនុស្សវ័យក្មេង ហើយទទួលបានការព្យាបាល និងការគោរព។
២. ធានាឱ្យមានសមភាពយេនឌ័រ ដោយផ្តោតការយកចិត្តទុកដាក់បន្ថែមទៀតលើស្ត្រី ដែលភាគច្រើនក្នុងចំណោមមនុស្សចាស់ និងមានភាពងាយរងគ្រោះជាងបុរស។
៣. ជំរុញឱ្យមានទំនាក់ទំនងអន្តរជំនាន់ ដែលអាចថែរក្សាភាពខ្លាំងនៃប្រព័ន្ធគ្រួសារចូលរួម និងលក្ខណៈសម្គាល់នៃវប្បធម៌ខ្មែរ។

ទស្សនទាននៃគោលនយោបាយនេះគឺធានាថា ប្រជាជនវ័យចាស់ ត្រូវបានផ្តល់អំណាចឱ្យចូលរួមពេញលេញ ដោយសេរី និងដោយសេចក្តីថ្លៃថ្នូរ តាមបំណងរបស់ពួកគាត់ ក្នុងសកម្មភាពគ្រួសារ សហគមន៍ សេដ្ឋកិច្ច សង្គម សាសនា និង នយោបាយ។ បន្ថែមលើនេះទៀត គ្រប់ប្រជាជនវ័យចាស់ ដែលមានចំណេះដឹង អនុញ្ញាតឱ្យពួកគាត់ដឹកនាំបង្កើតឱ្យមានផលិតភាពកាន់តែច្រើន សុខភាព សកម្មភាព និងភាពថ្លៃថ្នូរ នៅក្នុងជីវិតវ័យចាស់របស់ខ្លួន។

## ៣.៦ ការធានាឱ្យមានចីរភាពបរិស្ថាន

ក្នុងគោលបំណងធ្វើឱ្យសម្រេចបានទស្សនទានកម្ពុជាឆ្នាំ២០៥០ រាជរដ្ឋាភិបាលកម្ពុជាបានផ្តោតការយកចិត្តទុកដាក់កាន់តែខ្លាំងលើហេតុប៉ះពាល់បរិស្ថាន ពីការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម។ ការយកចិត្តទុកដាក់ច្រើនជាងមុន នឹងត្រូវបានផ្តោតលើការគ្រប់គ្រងធនធានធម្មជាតិ និងការឆ្លើយតបទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ បញ្ហានេះត្រូវបានបញ្ជាក់យ៉ាងច្បាស់ នៅក្នុងចតុកោណទី៤ នៃ*យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤*។ គោលនយោបាយជាក់លាក់ចំនួន២ ពាក់ព័ន្ធនឹងបញ្ហានេះ ត្រូវបានផ្តួចផ្តើមបង្កើតឡើងគឺ៖ **ទី១** តម្រូវការចាំបាច់ក្នុងការធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងព្រៃឈើ និងទឹកហូរដ៏ណ៌បែបរបស់កម្ពុជា។ ពាក់ព័ន្ធនឹងបញ្ហានេះ សេចក្តីព្រាង*ក្រមស្តីពីបរិស្ថាននិង*

*ធនធានធម្មជាតិ* ត្រូវបាននិងកំពុងរៀបចំ ដើម្បីជួយដល់ការអភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជា តាមរយៈការការពារនិងអភិរក្សបរិស្ថាន ការស្ដារឡើងវិញនិងគ្រប់គ្រង ធនធានវប្បធម៌ និងធម្មជាតិ។ **ទី២** តម្រូវការចាំបាច់ ក្នុងកិច្ចខិតខំប្រឹងប្រែងកាត់បន្ថយផលប៉ះពាល់ពីការកើនឡើងនៃកំដៅក្នុងពិភពលោក។ *ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា ២០១៤-២០២៣* ត្រូវបានរៀបចំឡើង ដោយឆ្លុះបញ្ចាំងពីឆន្ទៈនយោបាយ និងការប្ដេជ្ញាចិត្តយ៉ាងមុតមាំ និង ការត្រៀមខ្លួនរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការកាត់បន្ថយផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុទៅលើការអភិវឌ្ឍជាតិ និងការរួមចំណែកជាមួយសហគមន៍អន្តរជាតិ ក្នុងកិច្ចខិតខំប្រឹងប្រែងជាសកលសម្រាប់កាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ក្រោមក្របខ័ណ្ឌអនុសញ្ញារបស់អង្គការសហប្រជាជាតិស្ដីពីការប្រែប្រួលអាកាសធាតុ។ ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងផែនការនៅថ្នាក់ជាតិ តាមវិស័យ និងថ្នាក់ក្រោមជាតិ និងការរៀបចំយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុ ក្របខ័ណ្ឌផែនការសកម្មភាពនិងហិរញ្ញវត្ថុ គឺជាសកម្មភាពអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា។ *ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា* នឹងណែនាំស្ថាប័នជាតិ និងជួយអង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ ក្នុងការរៀបចំមូលដ្ឋានគ្រឹះ វិធានការនិងផែនការសមស្រប ពាក់ព័ន្ធនឹងការបន្សាំនិងកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ ដែលជាកត្តាដ៏សំខាន់សម្រាប់ការធ្វើឱ្យសម្រេចបានយុទ្ធសាស្ត្រចតុកោណ និង គ.អ.ច.ក.។

# ជំពូកទី៤

# វឌ្ឍនភាពតាមសូចនាករនិងចំណុចដៅក្នុងគោលដៅនីមួយៗ

## ៤.១ សេចក្ដីផ្ដើម

គោលបំណងសំខាន់របស់របាយការណ៍វឌ្ឍនភាពនេះ គឺបង្ហាញពីលទ្ធផលនៃការតាមដានត្រួតពិនិត្យនិងវាយតម្លៃ លើការសម្រេចបាន គ.អ.ច.ក. នៅថ្នាក់ជាតិរបស់កម្ពុជា ដោយផ្អែកលើរបាយការណ៍បែបគុណភាព និងទិន្នន័យបែបបរិមាណ។ ជំពូកនេះនឹងបង្ហាញពីវឌ្ឍនភាពរហូតត្រឹមឆ្នាំ ២០១៩ ដោយពិនិត្យមើលពីលទ្ធផលនៃការសម្រេចបានរបស់សូចនាករ និងចំណុចដៅនានា តាមគោលដៅនីមួយៗ ក្នុងគោលដៅទាំង១៧ ដែលទទួលយកពីគោលដៅអភិវឌ្ឍប្រកបដោយចីរភាពសាកល និងគោលដៅទី១៨ ដែលជាគោលដៅជាតិ។ ការតាមដានត្រួតពិនិត្យនិងវាយតម្លៃនេះ គឺផ្អែកជាសំខាន់លើលទ្ធផលដែលសម្រេចបានជាក់ស្ដែង ដោយធ្វើការប្រៀបធៀបទៅនឹងតម្លៃចំណុចដៅរបស់សូចនាករនីមួយៗ ដែលបានកំណត់ ពីឆ្នាំ២០១៦ ដល់២០១៩។ ជាការពិត មានសូចនាករមួយចំនួន មិនមានចំណុចដៅទេក្នុងឆ្នាំ២០១៩ នេះ ដោយសារទិន្នន័យដែលគាំទ្រសូចនាករនោះ ពុំមានវដ្តនៃការផលិតនៅក្នុងឆ្នាំនេះ ដូចនេះ ការវាយតម្លៃពីភាព "គ្មានទិន្នន័យ" គឺមួយចំនួនបណ្ដាលមកពីវដ្តនៃទិន្នន័យ។

ការវាយតម្លៃពីវឌ្ឍនភាពនៃសូចនាករនិងចំណុចដៅទាំងនេះ ត្រូវបានបែងចែកនិងបង្ហាញ ជា៣កម្រិត ដូចខាងក្រោម៖

ក. **លើសចំណុចដៅ៖** គឺជាការបង្ហាញឱ្យឃើញពីលទ្ធផលល្អប្រសើរ ដែលជាការអនុវត្តបានលើសតម្លៃចំណុចដៅដែលបានកំណត់១០% នៅក្នុងឆ្នាំអនុវត្តនីមួយៗ។

ខ. **ស្ថិតលើគន្លងឈានទៅសម្រេចបាន៖** គឺជាលទ្ធផលល្អ ដែលជាការកំណត់បង្ហាញតម្លៃនៃលទ្ធផលអនុវត្តនៅចន្លោះរវាងក្រោមតម្លៃចំណុចដៅដែលបានកំណត់ត្រឹម១០% និងលើសតម្លៃចំណុចដៅដែលបានកំណត់ត្រឹម១០% នៅក្នុងឆ្នាំអនុវត្តនីមួយៗ។

គ. **ទាបជាងចំណុចដៅ៖** គឺជាលទ្ធផល ដែលជាការកំណត់បង្ហាញតម្លៃនៃលទ្ធផលអនុវត្ត ទាបជាងតម្លៃចំណុចដៅដែលបានកំណត់១០% នៅក្នុងឆ្នាំអនុវត្តនីមួយៗ។

ក្រៅពីកម្រិតទាំង៣ នៃការវាយតម្លៃនេះ **គ្មានទិន្នន័យ** នឹងត្រូវផ្ដល់ជាការកំណត់ចំណាំ ចំពោះសូចនាករឬចំណុចដៅណា ដែលពុំមានទិន្នន័យគាំទ្រសម្រាប់ការវាយតម្លៃពីលទ្ធផលនៃការអនុវត្ត នៅក្នុងអាណត្តិកាលនៃការរៀបចំរបាយការណ៍វឌ្ឍនភាពនេះ។ ការពុំមានទិន្នន័យគាំទ្រ ត្រូវបានចែកចេញជាពីរផ្នែកគឺ **ទី១** សំដៅលើការពុំមិនមានប្រភពទិន្នន័យគាំទ្រ សម្រាប់ការវាយតម្លៃពីលទ្ធផលនៃការសម្រេចបាន សូចនាករឬចំណុចដៅ របស់ គ.អ.ច.ក. និង **ទី២** មានប្រភពទិន្នន័យគាំទ្រ ប៉ុន្តែពុំមានវដ្តសម្រាប់ផលិតនៅក្នុងអាណត្តិកាលនៃការរៀបចំរបាយការណ៍ (ក្នុងករណីរបាយការណ៍នេះ គឺឆ្នាំ២០១៩)

ជាពិសេស ទិន្នន័យដែលពឹងផ្អែកលើអង្កេតនានាដែលមានរយៈពេលវែង (៥ឆ្នាំម្តង) ដូចជា អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា និង អង្កេតប្រជាសាស្រ្តនិងសុខភាពកម្ពុជា ជាដើម។

## ៤.២ ការវាយតម្លៃសូចនាករនិងចំណុចដៅ តាមគោលដៅនីមួយៗ

ផ្នែកនេះនឹងបង្ហាញអំពីការវាយតម្លៃលម្អិតលើការសម្រេចបានរបស់គោលដៅទាំងអស់ នៃគោលដៅអភិវឌ្ឍប្រកបដោយចីរភពកម្ពុជា។ ការវាយតម្លៃនេះ នឹងធ្វើឡើងទៅលើការសម្រេចបានតាមសូចនាករ ឬចំណុចដៅទាំងអស់ នៅក្នុងគោលដៅនីមួយៗ ដោយវាយតម្លៃទៅតាមចំណាត់ថ្នាក់ចំនួន ៣ ដែលបានរៀបរាប់ខាងលើ និងកំណត់ថា គ្មានទិន្នន័យ ក្នុងករណីពុំមានព័ត៌មានឬទិន្ន័យសម្រាប់បង្ហាញពីលទ្ធផល។

ផ្អែកលើលទ្ធផលដែលទទួលបាន កម្ពុជាសម្រេចបានសមិទ្ធផលមួយចំនួនលើសូចនាករ និងចំណុចដៅទាំងអស់ ដែលចំណុចដៅប្រមាណចំនួន៥៦ ក្នុងចំណោមចំនួន៨៨ (ស្មើនឹង៦៣,៦៤%) ស្ថិតលើគន្លងឈានទៅសម្រេចបាន ឬសម្រេចលើសចំណុចដៅដែលបានកំណត់ និងមានតែចំណុចដៅចំនួន១៤ (ជិត១៦%) ប៉ុណ្ណោះ ដែលសម្រេចបានទាបជាងចំណុចដៅដែលបានកំណត់។

ក្នុងចំណោមចំណុចដៅចំនួន៨៨ មាន១៨ (ស្មើនឹង២០,៤៥%) គ្មានទិន្ន័យគាំទ្រ ដែលក្នុងនោះ មានតែប្រមាណជាង ១ភាគ៣ ប៉ុណ្ណោះ ដែលពុំមានប្រភពទិន្នន័យ ចំណែកឯសូចនាករជិត ២ភាគ៣ ទៀត មានប្រភពទិន្នន័យគាំទ្រ តែពុំមានវដ្តទិន្នន័យផលិតសម្រាប់ការវាយតម្លៃលទ្ធផលអនុវត្ត គ.អ.ច.ក. ក្នុងឆ្នាំ២០១៩ នេះទេ ដូចនេះ អាចចាត់ទុកថា ពុំមានទិន្នន័យក្នុងឆ្នាំ២០១៩ តែនឹងអាចមានទិន្ន័យគាំទ្រនៅឆ្នាំខាងមុខ ដែលមានវដ្តទិន្ន័យផលិត។ វឌ្ឍនភាពដែលត្រូវបានវាយតម្លៃដោយផ្អែកលើតម្លៃចំណុចដៅរបស់ គ.អ.ច.ក. ត្រូវបានបង្ហាញនៅក្នុងរូបភាព ៤.១ ដូចខាងក្រោម៖

- ៣១,៨២% នៃចំណុចដៅ៖ សម្រេចលើសចំណុចដៅ
- ៣១,៨២% នៃចំណុចដៅ៖ ស្ថិតលើគន្លងទៅសម្រេចបានចំណុចដៅ
- ១៥,៩១% នៃចំណុចដៅ៖ សម្រេចបានទាបជាងចំណុចដៅ
- ២០,៤៥% នៃសូចនាករ៖ គ្មានទិន្នន័យ (រួមទាំង គ្មានវដ្តទិន្នន័យ និង គ្មានប្រភពទិន្នន័យ)

**រូបភាព ៤.១៖ លទ្ធផលនៃការអនុវត្តគោលដៅនៃ គ.អ.ច.ក.**



# គោលដៅទី១៖ បញ្ចប់ភាពក្រីក្រគ្រប់ទម្រង់នៅគ្រប់ទីកន្លែង

## វឌ្ឍនភាព

កម្ពុជាសម្រេចបានសមិទ្ធផលជាច្រើនក្នុងទសវត្សរ៍ចុងក្រោយនេះ។ ភាពក្រីក្ររបស់ប្រជាជនកម្ពុជា បានថយចុះពី៤៧,៨% ក្នុងឆ្នាំ២០០៧ មកត្រឹម១៣,៥% ក្នុងឆ្នាំ២០១៤ ដែលជាការកាត់បន្ថយភាពក្រីក្រគួរឱ្យកត់សម្គាល់នៅក្នុងតំបន់ និងក្នុងពិភពលោក។ ជាមធ្យម ការកាត់បន្ថយភាពក្រីក្រមានប្រមាណជិត៥% ក្នុង១ឆ្នាំ។ នៅឆ្នាំ២០១៩ ប្រជាជនកម្ពុជាប្រមាណ៧៥% រស់នៅតាមតំបន់ជនបទ ហើយភាពក្រីក្រជនបទ មានការប្រែប្រួលទៅតាមនិន្នាការជាតិ។

### តារាង ៤.១៖ វឌ្ឍនភាពគោលដៅទី១ នៃ គ.អ.ច.ក.

| | ចំណុចដៅ/សូចនាករ | ឯកតា | ២០១៥ | ចំណុចដៅ គអ.ច.ក. | | | | ជាក់ស្តែង | | | | វឌ្ឍនភាព |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | |
| ១.២ | កាត់បន្ថយយ៉ាងតិចពាក់កណ្តាលនូវសមាមាត្រនៃបុរស ស្ត្រីនិងកុមារ គ្រប់អាយុ ដែលរស់នៅក្នុងភាពក្រីក្រ គ្រប់សមាសភាព ដោយផ្អែកលើនិយមន័យរបស់កម្ពុជានៅត្រឹមឆ្នាំ២០៣០ | | | | | | | | | | | គ្មានទិន្នន័យ |
| ១.២.១ | សមាមាត្រនៃប្រជាជនកម្ពុជារស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រជាតិ បែងចែកតាមភេទ អាយុ និងតំបន់ភូមិសាស្ត្រ | % | - | - | - | - | | - | - | - | | គ្មានទិន្នន័យ |
| ១.២.១.១ | សមាមាត្រនៃប្រជាជនកម្ពុជារស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រជាតិ។ | % | ១៣,៥ (២០១៤) | - | - | | ១១,៥ | - | - | - | | គ្មានទិន្នន័យ |
| ១.២.១.២ | សមាមាត្រនៃប្រជាជនកម្ពុជានៅរាជធានីភ្នំពេញ ដែលរស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រជាតិ។ | % | ១២,៩ (២០១៤) | - | - | | ១៥,៧ | - | - | - | | គ្មានទិន្នន័យ |
| ១.២.១.៣ | សមាមាត្រនៃប្រជាជនកម្ពុជានៅតំបន់ទីប្រជុំជន ដែលរស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រ។ | % | ១២,៩ (២០១៤) | - | - | | ១១,៥ | - | - | - | | គ្មានទិន្នន័យ |
| ១.២.១.៤ | សមាមាត្រនៃប្រជាជនកម្ពុជា តំបន់ជនបទ ដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្រ។ | % | ១២,៥ (២០១៤) | - | - | | ១១,៥ | - | - | - | | គ្មានទិន្នន័យ |
| ១.២.១.៥ | សមាមាត្រនៃកុមារកម្ពុជារស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រជាតិ។ | % | ២២,២ (បានស្មាន) | - | ២១,០ | | ១៩,៤ | - | - | - | | គ្មានទិន្នន័យ |
| ១.២.២ | សមាមាត្រកុមារ ដែលរស់នៅក្នុងភាពក្រីក្រគ្រប់សមាសភាព ផ្អែកតាមនិយមន័យរបស់ជាតិ។ | % | ៥០,៧ | - | - | | | - | - | - | | គ្មានទិន្នន័យ |
| ១.៣ | អនុវត្តប្រព័ន្ធជាតិគាំពារសង្គមនិងវិធានការផ្សេងៗ ឱ្យបានទូទាំងប្រទេស និងសម្រេចឱ្យបានភាគច្រើននូវភាពគ្របដណ្តប់នៃប្រព័ន្ធនេះ ដល់ប្រជាជនក្រីក្រ និងប្រជាជនងាយរងគ្រោះ នៅត្រឹមឆ្នាំ២០៣០។ | | | | | | | | | | | ទាបជាងចំណុចដៅ |
| ១.៣.១ | សមាមាត្រនៃជនក្រីក្រ និងជនងាយរងគ្រោះដែលទទួលបានសោវសង្គ្រោះសង្គម។ | % | ៣,៧៩ (២០១៧) | - | ៣,៧៩ | ៣,៦៧ | ៣,៥៤ | ២,៣២ | ៣,៥៨ | ៣,៤៩ | ២,២៨ | ទាបជាងចំណុចដៅ |
| ១.៤ | ត្រឹមឆ្នាំ២០៣០ ធានាថាបុរសស្ត្រីគ្រប់រូប ជាពិសេសប្រជាជនក្រីក្រនិងប្រជាជនងាយរងគ្រោះមានសិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់ធនធានសេដ្ឋកិច្ចនិងក្នុងការទទួលបានសេវាមូលដ្ឋាន ភាពជាម្ចាស់ និងការគ្រប់គ្រងដីនិងកម្មសិទ្ធិផ្សេងទៀត ធនធានធម្មជាតិ បច្ចេកវិទ្យាថ្មីៗសមស្របនិងសេវាហិរញ្ញវត្ថុ រួមទាំងមីក្រូហិរញ្ញវត្ថុ។ | | | | | | | | | | | លើសចំណុចដៅ |
| ១.៤.១ | ភាគរយនៃសមាជិកសហគមន៍នេសាទ និងព្រៃឈើដែលទទួលបានសិទ្ធិស្របច្បាប់ក្នុងការចូលរួមគ្រប់គ្រងធនធានជលផលនិងព្រៃឈើ តាមរយៈការចុះបញ្ជីនិងអភិវឌ្ឍសហគមន៍ប្រកបដោយប្រសិទ្ធភាព។ | % | ៤០,០ (២០១៦) | ៤០,០ | ៤៣,០ | ៤៥,០ | ៤៨,០ | 85,0 | ៨៨,០ | ៩១,០ | ៩២,០ | លើសចំណុចដៅ |

*ប្រភព៖ ក្របខ័ណ្ឌ គ.អ.ច.ក. និង ក្រសួង ស្ថាប័ន*

ទំហំជាមធ្យមនៃសមាជិកក្នុងគ្រួសារក្រីក្រ មានចំនួន៥,៦នាក់ ជាចំនួនច្រើនជាងទំហំមធ្យមនៃសមាជិកគ្រួសារទូទាំងប្រទេស ដែលមានចំនួនតែ៤,៥នាក់ ប៉ុណ្ណោះ។ ជាទូទៅ ការប្រើប្រាស់នៅក្នុងគ្រួសារដែលមានមនុស្សពេញវ័យធ្វើការងារនិងមានកម្រិតសិក្សាទាប មានកម្រិតទាប។ មធ្យមភាពនៃរយៈពេលសិក្សារបស់សមាជិកគ្រួសារក្រីក្រ មានការប្រែប្រួលពី៣,១ឆ្នាំ ក្នុងឆ្នាំ២០០៤ ទៅ

៣,៣ឆ្នាំ ក្នុងឆ្នាំ២០១១ បើប្រៀបធៀបទៅនឹងរយៈពេលនៃការសិក្សាក្នុងគ្រួសារដែលមានកម្រិតជីវភាពមធ្យម មានពី៣,៩ឆ្នាំ នៅឆ្នាំ២០០៤ ទៅ៥,១ឆ្នាំ ក្នុងឆ្នាំ២០១១។ តាមរយៈធនាគារពិភពលោក ឆ្នាំ ២០១៣ ភាពក្រីក្រមានកម្រិតខ្ពស់ជាងគេ ក្នុងចំណោមជនជាតិភាគ។

## បញ្ហាប្រឈម

ខណៈពេលដែលកម្រិតនៃការកាត់បន្ថយភាពក្រីក្រមានភាពរីកចម្រើន ប៉ុន្តែនៅមានប្រជាជនជាច្រើននៅតែស្ថិតក្នុងភាពងាយរងគ្រោះ គឺមានកម្រិតជីវភាពស្ថិតនៅកៀកកិតនឹងខ្សែបន្ទាត់ភាពក្រីក្រ។ នៅពេលដែលមានហានិភ័យណាមួយកើតមានឡើង ពួកគាត់អាចនឹងធ្លាក់ទៅក្នុងភាពក្រីក្រវិញ។ ភាពងាយរងគ្រោះនៃការធ្លាក់ចូលទៅក្នុងភាពក្រីក្រគឺមានកម្រិតខ្ពស់នៅក្នុងប្រទេសកម្ពុជា។ ការកាត់បន្ថយភាពក្រីក្រនាពេលអនាគត ក៏នឹងពឹងផ្អែកលើសមត្ថភាពរបស់កម្ពុជាខ្លួនឯង ក្នុងការដោះស្រាយបញ្ហាភាពងាយរងគ្រោះទៅនឹងភាពក្រីក្រនេះ។ ប្រជាជនភាគច្រើនដែលរួចចាកផុតពីភាពក្រីក្រ បានស្ថិតនៅលើខ្សែបន្ទាត់ភាពក្រីក្រ តែនៅកៀកកិតនឹងខ្សែបន្ទាត់ភាពក្រីក្រនោះ ហើយអត្រានៃភាពក្រីក្រមានការប្រែប្រួលយ៉ាងខ្លាំងចំពោះការផ្លាស់ប្តូរតិចតួចនៃតម្លៃខ្សែបន្ទាត់ភាពក្រីក្រ។ នៅក្នុងបរិការណ៍នេះ គឺជាការសំខាន់ណាស់ ដែលត្រូវពិចារណាថា ការកើនឡើងនៃការចំណាយដោយសារការទទួលបានឥណទានអាចនាំឱ្យកម្រិតនៃភាពក្រីក្រមានការថយចុះ ប៉ុន្តែភាពក្រីក្រនិងភាពងាយរងគ្រោះអាចនឹងមានកម្រិតខ្ពស់ជាងការគិតពីមុន។

## គោលនយោបាយឬយុទ្ធសាស្ត្រសំខាន់ៗ

កន្លងមក កិច្ចខិតខំប្រឹងប្រែងជាច្រើនត្រូវបានធ្វើឡើង ដើម្បីអនុមតិនិងអនុវត្តគោលនយោបាយសង្គម ជាពិសេស ដើម្បីធានាថាប្រជាជនក្រីក្រនិងងាយរងគ្រោះទទួលបានការគាំទ្រ តាមរយៈការបង្កើតកន្លែងថែទាំកុមារចាំបាច់នៅតាមសហគមន៍ មធ្យោបាយសម្រាប់ជនពិការ មជ្ឈមណ្ឌលថែទាំមាតានិងទារក សេវាសុខភាព ការឧបត្ថម្ភគាំទ្រដល់ជនក្រីក្រដែលត្រូវការសេវាព្យាបាលឬការសម្រាលកូន ការអប់រំនៅកម្រិតបឋមសិក្សានិងមធ្យមសិក្សាដោយមិនគិតថ្លៃ ជាដើម។ លើសពីនេះទៀត រាជរដ្ឋាភិបាលបានបង្កើតបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការ បេឡាជាតិសន្តិសុខសង្គម មូលនិធិជាតិសម្រាប់អតីតយុទ្ធជន និងមូលនិធិជនពិការ ដើម្បីធានាប្រាក់ចំណូលមានស្ថិរភាពសម្រាប់ប្រជាពលរដ្ឋ តាមរយៈប្រាក់សោធននិវត្តន៍ ការថែទាំសុខភាព ប្រាក់ឧបត្ថម្ភសម្រាប់គ្រោះថ្នាក់ក្នុងការងារ ប្រាក់ឧបត្ថម្ភពិការភាព និងប្រាក់ឧបត្ថម្ភផ្សេងៗទៀត។ សកម្មភាពទាំងនេះមានសង្គតិភាពជាមួយគោលនយោបាយកាត់បន្ថយភាពក្រីក្រ និងគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច របស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានបង្កើតរួចជាស្រេចនៅក្នុងគោលនយោបាយគន្លឹះផ្សេងៗទៀត ជាពិសេសយុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។

*ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០១៦-២០២៥*ដែលផ្តោតលើសសរស្តម្ភ២ គឺ *ប្រព័ន្ធជំនួយសង្គម* និង *ប្រព័ន្ធសន្តិសុខសង្គម*។ គោលបំណងនៃក្របខ័ណ្ឌគោលនយោបាយនេះ គឺដើម្បីរៀបចំផែនការយុទ្ធសាស្ត្រមួយសម្រាប់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីធានាបាននូវសុវត្ថិភាពប្រាក់ចំណូល និងកាត់បន្ថយភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរបស់ប្រជាពលរដ្ឋ។ ក្រៅពីក្របខ័ណ្ឌនេះ គោលនយោបាយជាតិប្រជាជន ឆ្នាំ២០១៦-២០៣០ ក៏បានឆ្លុះបញ្ចាំងពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការបន្តលើកកម្ពស់សុខុមាលភាព និងសាមគ្គីភាពរបស់ប្រជាពលរដ្ឋនៅក្នុងសង្គម និងមានគោលបំណងកាត់បន្ថយភាពក្រីក្រក្នុងកម្រិតអតិបរមា។ ក្របខ័ណ្ឌគោលនយោបាយបានបន្សុីការយកចិត្តទុកដាក់ និងកែលម្អកម្មវិធីឬគម្រោងគាំពារសង្គមដែលមានស្រាប់ និង បង្កើនប្រសិទ្ធភាព សមធម៌ តម្លាភាព និងភាពស៊ីសង្វាក់នៃប្រព័ន្ធគាំពារសង្គមទាំងមូល។ ដោយផ្អែកលើកម្រិតនៃកំណើនសេដ្ឋកិច្ចរបស់ប្រទេស ការគ្របដណ្តប់របស់ក្របខ័ណ្ឌគោលនយោបាយនេះនាពេលបច្ចុប្បន្ន ត្រូវបានពង្រីកដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋគ្រប់ផ្នែក។ ក្របខ័ណ្ឌមួយស្តីពីអភិបាលកិច្ចនិងបញ្ហាអន្តរវិស័យនឹងត្រូវបានបង្កើតឡើង ដើម្បីធានាប្រសិទ្ធភាពនៃប្រព័ន្ធថវិកា និងការអនុវត្ត។

រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញលិខិតបទដ្ឋានគតិយុត្តជាច្រើនដើម្បីផ្ទេរមុខងារ ធនធានមនុស្ស ធនធានហិរញ្ញវត្ថុ ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាដល់ការលើកកម្ពស់ប្រសិទ្ធភាព ទាំងការអភិវឌ្ឍមូលដ្ឋាន និងការផ្តល់សេវាសាធារណៈចាំបាច់នានាជូនប្រជាពលរដ្ឋ។ ជាក់ស្តែង រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវអនុក្រឹត្យស្តីពី ការផ្ទេរធនធានបន្ថែមពីថវិការដ្ឋ ជូនទៅមូលនិធិឃុំសង្កាត់ សម្រាប់ចំណាយលើការអភិវឌ្ឍមូលដ្ឋាន ក្នុងរយៈពេល៤ឆ្នាំ ពីឆ្នាំ២០២០ ដល់ ឆ្នាំ២០២៣។ អនុក្រឹត្យនេះបានកំណត់ ត្រូវបង្កើនអត្រាចែករំលែកចំណូលពីពន្ធរបស់រដ្ឋបាល រាជធានី ខេត្ត ទៅឱ្យរដ្ឋបាលឃុំ សង្កាត់ ពី១% ឆ្នាំ២០១៩ ដល់៤% នៅឆ្នាំ២០២០ និងកើន០,៥% ជារៀងរាល់ឆ្នាំ រហូតដល់ឆ្នាំ២០២៤។ ជាមួយគ្នានេះ ត្រូវបង្កើនអត្រាចែករំលែកចំណូលពីពន្ធរបស់រដ្ឋបាល រាជធានី ខេត្ត ទៅឱ្យរដ្ឋបាល ក្រុង ស្រុក ពី៣% នៅឆ្នាំ២០១៩ ដល់៤% ចាប់ពីឆ្នាំ២០២០ តទៅ។

ថវិកាចំនួន៤ ៩២៨លានរៀល ត្រូវបានផ្ទេរសម្រាប់ការគ្រប់គ្រងមជ្ឈមណ្ឌលថែទាំកុមារកំព្រា ប្រកាសឥណទានចំនួន៣៨៩លានរៀល ត្រូវបានរៀបចំសម្រាប់អនុវត្តមុខងារដែលបានធ្វើប្រតិភូកម្មទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងវិស័យអភិវឌ្ឍន៍ជនបទ និងបានផ្ទេរថវិកាចំនួន៤០០លានរៀលសម្រាប់អនុវត្តមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់អនុវត្តមុខងារសហគមន៍ក្នុងតំបន់ការពារធម្មជាតិ និងថវិកាចំនួ ៨ ០០០លានរៀល សម្រាប់អនុវត្តមុខងារគ្រប់គ្រងសំរាម និងសំណល់រឹងនៅតំបន់ទីប្រជុំជន។ ជាមួយគ្នានេះ រដ្ឋបាលស្រុកគោលដៅចំនួន១៥ នៃខេត្តចំនួន៧ ត្រូវបានជ្រើសរើស និងទទួលបានមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានថវិកាសរុបចំនួន ៥ ០០០លានរៀល សម្រាប់អនុវត្តគម្រោងចំនួន១៥ នៅក្នុងស្រុកគោលដៅទាំងនោះ។

ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំអនុក្រឹត្យលេខ១៨២ ១៨៣ និង១៨៤ ស្តីពីពីមុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីធ្វើសមាហរណកម្មការិយាល័យជំនាញនានានៅថ្នាក់ក្រុង ស្រុក ខណ្ឌ ទៅក្នុងរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវាប្រកបដោយគុណភាព សុវត្ថិភាព ប្រសិទ្ធភាព និងសមធម៌ តាមរយៈ ការបង្វិតការធ្វើសេចក្តីសម្រេចចិត្ត និងការទទួលខុសត្រូវ ក្នុងការគ្រប់គ្រងសេវានិងអភិវឌ្ឍមូលដ្ឋាន ឱ្យទៅជិតប្រជាពលរដ្ឋ។

## គោលដៅទី២៖ បញ្ចប់ភាពអត់ឃ្លាន សម្រេចឱ្យបានសន្តិសុខស្បៀង ធ្វើឱ្យប្រសើរឡើងស្ថានភាពអាហារូបត្ថម្ភ និងលើកកម្ពស់កសិកម្មប្រកប ដោយចីរភាព

### វឌ្ឍនភាព

ដើម្បីសម្រេចគោលដៅទី២ នៃគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា (គ.អ.ច.ក.) រាជរដ្ឋាភិបាលកម្ពុជា តាមរយៈ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ បានកំណត់សកម្មភាពជាអាទិភាពសម្រាប់វិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ទៅតាមសមាសភាគទាំង៤ នៃសន្តិសុខស្បៀង (ភាពមានស្បៀង ការទទួលបានស្បៀង ការប្រើប្រាស់និងការបឺតស្រូបស្បៀង និងស្ថិរភាពស្បៀង)។ អាទិភាពទាំង រំលេចពីផ្នែកពាក់ព័ន្ធមួយចំនួន ដើម្បីឆ្លុះបញ្ចាំងពីចរិតពហុវិស័យនៃបញ្ហាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។

ក្នុងអំឡុងឆ្នាំ២០១៩ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានជំរុញពិពិធកម្មផលិតកម្មកសិកម្ម ក្នុងក្របខ័ណ្ឌនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៩-២០២៣ ដើម្បីកាត់បន្ថយការនាំចូល និងធានាឱ្យមានការផលិតស្បៀងអាហារដែលផ្តល់នូវសារជាតិចិញ្ចឹមកាន់តែច្រើនជាងមុន ជាពិសេស តាមរយៈការជំរុញផលិតកម្មបន្លែនិងផ្លែឈើ ផលិកម្មសត្វ និង វារីវប្បកម្ម។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៩-២០២៣ ក៏ផ្តោតការយកចិត្តទុកដាក់លើការធ្វើទំនើបកម្មនិងពាណិជ្ជភាវូបនីយវិស័យកសិកម្មផងដែរ តាមរយៈ ការអភិវឌ្ឍខ្សែច្រវាក់តម្លៃ និងការលើកទឹកចិត្តឱ្យមានការកែច្នៃចំណីអាហារក្នុងស្រុក។ កិច្ចខិតខំប្រឹងប្រែងទាំងនេះ ទាមទារឱ្យមានការបង្កើនគុណភាពនិងសុវត្ថិភាពអាហារ ដើម្បីបំពេញតម្រូវការក្នុងស្រុកផង និងការនាំចេញផង។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានសហការជាមួយនឹងដៃគូអភិវឌ្ឍ ដើម្បីបង្កើនប្រសិទ្ធភាព និងនិរន្តរភាពនៃការអនុវត្តបច្ចេកទេសកសិកម្ម និងបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ជាតុចូលកសិកម្ម។ វិស័យឯកជន និងក្រុមផលិតករ បានសហការជាមួយនឹងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីបង្កើនគុណភាពកសិផល និងធានាឱ្យមានការបង្កើនលំហូរកសិផលក្នុងស្រុកទៅកាន់ទីផ្សារ។

នៅក្នុងឆ្នាំ២០១៩ ក្រសួងបរិស្ថាន បានដឹកនាំអនុវត្តគម្រោងលើកកម្ពស់ជីវភាពសហគមន៍តំបន់ការពារធម្មជាតិ ដែលបានអនុវត្តនៅខេត្តចំនួន១២ ក្នុងចំណោមខេត្ត១៦ ដែលមានតំបន់ការពារធម្មជាតិ។ គម្រោងទាំងនេះ បានផ្តល់ពូជសត្វចិញ្ចឹមដូចជា គោ ជ្រូក មាន់ ដល់សហគមន៍តំបន់ការពារធម្មជាតិចំនួន២៥សហគមន៍ ស្មើនឹង៥៥៧គ្រួសារ។ ការរៀបចំបង្កើតស្ថានីយបង្កាត់ជ្រូកពូជឦសានចំនួន២កន្លែងនៅខេត្តពោធិ៍សាត់ និងមណ្ឌលគិរី ដើម្បីផ្គត់ផ្គង់ពូជជ្រូកដល់សហគមន៍មូលដ្ឋាន ក្នុងការលើកកម្ពស់ជីវភាព និងអាហារូបត្ថម្ភ។

ទីផ្សារស្បៀងកំពុងបន្តមានភាពល្អប្រសើរ ហើយភាពអាចរកបាននៃទំនិញស្បៀងជាច្រើនមុខនៅលើទីផ្សារ បានឆ្លុះបញ្ចាំងពីការមានស្បៀងចម្រុះដ៏សម្បូរបែប។ ក្នុងឆ្នាំ២០១៩ រាជរដ្ឋាភិបាលកម្ពុជាបានវិនិយោគយ៉ាងច្រើន ដើម្បីផ្តល់ប្រាក់ឧបត្ថម្ភដល់ស្ត្រីក្នុងគ្រួសារក្រីក្រ ដែលមានផ្ទៃពោះ និងបន្ទាប់ពីសម្រាលកូនរួចក្នុងរយៈពេល២ឆ្នាំដំបូង (រយៈពេល ១ ០០០ ថ្ងៃដំបូងនៃជីវិត)។ វិធានការនេះគឺជាការអនុវត្តដោយផ្ទាល់ ដើម្បីបង្កើនលទ្ធភាពទទួលបានស្បៀង ក្នុងអំឡុងពេលដ៏សំខាន់សម្រាប់ក្រុមងាយរងគ្រោះ។ កម្មវិធីផ្តល់អាហារតាមសាលារៀនដែលអនុវត្តដោយក្រសួងអប់រំ យុវជន និងកីឡា ដោយមានការគាំទ្រ ពីកម្មវិធីស្បៀងអាហារពិភពលោក និងដៃគូអភិវឌ្ឍដទៃទៀត បានផ្តល់ឱ្យកុមារជាង ៣០០ ០០០នាក់ នូវអាហារប្រកបដោយអាហារូបត្ថម្ភ និងសាច់ប្រាក់ នៅរៀងរាល់ពេលដែលពួកគេមកសិក្សានៅសាលារៀន។ ក្នុងឆ្នាំ២០១៩ កម្មវិធីផ្តល់អាហារតាមសាលារៀន ដោយប្រើប្រាស់កសិផលក្នុងសហគមន៍ បានបន្តពង្រីកការអនុវត្តក្នុងខេត្តគោលដៅ ហើយបានក្លាយជាគំរូសម្រាប់កម្មវិធីផ្តល់អាហារតាមសាលារៀនរបស់រាជរដ្ឋាភិបាលកម្ពុជា។

ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងសុខាភិបាល ក្រសួងឧស្សាហកម្ម បច្ចេកវិទ្យា វិទ្យាសាស្ត្រ និងនវានុវត្តន៍ និង ដៃគូអភិវឌ្ឍនានា បានសហការគ្នាជួយឱ្យប្រជាពលរដ្ឋទទួលបានសេវាទឹកស្អាត និងអនាម័យ កាន់តែល្អប្រសើរជាងមុន និងផ្សព្វផ្សាយឱ្យមានការផ្លាស់ប្តូរឥរិយាបថប្រើប្រាស់ទឹកស្អាត និងមានទម្លាប់អនាម័យល្អ តាមរយៈ អនុក្រុមការងារបច្ចេកទេសទឹកស្អាតនិងអនាម័យ និងអាហារូបត្ថម្ភ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះ បានទទួលការបំពេញបន្ថែម តាមរយៈការបន្ស៊ីសកម្មភាពផ្លាស់ប្តូរសង្គមនិងឥរិយាបថប្រាស្រ័យទាក់ទង និងកិច្ចខិតខំប្រឹងប្រែងនានា ដែលកំពុងអនុវត្តនៅតាមមូលដ្ឋាន សំដៅជានាឱ្យប្រជាពលរដ្ឋកាន់តែទទួលបានសេវាសង្គមនិងសុខភាពប្រសើរជាងមុន និងធ្វើឱ្យទម្លាប់ហូបចុកកាន់តែល្អប្រសើរ។ តួអង្គពាក់ព័ន្ធនានាបានឯកភាពគ្នាប្រើប្រាស់អភិក្រមវដ្តជីវិតចំពោះអាហារូបត្ថម្ភ ដែលគ្របដណ្តប់លើរយៈពេល១ ០០០ថ្ងៃដំបូងនៃជីវិតរបស់កុមារដល់វ័យចូលរៀន (មត្តេយ្យ) ក្មេងជំទង់ មនុស្សពេញវ័យ និងមនុស្សចាស់។ លើសពីនេះ ក៏មានការផ្តោតការយកចិត្តទុកដាក់កាន់តែច្រើនជាងមុន លើការរៀបចំអន្តរាគមន៍នានាសម្រាប់ឆ្លើយតបចំពោះបន្ទុកទ្វេនៃបញ្ហាអាហារូបត្ថម្ភ និងជំងឺមិនឆ្លងនានា។

ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ បានរៀបចំយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភលើកទី២ ឆ្នាំ២០១៩-២០២៣ ដែលមានគោលដៅរួមដើម្បីកាត់បន្ថយអត្រាក្រិសក្រិនរបស់កុមារអាយុក្រោម៥ឆ្នាំ ឱ្យបានយ៉ាងហោចណាស់ ៧%ចំណុច កាត់បន្ថយអត្រាស្គមស្គាំងរបស់កុមារឱ្យបានយ៉ាងហោចណាស់ ២%ចំណុច និង កាត់បន្ថយការកើនឡើងនៃអត្រាលើសទម្ងន់និងធាត់របស់កុមារអាយុក្រោម៥ឆ្នាំ និងស្ត្រីក្នុងវ័យបន្តពូជ។

អាទិភាពរបស់យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភលើកទី២ ឆ្នាំ២០១៩-២០២៣ គឺការសម្របសម្រួល បញ្ហាអន្តរវិស័យ (យេនឌ័រនិងយុវជន បរិស្ថាន សមធម៌) ការទទួលខុសត្រូវតាមវិស័យ (កសិកម្ម សុខាភិបាល អប់រំ ទឹកស្អាតនិងអនាម័យ ពាណិជ្ជកម្ម ឧស្សាហកម្ម) និងអាទិភាពសម្រាប់ការសម្របសម្រួលពហុវិស័យ ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសលើ សកម្មភាពដែលអនុវត្តរួមគ្នារវាងក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ សហគមន៍ ស្ថាប័នសិក្សាស្រាវជ្រាវ និងវិស័យឯកជន ដូចជា (១) របបអាហារសុខភាព (២)ទឹកស្អាតនិងអនាម័យដែលគិតគូរដល់អាហារូបត្ថម្ភ (៣) ខ្សែច្រវាក់តម្លៃស្បៀង សុវត្ថិភាពស្បៀង និងការបញ្ចូលមីក្រូសារជាតិទៅក្នុងចំណីអាហារ (៤) អាហារូបត្ថម្ភដឹកនាំដោយសហគមន៍ (៥) ជំនួយសង្គម និងសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ (៦)សន្តិសុខស្បៀង និងអាហារូបត្ថម្ភក្នុងបរិបទនៃការគ្រប់គ្រងគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ ។

ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ បានសហការជាមួយនឹងដៃគូអភិវឌ្ឍ ដើម្បីលើកកម្ពស់អភិបាលកិច្ចក្នុងវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ តាមរយៈការបន្តដំណើរការក្រុមការងារបច្ចេកទេសលើវិស័យគាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភ និង វេទិកាសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ដែលរៀបចំជាប្រចាំសម្រាប់ធ្វើការចែករំលែកព័ត៌មាន។ ក្នុងឆ្នាំ២០១៩ នេះ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ បានពិគ្រោះយោបល់ជាមួយនឹងគ្រប់ក្រសួងស្ថាប័នសំខាន់ៗ ដើម្បីធានាឱ្យគោលនយោបាយនិងផែនការនានា មានភាពស៊ីសង្វាក់គ្នាជាមួយនឹងគោលនយោបាយនិងផែនការដែលរៀបចំដោយក្រសួងស្ថាប័នជំនាញ។ ជាមួយគ្នានេះ ក៏បានអនុវត្តសាកល្បងនូវវេទិកាផ្សេងៗ ដើម្បីគាំទ្រដល់ការងារសន្តិសុខស្បៀង និងអាហារូបត្ថម្ភ នៅថ្នាក់ក្រោមជាតិ ដោយសហការយ៉ាងជិតស្និទ្ធជាមួយនឹងអាជ្ញាធររាជធានី ខេត្ត និងអាជ្ញាធរមូលដ្ឋាន។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក៏បានរួមចំណែកយ៉ាងសកម្ម ក្នុងការលើកកម្ពស់ការងារគាំពារសង្គម ដោយបានឧបត្ថម្ភសាច់ប្រាក់ដល់ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំក្នុងគ្រួសារក្រីក្រ បានប្រមាណជាង១០ម៉ឺននាក់ ដែលជាគម្រោងរបស់រាជរដ្ឋាភិបាល ក្នុងការជួយលើកស្ទួយកម្រិតជីវភាពគ្រួសារក្រីក្រដែលមានស្ត្រីមានផ្ទៃពោះ និងមានកុមារតូចៗក្នុងបន្ទុក។

## តារាង ៤.២៖ វឌ្ឍនភាពគោលដៅទី២ នៃ គ.អ.ច.ក.

| | ចំណុចដៅ/សូចនាករ | ឯកតា | ២០១៥ | ចំណុចដៅ គអ.ច.ក. | | | | ជាក់ស្តែង | | | | វឌ្ឍនភាព |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | |
| **២.២** | **ត្រឹមឆ្នាំ២០៣០ បញ្ចប់គ្រប់ទម្រង់នៃកង្វះអាហារូបត្ថម្ភរួមទាំងការសម្រេចបាននៅឆ្នាំ២០២៥នូវ ចំណុចដៅដែលបានឯកភាពក្នុងកម្រិតអន្តរជាតិស្តីពីភាពគ្រិន និងភាពស្គមស្គាំងរបស់កុមារអាយុក្រោមអាយុ៥ឆ្នាំ និងដោះស្រាយនូវតម្រូវការអាហារូបត្ថម្ភរបស់កុមារីវ័យជំទង់ ស្ត្រីមានផ្ទៃពោះស្ត្រីកំពុងបំបៅដោះកូន និងស្ត្រីវ័យចាស់។** | | | | | | | | | | | គ្មានទិន្នន័យ |
| ២.២.១ | ប្រេវ៉ាឡង់នៃភាពគ្រិន (កម្ពស់ធៀបនឹងអាយុ មានកម្រិតទាបជាងបទដ្ឋានរីកលូតលាស់មធ្យមរបស់កុមារ របស់អង្គការសុខភាពពិភពលោក) ក្នុងចំណោមកុមារអាយុក្រោមអាយុ ៥ឆ្នាំ។ | % | ៣២,៤ | - | - | ២៥,០ | | - | - | - | | គ្មានទិន្នន័យ |
| ២.២.២ | ប្រេវ៉ាឡង់នៃភាពស្គមស្គាំងឬលើសទម្ងន់ (ទម្ងន់ធៀបនឹងកម្ពស់មានកម្រិតទាបជាងឬខ្ពស់ជាងបទដ្ឋានរីកលូតលាស់មធ្យមរបស់អង្គការសុខភាពពិភពលោក (>+2 ឬ<-2)) របស់កុមារ ក្នុងចំណោមកុមារអាយុក្រោម ៥ឆ្នាំ ទៅតាមប្រភេទនីមួយៗ នាំភាពស្គមស្គាំងឬលើសទម្ងន់។ | % | - | - | ៨,០ | ៨,០ | | - | - | - | | គ្មានទិន្នន័យ |
| **២.៣** | **ត្រឹមឆ្នាំ២០៣០ ទទួលបានកំណើនទ្វេដងនៃ ផលិតភាពក្នុងវិស័យកសិកម្ម និងចំណូលរបស់ផលិតករធុនតូច ជាពិសេស ស្ត្រីក្នុងគ្រួសារទុរគត គ្រួសារកសិករ អ្នកគង្វាល និងអ្នកនេសាទ តាមរយៈការធានានិងការទទួលបានស្មើភាពគ្នានូវ ដីធ្លី ធនធានផលិតកម្មផ្សេងទៀត និងធាតុចូល ចំណេះដឹង សេវាហិរញ្ញវត្ថុ ទីផ្សារ និងកាលានុវត្តភាពសម្រាប់តម្លៃបន្ថែម និងការងារក្នុងផ្នែកមិនមែនកសិកម្ម។** | | | | | | | | | | | គ្មានទិន្នន័យ |
| ២.៣.១ | ទំហំផលិតកម្មកសិកម្មក្នុងកសិករម្នាក់ ដែលប្រកបរបរកសិកម្ម (ស្រែចម្ការ ការចិញ្ចឹមសត្វ និងជលផល)។ | $/កសិករម្នាក់ | ១ ៥៥៥ (២០១៦) | ១ ៥៥៥ | ១ ៦៥៦ | ១ ៧៦៤ | ១ ៨៧៨ | - | | - | | គ្មានទិន្នន័យ |
| **២.៤** | **ត្រឹមឆ្នាំ២០៣០ ធានានូវប្រព័ន្ធផលិតកម្មស្បៀងអាហារដែលមានចីរភាព អនុវត្តសកម្មភាពកសិកម្មដោយមានការឆ្លើយតបនឹងការប្រែប្រួលអាសធាតុ ដែលជួយឱ្យមានការកើនឡើងនូវផលិតកម្មនិងផលិតផល ជួយថែរក្សាប្រព័ន្ធអេកូឡូស៊ី ជួយពង្រឹងសមត្ថភាពសម្រាប់ធន់នឹងការប្រែប្រួលអាកាសធាតុអាក្រក់ ភាពរាំងស្ងួត ទឹកជំនន់ និងគ្រោះមហន្តរាយផ្សេងទៀត និង ធ្វើឱ្យ ប្រសើរឡើងជាបន្តបន្ទាប់នូវគុណភាពដី។** | | | | | | | | | | | ស្ថិតលើគន្លងទៅសម្រេច |
| ២.៤.១ | ផលិតភាពនៃដីកសិកម្មដែលបាននិងកំពុងប្រើប្រាស់ដើម្បីធ្វើកសិកម្មប្រកបដោយចីរភាព។ | $/ហិកតា | ១ ៥៤៨ (២០១៦) | ១ ៥៤៨ | ១ ៦០៨ | ១ ៦៧១ | ១ ៧៣៦ | ១ ៥៤៨ | ១ ៦០៨ | ១ ៦៧១ | ១ ៧៣៦ | ស្ថិតលើគន្លងទៅសម្រេច |
| **២.៥** | **ត្រឹមឆ្នាំ២០២០ រក្សាការធ្វើពិពិធកម្មហ្សែននៃគ្រាប់ពូជ ការធ្វើកសិកម្មនិងចម្ការ ការផ្សាំពូជសត្វ និងប្រភេទសត្វព្រៃដែលពាក់ព័ន្ធ តាមរយៈការគ្រប់គ្រងសមស្រប ការធ្វើពិពិធកម្មនិងរក្សាគ្រាប់ពូជ នៅកម្រិតជាតិ តំបន់ និងអន្តរជាតិ និង លើកកម្ពស់ការទទួលបានចំណែកប្រកបដោយយុត្តិធម៌និងសមធម៌ នៃផលប្រយោជន៍ពីការប្រើប្រាស់ធនធានហ្សែននិងចំណេះដឹងប្រពៃណីដែលពាក់ព័ន្ធ ដូចការឯកភាពជាអន្តរជាតិ។** | | | | | | | | | | | លើសចំណុចដៅ |
| ២.៥.១ | ចំនួនធនធានពន្ធុរុក្ខជាតិសម្រាប់ស្បៀងអាហារនិងកសិកម្មដែលបានធានាក្នុងគោលនយោបាយ យុទ្ធសាស្ត្រ និង ទីកន្លែងអភិរក្សក្នុងរយៈពេលមធ្យម ឬរយៈពេលវែង។ | ចំនួនប្រភេទ | ៩៥ (២០១៦) | ៩៥ | ៩៦ | ៩៨ | ១០២ | - | - | - | | គ្មានទិន្នន័យ |
| ២.៥.២ | ចំនួនគ្រួសារក្នុងសហគមន៍តំបន់ការពារធម្មជាតិ ដែលត្រូវបានលើកកម្ពស់កម្រិតជីវភាព តាមរយៈ ការទទួលបានផលប្រយោជន៍ពី NTFP ការបញ្ចូលក្នុងវិស័យកសិកម្ម ទេសចរណ៍ធម្មជាតិ នៅក្នុងតំបន់ការពារ។ | % | ៧,០ (២០១៧) | - | ៧,០ | - | | ១៥,០ | ២៥,០ | ៣០,០ | ៤០,០ | លើសចំណុចដៅ |
| **២.a** | **បង្កើនការវិនិយោគ តាមរយៈការលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងផ្នែកហេដ្ឋារចនាសម្ព័ន្ធជនបទ ការស្រាវជ្រាវនិងសេវាផ្សព្វផ្សាយកសិកម្ម និង ការអភិវឌ្ឍបច្ចេកវិជ្ជានិងធនាគារហ្សែនរុក្ខជាតិនិងសត្វ ដើម្បីលើកកម្ពស់សមត្ថភាពផលិតក្នុងប្រទេសកម្ពុជា។** | | | | | | | | | | | លើសចំណុចដៅ |
| ២.a.១ | លំហូរនៃហិរញ្ញប្បទានសរុប (ហិរញ្ញប្បទានសហប្រតិបត្តិ ការនិងលំហូរផ្សេងទៀត) ដល់វិស័យកសិកម្ម ធៀបនឹង ផ.ស.ស.។ | % នៃ ផ.ស.ស. | ០,៧១ (២០១៦) | ០,៧១ | ០,៦៦ | ០,៦២ | ០,៥៨ | ០,៧៣ | ០,៨៣ | ០,៧៥ | ១,១៥ | លើសចំណុចដៅ |

*ប្រភព៖ ក្របខ័ណ្ឌ គ.អ.ច.ក. និង ក្រសួង ស្ថាប័ន*

## បញ្ហាប្រឈម

បញ្ហាប្រឈមមួយចំនួនដែលជួបប្រទះនៅក្នុងការអនុវត្តឱ្យសម្រេចបានគោលដៅនេះ រួមមាន (១) ការប្រែប្រួលយ៉ាងឆាប់រហ័សនៃស្ថានភាពនៃការអភិវឌ្ឍក្នុងបរិការណ៍កម្ពុជា រួមទាំង កំណើនប្រជាជន លក្ខខណ្ឌសេដ្ឋកិច្ច សង្គមកិច្ច នគរូបនីយកម្ម ការផ្លាស់ប្តូរទីលំនៅ និងការប្រែប្រួលអាកាសធាតុ (២) បរិមាណរបបអាហារដែលមានគុណភាព មិនគ្រប់គ្រាន់ចំពោះស្ត្រីមានផ្ទៃពោះនិងកុមារអាយុក្រោម៥ឆ្នាំ (៣) កង្វះខាតថវិកា(ទាំងរដ្ឋនិងឯកជន) សម្រាប់ការវិនិយោគប្រកបដោយចីរភាពដែលឆ្លើយតបចំពោះបញ្ហាអាហារូបត្ថម្ភគ្រប់ទម្រង់ នៅមានកម្រិត (៤) ការកើនឡើងនៃជំងឺលើសទម្ងន់ជាពិសេស ក្នុងចំណោមស្ត្រីក្នុងវ័យបន្តពូជ និង (៥) តម្រូវការចាំបាច់ក្នុងវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីពិពិធកម្មផលិតកម្មកសិកម្មឱ្យកាន់តែសម្បូរបែប និងការការពារធនធានធម្មជាតិដែលមាន

សារសំខាន់សម្រាប់វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (៦) ការឆ្លើយតបចំពោះអភិបាលកិច្ចពាក់ព័ន្ធវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ជាពិសេសនៅថ្នាក់ក្រោមជាតិ នៅមានកម្រិត (៧) បញ្ហាសុវត្ថិភាពស្បៀងនិងតម្រូវឱ្យមានការរៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្តិស្តីពីសុវត្ថិភាពស្បៀង។

## គោលនយោបាយឬយុទ្ធសាស្រ្តសំខាន់ៗ

*ផែនទីបង្ហាញផ្លូវដើម្បីពន្លឿនអាហារូបត្ថម្ភនៅកម្ពុជា* ផ្តល់ការណែនាំរយៈពេលវែង ដើម្បីដោះស្រាយបញ្ហាកង្វះអាហារូបត្ថម្ភរបស់មាតា ទារក និងកុមារ ជាពិសេស កាត់បន្ថយជំងឺ និងអត្រាមរណភាព។ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ នឹងបន្តសម្របសម្រួល និងសម្រួលដល់ការអនុវត្ត គោលនយោបាយ អាទិភាពនិងវិធានការនានា នៅក្នុង*យុទ្ធសាស្រ្តចតុកោណ* ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាព ដំណាក់កាលទី៤ (២០១៩-២០២៣)។ នៅក្នុង*ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣* ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ នឹងដឹកនាំអនុវត្តយុទ្ធសាស្រ្តជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភលើកទី២ ឆ្នាំ២០១៩-២០២៣ ដែលបានរួមបញ្ចូលផែនការសកម្មភាពជាតិស្តីពីការកាត់បន្ថយភាពស្រេកឃ្លានឱ្យដល់កម្រិតសូន្យ ២០១៦-២០២៥ ផែនការយុទ្ធសាស្រ្តនៃចលនាបង្កើនអាហារូបត្ថម្ភ ២០១៦-២០២៥ ផែនការសកម្មភាពនានា ដែលមានចែងក្នុងក្របខ័ណ្ឌសន្និសីទអន្តរជាតិលើកទី២ស្តីពីអាហារូបត្ថម្ភ និងសូចនាករតាមដានរួមគ្នារបស់ក្រុមការងារបច្ចេកទេសលើវិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ។ បន្ថែមលើនេះ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ នឹងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ គ្រឹះស្ថានសិក្សា បណ្តាញប្រទេសផ្តល់ជំនួយ បណ្តាញអង្គការសហប្រជាជាតិបណ្តាញសម្ព័ន្ធអង្គការសង្គមស៊ីវិលដើម្បីអាហារូបត្ថម្ភនៅកម្ពុជា និងវិស័យឯកជន ដើម្បីឆ្ពោះទៅសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍប្រកបដោយចីរភាព ឆ្នាំ២០៣០ ដោយមិនទុកឱ្យនណាម្នាក់ឱ្យនៅឯកោ ជាពិសេសគោលដៅទី២នៃគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា បញ្ចប់ភាពស្រេកឃ្លាន សម្រេចឱ្យបានសន្តិសុខស្បៀង ធ្វើឱ្យប្រសើរឡើងស្ថានភាពអាហារូបត្ថម្ភ និង លើកកម្ពស់កសិកម្មប្រកបដោយចីរភាព។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំ*ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យកសិកម្ម ឆ្នាំ២០១៤-២០១៨* ដើម្បីពន្លឿនការអភិវឌ្ឍវិស័យកសិកម្ម ក្នុងនោះរួមមាន ផលិតភាពកសិកម្ម ការធ្វើពិពិធកម្មនិងការធ្វើពាណិជ្ជកម្ម ការលើកកម្ពស់ការចិញ្ចឹមសត្វនិងវារីវប្បកម្ម កំណែទម្រង់ដីធ្លី និងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព។ ការិយាល័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងធ្វើសមាហរណកម្មឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ហើយ មុខងារចំនួន៥ ពាក់ព័ន្ធនឹងការងារកសិកម្ម សុខភាពសត្វនិងផលិតកម្មសត្វ ព្រៃឈើ ជលផល និងរដ្ឋបាលត្រូវបានប្រគល់ទៅឱ្យរដ្ឋបាលថ្នាក់ក្រុង ស្រុក ខណ្ឌ ក្នុងគោលបំណងបង្កិតការផ្តល់សេវាឱ្យកាន់តែកៀកទៅជិតប្រជាពលរដ្ឋ ក៏ដូចជា លើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការផ្តល់សេវា។

## គោលដៅទី៣៖ ធានាជីវភាពរស់នៅរបស់ប្រជាជនប្រកបដោយសុខភាពល្អ និងលើកកម្ពស់សុខុមាលភាពរបស់មនុស្សគ្រប់រូបនិងគ្រប់វិស័យ

### វឌ្ឍនភាព

ការអភិវឌ្ឍនៅក្នុងវិស័យសុខាភិបាលក៏ដូចជាវិស័យនានា ដែលមានឥទ្ធិពលដោយផ្ទាល់លើសុខភាពដូចជា ហេដ្ឋារចនាសម្ព័ន្ធ កំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ សុទ្ធតែដើរតួនាទីដ៏សំខាន់ក្នុងការធ្វើឱ្យប្រសើរឡើងអាយុកាលសង្ឃឹមរស់ និងកម្រិតជីវភាពរស់នៅរបស់ប្រជាជន។ ស្ថានភាពសុខភាពរបស់ប្រជាជនកម្ពុជា ត្រូវបានធ្វើឱ្យប្រសើរឡើងគួរឱ្យកត់សម្គាល់ តាមរយៈការពង្រីក និងបង្កើនការគ្របដណ្តប់របស់មូលដ្ឋានសុខាភិបាល រួមជាមួយនឹងការបង្កើនប្រព័ន្ធគាំពារសង្គម និងវិធានការនានា។ កម្រិតអាយុកាលសង្ឃឹមរស់ជាមធ្យម បានកើនឡើងពី៦១,៩ឆ្នាំ នៅឆ្នាំ២០០០ ដល់៧០ឆ្នាំ នៅឆ្នាំ២០១៩ ដែលក្នុងនោះបុរសមានអាយុ៦៨,១ឆ្នាំ និងស្ត្រី៧១,៩ឆ្នាំ។

រាជរដ្ឋាភិបាលកម្ពុជា សម្រេចបានសមិទ្ធផលជាច្រើនពាក់ព័ន្ធនឹងការកាត់បន្ថយអត្រាមរណភាព មាតា ទារក និងកុមារ ការឆ្លងថ្មីនិងការស្លាប់ដោយជំងឺអេដស៍ មូលហេតុដែលបណ្តាលមកពីជំងឺឆ្លងនិងជំងឺមិនឆ្លងផ្សេងទៀតនិងកត្តាហានិភ័យនានា ដែលធ្វើឱ្យមានផលប៉ះពាល់ដល់សុខភាពរបស់ប្រជាជន។ ផ្អែកលើទិន្នន័យបានបង្ហាញថាអត្រាមរណភាពមាតាបានថយចុះពី៤៧២ ក្នុង ១០០ ០០០កំណើតរស់ នៅឆ្នាំ២០០៥ មក ១៧០ ក្នុង ១០០ ០០០កំណើតរស់ នៅឆ្នាំ២០១៤។ ដូចគ្នានេះដែរ អត្រាមរណភាពរបស់ទារកទើបកើត បានថយចុះពី ៦៦ ក្នុង១ ០០០កំណើតរស់ នៅឆ្នាំ២០០៥ មក ១៨ ក្នុង ១ ០០០កំណើតរស់ នៅឆ្នាំ២០១៤។ រាជរដ្ឋាភិបាលកម្ពុជា បាននិងកំពុងពង្រីកបន្ថែមនូវចំនួនមណ្ឌលសុខភាព មន្ទីរពេទ្យ និងបុគ្គលិកសុខាភិបាលនៅទូទាំងប្រទេស។ ចំនួនមណ្ឌលសុខភាពបានកើនឡើងពី ១ ១០៥ នៅឆ្នាំ២០១៤ ដល់ ១ ២២១ នៅឆ្នាំ២០១៩ និង មន្ទីរពេទ្យបានកើនឡើងពី ៩៧ នៅឆ្នាំ២០១៤ ទៅ ១២៦ នៅឆ្នាំ២០១៩។ លើសពីនេះទៀត ចំនួនគ្លីនិកឯកជននិងឱសថស្ថានក៏បានកើនឡើងយ៉ាងច្រើនផងដែរ។

កម្ពុជាកំពុងដំណើរការលុបបំបាត់ទាំងស្រុងនូវការរីករាលដាលថ្មីនៃមេរោគអេដស៍ និងការរើសអើងលើការស្លាប់បណ្តាលមកពីមេរោគអេដស៍/ជំងឺអេដស៍។ ជាលទ្ធផល កម្ពុជាបានក្លាយជាប្រទេសមួយក្នុងចំណោមប្រទេសចំនួន៧ ក្នុងពិភពលោក ដែលសម្រេចបានចំណុចដៅ៩០-៩០-៩០។ ប្រទេសកម្ពុជាក៏មានមហិច្ឆតាផងដែរ ដើម្បីសម្រេចឱ្យបានគោលដៅ៩៥-៩៥-៩៥ នៅឆ្នាំ២០២៥ មានន័យថានឹងសម្រេចចំណុចដៅ៥ឆ្នាំ មុនចំណុចដៅដែលបានកំណត់ដោយកម្មវិធីរបស់អង្គការសហប្រជាជាតិស្តីពីមេរោគអេដស៍/ជំងឺអេដស៍។

# តារាង ៤.៣៖ វឌ្ឍនភាពគោលដៅទី៣ នៃ គ.អ.ច.ក.

| | ចំណុចដៅ/សូចនាករ | ឯកតា | ចំណុចដៅ គ.អ.ច.ក. | | | | | ជាក់ស្តែង | | | | វឌ្ឍនភាព |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | |
| **៣.១** | **កម្រិតនៃការអភិវឌ្ឍនៅប្រទេសកម្ពុជា សុខភាពនិងសុខុ មាលភាពរបស់ប្រជាពលរដ្ឋ និងបង្ការហានិភ័យហិរញ្ញវត្ថុ។** | | | | | | | | | | | **គ្មានទិន្នន័យ** |
| ៣.១.១ | អាយុកាល សង្ឃឹមរស់ពីកំណើត។ | | | | | | | | | | | គ្មានទិន្នន័យ |
| | ប្រុស | ឆ្នាំ | ៦៧,៥ | ៦៧,៥ | ៦៧,៩ | ៦៨,១ | ៦៨,១ | - | - | - | - | គ្មានទិន្នន័យ |
| | ស្រី | ឆ្នាំ | ៧១,៤ | ៧១,៦ | ៧១,៨ | ៧១,៩ | ៧១,៩ | - | - | - | - | គ្មានទិន្នន័យ |
| ៣.១.២ | អត្រាបង្កើតកូនសរុប (ក្នុងស្ត្រីក្នុងវ័យបន្តពូជម្នាក់) ។ | នាក់ | ២,៧ (២០០៤) | ២,៥ | ២,៤ | ២,៣ | ២,២ | - | - | - | - | គ្មានទិន្នន័យ |
| **៣.២** | **ត្រឹមឆ្នាំ២០៣០ កាត់បន្ថយអត្រាមរណៈភាពមាតានៅកម្រិតសាកល ឱ្យនៅកម្រិតទាបជាង៧០ក្នុងចំណោម ១០០ ០០០កំណើតរស់។** | | | | | | | | | | | **ស្ថិតលើគន្លងទៅសម្រេច** |
| ៣.២.១ | អត្រាមរណភាពមាតា (ក្នុង១០០ ០០០កំណើតរស់)។ | ករណី | ១៧០ (២០១៤) | - | - | - | | - | - | - | | គ្មានទិន្នន័យ |
| ៣.២.២ | ភាគរយនៃការសម្រាលដោយបុគ្គលិកសុខាភិបាល មានជំនាញ។ | % | ៨៩,០ | ៨៩,០ | ៨៩,០ | ៨៩,០ | ៩០,០ | ៨៥,០ | ៨៩,០ | ៨៧,៣ | ៨៩,៤៨ | ស្ថិតលើគន្លងទៅសម្រេច |
| **៣.៣** | **ត្រឹមឆ្នាំ២០៣០ បញ្ចប់ការស្លាប់ដែលអាចការពារបាននៃទារកទើបកើតនិងកុមារអាយុក្រោម៥ឆ្នាំ ដោយគ្រប់ប្រទេសទាំងអស់មានគោលដៅកាត់បន្ថយមរណភាពទារកទើបកើតដល់ត្រឹម ១២ ក្នុង ១ ០០០កំណើតរស់ និងមរណភាពកុមារក្រោមអាយុ៥ឆ្នាំ យ៉ាងហោចណាស់ដល់ត្រឹម២៥ ក្នុង ១ ០០០កំណើតរស់។** | | | | | | | | | | | **គ្មានទិន្នន័យ** |
| ៣.៣.១ | អត្រាមរណភាពកុមារអាយុក្រោម ៥ឆ្នាំ (ក្នុង ១០០០ កំណើតរស់)។ | ករណី | ៣៥ | - | - | - | - | - | - | - | - | គ្មានទិន្នន័យ |
| ៣.៣.២ | អត្រាមរណភាពទារកទើបកើត (ក្នុង ១០០០កំណើតរស់)។ | ករណី | ១៨ (២០១៤) | - | - | - | - | - | - | - | - | គ្មានទិន្នន័យ |
| **៣.៤** | **ត្រឹមឆ្នាំ២០៣០ បញ្ចប់ការរីករាលដាលមេរោគអេដស៍ ជំងឺរបេង គ្រុនចាញ់ ជំងឺតំបន់ត្រូពិចដែលមិនត្រូវបានយកចិត្តទុកដាក់ ជំងឺថ្លើម ជំងឺឆ្លងតាមទឹក និងជំងឺឆ្លងផ្សេងទៀត។** | | | | | | | | | | | **ស្ថិតិលើគន្លងទៅស ម្រេចបាន** |
| ៣.៤.១ | អត្រានៃករណីឆ្លងថ្មីនៃមេរោគអេដស៍ ក្នុងចំណោម ប្រជាជនដែលគ្មានផ្ទុកមេរោគអេដស៍ ១០០០នាក់។ | ក្នុងប្រ/ជ ១០០០នាក់ | ០,០៥ | ០,០៥ | ០,០៥ | ០,០៥ | ០,០៥ | ០,០៤ | ០,០៣ | ០,០៣ | ០,០៣ | លើសចំណុចដៅ |
| ៣.៤.២ | អាំងស៊ីដង់ (ករណីឆ្លងថ្មី) នៃជំងឺរបេង ក្នុងប្រជាជន ១០០០០នាក់។ | ក្នុងប្រ/ជ ១០០ ០០០ នាក់ | ៣៨០ | ៣៦៥ | ៣៥០ | ៣៣៦ | ៣២៣ | ៣៤៥ | ៣២៦ | ៣០២ | | គ្មានទិន្នន័យ ឆ្នាំ ២០១៩ |
| ៣.៤.៣ | អាំងស៊ីដង់ (ករណីឆ្លងថ្មី) នៃជំងឺគ្រុនចាញ់ ក្នុងប្រជាជន ១០០០នាក់។ | ក្នុងប្រ/ជ ១០០០នាក់ | ២,០០ | ១,៨៥ | ១,៦៥ | ១,៤៥ | ១,២៥ | ១,៥ | ២,៩៦ | ៤,០០ | ១,៩០ | ទាបជាងចំណុចដៅ |
| **៣.៥** | **ត្រឹមឆ្នាំ២០៣០ កាត់បន្ថយឱ្យបានមួយភាគបីនៃមរណភាពមុនអាយុកាលរំពឹងទុក ពីជំងឺមិនឆ្លង តាមរយៈការការពារនិងការព្យាបាល និងលើកកម្ពស់សុខភាពផ្លូវចិត្តនិងសុខុមាលភាព។** | | | | | | | | | | | **ទាបជាងចំណុចដៅ** |
| ៣.៥.១ | អត្រាស្លាប់ដែលបណ្តាលមកពីជំងឺបេះដូង សរសៃឈាមមហារីក ទឹកនោមផ្អែម ឬជំងឺផ្លូវដង្ហើមរ៉ាំរ៉ៃ ក្នុងចំណោមប្រជាជនអាយុពី ៣០ ទៅ៧០ឆ្នាំ។ | % | 36 | - | - | - | - | - | - | - | - | គ្មានទិន្នន័យ |
| ៣.៥.២ | ភាគរយនៃប្រជាជនពេញវ័យមានជំងឺធ្លាក់ទឹកចិត្ត បានទទួលសេវាព្យាបាល។ | % | ២,០ | ៤,០ | ៦,០ | ១០,០ | ១៥,០ | ២,០ | ២,០ | ១,៧ | ២,២ | ទាបជាងចំណុចដៅ |
| **៣.៦** | **ពង្រឹងការបង្ការនិងការព្យាបាលពីការសេពសារធាតុញៀនទាំង ការសេពគ្រឿងញៀន និងការប្រើប្រាស់ជាតិសុរាដែលនាំឱ្យគ្រោះថ្នាក់។** | | | | | | | | | | | **លើសចំណុចដៅ** |
| ៣.៦.១ | ភាគរយនៃប្រជាជនប្រើប្រាស់គ្រឿងញៀន បានទទួលសេវាព្យាបាល។ | % | ២២,០ | ៤០,០ | ៥០,០ | ៦០,០ | ៧០,០ | ២៨,០ | ៣០,១ | ៤២,០ | ៨៩,៣ | លើសចំណុចដៅ |
| ៣.៦.២ | ប្រេវ៉ាឡង់នៃការប្រើប្រាស់ជាតិអាល់កុល ក្នុងចំណោមមនុស្សពេញវ័យអាយុ ១៨ឆ្នាំឡើង។ | % | ៥៣,៥ (២០១០) | ៤៥,៥ | ៤៥,៥ | ៤៥,៥ | ៤៥,៤ | - | - | - | | គ្មានទិន្នន័យ |
| **៣.៧** | **ត្រឹមឆ្នាំ២០២០ កាត់បន្ថយឱ្យបានពាក់កណ្តាលនៃចំនួនមនុស្សស្លាប់ដោយគ្រោះថ្នាក់ចរាចរនៅទូទាំងពិភពលោក។** | | | | | | | | | | | **ស្ថិតលើគន្លងទៅសម្រេច** |
| ៣.៧.១ | អត្រាស្លាប់ដោយគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក ក្នុងប្រជាជន ១០០ពាន់នាក់។ | ករណី | ១៤,៧០ | ១៤,២០ | ១៣,៧២ | ១៣,២៣ | ១២,៧៤ | ១០,៩៩ | ១១,២៣ | ១០,៩៦ | ១២,១៦ | ស្ថិតលើគន្លងទៅសម្រេច |
| **៣.៨** | **ត្រឹមឆ្នាំ២០៣០ ធានាថាការទទួលបានជាសាកលនូវ សេវាថែទាំសុខភាពផ្លូវភេទ និងសេវាសុខភាពបន្តពូជ រួមទាំងផែនការគ្រួសារ ព័ត៌មាននិងការអប់រំ និងការធ្វើសមាហរណកម្មសុខភាពបន្តពូជទៅក្នុងកម្មវិធីនិងយុទ្ធសាស្រ្តជាតិ។** | | | | | | | | | | | **គ្មានទិន្នន័យ** |
| ៣.៨.១ | សមាមាត្រនៃស្ត្រីក្នុងវ័យបន្តពូជ (អាយុ១៥-៤៩ឆ្នាំ) ដែលត្រូវការនិងពេញចិត្តមធ្យោបាយពន្យារកំណើតទំនើប។ | % | ៥៧,០ | - | - | - | - | - | - | - | - | គ្មានទិន្នន័យ |
| ៣.៨.២ | ភាគរយនៃស្ត្រីវ័យជំទង់អាយុ១៥-១៩ឆ្នាំ ដែលមានគភ៌។ | % | ១១,៥ | - | - | - | - | - | - | - | - | គ្មានទិន្នន័យ |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ៣.៩ | **សម្រេចឱ្យបាន នូវសុខភាពល្អជា សកល រួមទាំងការបង្ការហានីភ័យផ្នែកហិរញ្ញវត្ថុ ការទទួលបាននូវសេវាថែទាំសុខភាពចាំបាច់ដែលមានគុណភាព និង ការទទួលបានថ្នាំពេទ្យនិងថ្នាំបង្ការចាំបាច់ដែលមានគុណភាព មានប្រសិទ្ធភាពនិងសុវត្ថិភាព សម្រាប់ប្រជាជនគ្រប់រូប។** | | | | | | | | | | | លើសចំណុចដៅ |
| ៣.៩.១ | ភាគរយនៃប្រជាជនដែលគ្របដណ្តប់ដោយប្រព័ន្ធគាំពារសុខភាពសង្គម (មូលនិធិសមធម៌ និងការធានារ៉ាប់រងសុខភាព)។ | % | ២៣,០០ | - | - | - | - | ២៣,៩៨ | ៣០,០០ | ៣៥,៧០ | ៣៨,៥ | លើសចំណុចដៅ |
| ៣.៩.២ | ចំណាយថវិកាជាតិចរន្តលើសុខភាពគិតជាភាគរយ នៃផលិតផលសរុបក្នុងស្រុក។ | % | ១,២៤ | ១,៥០ | ១,៧៥ | ២,០០ | ២,០០ | ១,២៩ | ១,៣០ | ១,៤៣ | - | គ្មានទិន្នន័យ |
| ៣.a | **ពង្រឹងការអនុវត្តក្របខ័ណ្ឌអនុសញ្ញារបស់អង្គការសុខភាពពិភពលោក ស្តីពីការត្រួតពិនិត្យថ្នាំជក់ឱ្យបានហ្មត់ចត់នៅក្នុងគ្រប់ប្រទេស។** | | | | | | | | | | | គ្មានទិន្នន័យ |
| ៣.a.១ | ប្រេវ៉ាឡង់នៃការប្រើប្រាស់ថ្នាំជក់ក្នុងចំណោមប្រជាជនអាយុ ១៥ឆ្នាំឡើង។ | | - | - | - | - | - | - | - | - | - | គ្មានទិន្នន័យ |
| | ប្រុស | % | ៤០ | - | - | - | - | - | - | - | - | គ្មានទិន្នន័យ |
| | ស្រី | % | ១៥ | - | - | - | - | - | - | - | - | គ្មានទិន្នន័យ |
| ៣.a.២ | ប្រេវ៉ាឡង់នៃការប្រើប្រាស់ថ្នាំជក់ក្នុងចំណោមយុវវ័យអាយុពី១៣-១៥ឆ្នាំ | % | ៦,៣ | - | - | - | - | - | - | - | - | គ្មានទិន្នន័យ |
| ៣.c | **បង្កើនជាបន្តបន្ទាប់ការវិភាជថវិកាលើវិស័យសុខាភិបាល និងជ្រើសរើសការអភិវឌ្ឍការបណ្តុះបណ្តាល និងការរក្សាបុគ្គលិកផ្នែកសុខាភិបាល នៅក្នុងប្រទេសកម្ពុជា។** | | | | | | | | | | | គ្មានទិន្នន័យ |
| ៣.c.១ | ផលធៀបវេជ្ជបណ្ឌិត/គិលានុប្បដ្ឋាក/ឆ្មប លើប្រជាជន ១ ០០០នាក់។ | នាក់ | ១,៥ | ១,៥ | ១,៧ | ១,៨ | ១,៩ | - | - | - | - | គ្មានទិន្នន័យ |

*ប្រភព÷ ក្របខ័ណ្ឌ គ.អ.ច.ក. និង ក្រសួង ស្ថាប័នពាក់ព័ន្ធ*

## បញ្ហាប្រឈម

ទោះបីស្ថានភាពសុខភាពទូទៅរបស់ប្រជាពលរដ្ឋ ត្រូវបានកែលម្អឱ្យកាន់តែប្រសើរឡើងក្តី ក៏វិស័យសុខាភិបាលនៅតែជួបប្រទះបញ្ហាប្រឈមចម្បងៗមួយចំនួន នៅក្នុងឆ្នាំ២០១៩ នេះ គឺ៖ (១) កំណើនប្រជាជនដែលជាបាតុភូតធម្មជាតិ និន្នាការឆ្ពោះទៅកាន់សង្គមដែលមានមនុស្សចាស់កាន់តែច្រើន បន្ទុកនៃជំងឺមិនឆ្លង-ជំងឺរ៉ាំរ៉ៃកំពុងកើនឡើង និង ការពង្រីកការគ្របដណ្តប់នៃយន្តការគាំពារសុខភាពសង្គម បានបង្កើនតម្រូវការប្រើប្រាស់សេវាថែទាំសុខភាព ដែលតម្រូវឱ្យពង្រឹងសមត្ថភាពប្រព័ន្ធសុខាភិបាល ដើម្បីឆ្លើយតបទាន់ពេលវេលានិងប្រកបដោយប្រសិទ្ធភាព។ (២) ការប្រើប្រាស់សេវាថែទាំសុខភាពនៅមន្ទីរពេទ្យបង្អែក ជាពិសេស នៅមន្ទីរបង្អែកថ្នាក់ស្រុកប្រតិបត្តិ នៅមានកម្រិតនៅឡើយ ដោយសារមន្ទីរពេទ្យបង្អែកជាច្រើននៅមិនទាន់មានលទ្ធភាពផ្តល់សេវាសុខភាពពេញលេញ ដូចបានកំណត់នៅក្នុងសំណុំសកម្មភាពបង្គ្រប់ កម្រិត១ និង កម្រិត២ នៅឡើយ ហើយ គុណភាពសេវាពិនិត្យព្យាបាល ថែទាំក៏នៅមិនទាន់ឆ្លើយតបនឹងការរំពឹងទុករបស់ប្រជាពលរដ្ឋផងដែរ។ (៣) កង្វះចំនួនគ្រូពេទ្យនិងបុគ្គលិកបច្ចេកទេសតាមប្រភេទជំនាញ នៅតាមមណ្ឌលសុខភាពនិងមន្ទីរពេទ្យបង្អែកថ្នាក់ស្រុក ស្របតាមនិយាមកំណត់ គឺជាឧបសគ្គចម្បងសម្រាប់ការពង្រីកការគ្របដណ្តប់នៃសេវាសុខភាព និងលើកកម្ពស់គុណភាពសេវា។ (៤) ការបំពាក់និងប្រើប្រាស់បច្ចេកវិទ្យាវេជ្ជសាស្ត្រទំនើប ឧបករណ៍ពេទ្យជាមូលដ្ឋាន ដើម្បីគាំទ្រដល់ ការធ្វើរោគវិនិច្ឆ័យ ការព្យាបាលនិងការថែទាំ និង ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានដើម្បីលើកកម្ពស់ការគ្រប់គ្រងនិងការផ្តល់សេវាថែទាំសុខភាពនៅមានកម្រិត។ (៥) និយ័តកម្មទីផ្សារឱសថ និងសេវាសុខាភិបាលឯកជន នៅមិនទាន់មានប្រសិទ្ធភាពដូចការរំពឹងទុក ឯការលុបបំបាត់ការផ្សព្វផ្សាយពាណិជ្ជកម្មតាមប្រព័ន្ធផ្សព្វផ្សាយសង្គម (social media) ស្តីពីផលិតផលឱសថ អាហារបំប៉នសុខភាព និងផលិតផលគ្រឿងសម្អាង ដែលប្រាសចាកពីការពិត នៅតែបន្តមាន ទោះបីជាក្រសួងសុខាភិបាលបានចាត់វិធានការទប់ស្កាត់ជាប្រចាំក៏ដោយ។

បញ្ហាប្រឈមមួយទៀតគឺទាក់ទងនឹង ការថយចុះនៃមូលនិធិសម្រាប់លុបបំបាត់មេរោគអេដស៍/ជំងឺអេដស៍នៅកម្ពុជា ដែលកម្មវិធីបង្ការនេះបានផ្តោតលើក្រុមប្រជាជនគោលដៅសំខាន់ៗ។ ការគាំទ្រហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍបានថយចុះ ហើយនេះជាក្តីកង្វល់ដ៏ធំមួយសម្រាប់កម្ពុជាក្នុងការសម្រេចឱ្យបានគោលដៅ ៩៥-៩៥-៩៥ នៅឆ្នាំ២០២៥។

## គោលនយោបាយឬយុទ្ធសាស្ត្រសំខាន់ៗ

ក្រសួងសុខាភិបាលបាននិងកំពុងអនុវត្ត *ផែនការយុទ្ធសាស្ត្រសុខាភិបាល ២០១៦-២០២០* ដែលមានសង្គតិភាពនឹងយុទ្ធសាស្ត្រចតុកោណ តាមរយៈ ការពង្រឹងការគ្រប់គ្រងប្រព័ន្ធសុខាភិបាល ជាពិសេស ការលើកកម្ពស់ការផ្តល់សេវាថែទាំសុខភាពដែលមានគុណភាព សុវត្ថិភាព ប្រសិទ្ធភាព និងប្រកបដោយសមធម៌ ជូនប្រជាពលរដ្ឋកម្ពុជា នៅក្នុងគ្រប់តំបន់ទូទាំងប្រទេស ដោយមិនគិតពីលក្ខខណ្ឌសេដ្ឋកិច្ចនិងសង្គមកិច្ច។ ផែនការយុទ្ធសាស្ត្រសុខាភិបាល បានបង្ហាញអំពីចក្ខុវិស័យរយៈពេលវែងនៃការអភិវឌ្ឍវិស័យសុខាភិបាលគឺ *ប្រជាពលរដ្ឋកម្ពុជាទាំងអស់មានសុខភាពនិងសុខុមាលភាពកាន់តែល្អប្រសើរ ដើម្បីរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ចប្រកបដោយចីរភាព* និងគោលដៅយុទ្ធសាស្ត្រទាំង៧ (រូបភាពខាងក្រោម)។

### រូបភាព ៤.២៖ គោលដៅយុទ្ធសាស្ត្រទាំង ៧ នៃវិស័យសុខាភិបាល




រាជរដ្ឋាភិបាលកម្ពុជា តាមរយៈអនុក្រឹត្យលេខ១៩៣ អនក្រ.បក ចុះថ្ងៃទី០៤ខែធ្នូ ឆ្នាំ២០១៩ នឹងផ្ទេរមុខងារក្នុងវិស័យសុខាភិបាលទៅឱ្យរដ្ឋបាលរាជធានី ខេត្ត រួមមាន មុខងារគ្រប់គ្រងមន្ទីរសុខាភិបាល ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ និងការផ្តល់សេវាសុខាភិបាល នៃមន្ទីរពេទ្យ

បង្អែករាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ មណ្ឌលសុខភាព និង ប៉ុស្តិ៍សុខភាព ក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវាសុខាភិបាលប្រកបដោយគុណភាព សុវត្ថិភាព ប្រសិទ្ធភាព និងសមធម៌ តាមរយៈការបង្ហិតការធ្វើសេចក្តីសម្រេចចិត្ត និងការទទួលខុសត្រូវក្នុងការគ្រប់គ្រងសេវាសុខាភិបាលឱ្យទៅកៀកជិតប្រជាពលរដ្ឋ។

*ផែនការយុទ្ធសាស្ត្រជាតិសម្រាប់ការឆ្លើយតបយ៉ាងទូលំទូលាយនិងពហុវិស័យ ចំពោះមេរោគអេដស៍/ជំងឺអេដស៍ ២០១៩-២០២៣* នឹងដាក់ឱ្យអនុវត្តក្នុងពេលឆាប់ៗខាងមុខ ដែលនឹងដើរតួនាទីជាយុទ្ធសាស្ត្រតែមួយគត់ ដើម្បីប្រយុទ្ធប្រឆាំងនឹងមេរោគអេដស៍/ជំងឺអេដស៍នៅកម្ពុជា។ *ផែនការយុទ្ធសាស្ត្រជាតិសម្រាប់ការឆ្លើយតបយ៉ាងទូលំទូលាយនិងពហុវិស័យ ចំពោះមេរោគអេដស៍/ជំងឺអេដស៍ ២០១៩-២០២៣* នេះ មានគោលបំណងលុបបំបាត់មេរោគអេដស៍/ជំងឺអេដស៍ ដែលជាការគំរាមកំហែងសុខភាពសាធារណៈ នៅត្រឹមឆ្នាំ២០២៥ និង គាំទ្រដល់ការឆ្លើយតបដោយចីរភាពនឹងជំងឺអេដស៍ តាមរយៈគោលដៅសំខាន់ចំនួន ៤គឺ៖ (១) ការកាត់បន្ថយចំនួនអ្នកផ្ទុកមេរោគអេដស៍ថ្មី ដល់ ៤០០នាក់ ក្នុងមួយឆ្នាំ និងឈានទៅសម្រេចគោលដៅ ៩៥-៩៥-៩៥ នៅឆ្នាំ២០២៥ តាមរយៈកិច្ចសហប្រតិបត្តិការពហុវិស័យ (២) ការការពារ ការថែរក្សា និងការព្យាបាលអ្នកផ្ទុកមេរោគអេដស៍ ត្រូវបានដាក់បញ្ចូលជាបណ្តើរៗ ទៅក្នុងប្រព័ន្ធរបស់ក្រសួងសុខាភិបាល និងទៅក្នុងការងាររបស់ក្រសួងពាក់ព័ន្ធដទៃទៀត (៣) អ្នកផ្ទុកមេរោគអេដស៍ទាំងអស់ ត្រូវបានគ្រប់ដណ្តប់ដោយទម្រង់មួយចំនួននៃយន្តការគាំពារសង្គម និងធ្វើឱ្យបរិស្ថានមានភាពប្រសើរឡើង សម្រាប់ការបង្កើនលទ្ធភាពទទួលបានសេវាគាំទ្រផ្នែកសុខភាព សង្គម និងច្បាប់ និង (៤) សមាមាត្រនៃហិរញ្ញប្បទានទាក់ទងនឹងមេរោគអេដស៍ ដែលបានបម្រុងទុកពីធនធានក្នុងស្រុកបានកើនឡើងជាលំដាប់ជារៀងរាល់ឆ្នាំ ហើយអង្គការសង្គមស៊ីវិលក៏កំពុងទទួលបានការវិភាជថវិកាពីរាជរដ្ឋាភិបាលផងដែរ។

ទន្ទឹមនឹងនេះ ដោយផ្អែកលើ សេចក្តីជូនដំណឹងលេខ ២១៣ សជណ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ យើងបានទទួលជោគជ័យជាបន្តបន្ទាប់ក្នុងការ (ក) ដាក់បញ្ចូលប្រជាជនដែលមានផ្ទុកមេរោគអេដស៍ ទៅក្នុងប្រព័ន្ធដែលអាចទទួលបានប័ណ្ណសមធម៌ (ខ) ទទួលបានការគាំទ្រពីក្រសួងមហាផ្ទៃ/គណៈកម្មាធិការជាតិសម្រាប់ការអនុវត្តតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.) ដើម្បីបញ្ចូលសកម្មភាពទាក់ទងនឹងមេរោគអេដស៍/ជំងឺអេដស៍ ទៅក្នុងផែនការអភិវឌ្ឍន៍/កម្មវិធីវិនិយោគឃុំ សង្កាត់ និង ផែនការថវិកាប្រចាំឆ្នាំរបស់ឃុំ សង្កាត់ ខណៈឃុំសង្កាត់បានចាប់ផ្តើមទទួលបានថវិកាកាន់តែច្រើន **និង** (គ) វិភាជថវិកាជាតិសម្រាប់សកម្មភាពទាក់ទងនឹងមេរោគអេដស៍/ជំងឺអេដស៍ ដែលបានស្នើឡើងដោយក្រសួង/ស្ថាប័នចំនួន១១ ក្នុងចំណោមក្រសួង/ស្ថាប័នពាក់ព័ន្ធទាំងអស់។ ការសម្រេចបាននេះ នឹងគាំទ្រដល់ (១) ការការពារប្រជាជនពីការឆ្លងថ្មីៗនៃមេរោគអេដស៍ (២) ការពង្រឹងការងាររបស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹង ជំងឺអេដស៍ ជំងឺសើរស្បែក និងជំងឺកាមរោគ ក្នុងការស្រាវជ្រាវរកករណីឆ្លងនៃមេរោគអេដស៍ ដែលបាត់ខ្លួនចំនួន ១០ ០០០ នាក់ដើម្បីធ្វើការព្យាបាល ថែរក្សាការគ្រប

ដណ្តប់ខ្ពស់នៃការព្យាបាលដែលមានគុណភាព និង តាមដានអ្នកជំងឺដែលបាត់បង់ត្រឡប់មកវិញ (៣) កាត់បន្ថយការប្រមាថមាក់ងាយ/ការរើសអើង ប្រឆាំងនឹងប្រជាជនដែលផ្ទុកមេរោគអេដស៍ និង (៤) គាំទ្រដល់ការគ្រប់គ្រងការរីករាលដាលនៃមេរោគអេដស៍។

រាជរដ្ឋាភិបាលកម្ពុជាបានបង្កើនការវិភាជថវិកាជាតិជាបន្តបន្ទាប់ សម្រាប់ការឆ្លើយតបនឹងមេរោគអេដស៍ ខណៈពេលដែលនិន្នាការគាំទ្រហិរញ្ញវត្ថុពីដៃគូ មានការថយចុះជាលំដាប់ចាប់តាំងពីឆ្នាំ២០១១ មក។ ការវិភាជថវិកាជាតិនេះ បានកើនឡើងពី៣% ក្នុងឆ្នាំ២០០៩ ដល់២៥% នៅឆ្នាំ២០១៧ និងបានសន្យាថា នឹងបង្កើនដល់៥០% នៅឆ្នាំ២០២៣។ ថវិកាវិភាជរបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់ទិញថ្នាំប្រឆាំងនឹងការឆ្លងមេរោគអេដស៍ មានចំនួន១,៥ លានដុល្លារ រៀងរាល់ឆ្នាំ ចាប់ពីឆ្នាំ២០១៨ ដល់ ឆ្នាំ២០២០ ហើយប្តេជ្ញាបង្កើនដល់២,៥ លានដុល្លារ នៅឆ្នាំ២០២១ ដល់៣,៥លានដុល្លារ នៅឆ្នាំ២០២២ និងដល់៥លានដុល្លារ នៅឆ្នាំ២០២៣។

ដើម្បីធានាឱ្យមានភាពប្រសើរឡើងនូវសន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈ ជូនប្រជាពលរដ្ឋ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើត គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក ដែលមានសមាសភាពចូលរួមពីក្រសួង ស្ថាប័ន ដើម្បីជំរុញឱ្យអនុវត្តគោលនយោបាយ និងច្បាប់ចរាចរណ៍ផ្លូវគោកឱ្យកាន់តែមានប្រសិទ្ធភាព សំដៅការពារសណ្តាប់ធ្នាប់សាធារណៈ បង្ការទប់ស្កាត់គ្រោះថ្នាក់ចរាចរណ៍ និងការពារអាយុជីវិតប្រជាពលរដ្ឋឱ្យបានជាអតិបរមា។

## គោលដៅទី៤៖ ធានាការអប់រំប្រកបដោយគុណភាព បរិយាប័ន្ន និងសមធម៌ និងលើកកម្ពស់ភាពនុវត្តភាពសិក្សាមួយជីវិតសម្រាប់ប្រជាជនគ្រប់រូប

## វឌ្ឍនភាព

កម្ពុជាសម្រេចបាននូវសមិទ្ធផលគួរឱ្យកត់សម្គាល់ក្នុងវិស័យអប់រំ ដូចមានបង្ហាញក្នុងតារាង ៤.៤។ កម្រិតនៃសិស្សថ្នាក់ទី១ ដែលបានឆ្លងកាត់កម្មវិធីអប់រំកុមារតូច បានកើនឡើងពី៦២,០% នៅឆ្នាំ២០១៥ ដល់៧១,៣% ក្នុងឆ្នាំ២០១៩។ អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សាបានកើនឡើងពី ៨០,០% នៅឆ្នាំ២០១៥ ដល់៨៦,២% ក្នុងឆ្នាំ២០១៩ ចំណែកឯនៅមធ្យមសិក្សាបឋមភូមិ អត្រានេះបានកើនឡើងពី៣៩,០% នៅឆ្នាំ២០១៥ ដល់៤៧,៥% នៅឆ្នាំ២០១៩។ ទន្ទឹមនឹងនេះ ការចុះឈ្មោះចូលរៀនក្នុងកម្មវិធីបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ មានការកើនឡើងគួរឱ្យកត់សម្គាល់នៅគ្រប់កម្រិតទាំងរយៈពេលវែងនិងខ្លី ស្របជាមួយនឹងគុណភាពអប់រំត្រូវបានពង្រឹង ហើយ លទ្ធភាពនៃការទទួលបានការបណ្តុះបណ្តាលកាន់តែងាយស្រួលនិងត្រូវបានពង្រីកនៅទូទាំងប្រទេស។

## តារាង ៤.៤÷ វឌ្ឍនភាពគោលដៅទី៤ នៃ គ.អ.ច.ក.

| | ចំណុចដៅ/សូចនាករ | ឯកតា | ២០១៥ | ចំណុចដៅ គ.អ.ច.ក. | | | | ជាក់ស្តែង | | | | វឌ្ឍនភាព |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | |
| ៤.១ | **ត្រឹមឆ្នាំ២០៣០ ធានាថាកុមារានិងកុមារីទទួលបានការអប់រំពេញលេញ ប្រកបដោយសមធម៌និងគុណភាព នៅកម្រិតបឋមសិក្សានិងមធ្យមសិក្សាដោយមិនមានការបង់ថ្លៃឈ្នួល ដែលនឹងធ្វើឱ្យលទ្ធផលនៃការសិក្សាមានប្រសិទ្ធភាព។** | | | | | | | | | | | ស្ថិតិលើគន្លង ទៅសម្រេចបាន |
| ៤.១.១ | សមាមាត្រនៃកុមារ និងប្រជាជនវ័យក្មេង ដែលបានបញ្ចប់ការសិក្សានៅ៖ **ក.** នៅថ្នាក់ទី២/៣ **ខ.** កម្រិតបឋមសិក្សាបឋមភូមិ **គ.** នៅមធ្យមសិក្សាបឋមភូមិ សម្រេចបានយ៉ាងហោចណាស់កម្រិតជំនាញអប្បបរមាក្នុងការអាន និងគណិតវិទ្យា។ | | | | | | | | | | | |
| ៤.១.១.១ | អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា។ | % | ៨០,០ | ៨១,២ | ៨២,៦ | ៨៣,៩ | ៨៥,២ | ៨៣,៧ | ៨២,៥ | ៨២,៧ | ៨៦,២ | ស្ថិតិលើគន្លង ទៅសម្រេចបាន |
| ៤.១.១.២ | អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ។ | % | ៣៩,០ | ៤០,៧ | ៤២,១ | ៤៣,៦ | ៤៥,០ | ៤១,២ | ៤៤,៥ | ៤៦,៥ | ៤៧,៥ | ស្ថិតិលើគន្លង ទៅសម្រេចបាន |
| ៤.២ | **ត្រឹមឆ្នាំ២០៣០ ធានាថាកុមារានិងកុមារីគ្រប់រូបនឹងទទួលបាននូវការអភិវឌ្ឍក្នុងភាពជាកុមារតូច ទាំងការថែទាំនិងការអប់រំនៅមត្តេយ្យសិក្សា ប្រកប ដោយគុណភាព សម្រាប់ត្រៀមខ្លួនគ្រប់គ្រាន់សិក្សានៅកម្រិតបឋមសិក្សា។** | | | | | | | | | | | លើសចំណុចដៅ |
| ៤.២.១ | ភាគរយសិស្សថ្នាក់ទី១ បានឆ្លងកាត់កម្មវិធីអប់រំកុមារតូចគ្រប់រូបភាព (បែងចែកតាមភេទ)។ | % | ៦២,០ | ៦៤,១ | ៦៦,៣ | ៦៨,៥ | ៧០,៧ | ៦៤,០ | ៦៥,០ | ៦៨,៤ | ៧១,៣ | ស្ថិតិលើគន្លង ទៅសម្រេចបាន |
| ៤.២.២ | អត្រារួមនៃការសិក្សានៅមត្តេយ្យសិក្សា។ | % | ២១,០ | ២២,៩ | ២៤,៩ | ២៦,៨ | ២៨,៧ | ៤១,០ | ៤៣,១ | ៣៥,៩ | ៣៨,៤ | លើសចំណុចដៅ |
| ៤.៣ | **ត្រឹមឆ្នាំ២០៣០ ធានាការទទួលបានស្មើភាពគ្នាសម្រាប់បុរស និងស្ត្រីគ្រប់រូប នូវការបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈនិងការសិក្សានៅកម្រិតឧត្តមសិក្សា រួមទាំង សាកលវិទ្យាល័យ។** | | | | | | | | | | | ទាបជាងចំណុចដៅ |
| ៤.៣.១ | អត្រារួមនៃការសិក្សានៅឧត្តមសិក្សា (អាយុ១៨ ដល់២១ឆ្នាំ) បែងចែកតាមភេទ។ | % | ១៤,០ | ១៦,៤ | ១៨,៨ | ២១,២ | ២៣,៦ | ១០,៩ | ១០,៥ | ១១,៦ | ១២,០ | ទាបជាងចំណុចដៅ |
| | ប្រុស | % | - | - | - | - | | - | - | ១៣,២ | ១២,២ | |
| | ស្រី | % | - | - | - | - | | - | - | ១១,៣ | ១១,៨ | |
| ៤.៣.២ | អត្រារួមនៃការសិក្សាក្នុងកម្មវិធីអប់រំបច្ចេកទេសនិងវិជ្ជាជីវៈ(១៥ ដល់ ២៤ឆ្នាំ) បែងចែកតាមភេទ។ | % | ០,០៣ | ២,៤ | ៤,៧ | ៧,០ | ៩,៤ | - | - | - | | មិនមានទិន្នន័យ |
| | ប្រុស | % | - | - | - | - | | - | - | - | | |
| | ស្រី | % | - | - | - | - | | - | - | - | | |
| ៤.៥ | **ត្រឹមឆ្នាំ២០៣០ លុបបំបាត់កម្លាតយេនឌ័រនៅក្នុងវិស័យអប់រំ និងធានាការទទួលបានភាពស្មើភាពគ្នាក្នុងការអប់រំគ្រប់កម្រិត និងនៅក្នុងការបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់ក្រុមជនងាយរងគ្រោះ រួមទាំងក្រុមជនដែលបាត់បង់សមត្ថភាពពលកម្ម ប្រជាជននិងកុមារដែលរស់នៅក្នុងស្ថានភាពងាយរងគ្រោះ។** | | | | | | | | | | | លើសចំណុចដៅ |
| ៤.៥.១ | សន្ទស្សន៍យុគភាពយេនឌ័រនៃអត្រារួមនៃការសិក្សា នៅមធ្យមសិក្សាបឋមភូមិ។ | សន្ទស្សន៍ | ១,១១ | ១,១០ | ១,១០ | ១,០៩ | ១,០៨ | ១,១០ | ១,២០ | ១,២០ | ១,១៦ | ស្ថិតិលើគន្លង ទៅសម្រេចបាន |
| ៤.៥.២ | សន្ទស្សន៍យុគភាពយេនឌ័រនៃអត្រារួមនៃការសិក្សា នៅមធ្យមសិក្សាទុតិយភូមិ។ | សន្ទស្សន៍ | ១,០៨ | ១,០៧ | ១,០៧ | ១,០៦ | ១,០៦ | ១,០៨ | ១,១២ | ១,១៧ | ១,២៣ | លើសចំណុចដៅ |
| ៤.៦ | **ត្រឹមឆ្នាំ២០៣០ ធានាថា យុវវ័យគ្រប់រូប និងសមាមាត្រភាគច្រើននៃប្រជាជនពេញវ័យ ទាំងបុរសនិងស្ត្រីសម្រេចបាននូវលក្ខខណ្ឌអក្ខរភាព។** | | | | | | | | | | | មិនមានទិន្នន័យ |
| ៤.៦.១ | អត្រាអក្ខរជន មនុស្សពេញវ័យអាយុ ១៥ឆ្នាំឡើង។ | % | ៧៨,០ | ៧៩,៦ | ៨១,០ | ៨២,៥ | ៨៣,៩ | ៨៤,៤ | ៨២,៥ | - | | មិនមានទិន្នន័យ |
| ៤.a | **កសាងនិងធ្វើឱ្យប្រសើរឡើងសម្ភារៈ បរិក្ខារអប់រំ ដែលធ្វើឱ្យមានភាពប្រែប្រួលដល់កុមារអ្នកបាត់បង់សមត្ថភាពពលកម្មនិងយេនឌ័រ និងផ្តល់នូវសុវត្ថិភាព គ្មានអំពើហិង្សា មានបរិស្ថាននៃការសិក្សាប្រកបដោយបរិយាប័ន្ននិងមានប្រសិទ្ធភាពសម្រាប់ប្រជាជនគ្រប់រូប។** | | | | | | | | | | | លើសចំណុចដៅ |
| ៤.a.១ | សមាមាត្រនៃសាលាមត្តេយ្យសិក្សា សាលាបឋមសិក្សា និងសាលាមធ្យមសិក្សា ដែលមានឧបករណ៍ទឹកស្អាតសម្រាប់បរិភោគ។ | % | ២៧,០ | ៣០,០ | ៣៤,១ | ៣៧,៦ | ៤១,១ | ៤៧,៩ | ៤៨,២ | ៤៦,៧ | ៧៣,៥ | លើសចំណុចដៅ |
| ៤.a.២ | សមាមាត្រនៃសាលាមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សា ដែលមានបង្គន់អនាម័យប្រើប្រាស់។ | % | ៥៧,០ | ៦០,២ | ៦៣,១ | ៦៥,៩ | ៦៨,៨ | ៦២,៥ | ៦៩,០ | ៦៨,៧ | ៨០,៨ | លើសចំណុចដៅ |
| ៤.a.៣ | ភាគរយនៃសាលាបឋមសិក្សានិងមធ្យមសិក្សាដែលមានជម្រាលសម្រាប់សិស្សពិការ។ | % | ០ | ១,៣ | ២,៧ | ៤,០ | ៥,៣ | - | - | - | ៣១,៤ | លើសចំណុចដៅ |
| ៤.c | **ត្រឹមឆ្នាំ២០៣០ បង្កើនឱ្យបានច្រើនការផ្គត់ផ្គង់គ្រូបង្រៀនដែលមានគុណភាព តាមរយៈ កិច្ចសហប្រតិបត្តិការអន្តរជាតិសម្រាប់ការបណ្តុះបណ្តាលគ្រូបង្រៀននៅក្នុងប្រទេសកម្ពុជា។** | | | | | | | | | | | លើសចំណុចដៅ |
| ៤.c.១ | ភាគរយគ្រូបង្រៀននៅសាលាមត្តេយ្យសិក្សា បឋមសិក្សា មធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ ដែលបានឆ្លងកាត់ការបណ្តុះបណ្តាលនិងវិក្រឹត្យការ។ | % | ៩៩,០ | ៩៩,០ | ៩៩,០ | ៩៩,១ | ៩៩,២ | ៩៨,៧ | ៩៨,៤ | ៩៩,៣ | ៩៨,៨ | ស្ថិតិលើគន្លង ទៅសម្រេចបាន |
| ៤.c.២ | ភាគរយគ្រូមត្តេយ្យសិក្សាដែលមានគុណវុឌ្ឍិ ស្របតាមស្តង់ដាជាតិ។ | % | ៥៦,០ | ៥៧,៦ | ៥៩,២ | ៦០,៨ | ៦២,៤ | ៦២,១ | ៦៣,៦ | ៦៤,០ | ៦៦,០ | ស្ថិតិលើគន្លង ទៅសម្រេចបាន |
| ៤.c.៣ | ភាគរយគ្រូបឋមសិក្សាដែលមានគុណវុឌ្ឍិ ស្របតាមស្តង់ដាជាតិ។ | % | ៦១,០ | ៦២,៩ | ៦៤,៩ | ៦៦,៨ | ៦៨,៧ | ៧០,២ | ៧២,១ | ៧៣,០ | ៧៩,០ | លើសចំណុចដៅ |
| ៤.c.៤ | ភាគរយគ្រូមធ្យមសិក្សាដែលមានគុណវុឌ្ឍិ ស្របតាមស្តង់ដាជាតិ។ | % | ៣២,០ | ៣៤,៥ | ៣៤,១ | ៣៩,៦ | ៤២,១ | ៨៥,៨ | ៨៥,០ | ៨៦,០ | ៨៧,០ | លើសចំណុចដៅ |
| ៤.c.៥ | ភាគរយគ្រូបង្រៀនដែលបានទទួលការបណ្តុះបណ្តាលវិក្រឹត្យការ។ | % | ២,០ | ៣,៩ | ៥,៧ | ៧,៦ | ៩,៥ | ៨,៥ | ៥,៩ | ៩,៥ | ១០,២ | ស្ថិតិលើគន្លង ទៅសម្រេចបាន |

*ប្រភព÷ ក្របខ័ណ្ឌ គ.អ.ច.ក. និង ប្រព័ន្ធគ្រប់គ្រងព័ត៌មានវិស័យអប់រំ*

កម្ពុជាសម្រេចបានយុគភាពយេនឌ័រក្នុងវិស័យអប់រំ និងកំពុងចាប់ផ្តើមងាកទៅរកនារីក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ។ សន្ទស្សន៍យុគភាពយេនឌ័រនៃអត្រាសិក្សារួមនៅមធ្យមសិក្សាបឋមភូមិបានកើនឡើងពី១,១១ ក្នុងឆ្នាំ២០១៥ ដល់១,១៦ ក្នុងឆ្នាំ២០១៩ និងនៅកម្រិតមធ្យមសិក្សាទុតិយភូមិបានកើនឡើងពី១,០៨ ក្នុងឆ្នាំ២០១៥ ដល់១,២៣ ក្នុងឆ្នាំ២០១៩។ អត្រាអក្ខរជនពេញវ័យក៏បានកើនឡើងផងដែរពី៧៨,០% ក្នុងឆ្នាំ២០១៥ ទៅ៨២,៥% ក្នុងឆ្នាំ២០១៧។ ផ្អែកលើការប្រៀបធៀបទៅនឹងចំណុចដៅក្នុងក្របខ័ណ្ឌ គ.អ.ច.ក. (១៧ សូចនាករ) បានបង្ហាញថា កម្ពុជាសម្រេចបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ដោយសូចនាករស្ទើរតែទាំងអស់ លើសចំណុចដៅ ឬស្ថិតលើគន្លងទៅសម្រេចបាន លើកលែងតែសូចនាករចំនួន២ ប៉ុណ្ណោះដែលទាបជាងចំណុចដៅ។ នៅក្នុងឆ្នាំ២០១៩ នេះ សូចនាករពាក់ព័ន្ធនឹងអត្រាអក្ខរជនមនុស្សពេញវ័យ អាយុ១៥ឆ្នាំឡើង មិនមានវដ្តទិន្នន័យសម្រាប់វាយតម្លៃលទ្ធផលនៃការសម្រេចបានទេ។ សមិទ្ធផលដែលទទួលបាននេះ ដោយសារតែកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា តាមរយៈ ក្រសួងអប់រំ យុវជន និងកីឡា និង ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រួមជាមួយ ដៃគូអភិវឌ្ឍ និងភាគីដែលមានចំណែកពាក់ព័ន្ធទាំងអស់ ក្នុងការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ និងគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឆ្នាំ២០១៧-២០២៥។

ក្នុងគោលបំណងលើកកម្ពស់ប្រសិទ្ធភាពក្នុងការគ្រប់គ្រង ការផ្តល់សេវាអប់រំ ប្រកបដោយគុណភាព បរិយាប័ន្ន និងសមធម៌ រាជរដ្ឋាភិបាលកម្ពុជា នឹងធ្វើសមាហរណកម្មការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងដោយផ្ទាល់របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ហើយមុខងារមួយចំនួនពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការគ្រប់គ្រងការអប់រំនៅកម្រិតបឋមសិក្សា ការងាររដ្ឋបាលគាំទ្រគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅ ការអភិវឌ្ឍយុវជន និង ការងារអប់រំកាយនិងកីឡា នឹងត្រូវផ្ទេរជាលក្ខណៈប្រគល់និងប្រតិភូកម្ម ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

## បញ្ហាប្រឈម

ទោះបីជាសម្រេចបានសមិទ្ធផលគួរឱ្យកត់សម្គាល់ដូចបានរៀបរាប់ខាងលើក្តី កម្ពុជានៅតែជួបប្រទះបញ្ហាប្រឈមមួយចំនួនដែលត្រូវដោះស្រាយ គឺ (១) ការទទួលបានការអប់រំប្រកបដោយសមធម៌ និងបរិយាប័ន្ន សម្រាប់កុមារទាំងអស់នៅគ្រប់កម្រិតការអប់រំ និងការបណ្តុះបណ្តាល (២) ការបន្តការសិក្សាពីបឋមសិក្សាទៅមធ្យមសិក្សាបឋមភូមិ និងអត្រាបោះបង់ការសិក្សាខ្ពស់នៅមធ្យមសិក្សាបឋមភូមិ (៣) បញ្ហាគុណភាពគ្រូបង្រៀននៅកម្រិតមត្តេយ្យសិក្សារហូតដល់ឧត្តមសិក្សា (៤) ការសិក្សាពេញមួយជីវិត ដែលមានសារសំខាន់សម្រាប់ការងារពេញមួយជីវិត និងការទទួលយកជំនាញនានា និងចំណេះដឹងសម្រាប់រួមចំណែកដល់ការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ច ដែលនៅតែជាទស្សនទានថ្មីសម្រាប់ប្រជាជនជាច្រើន។

## គោលនយោបាយឬយុទ្ធសាស្ត្រសំខាន់ៗ

ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំ និងអនុមតិផែនទីបង្ហាញផ្លូវការអប់រំកម្ពុជា ឆ្នាំ២០៣០ សម្រាប់គោលដៅទី៤ នៃ គ.អ.ច.ក. ដែលផ្តល់នូវក្របខ័ណ្ឌរួមរយៈពេលវែងសម្រាប់ការអភិវឌ្ឍនិងការផ្តល់សេវាអប់រំ និង កំណត់អាទិភាពនិងយុទ្ធសាស្ត្រ ដើម្បីឱ្យកម្ពុជាឈានទៅសម្រេចបានចំណុចដៅទាំងនេះ។

គោលដៅទី៤ នៃ គ.អ.ច.ក. បានបន្សុីយ៉ាងល្អទៅនឹងអាទិភាពនៃ*យុទ្ធសាស្ត្រចតុកោណ ដំណាក់ទី៤*របស់រាជរដ្ឋាភិបាលកម្ពុជា ដោយការធ្វើឱ្យប្រសើរឡើងនូវការអប់រំទូទៅ ការបណ្តុះបណ្តាលជំនាញបច្ចេកទេស សហគ្រិនភាព ការច្នៃប្រឌិតនិងនវានុវត្តន៍ និងជីវិតដែលមានសុខភាពល្អ គឺជាសមាសភាពដ៏សំខាន់នៅក្នុងចតុកោណទី១ នៃ*យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤*។

រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំនូវអន្តរាគមន៍គោលនយោបាយ និងយុទ្ធសាស្ត្រសំខាន់ៗ សម្រាប់ឆ្នាំ២០១៩-២០២៣ រួមមាន៖

១. ចក្ខុវិស័យនិងបេសកកម្មច្បាស់លាស់សម្រាប់ប្រព័ន្ធអប់រំក្នុងសង្គម ដែលប្រកបដោយអ្នកមានចំណេះដឹងនៅត្រឹមឆ្នាំ២០៣០ ដោយក្រសួងអប់រំ យុវជន និងកីឡា ជាអ្នកដឹកនាំតម្រង់ទិសការអភិវឌ្ឍវិស័យអប់រំ ដើម្បីធានាថា គ្រប់សាលារៀនត្រូវផ្លាស់ប្តូរខ្លួនទៅជាស្ថាប័នសិក្សា ដោយធានាឱ្យមានការអប់រំប្រកបដោយគុណភាពខ្ពស់សម្រាប់ទាំងអស់គ្នា។

២. បង្កើនការគ្រប់ដណ្តប់ការអប់រំកុមារតូចជាប្រព័ន្ធ ដើម្បីសម្រេចបាន ៨២% ការបញ្ចប់ការសិក្សានៅបឋមសិក្សា ៩១,១% ការបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ ៦១,១% ការបញ្ចប់ការសិក្សានៅមធ្យមសិក្សាទុតិយភូមិ ៤៥% ជំនាញបច្ចេកទេស ៣៥% និងឧត្តមសិក្សា ២៥% នៅឆ្នាំ២០៣០។

៣. អនុវត្តគោលនយោបាយកំណែទម្រង់គ្រូបង្រៀន ដោយដោះស្រាយបញ្ហានានាទាក់ទងនឹងការជ្រើសរើស ការបណ្តុះបណ្តាល ការពង្រាយ ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ការជួយគាំទ្រផ្ទាល់នឹងកន្លែង និងគន្លងអាជីពគ្រូបង្រៀន។

៤. ផ្តល់ការធ្វើវិក្រឹតការសម្រាប់គ្រូបង្រៀននៅគ្រប់កម្រិត ស្របតាមគោលនយោបាយអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់គ្រូបង្រៀនរបស់ក្រសួងអប់រំយុវជន និងកីឡា (១០០ម៉ោងក្នុងមួយឆ្នាំ) និងបំប៉នវិធីសាស្ត្របង្រៀនតាមបែបត្រិះរិះក្នុងបរិបទទសវត្សទី២១។

៥. បង្កើនការសិក្សានៅថ្នាក់ដំបូង ដើម្បីពង្រឹងការអាន ការសរសេរ និងគណិតវិទ្យា ដើម្បីផ្តល់មូលដ្ឋានគ្រឹះសម្រាប់អ្នកសិក្សាឱ្យទទួលបានជោគជ័យនៅថ្នាក់ខ្ពស់។

៦. ពង្រឹងការអនុវត្ត និងការតាមដានត្រួតពិនិត្យគោលនយោបាយអប់រំបរិយាប័ន្ន រួមទាំងការផ្តល់អាហារូបករណ៍សម្រាប់សិស្សមកពីក្រុមងាយរងគ្រោះ ដើម្បីធានាបាននូវសមធម៌ និងមិនទុកអ្នកណាម្នាក់ចោលឱ្យនៅឯកោ។

៧. ធ្វើកំណែទម្រង់អប់រំនៅតាមកម្រិតថ្នាក់រៀន ដោយធ្វើការពង្រឹងសមត្ថភាពរបស់នាយកសាលា គណៈកម្មការគ្រប់គ្រងសាលារៀន និងអ្នកដែលមានចំណែកពាក់ព័ន្ធ តាមរយៈការបណ្តុះបណ្តាល និងការអនុវត្តការគ្រប់គ្រងផ្នែកតាមសាលារៀន។

៨. កែលម្អកម្មវិធីសិក្សា ឱ្យឆ្លើយតបនឹងជំនាញសតវត្សរ៍ទី២១ រួមបញ្ចូលការសិក្សាតាមបែបត្រិះរិះ ជំនាញប្រាស្រ័យទាក់ទង និងជំនាញដោះស្រាយបញ្ហា។

៩. ធ្វើការវាយតម្លៃការសិក្សារបស់សិស្សនៅថ្នាក់ទី៣ ទី៦ ទី៨ និងទី១១ ដើម្បីតាមដានការសិក្សារបស់សិស្ស ទៅតាមគោលបំណងនៃកម្មវិធីសិក្សា។

១០. ជំរុញនិងពង្រីកឱកាសសិក្សា និងកម្មវិធីសមមូល ជាពិសេស នៅកម្រិតមធ្យមសិក្សា ដើម្បីជំរុញឱ្យយុវជនបន្តការសិក្សា និងជំនាញដោយខ្លួនឯង តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន។

១១. ធ្វើឱ្យប្រសើរឡើង និងបង្កើនការវិភាជថវិកាដល់សាលារៀនឱ្យឆ្លើយតបនឹងតម្រូវការនៃការបង្រៀននិងរៀននៅក្នុងថ្នាក់រៀន និង ពង្រឹងសមត្ថភាពគ្រប់គ្រងហិរញ្ញវត្ថុ និងគណនេយ្យភាព។

១២. ពង្រឹងការអនុវត្តប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុង និងការទទួលស្គាល់គុណភាពអប់រំសម្រាប់គ្រឹះស្ថានឧត្តមសិក្សា និង លើកទឹកចិត្តឱ្យអ្នកសិក្សាចូលរៀនក្នុងកម្មវិធីបណ្តុះបណ្តាលស្នែមនៅឧត្តមសិក្សា។

១៣. អនុវត្តយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍន៍ស្ថិតិអប់រំ ដើម្បីពង្រឹងការសម្របសម្រួល និងការតាមដានត្រួតពិនិត្យការអនុវត្តគោលដៅទី៤ នៃ គ.អ.ច.ក.។

១៤. បន្តពង្រឹងការអនុវត្ត *គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឆ្នាំ២០១៧-២០២៥* ដើម្បីលើកកម្ពស់កម្រិតជីវភាពរស់នៅនិងសេចក្តីថ្លៃថ្នូរបស់ប្រជាពលរដ្ឋ បង្កើនបាននូវកម្លាំងពលកម្ម/ធនធានមនុស្សកម្ពុជាប្រកបដោយចំណេះដឹង សមត្ថភាពជំនាញ ឥរិយាបទការងារ សីលធម៌វិជ្ជាជីវៈ ផលិតភាពខ្ពស់ និងមានលក្ខណៈប្រកួតប្រជែងសម្រាប់ការងារពេញមួយជីវិត។

**ករណីសិក្សាទី១៖ ការស្ម័គ្រចិត្តលើកកម្ពស់ការអប់រំប្រកបដោយបរិយាប័ន្ននិងការគ្រប់គ្រងយុវជននៅកម្ពុជា**

អ្នកស្ម័គ្រចិត្ត អាចធ្វើជាភាគីកណ្តាលនៃការចូលរួម ដោយភ្ជាប់គំនិតផ្តួចផ្តើមស្ថាប័នជាមួយសកម្មភាពស្ម័គ្រចិត្តនៅតាមសហគមន៍ និងការពង្រឹងអភិបាលកិច្ចមូលដ្ឋាន។ អ្នកស្ម័គ្រចិត្ត អាចសម្របសម្រួលនិងគាំទ្រដល់ការចូលរួមរបស់ប្រជាជនក្នុងការរៀបចំផែនការ ការអនុវត្ត និងការតាមដានត្រួតពិនិត្យ គ.អ.ច.ក. ដោយជំរុញឱ្យមានភាពជាម្ចាស់ក្នុងតំបន់ និងលើកកម្ពស់ឱ្យមានដំណោះស្រាយអភិវឌ្ឍន៍ចេញពីមូលដ្ឋាន។ ដូចនេះ ការស្ម័គ្រចិត្តបានចូលរួមចំណែកយ៉ាងច្រើន ក្នុងការប្រើប្រាស់អំណាចនិងការចូលរួមរបស់បុគ្គលនិងសហគមន៍ ដើម្បីផ្តល់អំណាចបន្ថែមទៀត ដល់ភាគីដែលស្ថិតនៅឆ្ងាយបំផុតនិងដោះស្រាយពីការមិនបញ្ចូលភាគីមួយចំនួនក្នុងសង្គម ដោយសារភាពក្រីក្រ យេនឌ័រ ពិការភាព ជាតិសាសន៍ និងមូលហេតុផ្សេងៗទៀតនៃវិសមភាព។

ប្រជាជនវ័យក្មេងដែលមានអាយុចន្លោះពី១០ឆ្នាំ ទៅ២៤ឆ្នាំ មានប្រហែល២ភាគ៣នៃចំនួនប្រជាជនសរុបក្នុងប្រទេស។ ជារៀងរាល់ឆ្នាំ យុវជនប្រហែល ៣០០ ០០០នាក់បានចូលក្នុងទីផ្សារការងារ។ ប៉ុន្តែ ជំនាញបច្ចេកទេសនិងសមត្ថភាពរបស់មនុស្សវ័យក្មេង ត្រូវការពង្រឹងបន្ថែមទៀត ដើម្បីបំពេញតម្រូវការជំនាញក្នុងទីផ្សារដែលកំពុងតែកើនឡើង។ ការលើកឡើងពីគោល

នយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាលើកំណែទម្រង់កម្មវិធីសិក្សា ដើម្បីបញ្ចូលជំនាញសតវត្សទី២១ ក្រសួងអប់រំ យុវជន និងកីឡា និងអ្នកស្ម័គ្រចិត្តអង្គការសហប្រជាជាតិ បានដាក់ចេញកម្មវិធីសាកល្បងយុវជនស្ម័គ្រចិត្តចំនួន៣ រួមមាន៖

១. ការស្ម័គ្រចិត្តសម្រាប់សេវាសហគមន៍
២. ការស្ម័គ្រចិត្តសម្រាប់សហគ្រិនភាពសង្គម និង
៣. ការស្ម័គ្រចិត្តនៅថ្ងៃសម្រាកពីការសិក្សា។

កម្មវិធីសាកល្បងទាំង៣នេះ មានបំណងកែលម្អជំនាញ រួមទាំង ការធ្វើការជាក្រុម ការដោះស្រាយបញ្ហា និងការសិក្សារៀនសូត្រដែលមានមូលដ្ឋានលើការសួរសំណួរក្នុងចំណោមយុវវ័យ។ លើសពីនេះទៀត កម្មវិធីទាំង៣នេះក៏ខិតខំប្រឹងប្រែងក្នុងការបង្កើនសមត្ថភាពយុវជន ដែលជាដំណោះស្រាយសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព តាមរយៈឱកាសការងារស្ម័គ្រចិត្ត។

ចាប់ពីខែតុលា ឆ្នាំ២០១៨ កម្មវិធីសាកល្បងទាំង៣ បានប្រមូលអ្នកស្ម័គ្រចិត្តវ័យក្មេងចំនួន ១ ៣៥០នាក់ នៅក្នុងខេត្តចំនួន៧ នៅកម្ពុជា ដែលបានផ្តល់សេវាអភិវឌ្ឍន៍សហគមន៍ដល់មនុស្សជាង ៩ ០០០នាក់។ សេវាដែលផ្តល់ដោយអ្នកស្ម័គ្រចិត្តវ័យក្មេង រួមមានប្រធានបទផ្សេងៗដែលទាក់ទងនឹង គ.អ.ច.ក. ដូចជាវិស័យកសិកម្មសរីរាង្គ សុខភាពកុមារ ទឹកស្អាត អនាម័យ និងការគ្រប់គ្រងសំរាម។ សេវាកម្មដែលផ្តល់ដោយអ្នកស្ម័គ្រចិត្តវ័យក្មេងនេះបានបំពេញបន្ថែមប្រកបដោយប្រសិទ្ធភាព ដល់សេវានានា ដែលផ្តល់ដោយរាជរដ្ឋាភិបាលកម្ពុជា ជាពិសេស សហគមន៍ក្រីក្រ និងសហគមន៍ដាច់ស្រយាល។

សេវារបស់អ្នកស្ម័គ្រចិត្តវ័យក្មេង គឺជាសេវាចូលរួមដោយស្ម័គ្រចិត្តពីដួងចិត្តប្រកបដោយបរិយាប័ន្ន។ ក្នុងចំណោមអ្នកស្ម័គ្រចិត្តដែលចូលរួមក្នុងកម្មវិធីសាកល្បង៣នេះ ស្ទើរតែពាក់កណ្តាលគឺស្ត្រី ហើយភាគច្រើនមានប្រភពមកពីគ្រួសារជនបទក្រីក្រ។ បន្ថែមលើឱកាសនៃការពង្រឹងជំនាញ ការងារស្ម័គ្រចិត្តផ្តល់នូវឱកាសស្មើៗគ្នាសម្រាប់យុវជនទាំងអស់ ដើម្បីរៀននិងបង្កើនចំណេះដឹងរបស់ខ្លួនលើសេវាសហគមន៍។ តាមរបៀបនេះ ការស្ម័គ្រចិត្តបានក្លាយជាយានជំនិះដើម្បីពង្រីកឱកាសអប់រំប្រកបដោយបរិយាប័ន្ន ដែលអាចឱ្យយុវជនទាំងអស់រៀននិងផ្លាស់ប្តូរចំណេះដឹង តាមរយៈវិធីសាស្ត្រដែលមានការចូលរួម។

ដោយយល់ឃើញថា អំណាចនៃការស្ម័គ្រចិត្តក្នុងការចូលរួមរបស់យុវជន ជាផ្នែកមួយនៃដំណោះស្រាយក្នុងការអភិវឌ្ឍ សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានកំណត់ការបង្កើតបណ្តាញការងារស្ម័គ្រចិត្តជាផ្លូវការនៅកម្រិតមូលដ្ឋាន ជាអនុសាសន៍យុទ្ធសាស្ត្រមួយក្នុងចំណោមអនុសាសន៍យុទ្ធសាស្ត្រទាំង៥ នៅមហាសន្និបាតអប់រំឆ្នាំ២០១៩។

## គោលដៅទី៥៖ សម្រេចឱ្យបានសមភាពយេនឌ័រនិងពង្រឹងភាពអង់អាចរបស់ស្ត្រីនិងកុមារីគ្រប់រូប

## វឌ្ឍនភាព

### ក្របខណ្ឌច្បាប់ គោលនយោបាយ ផែនការ និងលិខិតបទដ្ឋានគតិយុត្ត៖

នៅក្នុងអំឡុងឆ្នាំ២០១៦-២០១៩ គោលនយោបាយ និងកម្មវិធីជាតិ ក្នុងក្របខណ្ឌអភិវឌ្ឍសេដ្ឋកិច្ច-សង្គម និងអភិបាលកិច្ច ត្រូវបានតាក់តែងឡើង ដោយមានការយកចិត្តទុកដាក់ និងឆ្លើយតបនឹងការដោះស្រាយវិសមភាពយេនឌ័រ និងបញ្ហាស្ត្រី។ ជាក់ស្តែង មានដូចជាគោលនយោបាយអភិវឌ្ឍន៍យុវជនកម្ពុជា ការសិក្សាពេញមួយជីវិត ការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្មនិងគណិតវិទ្យា ប្រជាជន ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ មុខរបរនិងការងារ ការអភិវឌ្ឍបៃតង ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា ផែនការមេស្តីពីយេនឌ័រនិងការប្រែប្រួលអាកាសធាតុ ក្របខណ្ឌបរិយាប័ន្នហិរញ្ញវត្ថុ គោលនយោបាយភូមិឃុំមានសុវត្ថិភាព គោលនយោបាយជាតិសម្រាប់មនុស្សចាស់ ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព យុទ្ធសាស្ត្រចិញ្ចឹមកូនបែបវិជ្ជមាន ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីលើកទី៣ ផែនការសកម្មភាពស្តីពីការបង្ការទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ផែនការសកម្មភាពស្តីពីការបង្ការទប់ស្កាត់

អាពាហ៍ពិពាហ៍កុមារនិងការមានផ្ទៃពោះក្នុងវ័យជំទង់ រួមទាំងកម្មវិធីនិងលិខិតបទដ្ឋានគតិយុត្តលើការងារកំណែទម្រង់រដ្ឋបាលសាធារណៈ និងការងារវិមជ្ឈការនិងវិសហមជ្ឈការ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់ជីផ្លី ជាដើម។

## ការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងកុមារៈ

រាជរដ្ឋាភិបាលបានរៀបចំ និងអនុវត្តដោយជោគជ័យនូវផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ចំនួនពីរ (ឆ្នាំ២០០៩-២០១៣ និង ឆ្នាំ២០១៤-២០១៨)។

កញ្ចប់សេវាចាំបាច់ រួមទាំងគោលការណ៍ណែនាំនិងលិខិតបទដ្ឋានគតិយុត្តចាំបាច់នានា សម្រាប់ជួយស្ត្រីនិងក្មេងស្រីរងគ្រោះដោយអំពើហិង្សា ត្រូវបានបង្កើតនិងដាក់ឱ្យអនុវត្ត សម្រាប់គាំទ្រនិងសម្របសម្រួលដល់កិច្ចការពារផ្នែកច្បាប់ ការប្រឹក្សាផ្លូវចិត្តនិងសុខភាព ការបញ្ជូនជនរងគ្រោះទៅរកសេវាពាក់ព័ន្ធ និងការគ្រប់គ្រងករណីពាក់ព័ន្ធនឹងជនរងគ្រោះ ប្រកបដោយប្រសិទ្ធភាពនិងទាន់ពេលវេលា។ យន្តការឆ្លើយតបសេវាពហុវិស័យ ចំពោះអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ ត្រូវបានបង្កើតឡើងនៅក្នុងខេត្តចំនួន៨ ដោយមានការចូលរួមពីស្ថាប័នពាក់ព័ន្ធផ្តល់សេវាពាក់ព័ន្ធ ទាំងរាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល និងផ្នែកឯកជន ដើម្បីសម្របសម្រួលនិងឆ្លើយតបដោយប្រសិទ្ធភាព និងទាន់ពេលវេលា ដល់ជនរងគ្រោះដោយអំពើហិង្សា និងបានអភិវឌ្ឍសមត្ថភាពអ្នកផ្តល់សេវា ក្នុងការជួយជនរងគ្រោះ ដោយគោរពតាមស្តង់ដាសេវានិងគោលការណ៍ណែនាំសំខាន់ៗ នៃការផ្តល់សេវាពាក់ព័ន្ធ។ មន្ត្រីក្រសួងកិច្ចការនារីចំនួន៩៤រូប (ស្ត្រី៨៥រូប) បានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ និងកំពុងបន្តអភិវឌ្ឍសមត្ថភាព។

សេចក្តីព្រាងផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ឆ្នាំ២០១៩-២០២៣ ត្រូវបានរៀបចំឡើង ដោយមានការចូលរួមយ៉ាងទូលំទូលាយពីគ្រប់អ្នកមាមនចំណែកពាក់ព័ន្ធទាំងថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិ និងកំពុងរងចាំការអនុមតិពីរាជរដ្ឋាភិបាលក្នុងប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការ។ ក្រសួងកិច្ចការនារីក៏បានបង្កើតនិងអនុវត្ត យុទ្ធសាស្ត្រចិញ្ចឹមកូនបែបវិជ្ជមាន ដោយបានបង្កើតឧបករណ៍ចំនួន៣កម្រិត ដែលក្នុងនោះ ឧបករណ៍កម្រិតទី១ សម្រាប់ផ្សព្វផ្សាយបង្កើនការយល់ដឹងជាសាធារណៈនិងជាសាកល ឧបករណ៍កម្រិតទី២ សម្រាប់ការបណ្តុះបណ្តាលកំណត់គោលដៅ និងកម្រិតទី៣ សម្រាប់ក្រុមដែលងាយរងគ្រោះ។ ក្រសួងកិច្ចការនារីបានអភិវឌ្ឍសមត្ថភាពក្រុមការងារថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងរាជធានីនិងខេត្តគោលដៅចំនួន០៧ (រាជធានីភ្នំពេញ ខេត្តកណ្តាល បាត់ដំបង សៀមរាប ព្រះសីហនុ រតនគិរី និងព្រៃវែង) សម្រាប់ប្រើប្រាស់ឧបករណ៍កម្រិតទី១ និងកម្រិតទី២ ដោយបានផ្សព្វផ្សាយដល់ប្រជាពលរដ្ឋក្នុងសហគមន៍ចំនួន១២ ៩៧២នាក់ ស្រី១០ ២៦៦នាក់។

រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតផែនការសកម្មភាពដើម្បីបង្ការ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ឆ្នាំ២០១៧-២០២១ ដែលសម្របសម្រួលនិងដឹកនាំដោយក្រសួងកិច្ចការនារី និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ ក្នុងក្របខណ្ឌអន្តរជាតិ ប្រទេសកម្ពុជាបានក្លាយ

ជាសមាជិកទី២៦ នៃប្រទេសជាដៃគូសាកល ដើម្បីបញ្ចប់អំពើហិង្សាលើកុមារ ដើម្បីចូលរួមជាមួយសហគមន៍អន្តរជាតិ ក្នុងការប្តេជ្ញាចិត្តអនុវត្តច្បាប់និងគោលនយោបាយ ស្តីពីការទប់ស្កាត់អំពើហិង្សា ការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្សេងៗមកលើកុមារ។

## ការលុបបំបាត់ទង្វើដែលមានគ្រោះថ្នាក់ ដូចជាការបង្ខំកុមារឱ្យរៀបអាពាហ៍ពិពាហ៍

ក្រសួងកិច្ចការនារី បានរៀបចំនិងអនុវត្តផែនការសកម្មភាពស្តីពីកាបង្ការទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ផែនការសកម្មភាពស្តីពីការបង្ការទប់ស្កាត់អាពាហ៍ពិពាហ៍កុមារនិងការមានផ្ទៃពោះក្នុងវ័យជំទង់ ដោយផ្តល់ការគាំទ្រដល់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ (គ.ក.ស.ក) និងមានការចូលរួមពីគ្រប់ភាគីដែលមានចំណែកពាក់ព័ន្ធនៅថ្នាក់ក្រោមជាតិ រួមទាំងយុវជន និងអ្នកដែលធ្លាប់មានបទពិសោធន៍រៀបការក្នុងវ័យកុមារ និងមានផ្ទៃពោះក្នុងវ័យជំទង់ ជាពិសេស ជនជាតិដើមភាគតិច ដើម្បីបង្កើនការយល់ដឹង និងចូលរួមទប់ស្កាត់ការរៀបអាពាហ៍ពិពាហ៍វ័យកុមារ និងការមានផ្ទៃពោះក្នុងវ័យជំទង់។

## កម្មវិធី និងវិធានការឆ្លើយតបនឹងតុល្យភាពជីវិត និងការងារ

ផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ ឆ្នាំ២០១៩-២០២៣ ដែលជាផែនការយុទ្ធសាស្ត្រជាតិសម្រាប់លើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី បានដាក់បញ្ចូលអាទិភាព ក្នុងការលើកកម្ពស់ការយល់ដឹង ការគាំទ្រជាសាធារណៈ និងនៅកន្លែងការងារ អំពីតម្លៃនៃតុល្យភាពជីវិតនិងការងារ និងការផ្តល់តម្លៃលើការងារថែទាំដែលមិនមានប្រាក់កម្រៃ។

## ស្ត្រីក្នុងភាពជាអ្នកដឹកនាំ៖

គោលនយោបាយនិងយុទ្ធសាស្ត្រសម្រាប់លើកកម្ពស់ ភាពជាអ្នកដឹកនាំក្នុងវិស័យមុខងារសាធារណៈ ត្រូវបានរៀបចំឡើង។ ជាមួយគ្នានេះ ផែនការសកម្មភាពបញ្ជ្រាបយេនឌ័រក្នុងវិស័យមុខងារសាធារណៈ ដំណាក់កាលទី៤ ឆ្នាំ២០១៩-២០២៣ ដើម្បីបញ្ជ្រាបយេនឌ័រក្នុងវិស័យមុខងារសាធារណៈ ដោយរួមបញ្ចូលទាំងការបណ្តុះបណ្តាលចាំបាច់ និងការកែលម្អកម្មវិធីសិក្សាសម្រាប់មន្ត្រីជ្រើសរើសថ្មី មន្ត្រីរាជការ និងថ្នាក់ដឹកនាំ។ គណៈកម្មាការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ បានរៀបចំផែនការយុទ្ធសាស្ត្រសម្រាប់បង្កើនចំនួនស្ត្រីក្នុងតួនាទីជាអ្នកដឹកនាំនៅថ្នាក់ក្រោមជាតិ ឆ្នាំ២០១៧-២០១៩ ហើយគោលនយោបាយជាតិស្តីពីការលើកកម្ពស់សមភាពយេនឌ័រសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវបានអនុមតិ និងដាក់ឱ្យប្រើប្រាស់ជាផ្លូវការក្នុងឆ្នាំ២០១៩។

គិតត្រឹមឆ្នាំ២០១៩ នៅក្នុងស្ថាប័ននីតិប្បញ្ញត្តិ សមាជិករដ្ឋសភាជាស្ត្រី មាន២៦រូប ក្នុងចំណោម១២៥រូប (២០,៨០%) ក្នុងនោះមានស្ត្រី១រូប ជាអនុប្រធានរដ្ឋសភា និង០២រូបជាប្រធានគណៈកម្មការជំនាញ។ សមាជិកព្រឹទ្ធសភាជាស្ត្រីមានចំនួន១០រូបក្នុងចំណោម៦២រូប (១៦%) មាន

ស្រ្តី២រូប ជាប្រធានគណៈកម្មការជំនាញ និង ៤រូប ជាអនុប្រធានគណៈកម្មការជំនាញ។ នៅក្នុងស្ថាប័ននីតិប្រតិបត្តិ ចំនួនមុខតំណែងស្ត្រីជាថ្នាក់ដឹកនាំមានការកើនឡើងតាមរយៈការលើកទឹកចិត្ត និងការចាត់តាំង រួមមាន ឧបនាយករដ្ឋមន្ត្រីជាស្ត្រីចំនួន១រូប (១០%) រដ្ឋមន្ត្រីជាស្ត្រីមានចំនួន៣រូប (១០%) ស្ត្រីជារដ្ឋលេខាធិការមានចំនួន៥៣រូប (១៦%) និងស្ត្រីជាអនុរដ្ឋលេខាធិការ ចំនួន៧០រូប (១៧%)។ សមាមាត្រស្ត្រីក្នុងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ បានកើនឡើងដល់១៦,៧៥%។ តំណាងមន្ត្រីរាជការជាស្ត្រីបានកើនឡើពី៣៨% ក្នុងឆ្នាំ២០១៤ ដល់៤១% ក្នុងឆ្នាំ២០១៩ ក្នុងនោះសមាមាត្រស្ត្រីមានតួនាទីជាអ្នកគ្រប់គ្រងក្នុងវិស័យសាធារណៈទាំងថ្នាក់ជាតិ និងក្រោមជាតិ ចាប់ពីអនុប្រធានការិយាល័យដល់ អគ្គនាយក មានការកើនឡើងពី២២% ក្នុងឆ្នាំ២០១៤ ដល់២៥%ក្នុងឆ្នាំ២០១៩។

## សុខភាពបន្តពូជ និងសុខភាពផ្លូវភេទ សម្រាប់ស្ត្រី

យោងតាមការប៉ាន់ស្មានរបស់ក្រសួងសុខាភិបាល នៅឆ្នាំ២០១៩នេះ ក្រុមមនុស្សវ័យជំទង់ (អាយុពី១៥-១៩ឆ្នាំ) មានចំនួន១ ៤៩២ ២៥៩នាក់ (ស្ត្រី ៧៣០ ៦៤៦នាក់)។ ក្រុមនេះអាចប្រឈមខ្ពស់នឹងហានិភ័យនៃមេរោគអេដស៍ឬជំងឺកាមរោគ ភាពមានគភ៌ដោយចៃដន្យឬមានគភ៌នៅអាយុក្មេង ពេកដែលអាចជួបការលំបាកនៅពេលសម្រាលកូន។ ដូច្នេះក្រសួងសុខាភិបាលបានខិតខំប្រឹងប្រែងពង្រឹកការផ្ដល់និងលើកកម្ពស់គុណភាពសេវាសុខភាពបន្តពូជដល់យុវវ័យ និងការផ្ដល់ព័ត៌មានឬសារអប់រំសុខភាព ឱ្យកាន់តែទូលំទូលាយនៅក្នុងសហគមន៍។ ម្យ៉ាងវិញទៀត កម្មវិធីសុខភាពបន្តពូជ មាតា ទារក និងកុមារ និង អាហារូបត្ថម្ភ បានផ្ដោតលើ ការពង្រឹកការគ្របដណ្ដប់ និងការលើកកម្ពស់គុណភាព សុវត្ថិភាព និងប្រសិទ្ធភាព នៃសេវាពន្យារកំណើតឬផែនការគ្រួសារ សេវារំលូតកូនដោយសុវត្ថិភាព សេវាសុខភាពបន្តពូជយុវវ័យ សេវាថែទាំមុននិងក្រោយសម្រាល សេវាថែទាំទារក សេវាបង្ការការចម្លងមេរោគអេដស៍ពីម្ដាយទៅកូន។ល។ ទន្ទឹមនឹងនេះ ក្រសួងកិច្ចការនារី បានបណ្ដុះបណ្ដាលដល់មន្ត្រីថ្នាក់ខេត្ត ស្រុក គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីឃុំ សង្កាត់ ចំនួន២៧០នាក់ជារៀងរាល់ឆ្នាំ និងរៀបចំវេទិកាអប់រំផ្ទាល់ជាមួយប្រជាជនជាច្រើនលើក ស្ដីពីសុខភាពបន្តពូជ ការបង្ការជំងឺឆ្លង (អេដស៍ឬកាមរោគ) សិទ្ធិនិងការទៅទទួលបានសេវាសុខភាពប្រកបដោយគុណភាព ប្រសិទ្ធភាព ដែលជាការរួមចំណែកក្នុងការកាត់បន្ថយអត្រាមរណភាពមាតា ទារក និងកុមារ ការប្រើវិធីសាស្ត្រពន្យារកំណើតទំនើប និង ការឆ្លងថ្មីនៃមេរោគអេដស៍។

## យន្តការបញ្ជ្រាបយេនឌ័រតាមវិស័យ និងការរៀបចំថវិកាឆ្លើយតបយេនឌ័រ

ក្រុមការងារបញ្ជ្រាបយេនឌ័រ គឺជាយន្តការសម្រាប់អនុវត្តនៅគ្រប់វិស័យ។ គិតត្រឹមឆ្នាំ២០១៩ ក្រសួង ស្ថាប័ន ចំនួន៣០ ក្នុងចំណោមក្រសួង-ស្ថាប័នចំនួន៣២ បានបង្កើតក្រុមការងារ និងកំពុងដំណើរការ ក្នុងនោះ ក្រសួង ស្ថាប័ន ចំនួន២៩ មានផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រតាមវិស័យ និងទទួលបានថវិកាជាតិ សម្រាប់ការអនុវត្ត។ ក្រសួងកិច្ចការនារី បន្តជំរុញការលើកកម្ពស់ការរៀបចំថវិកាឆ្លើយតបយេនឌ័រ ដែលជាឧបករណ៍សម្រាប់បញ្ជ្រាបយេនឌ័រនៅគ្រប់វិស័យ ដោយសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## តារាង ៤.៥៖ វឌ្ឍនភាពគោលដៅទី៥ នៃ គ.អ.ច.ក.

| | ចំណុចដៅ/សូចនាករ | ឯកតា | ២០១៥ | ចំណុចដៅ គ.អ.ច.ក. | | | | ជាក់ស្តែង | | | | វឌ្ឍនភាព |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | |
| **៥.១** | **បញ្ចប់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីនិងកុមារី នៅគ្រប់ទីកន្លែង។** | | | | | | | | | | | **ស្ថិតិលើគន្លង ទៅសម្រេចបាន** |
| ៥.១.១ | ចំនួនច្បាប់ គោលនយោបាយ ផែនការ និងក្របខ័ណ្ឌគតិយុត្ត សម្រាប់លើកកម្ពស់ការអនុវត្ត និងតាមដានត្រួតពិនិត្យ ការលើកកម្ពស់សមភាពយេនឌ័រ និងការមិនរើសអើងភេទ។ | ចំនួន | ៥០ (២០១៦) | ៥០ | | ៥៥ | | ៥០ | ៥២ | ៥៥ | ៥៦ | ស្ថិតិលើគន្លង ទៅសម្រេចបាន |
| **៥.២** | **លុបបំបាត់រាល់ទម្រង់នៃអំពើហិង្សាលើស្ត្រីនិងកុមារី នៅទីសាធារណៈនិងទីកន្លែងឯកជននានា រួមទាំងការជួញដូរ ការធ្វើអាជីវកម្មផ្លូវភេទ និងអាជីវកម្មផ្សេងទៀត។** | | | | | | | | | | | **មិនមានទិន្នន័យ** |
| ៥.២.១ | សមាមាត្ររបស់ស្ត្រីនិងក្មេងស្រី ដែលមានអាយុ ១៥ឆ្នាំឡើង ដែលធ្លាប់ទទួលរងនូវអំពើហិង្សាលើរាងកាយ ផ្លូវភេទឬផ្លូវចិត្ត ពីដៃគូបច្ចុប្បន្ន ឬអតីត ក្នុងរយៈពេល ១២ខែចុងក្រោយ បែងចែកតាមទម្រង់នៃអំពើហិង្សា និងតាមអាយុ។ | % | ៣០,០ (២០១៤) | ៣០,០ | ៣០,០ | ៣០,០ | ៣០,០ | | | | | មិនមានទិន្នន័យ |
| ៥.២.២ | សមាមាត្ររបស់ស្ត្រីនិងក្មេងស្រី ដែលមានអាយុ១៥ឆ្នាំឡើង ដែលធ្លាប់ទទួលរងនូវអំពើហិង្សាលើ ផ្លូវភេទពីអ្នកមិនមែនជាដៃគូ ក្នុងរយៈពេល ១២ខែចុងក្រោយ បែងចែកតាមតាមអាយុ។ | % | ០,១ (២០១៤) | ០,១ | ០,១ | ០,១ | ០,១ | | | | | មិនមានទិន្នន័យ |
| **៥.៣** | **លុបបំបាត់រាល់ ទង្វើដែលមានគ្រោះថ្នាក់ ដូចជាការបង្ខំកុមារឱ្យរៀបអាពាហ៍ពិពាហ៍ និងការធ្វើឱ្យមានរបួសស្នាមប្រដាប់បន្តពូជ។** | | | | | | | | | | | **មិនមានទិន្នន័យ** |
| ៥.៣.១ | សមាមាត្ររបស់ស្ត្រីអាយុពី ២០ ដល់ ២៤ឆ្នាំ ដែលបានរៀបការឬរស់នៅជាមួយគ្នាមុនអាយុ១៨ឆ្នាំ។ | % | ១,៩ (២០១៦) | ១,៩ | ១,៩ | ១,៩ | ១,៩ | | | | | មិនមានទិន្នន័យ |
| **៥.៤** | **ទទួលស្គាល់និងផ្តល់តម្លៃដល់ការងារផ្ទះដែលមិនមានកម្រៃ តាមរយៈ ការផ្តល់សេវាសាធារណៈ ហេដ្ឋារចនាសម្ព័ន្ធ និងគោលនយោបាយគាំពារសង្គម និងលើកកម្ពស់ការរួមចំណែកទទួលខុសត្រូវឱ្យបានសមរម្យ នៅក្នុងសង្គមគ្រួសារ និងសង្គមជាតិ។** | | | | | | | | | | | **លើសចំណុចដៅ** |
| ៥.៤.១ | ចំនួនវិធានការផ្លូវច្បាប់និងគោលនយោបាយដែលដោះស្រាយនិងទទួលស្គាល់នូវតុល្យភាពជីវិតនិងការងារ (ការងារ ផ្ទះនិងការងារថែទាំដែលមិនមានកម្រៃ) និងលើកកម្ពស់ការទទួលបាន កាន់តែច្រើននូវការងារ សមរម្យសម្រាប់ស្ត្រី។ | ចំនួន | ៥ (២០១៦) | ៥ | - | ៧ | | - | - | ៨ | ៩ | លើសចំណុចដៅ |
| **៥.៥** | **ធានាការចូលរួមពេញលេញនិងមានប្រសិទ្ធភាពរបស់ស្ត្រី និងមានឱកាសដូចគ្នាក្នុងភាពជាអ្នកដឹកនាំនៅគ្រប់កម្រិតនៃការធ្វើសេចក្តីសម្រេចក្នុងវិស័យនយោបាយ សេដ្ឋកិច្ច និងជីវិតជាសាធារណៈ។** | | | | | | | | | | | **ទាបជាងចំណុចដៅ** |
| ៥.៥.១ | សមាមាត្រអាសនៈរបស់ស្ត្រីនៅក្នុងស្ថាប័ននីតិប្បញ្ញត្តិ។ | % | ១៧,៨១ (២០១៦) | ១៧,៨១ | | ២៥,០០ | | ១៧,៨០ | - | ១៩,៦៧ | ១៩,៦៧ | ទាបជាងចំណុចដៅ |
| ៥.៥.២ | សមាមាត្រស្ត្រីជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ។ | % | - | ១៦,២៧ | - | ២១,០០ | | ១៦,២៧ | - | ១៤,៥៥ | ១៤,៣៣ | ទាបជាងចំណុចដៅ |
| ៥.៥.៣ | សមាមាត្រនៃស្ត្រីជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់។ | % | ១៦,៧៥ (២០១៧) | - | ១៦,៧៥ | - | | - | ១៦,៧៥ | - | ១៦,៧៥ | ស្ថិតិលើគន្លង ទៅសម្រេចបាន |
| **៥.៦** | **ធានាការទទួលបានសុខភាពផ្លូវភេទនិងសុខភាពបន្តពូជ និងសិទ្ធិបន្តពូជជាសកល ដូចបានឯកភាពដោយផ្អែកលើកម្មវិធីសកម្មភាពរបស់សន្និសីទអន្តរជាតិស្តីពីប្រជាជននិងការអភិវឌ្ឍ និងផែនការសកម្មភាពទីក្រុងប៉េកាំង និងឯកសារពាក់ព័ន្ធនានា។** | | | | | | | | | | | **ស្ថិតិលើគន្លង ទៅសម្រេចបាន** |
| ៥.៦.១ | សមាមាត្រនៃស្ត្រីអាយុពី ១៥ដល់៤៩ឆ្នាំ ដែលសម្រេចចិត្តដោយខ្លួនឯងពាក់ព័ន្ធទៅនឹងការប្រើប្រាស់មធ្យោបាយ ពន្យារកំណើត និងការថែទាំសុខភាពបន្តពូជ។ | % | ៥៧,៦ (២០១៦) | ៥៧,៦ | - | ៧៧ | | | | | | មិនមានទិន្នន័យ |
| ៥.៦.២ | ចំនួនច្បាប់ គោលនយោបាយ ផែនការ និងលិខិតបទដ្ឋានគតិយុត្ត ដែលធានាឱ្យស្ត្រីគ្រប់រូបមានលទ្ធភាពទទួលបានព័ត៌មាន ការអប់រំ និងសេវាសុខភាពបន្តពូជ និងសុខភាពផ្លូវភេទ។ | ចំនួន | ១០ (២០១៦) | ១០ | - | ១២ | | ១២ | ១២ | ១៣ | ១៣ | ស្ថិតិលើគន្លង ទៅសម្រេចបាន |
| **៥.c** | **អនុម័តនិងពង្រឹងគោលនយោបាយនិងបទដ្ឋានគតិយុត្តនានា សម្រាប់លើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រីនិងកុមារី នៅគ្រប់កម្រិត។** | | | | | | | | | | | **លើសចំណុចដៅ** |
| ៥.c.១ | ចំនួនក្រសួង ស្ថាប័ន ដែលមានប្រព័ន្ធតាមដាន និងវិភាជថវិកា សម្រាប់លើកកម្ពស់សមភាពយេនឌ័រ និងការពង្រឹងភាពអង់អាចដល់ស្ត្រី។ | ចំនួន | ០ | - | ៣ | | | ០ | ២ | ២ | ២ | ទាបជាងចំណុចដៅ |
| ៥.c.២ | ចំនួនក្រសួង ស្ថាប័ន ដែលបានអនុវត្តផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ។ | ចំនួន | - | ៦ | ៧ | ៦ | ៨ | ២៧ | ២៨ | ២៩ | ២៩ | លើសចំណុចដៅ |

*ប្រភព÷ ក្របខ័ណ្ឌ គ.អ.ច.ក. និង ក្រសួង ស្ថាប័ន*

## បញ្ហាប្រឈម

- ការចាប់យកជំនាញសម្រាប់ស្ត្រី និងផ្នត់គំនិតរបស់គ្រួសារនិងសង្គម ក្នុងការលើកទឹកចិត្តឱ្យស្ត្រីចូលរួមយល់ដឹងនិងមានជំនាញពាក់ព័ន្ធបច្ចេកវិទ្យា និងសេដ្ឋកិច្ចឌីជីថល នៅមិនទាន់បានទូលំទូលាយនៅឡើយ។
- ផ្នត់គំនិតនិងឥរិយាបថគ្រួសារនិងសង្គម នៅបន្តរើសអើងលើតួនាទីស្ត្រីក្នុងភាពជាអ្នកដឹកនាំដែលជាកត្តារារាំងដល់ការអភិវឌ្ឍសក្តានុពលរបស់ស្ត្រី ក្នុងការចូលរួមពេញលេញក្នុងតួនាទីធ្វើសេចក្តីសម្រេច ក្នុងវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងនយោបាយ។
- ការប្តេជ្ញាចិត្តរបស់ក្រសួង ស្ថាប័ន និង អង្គាធរពាក់ព័ន្ធ ក្នុងការចូលរួមអនុវត្តផែនការសកម្មភាពជាតិ គោលនយោបាយ គោលការណ៍ណែនាំ និងនិតិវិធីនានា ពាក់ព័ន្ធនឹងយេឌ័រ នៅមានកម្រិត។ ដូច្នេះទាមទារឱ្យមានកិច្ចសហប្រតិបត្តិការគ្រប់វិស័យពីភាគីពាក់ព័ន្ធទាំងអស់ និង ចូលរួមអនុវត្តការងារនេះ ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ។
- ការរីករាលដាលនៃជម្ងឺកូវីដ-១៩ បានធ្វើឱ្យមានការរាំងស្ទះក្នុងការអនុមតិ និងអនុវត្តគោលនយោបាយជាតិ ស្តីពីសមភាពយេនឌ័រ និងផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី រួមទាំងផែនការ គម្រោង កម្មវិធីនានា។

## គោលនយោបាយ យុទ្ធសាស្ត្រសំខាន់ៗ

រាជរដ្ឋាភិបាលកម្ពុជាប្តេជ្ញាចិត្តលើកកម្ពស់បទដ្ឋានសង្គមជាវិជ្ជមាន តាមរយៈការអនុវត្តច្បាប់ជាតិ គោលនយោបាយ ផែនការ និងកម្មវិធីនៅគ្រប់កម្រិត។ ក្រសួងកិច្ចការនារី ដោយមានកិច្ចសហការនិងការគាំទ្រពីក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ និងភាគីដែលមានចំណែកពាក់ព័ន្ធ បានចូលរួមចំណែកលើកកម្ពស់សមភាពយេនឌ័រក្នុងគោលនយោបាយយុទ្ធសាស្ត្រ និងកម្មវិធីកំណែទម្រង់សំខាន់ៗ ដូចជា៖

- ផែនការយុទ្ធសាស្ត្រ៥ឆ្នាំ ស្តីពីការលើកកម្ពស់សមភាពយេឌ័រនិងការផ្តល់ភាពអង់អាចដល់ស្ត្រី ២០១៩-២០២៣ «នារីរតនៈទី៥» មានគោលបំណងពង្រឹងសមត្ថភាពស្ថាប័ន ដើម្បីលើកកម្ពស់សមភាពយេនឌ័រ តាមរយៈអភិក្រមតាមកម្មវិធីនិងអភិបាលកិច្ចល្អ។ ផែនការនេះដាក់បញ្ជ្រាបយុទ្ធសាស្ត្រនានាគ្រប់ជ្រុងជ្រោយ ដើម្បីពង្រឹងមុខងាររបស់ក្រសួងកិច្ចការនារី ដែលជាកត្តាជំរុញ ស្វែងរកការគាំទ្រមតិ សម្របសម្រួល និងលើកទឹកចិត្តដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ សង្គមស៊ីវិល វិស័យឯកជន ក្នុងការបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយ ផែនការ គម្រោង កម្មវិធីរបស់ខ្លួន។
- គោលនយោបាយជាតិ ស្តីពីសមភាពយេនឌ័រ នឹងផ្តល់នូវក្របខណ្ឌគោលនយោបាយកម្រិតជាតិរយៈពេលវែង សម្រាប់ក្រសួង ស្ថាប័ន ក្នុងការអនុវត្ត និងការទទួលខុសត្រូវលើការលើក

កម្ពស់សមភាពយេនឌ័រនៅតាមវិស័យ និងគ្រប់កម្រិត។ គោលនយោបាយនេះ ក៏បានដាក់បញ្ចូលខ្លឹមសារ នៃការរើសអើងយេនឌ័រ ដោយផ្អែកលើអនុសញ្ញា ស៊ី-ដ។

- ផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី បានកំណត់នូវអាទិភាព និងសកម្មភាពសំខាន់ៗសម្រាប់ការទប់ស្កាត់ និងការឆ្លើយតបប្រកបដោយប្រសិទ្ធភាព ចំពោះអំពើហិង្សាផ្អែកលើយេនឌ័រនៅគ្រប់វិស័យ និងតម្រូវឱ្យមានការដាក់បញ្ចូលទៅក្នុងផែនការសកម្មភាពរបស់ក្រសួង ស្ថាប័ន និងដៃគូពាក់ព័ន្ធ។
- ក្រុមការងារបច្ចេកទេសយេនឌ័រ គឺជាយន្តការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ ដើម្បីធ្វើសុខដុមនីកម្មផែនការសកម្មភាពផ្អែកលើលទ្ធផល ពង្រឹងភាពជាអ្នកដឹកនាំ និងភាពជាម្ចាស់របស់រដ្ឋាភិបាល ដោយផ្អែកលើសូចនាករតាមដានរួមគ្នា (២០១៩-២០២៣)។ ក្រុមការងារនេះ បានបង្កើតក្រុមការងារតាមវិស័យ ចំនួន៣ រួមមាន ក្រុមទប់ស្កាត់អំពើហិង្សាឆ្លើយតបនឹងយេនឌ័រ ក្រុមបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី និងក្រុមស្ត្រីក្នុងភាពជាអ្នកដឹកនាំ និងអភិបាល។ ក្រុមទាំង ៣ នេះ បានដើរតួទីយ៉ាងសំខាន់ក្នុងការរៀបចំ អនុវត្ត សម្របសម្រួល និងតាមដានត្រួតពិនិត្យ កម្មវិធីរបស់ក្រសួង ស្ថាប័ន ពីការសម្រេចបានសមភាពយេនឌ័រនិងការបង្កើនភាពអង់អាចដល់ស្ត្រី និង ឈានទៅសម្រេចបាន គ.អ.ច.ក.។ ក្រុមការងារបញ្ជ្រាបយេនឌ័រ និងផែនការបញ្ជ្រាបយេនឌ័រ គឺជាយុទ្ធសាស្ត្រគន្លឹះសម្រាប់ពន្លឿនការបញ្ជ្រាបយេនឌ័រនៅតាមវិស័យ និងស្ថាប័ន។
- យេនឌ័រត្រូវបានធ្វើសមាហរណកម្មទៅក្នុងយុទ្ធសាស្ត្រចតុកោណ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ផែនការយុទ្ធសាស្ត្រតាមវិស័យ និងគោលនយោបាយនិងយុទ្ធសាស្ត្រនានា។
- យេនឌ័រត្រូវបានដាក់បញ្ចូលទៅក្នុងដំណើរការកំណែទម្រង់សំខាន់ៗ ដូចជា កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ វិមជ្ឈការនិងវិសហមជ្ឈការ និងតាមរយៈយុទ្ធសាស្ត្រជាតិដើម្បីលើកកម្ពស់ស្ត្រីនៅក្នុងមុខតំណែងគ្រប់គ្រងនៅថ្នាក់ក្រោមជាតិ ឆ្នាំ២០១៧-២០១៩ និងគោលនយោបាយជាតិស្តីពីការលើកកម្ពស់សមភាពយេនឌ័រ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងក្របខណ្ឌប្រែប្រួលអាកាសធាតុ កំណើនបៃតង និងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ។
- ក្នុងគោលបំណងលើកកម្ពស់សមភាពយេនឌ័រនិងពង្រឹងភាពអង់អាចរបស់ស្ត្រីនិងកុមារីគ្រប់រូប នៅថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាលកម្ពុជានឹងធ្វើសមាហរណកម្មការិយាល័យកិច្ចការនារីក្រុង ស្រុក ខណ្ឌ ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងដោយផ្ទាល់របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ហើយមុខងារមួយចំនួន ពាក់ព័ន្ធនឹងស្ត្រីនិងកុមារ ត្រូវបានប្រគល់ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

# គោលដៅទី៦៖ ធានាឱ្យមានទឹកនិងអនាម័យនិងការគ្រប់គ្រងទឹក និង អនាម័យប្រកបដោយចីរភាពសម្រាប់ប្រជាជនគ្រប់រូប

## វឌ្ឍនភាព

ទឹកនិងអនាម័យដើរតួយ៉ាងសំខាន់ក្នុងការធ្វើឱ្យប្រសើរឡើងនូវ សុខភាពសាធារណៈនិងសុខុមាលភាពរបស់ប្រជាពលរដ្ឋ។ រាជរដ្ឋាភិបាលកម្ពុជាកំពុងបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីសម្រេចឱ្យបានតាមគោលដៅដែលបានកំណត់ ពាក់ព័ន្ធនឹងការលើកកម្ពស់ការទទួលបានទឹកស្អាត និងសេវាកម្មផ្គត់ផ្គង់ទឹកជាមូលដ្ឋាន និង ការទទួលបានអនាម័យមូលដ្ឋានរបស់ប្រជាជននៅជនបទ។ គោលដៅទី៦ បានបង្ហាញពីវឌ្ឍនភាពនៃការអនុវត្ត របស់រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងអភិវឌ្ឍន៍ជនបទ ដោយមានការចូលរួមពី ដៃគូអភិវឌ្ឍ និងភាគីដែលមានចំណែកពាក់ព័ន្ធផ្សេងទៀត ពាក់ព័ន្ធនឹងការទទួលបានទឹកស្អាតនៅតំបន់ជនបទ។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលកម្ពុជា ក៏បានខិតខំកែលម្អហេដ្ឋារចនាសម្ព័ន្ធសេវាអនាម័យសម្រាប់ប្រជាជនប្រើប្រាស់ ជាពិសេស បង្គន់អនាម័យ និងបន្ទប់ទឹកដែលជាការលើកកម្ពស់ការប្រើប្រាស់សេវាអនាម័យនៅតំបន់ជនបទ។ ដោយសារលទ្ធផលដែលទទួលបានពាក់ព័ន្ធនឹងទឹកស្អាតនិងអនាម័យ មិនទាន់មានភាពល្អប្រសើរតាមការកំណត់ រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងអភិវឌ្ឍន៍ជនបទ ដៃគូអភិវឌ្ឍ និងភាគីដែលមានចំណែកពាក់ព័ន្ធផ្សេងទៀត នឹងនៅតែបន្តកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីបំពេញនិងសម្រេចឱ្យបានតាមការកំណត់របស់រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជា សម្រេចឱ្យបាននូវចំណុចដៅរបស់ គ.អ.ច.ក.។ គោលនយោបាយនិងយុទ្ធសាស្ត្រគន្លឹះៗមួយចំនួនត្រូវបានដាក់ចេញ ដើម្បីពន្លឿនការសម្រេចបានគោលដៅទាំងនេះ។

ក្រសួងធនធានទឹក និងឧតុនិយម និងគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា បានខិតខំប្រឹងប្រែងរក្សានូវគុណភាពទឹកនៅលើដី និងតាមដានគុណភាពទឹកនៅកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជាបាននឹងកំពុងយកចិត្តទុកដាក់ក្នុងការពង្រឹងហេដ្ឋារចនាសម្ព័ន្ធទឹក ដើម្បីរួមចំណែកពង្រឹងគុណភាពទឹក និងសេវាផ្គត់ផ្គង់ទឹក។ ចំពោះដំណើរការអនុវត្តការងារគ្រប់គ្រងធនធានទឹកចម្រុះ ក្រសួងធនធានទឹក និងឧតុនិយម បានអនុវត្តការទទួលខុសត្រូវរបស់ខ្លួនក្នុងការគ្រប់គ្រងគុណភាពទឹក។ ចំណែកក្រសួងបរិស្ថានទទួលខុសត្រូវ និងយកចិត្តទុកដាក់លើការការពារគុណភាពទឹក តាមរយៈ ការតាមដានគុណភាពទឹកសាធារណៈ ការត្រួតពិនិត្យជាប្រចាំលើប្រភពបំពុល និងសកម្មភាពដែលអាចបង្កឱ្យមានការបំពុលទឹកដោយជំរុញ ឱ្យមានការបំពាក់ឧបករណ៍ស្វ័យប្រវត្តិកម្ម សម្រាប់វាស់ស្ទង់បរិមាណសំណល់ និងសារធាតុបំពុលបរិស្ថាននៅតាមប្រភពដែលមានសក្តានុពលបំពុលខ្លាំង និងការគ្រប់គ្រងការចោលសំរាម សំណល់រឹង ឬសារធាតុគីមីពុលចូលទៅក្នុងប្រភពទឹក ។

គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ក៏បានរួមចំណែក សម្រេចបាននូវសមិទ្ធផលមួយចំនួនដូចខាងក្រោម៖

- បានអនុមតិយុទ្ធសាស្ត្រអភិវឌ្ឍន៍អាងទន្លេ ឆ្នាំ២០១៦-២០២០ និងផែនការយុទ្ធសាស្ត្រគណៈកម្មការទន្លេមេគង្គ ឆ្នាំ២០១៦-២០២០។
- បានបញ្ចប់ការសិក្សាស្ដីពីការអភិវឌ្ឍ និងការគ្រប់គ្រងប្រកបដោយចីរភាពនៃទន្លេមេគង្គ ដោយរាប់បញ្ចូលទាំងផលប៉ះពាល់នៃគម្រោងទំនប់វារីអគ្គិសនីនៅលើទន្លេមេ។
- បានអនុមតិយុទ្ធសាស្ត្រ និងផែនការសកម្មភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុ ក្នុងអាងទន្លេមេគង្គ និងយុទ្ធសាស្ត្រគ្រប់គ្រងនិងអភិវឌ្ឍវិស័យជលផលក្នុងអាងទន្លេមេគង្គ។
- បានរៀបចំសេចក្តីព្រាងគោលការណ៍ណែនាំស្ដីពី ការវាយតម្លៃផលប៉ះពាល់បរិស្ថានឆ្លងដែន រៀបចំសកម្មភាពតាមដានត្រួតពិនិត្យបរិស្ថានរួមគ្នាសម្រាប់ទំនប់វារីអគ្គីសនីលើទន្លេមេ និងយុទ្ធសាស្ត្រគ្រប់គ្រងគ្រោះរាំងស្ងួត និង ការធ្វើបច្ចុប្បន្នភាពគោលការណ៍ណែនាំគ្រោងប្លង់សម្រាប់ទំនប់វារីអគ្គិសនីលើទន្លេមេ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍វារីអគ្គិសនីប្រកបដោយចីរភាព។
- បានបន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូសន្ទនាចិននិងមីយ៉ាន់ម៉ា ដោយបានចែករំលែកទិន្នន័យនិងព័ត៌មាន រៀបចំសន្និសីទបច្ចេកទេស ផ្លាស់ប្តូរទស្សនកិច្ចរួមគ្នា ស្រាវជ្រាវរួមគ្នាលើបញ្ហាសំខាន់ៗ និងកិច្ចសហការជាមួយមជ្ឈមណ្ឌលសហប្រតិបត្តិការធនធានទឹកមេគង្គ-ឡានឆាង។ ជាមួយគ្នានេះ ក៏បានកៀរគរការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសពីដៃគូអភិវឌ្ឍ ទាំងដៃគូទ្វេភាគី និងពហុភាគី សម្រាប់ការងារថែរក្សានិងពង្រឹងគុណភាពទឹក។

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ គឺជាស្ថាប័នសំខាន់ដែលទទួលបន្ទុករៀបចំនិងការអនុវត្តការគ្រប់គ្រងការផ្គត់ផ្គង់ទឹកស្អាតដល់ប្រជាជននៅតំបន់ទីប្រជុំជន។ នៅឆ្នាំ២០១៩ នេះ ការផ្គត់ផ្គង់ទឹកស្អាតនៅតំបន់ទីប្រជុំជន សម្រេចបានតែប្រមាណ៥៦,៣៧% នៃចំនួនប្រជាជនសរុបនៅតំបន់ទីប្រជុំជន។ សេវាផ្គត់ផ្គង់ទឹកស្អាត បានកើនឡើងពីជាង៣លាននាក់ នៅឆ្នាំ២០១៦ ដល់ជាង៤លាននាក់ នៅឆ្នាំ២០១៨ ហើយនិន្នាការនេះបន្តកើនឡើង ដោយសារតែការបង្កើនសមត្ថភាពនៃការផ្គត់ផ្គង់ទឹកស្អាត មានថ្លៃសមរម្យ មានលក្ខណៈចីរភាព និងការពង្រីកការគ្របដណ្តប់សេវាកម្មផ្គត់ផ្គង់ទឹកស្អាតទូទាំងប្រទេស។ លើសពីនេះទៀត រាជរដ្ឋាភិបាលបានកាត់បន្ថយអត្រាតម្លៃប្រើប្រាស់ទឹក និងផ្តល់ការឧបត្ថម្ភលើការតភ្ជាប់ទឹកស្អាតទៅដល់កម្មករកាត់ដេរនៅក្នុងបន្ទប់ជួល និងដល់ប្រជាជនក្រីក្រ។ សេវាផ្គត់ផ្គង់ទឹកស្អាត ត្រូវបានធ្វើឯកជនភាវូបនីយកម្ម ដើម្បីបង្កើនការគ្របដណ្តប់បន្ថែមទៀតដល់តំបន់ជនបទ។ ការផ្គត់ផ្គង់ទឹកស្អាតត្រូវបានព្យាករណ៍ថា នឹងសម្រេចបានគោលដៅ៩០% នៃចំនួនប្រជាជនសរុបនៅឆ្នាំ២០២៣ និង១០០%នៅឆ្នាំ២០២៥។

ទន្ទឹមនឹងការយកចិត្តទុកដាក់ផ្គត់ផ្គង់ទឹកស្អាតដល់ប្រជាជននៅតំបន់ទីប្រជុំជន រាជរដ្ឋាភិបាលកម្ពុជាក៏បានផ្តោតជាសំខាន់ផងដែរលើការផ្គត់ផ្គង់សេវាអនាម័យនៅតំបន់ជនបទផងដែរ។ តាមរយៈក្រសួងអភិវឌ្ឍន៍ជនបទ យកចិត្តទុកដាក់លើការរៀបចំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ដល់គ្រួសារនានានៅតាមភូមិជនបទ គឺជាអាទិភាពខ្ពស់។

## តារាង ៤.៦÷ វឌ្ឍនភាពគោលដៅទី៦ នៃ គ.អ.ច.ក.

| | ចំណុចដៅ/សូចនាករ | ឯកតា | ២០១៥ | ចំណុចដៅ គ.អ.ច.ក. | | | | ជាក់ស្តែង | | | | វឌ្ឍនភាព |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | |
| ៦.១ | ៦.១ ត្រឹមឆ្នាំ២០៣០ សម្រេចនូវការទទួលបានជាសាកលក និងសមធម៌នូវទឹកបរិភោគដែលមានសុវត្ថិភាព និងមានតម្លៃសមរម្យ សម្រាប់ប្រជាជនទាំងអស់។ | | | | | | | | | | | ទាបជាងចំណុចដៅ |
| ៦.១.១ | សមាមាត្រនៃប្រជាជនកម្ពុជារស់នៅក្នុងតំបន់ទីប្រជុំជន ដែលទទួលបានការប្រើប្រាស់សេវាផ្គត់ផ្គង់ទឹកស្អាត ប្រកបដោយសុវត្ថិភាព។ | % | ៨៣,០ (២០១៦) | ៨៣,៥ | ៨៤,០ | ៨៥,០ | ៨៧,០ | - | - | - | | គ្មានទិន្នន័យ |
| ៦.១.២ | សមាមាត្រនៃប្រជាជននៅតំបន់ជនបទ ដែលប្រើប្រាស់សេវាផ្គត់ផ្គង់ទឹកបរិភោគប្រកបដោយសុវត្ថិភាព។ | % | ១៦,០ | ១៦,០ | ១៨,០ | ២១,០ | ២៣,០ | ១៦,០ | ១៦,០ | ១៦,០ | ១៦,០ | ទាបជាងចំណុចដៅ |
| ៦.២ | ត្រឹមឆ្នាំ២០៣០ ទទួលបានគ្រប់គ្រាន់និងសមធម៌ នូវអនាម័យ សម្រាប់ប្រជាជនគ្រប់រូប និងបញ្ចប់ការបន្ទោរបង់នៅក្រៅបង្គន់ ផ្តោតការយកចិត្តទុកដាក់លើតម្រូវការរបស់ស្ត្រីនិងកុមារី និងប្រជាជនដែលរស់នៅក្នុងស្ថានភាពងាយរងគ្រោះ។ | | | | | | | | | | | ស្ថិតិលើគន្លងទៅសម្រេចបាន |
| ៦.២.១ | សមាមាត្រនៃប្រជាជននៅតំបន់ជនបទ ដែលប្រើប្រាស់សេវាគ្រប់គ្រងអនាម័យ រួមទាំង ឧបករណ៍លាងសម្អាតដៃ ទឹក និងសាប៊ូ។ | % | ២៧,០ | ២៨,០ | ២៩,០ | ៣០,០ | ៣១,០ | - | - | - | - | គ្មានទិន្នន័យ |
| | សមាមាត្រនៃប្រជាជននៅតំបន់ជនបទ ដែលប្រើប្រាស់ សេវាគ្រប់គ្រងអនាម័យ។ | % | ៥៦,០ (២០១៦) | ៥៦,០ | ៦០,០ | ៦២,០ | ៧១,០ | ៦៧,៤ | ៧១,២ | ៧១,២ | ៧១,២ | ស្ថិតិលើគន្លង ទៅសម្រេចបាន |
| ៦.៣ | ត្រឹមឆ្នាំ២០៣០ ធ្វើឱ្យប្រសើរឡើងគុណភាពទឹក ដោយកាត់បន្ថយការបំពុល លុបបំបាត់ការបោះបង់សម្រាម និងកាត់បន្ថយ ឱ្យនៅកម្រិតទាបបំផុតនៃការបោះបង់ចោលសម្ភារៈនិងសារធាតុជាតិគីមីដែលមានគ្រោះថ្នាក់ កាត់បន្ថយឱ្យនៅពាក់កណ្តាល សមាមាត្រនៃសំណល់រាវដែលមិនបានសម្អាត និងបង្កើនឱ្យបានច្រើនវត្ថុធាតុដើមកកើតឡើងវិញ និងការប្រើប្រាស់ឡើងវិញប្រកបដោយសុវត្ថិភាពជាសកល។ | | | | | | | | | | | លើសចំណុចដៅ |
| ៦.៣.១ | សមាមាត្រនៃសំណល់រាវដែលបានសម្អាតប្រកបដោយសុវត្ថិភាព (សំណល់រាវឧស្សាហកម្ម)។ | % | ១២,០ | ១៥,០ | ១៩,០ | ១៩,០ | ២៣,០ | ៤០,០ | ៤៨,០ | ៥៧,០ | ៦៥,០ | លើសចំណុចដៅ |
| ៦.៤ | ត្រឹមឆ្នាំ២០៣០ កាត់បន្ថយឱ្យបានច្រើននូវលំហូរហិរញ្ញវត្ថុនិងគ្រឿងសព្វាវុធខុសច្បាប់ ពង្រឹងភាពដូចដើមវិញ និងការទទួលបានមកវិញនូវអចលនទ្រព្យដែលត្រូវបានលួច និងប្រយុទ្ធប្រឆាំងនឹងអង្គការឧក្រិដ្ឋកម្មគ្រប់ទម្រង់។ | | | | | | | | | | | ទាបជាងចំណុចដៅ |
| ៦.៤.១ | ត្រឹមឆ្នាំ២០២៥ ប្រជាជនកម្ពុជាគ្រប់រូបនៅតំបន់ទីប្រជុំជនទទួលបានទឹកស្អាតប្រើប្រាស់ប្រកបដោយចីរភាព គុណភាពល្អ និងតម្លៃសមរម្យ។ | % | ៨៣,០០ (២០១៦) | ៨៣,០០ | ៨៥,០០ | ៨៧,០០ | ៩០,០ | ៧៥,០៧ | ៨៥,៨៤ | ៤៥,៤១ | ៥៦,៣៧ | ទាបជាងចំណុចដៅ |
| ៦.a | ត្រឹមឆ្នាំ២០៣០ ពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិ និងគាំទ្រការកសាងសមត្ថភាពដល់បណ្តាប្រទេសកំពុងអភិវឌ្ឍ ក្នុងកម្មវិធីនិងសកម្មភាពពាក់ព័ន្ធនឹងទឹកស្អាតនិងអនាម័យ រួមទាំងបច្ចេកវិជ្ជាប្រមូលទឹក បន្សាបទឹកប្រៃ ប្រសិទ្ធភាពទឹក សម្អាតសំណល់រាវ កែច្នៃនិងប្រើប្រាស់ឡើងវិញ។ | | | | | | | | | | | លើសចំណុចដៅ |
| ៦.a.១ | ទំហំហិរញ្ញប្បទានសហប្រតិបត្តិការដែលពាក់ព័ន្ធទៅនឹងទឹកស្អាតនិងអនាម័យ ដែលជាផ្នែកនៃផែនការចំណាយសម្របសម្រួលដោយរដ្ឋាភិបាល ធៀបនឹង ផ.ស.ស.។ | % នៃ ផ.ស.ស. | ០,១៤ (២០១៦) | ០,១៤ | ០,១៣ | ០,១២ | ០,១១ | ០,១៩ | ០,៣៩ | ០,៣២ | ០,៥៧ | លើសចំណុចដៅ |

*ប្រភព÷ ក្របខ័ណ្ឌ គ.អ.ច.ក. និង ក្រសួង ស្ថាប័ន ពាក់ព័ន្ធ*

## បញ្ហាប្រឈម

ដោយផ្អែកលើលទ្ធភាពទទួលបានទឹកប្រើប្រាស់សម្រាប់ប្រជាជនម្នាក់ៗ កម្ពុជាមិនមែនជាប្រទេសដែលមានភាពតានតឹងលើការប្រើប្រាស់ទឹកទេ ប៉ុន្តែបញ្ហាប្រឈមគឺធនធានទឹកដ៏សម្បូរបែប មិនត្រូវបានចែកចាយស្មើគ្នាតាមពេលវេលា (រដូវវស្សា និងរដូវប្រាំង) និងទីកន្លែង ហើយកម្ពុជាត្រូវការការអភិវឌ្ឍការស្តុកទឹក ប្រព័ន្ធ និងសមត្ថភាពចែកចាយ។ ការគ្រប់គ្រងធារស្តុកទឹក នៃប្រព័ន្ធទន្លេដែលឆ្លងកាត់ច្រើនប្រទេស ទាមទារឱ្យមានការសហការពីបណ្តាប្រទេសដែលទន្លេបានហូរកាត់នោះ តាមរយៈកិច្ចសហការឱ្យមានប្រសិទ្ធភាពខ្ពស់ជាអន្តរជាតិ។

ផលប៉ះពាល់ដោយការប្រែប្រួលអាកាសធាតុ ដល់ទឹកលើដីនិងទឹកក្រោមដី នៅតែបន្តមាន។ លទ្ធភាពផ្គត់ផ្គង់ទឹកស្អាតដល់ប្រជាជននៅតាមតំបន់ជនបទ នៅមានបញ្ហាដោយកន្លែងដែលទាមទារឱ្យរាជរដ្ឋាភិបាលត្រូវខិតខំប្រឹងប្រែងបន្ថែមទៀត ក្នុងការដោះស្រាយ ជាពិសេសបញ្ហាពាក់ព័ន្ធនឹងការគ្រប់គ្រងថវិកាអភិវឌ្ឍន៍ និងការចូលរួម។ បញ្ហាគន្លឹះបន្ទាប់គឺប្រភពហិរញ្ញប្បទាននៅមានកម្រិត តម្រូវការហេដ្ឋារចនាសម្ព័ន្ធនៅតំបន់ជនបទនៅមានទំហំធំ។ ទន្ទឹមនឹងនេះ ទោះបីជាការធ្លាក់ចុះនូវគុណភាព

ទឹកពីប្រភពទឹកសាធារណៈនៅកម្ពុជា មិនទាន់មានកម្រិតធ្ងន់ធ្ងរក្តី ប៉ុន្តែកម្ពុជាមានបញ្ហាប្រឈមលើការខ្វះខាតហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងសំរាមនិងសំណល់រឹងនៅតំបនទីប្រជុំជន។ ទីកន្លែងទុកដាក់សំរាមចុងក្រោយ (ទីលានចាក់) និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ (ទឹកល្ងូ) នៅតំបន់ទីប្រជុំជនគឺជាកិច្ចការចាំបាច់ដែលរាជរដ្ឋាភិបាលត្រូវពង្រឹង និងអភិវឌ្ឍប្រកបដោយបរិយាប័ន្ន តម្លាភាព និងប្រសិទ្ធភាព។

## គោលនយោបាយឬយុទ្ធសាស្ត្រសំខាន់ៗ

ផែនការយុទ្ធសាស្ត្រជាតិស្តីពីទឹកនិងអនាម័យជនបទ ២០១១-២០១៥ បានតម្រង់ទិសសកម្មភាពនិងអនុវត្តន៍ ដើម្បីពង្រីកការតភ្ជាប់ ការផ្គត់ផ្គង់ទឹកស្អាត អណ្តូង និងស្រះ ការចែកចាយប្រព័ន្ធចម្រោះទឹក និងការដំឡើងធុងស្តុកទឹក។ ចំណុចដៅរបស់រាជរដ្ឋាភិបាលកម្ពុជានៅឆ្នាំ២០២៥ គឺសហគមន៍ជនបទទាំងអស់នឹងមានលទ្ធភាពទទួលបានទឹកស្អាតនិងអនាម័យ និងរស់នៅក្នុងបរិយាកាសស្អាតនិងអនាម័យ ដោយលុបបំបាត់ការបន្ទោបង់នៅតាមទីវាល ដែលមានផលប៉ះពាល់ចំពោះស្ត្រីនិងកុមារ។ ដើម្បីសម្រេចបានចំណុចដៅនេះ ក្រសួងអភិវឌ្ឍន៍ជនបទបានរៀបចំផែនការសកម្មភាពជាតិសម្រាប់ការផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យជនបទឆ្នាំ២០១៤-២០១៨ និងផែនការសកម្មភាពជាតិលើកទី២ សម្រាប់ការផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យជនបទក្នុងឆ្នាំ២០១៩-២០២៣ រួមជាមួយ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ២០១៩-២០២៣ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ដោយកិច្ចខិតខំប្រឹងប្រែងនិងការចូលរួមចំណែករបស់ភាគីពាក់ព័ន្ធទាំងអស់ ជាពិសេស ដៃគូអភិវឌ្ឍនៅគ្រប់កម្រិត។ លើសពីនេះទៀត កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍនានា ដូចជា ភ្នាក់ងារសហប្រតិបត្តិអន្តរជាតិជប៉ុន ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ ភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិរបស់អូស្ត្រាលី និងជំនួយអភិវឌ្ឍន៍ផ្លូវការរបស់ចិន នឹងជួយបង្កើនល្បឿនការពង្រីកការផ្គត់ផ្គង់ទឹកស្អាត ដែលមានសុវត្ថិភាព ស្អាត អាចជឿទុកចិត្តបាន និងមានតម្លៃសមរម្យ។ ទន្ទឹមនេះ សកម្មភាព និងវិធានការទប់ស្កាត់ការបំពុលទឹកពីការចោលសំរាមសំណល់រឹង ការបញ្ចេញសំណល់រាវ ទឹកកខ្វក់ពីតំបន់ទីប្រជុំជន និងការសាយភាយសារធាតុគីមីពុលដែលមានគ្រោះថ្នាក់ចេញពីប្រភពផលិតកម្មនិងអាជីវកម្មនានា ត្រូវបានកំណត់នៅក្នុងយុទ្ធសាស្ត្រជាតិបរិស្ថាននិងផែនការសកម្មភាព ២០១៦-២០២៣ ក្របខណ្ឌយុទ្ធសាស្ត្របរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ (ផែនទីឯកភាពការងារ) ២០១៩-២០២៣ និងទទួលបានការគាំទ្រពីបណ្តាដៃគូអភិវឌ្ឍ និងមានការចូលរួមសហការពីគ្រប់ភាគីពាក់ព័ន្ធ ជាពិសេសវិស័យឯកជន។

រាជរដ្ឋាភិបាលនឹងធ្វើសមាហរណកម្ម ការិយាល័យអភិវឌ្ឍន៍ជនបទ និង ការិយាល័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងដោយផ្ទាល់របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ហើយមុខងារមួយចំនួនពាក់ព័ន្ធនឹងការគ្រប់គ្រងនិងផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត និង ការគ្រប់គ្រងនិងការផ្តល់សេវាអនាម័យ នឹងត្រូវប្រគល់ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងគោលបំណងលើកកម្ពស់ប្រសិទ្ធភាពក្នុងការគ្រប់គ្រង ការគ្រប់គ្រងនិងការផ្តល់សេវាទឹកស្អាតនិងអនាម័យ ប្រកបដោយចីរភាព គុណភាព បរិយាប័ន្ន និងសមធម៌។

# គោលដៅទី៧៖ ធានាឱ្យទទួលបានថាមពលដែលមានលក្ខណៈបច្ចេកទេសទំនើប ប្រកបដោយចីរភាព អាចជឿជាក់បាន និងមានតម្លៃសមរម្យ សម្រាប់ប្រជាជនគ្រប់រូប

## វឌ្ឍនភាព

ក្នុងវិស័យថាមពលអគ្គិសនី រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់អាទិភាពខ្ពស់លើការចូលរួមចំណែករបស់ផ្នែកឯកជន ក្នុងការវិនិយោគដើម្បីអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធថាមពលអគ្គិសនី ទាំងក្នុងការផលិត ការបញ្ជូន និងការចែកចាយ។ ការគ្រប់គ្រងសេវាផ្គត់ផ្គង់អគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានដំណើរការស្របតាមការកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងនោះ ក្រសួងរ៉ែ និង ថាមពល មានសមត្ថកិច្ចទទួលខុសត្រូវក្នុងការរៀបចំនិងគ្រប់គ្រងគោលនយោបាយ យុទ្ធសាស្ត្រ ស្តង់ដា និងផែនការអភិវឌ្ឍន៍វិស័យថាមពលអគ្គិសនី ដើម្បីធានាដល់ការផ្តល់សេវាផ្គត់ផ្គង់អគ្គិសនី និងការប្រើប្រាស់អគ្គិសនី ប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព គុណភាព ចីរភាព និងមានតម្លាភាព។ ក្នុងបរិការណ៍នេះ ក្រសួងរ៉ែ និង ថាមពលបានកំណត់ឱ្យអ្នកផ្តល់សេវាផ្គត់ផ្គង់អគ្គិសនី ត្រូវអនុវត្តតាមស្តង់ដាបច្ចេកទេស ស្តង់ដាសុវត្ថិភាព និងលិខិតបទដ្ឋាននានា ដែលបង្កើតឡើងនិងផ្សព្វផ្សាយដោយរាជរដ្ឋាភិបាលកម្ពុជា ក្រសួងរ៉ែ និង ថាមពល និងអាជ្ញាធរអគ្គិសនីកម្ពុជា ដើម្បីធានាបាននូវការផ្តល់សេវាផ្គត់ផ្គង់អគ្គិសនីមួយដែលមានប្រសិទ្ធភាពនិងសុវត្ថិភាព។

ក្រសួងរ៉ែ និង ថាមពល បានខិតខំកាត់បន្ថយឱ្យបានជាអតិបរមា នូវផលប៉ះពាល់ដែលអាចកើតឡើងដោយសារគម្រោងអភិវឌ្ឍន៍ក្នុងវិស័យថាមពល ទៅលើបរិស្ថានធម្មជាតិនិងសង្គម តាមរយៈកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងបរិស្ថាន និងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ក្នុងការរិះរកវិធានការនិងដំណោះស្រាយនានា ដើម្បីកាត់បន្ថយនិងគ្រប់គ្រងផលប៉ះពាល់ទាំងនេះ។ ការអភិវឌ្ឍគម្រោងនានា តែងតែឈរលើមូលដ្ឋាននៃការថ្លឹងថ្លែង និងប្រៀបធៀបយ៉ាងល្អិតល្អន់និងត្រឹមត្រូវ រវាងផលប៉ះពាល់និងផលប្រយោជន៍ តាមរយៈ ការសិក្សាវាយតម្លៃលម្អិតប្រកបដោយវិជ្ជាជីវៈត្រឹមត្រូវ ដែលបានគិតគូរដល់ផលប្រយោជន៍ជាតិ និងផលប្រយោជន៍រួមរបស់ប្រជាជន។

នៅក្នុងឆ្នាំ២០១៩ បរិមាណប្រភពថាមពលអគ្គិសនីដែលបានផលិត និងនាំចូលពីប្រទេសជិតខាងនៅទូទាំងប្រទេស មានចំនួន១១ ៧៣៧,៩១លានគីឡូវ៉ាត់ម៉ោង បើប្រៀបធៀបទៅនឹងឆ្នាំ២០១៨ មានត្រឹមតែ៩ ៧៣៨,៧៧ លានគីឡូវ៉ាត់ម៉ោង គឺមានការកើនឡើងប្រមាណ២៣,៣៧%។ ទំហំនៃការអភិវឌ្ឍប្រភពថាមពលអគ្គិសនីបានកើនឡើងពី២ ០៩៧,៤៩មេហ្គាវ៉ាត់ ក្នុងឆ្នាំ២០១៦ ដល់៣ ០៦៩,២៦មេហ្គាវ៉ាត់ ក្នុងឆ្នាំ២០១៩ ដែលក្នុងនោះ ការផលិតក្នុងស្រុកកើនពី១ ៦៨០,៩៩ មេហ្គាវ៉ាត់ ដល់២ ៤៤២,៥១មេហ្គាវ៉ាត់ និងការនាំចូលពីប្រទេសជិតខាងបានកើនឡើងពី២២,០៦% មក២៥,២០% នៃថាមពលសរុប ដែលកំណើននេះស្របទៅនឹងកំណើននៃតម្រូវការប្រើប្រាស់អគ្គិសនីក្នុងប្រទេស។

ប្រព័ន្ធបណ្តាញជាតិបញ្ជូនអគ្គិសនី បានលាតសន្ធឹងពីខេត្តព្រះសីហនុ កាត់តាមរាជធានីភ្នំពេញ ទៅដល់ខេត្តស្ទឹងត្រែងភាគខាងកើត និងទៅដល់ខេត្តឧត្តរមានជ័យនៅភាគពាយព្យ ព្រមទាំងភ្ជាប់ពីខេត្តពោធិ៍សាត់ទៅខេត្តកោះកុង។ នៅចុងឆ្នាំ២០១៩នេះ ប្រព័ន្ធបណ្តាញជាតិមានលទ្ធភាពនាំចូលប្រភពអគ្គិសនីពីប្រទេសវៀតណាម ថៃ និងឡាវ ព្រមទាំងទទួលពីប្រភពថាមពលនានាដែលផលិតនៅក្នុងស្រុក ដើម្បីរួមបញ្ចូលគ្នាបញ្ជូនទៅផ្តល់ឱ្យដល់រាជធានី-ខេត្តចំនួន២១ តាមតម្រូវការប្រើប្រាស់តាមរយៈអនុស្ថានីយ ដែលស្ថិតនៅក្នុងរាជធានី-ខេត្តទាំងនោះ គឺរាជធានីភ្នំពេញ ខេត្តកណ្តាល តាកែវ កំពង់ស្ពឺ កំពត កែប ព្រះសីហនុ បន្ទាយមានជ័យ សៀមរាប បាត់ដំបង កំពង់ឆ្នាំង ព្រៃវែង ពោធិ៍សាត់ កោះកុង កំពង់ចាម ស្វាយរៀង ប៉ៃលិន ក្រចេះ ស្ទឹងត្រែង ព្រះវិហារ និងឧត្តរមានជ័យ។ ជាមួយគ្នានេះ បណ្តាញជាតិនេះ ក៏មានលទ្ធភាពបញ្ជូនអគ្គិសនីបន្តទៅជួយដល់ខេត្តជិតខាងចំនួន៤ទៀត គឺ ខេត្តត្បូងឃ្មុំ កំពង់ធំ រតនគិរី និងមណ្ឌលគិរី។ បណ្តាញជាតិនេះ ក៏មានលទ្ធភាពផ្គត់ផ្គង់អគ្គិសនីឱ្យដល់រោងចក្រនានា និងតំបន់ឧស្សាហកម្មធំៗ ដែលមានទីតាំងស្ថិតនៅក្នុងរង្វង់ដែនផ្គត់ផ្គង់របស់អនុស្ថានីយទាំង៣៦ ដែលស្ថិតនៅក្នុងខេត្តទាំង២១ នេះផងដែរ។ ជារួម ខ្សែបណ្តាញបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់ មានប្រវែង ២ ២៦៧គីឡូម៉ែត្រ និងអនុស្ថានីយចំនួន៣១កន្លែង ដែលគ្របដណ្តប់ដោយផ្ទាល់លើរាជធានី-ខេត្តទាំង២១ ខាងលើ។

ក្នុងឆ្នាំ២០១៩ នេះ ការបញ្ជូនប្រភពអគ្គិសនីពីអនុស្ថានីយបណ្តាញជាតិ ទៅកាន់តំបន់ជនបទនានានៅក្នុងប្រទេសកម្ពុជា មានខ្សែបណ្តាញតង់ស្យុងមធ្យមប្រវែង៣៥ ៦៧៣គីឡូម៉ែត្រ ដែលក្នុងនោះ ការវិនិយោគដោយអគ្គិសនីកម្ពុជាមានប្រវែង១៦ ៥៦៧គីឡូម៉ែត្រ និងវិនិយោគដោយសេវាករឯកជន មានប្រវែង១៩ ១០៦គីឡូម៉ែត្រ។ បន្ថែមពីលើនេះ អគ្គិសនីកម្ពុជាបាននិងកំពុងតែធ្វើការពង្រីកបណ្តាញបញ្ជូនរងចេញពីអនុស្ថានីយទៅកាន់តំបន់ជនបទនានា ក្នុងក្របខណ្ឌឥណទានពីប្រទេសចិន ធនាគារអភិវឌ្ឍន៍អាស៊ី និងពីដៃគូអភិវឌ្ឍផ្សេងទៀត ដើម្បីបញ្ជូនប្រភពអគ្គិសនីរបស់បណ្តាញជាតិ ឱ្យទៅដល់តំបន់នានាដែលមិនទាន់ទទួលបានប្រភពអគ្គិសនីពីបណ្តាញជាតិ។

ដើម្បីចូលរួមកាត់បន្ថយភាពក្រីក្រ និងបង្កើតសុខដុមនីយភាពនៃការរស់នៅរបស់ប្រជាជននៅតំបន់ជនបទ រាជរដ្ឋាភិបាលកម្ពុជាបានជំរុញការអភិវឌ្ឍអគ្គិសនីភាវូបនីយកម្មជនបទជាបន្តទៀត ដើម្បីសម្រេចឱ្យបាននូវគោលដៅជាយុទ្ធសាស្ត្រចំនួន២ គឺ **ទី១៖** នៅត្រឹមឆ្នាំ២០២០ ភូមិទាំងអស់ទូទាំងព្រះរាជាណាចក្រកម្ពុជា នឹងមានអគ្គិសនីប្រើប្រាស់ពីប្រភពអគ្គិសនីផ្សេងៗគ្នា និង **ទី២៖** នៅត្រឹមឆ្នាំ ២០៣០ យ៉ាងហោច៩០% នៃគ្រួសារទាំងអស់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា នឹងមានអគ្គិសនីដែលមានគុណភាពដូចអគ្គិសនីពីបណ្តាញជាតិប្រើប្រាស់។ នៅក្នុងឆ្នាំ២០១៩នេះ ការអភិវឌ្ឍបណ្តាញចែកចាយបានគ្របដណ្តប់លើភូមិចំនួន១៣ ១៣១ ឬ ៩២,៦៨% នៃចំនួនភូមិទូទាំងប្រទេស ហើយការភ្ជាប់ចរន្តពីបណ្តាញទៅឱ្យអ្នកប្រើប្រាស់ មានចំនួនប្រមាណ២,៦៨លានខ្នងផ្ទះ ឬប្រមាណ៧៤,៧៨% នៃចំនួនខ្នងផ្ទះសរុបទូទាំងប្រទេស ប្រមាណ៣,៥៧លាន។

ចាប់ពីខែមេសា ឆ្នាំ២០១៦ រហូតដល់ចុងឆ្នាំ២០១៩ នេះ អ្នកប្រើប្រាស់នៅតាមតំបន់នានាដែលទទួលបានអគ្គិសនីពីបណ្តាញជាតិចំនួន៣៥២អាជ្ញាបណ្ណ បានទទួលការបញ្ចុះថ្លៃអគ្គិសនីពី

៨០០រៀល មកត្រឹមថ្លៃ ៧៤០រៀល ក្នុងមួយគីឡូវ៉ាត់ម៉ោង រួមបញ្ចូលនឹងថ្លៃអនុគ្រោះផ្សេងៗទៀត។ ជាក់ស្តែង លំនៅដ្ឋានដែលប្រើប្រាស់ថាមពលមិនលើសពី១០គីឡូវ៉ាត់ម៉ោងក្នុងមួយខែ ទទួលបានការបញ្ចុះថ្លៃពី ៤៨០រៀល ក្នុងមួយគីឡូវ៉ាត់ម៉ោង មកត្រឹមថ្លៃ ៣៨០រៀល ក្នុងមួយគីឡូវ៉ាត់ម៉ោង និងសម្រាប់លំនៅដ្ឋានដែលប្រើប្រាស់ថាមពលមិនលើសពី ៥០គីឡូវ៉ាត់ម៉ោងក្នុងមួយខែ ត្រូវទទួលបានការផ្គត់ផ្គង់ថ្លៃ ៦១០រៀលក្នុងមួយគីឡូវ៉ាត់ម៉ោង។ ជាមួយគ្នានេះ ចំពោះការប្រើប្រាស់អគ្គិសនីសម្រាប់ដំណើរការមុខរបរកសិកម្មនៅពេលយប់ ចាប់ពីម៉ោង៩យប់ រហូតដល់ម៉ោង៧ព្រឹក ត្រូវទទួលបានការផ្គត់ផ្គង់តាមថ្លៃ ៤៨០រៀល ក្នុងមួយគីឡូវ៉ាត់ម៉ោង។ ការបញ្ចុះថ្លៃអគ្គិសនីនេះ គឺស្របទៅតាមផែនការយុទ្ធសាស្ត្រកាត់បន្ថយអត្រានិងគម្លាតថ្លៃលក់អគ្គិសនីនៅក្នុងកម្ពុជា ឆ្នាំ២០១៥-២០២០ ដែលរាជរដ្ឋាភិបាលបានអនុមតិ។ ចាប់តាំងពីឆ្នាំ២០១២ ដល់ចុងឆ្នាំ២០១៩ នេះ មូលនិធិអគ្គិសនីការូបនីយកម្មជនបទរបស់អគ្គិសនីកម្ពុជា បានផ្តល់នូវកញ្ចប់ថវិកាចំនួន ៣០៧លានដុល្លារអាមេរិក ដើម្បីជួយជំរុញការពង្រីកបណ្តាញផ្គត់ផ្គង់អគ្គិសនីទៅដល់តំបន់ជនបទដាច់ស្រយាល ដើម្បីជួយដល់គ្រួសារក្រីក្ររស់នៅក្នុងតំបន់ជនបទនិងតំបន់ជនបទដាច់ស្រយាល ឱ្យអាចមានលទ្ធភាពតភ្ជាប់ចរន្តពីបណ្តាញអគ្គិសនី និងមានចរន្តអគ្គិសនីប្រើប្រាស់ពីប្រព័ន្ធពន្លឺព្រះអាទិត្យ។ សមិទ្ធផលសំខាន់ៗក្នុងការងារនេះ មានដូចជា ផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រនៅជនបទ ចំនួន ៧៤ ៦៨៣គ្រួសារ ផ្តល់ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះចំនួន១០៧ ៦៤០ប្រព័ន្ធ និង ឧបត្ថម្ភទុនសម្រាប់ពង្រីក និងកែលម្អប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ ប្រវែង១១ ៤៨៤គីឡូម៉ែត្រ។

ជាទូទៅ កម្ពុជាគាំទ្រដល់ការអភិវឌ្ឍថាមពលកកើតឡើងវិញ ដូចជា ថាមពលពន្លឺព្រះអាទិត្យជាដើម។ កម្ពុជាក៏បានអនុមតិលើការវិនិយោគថាមពលពន្លឺព្រះអាទិត្យ ដែលមានសមត្ថភាពផលិតសរុបប្រមាណ៤១៥មេហ្គាវ៉ាត់ និងកំពុងពិចារណាសាងសង់រោងចក្រថាមពលខ្យល់ដែលមានសមត្ថភាពចំនួន៨០មេហ្គាវ៉ាត់ ផងដែរ។

### តារាង ៤.៧៖ វឌ្ឍនភាពគោលដៅទី៧ នៃ គ.អ.ច.ក.

| | ចំណុចដៅ/សូចនាករ | ឯកតា | ២០១៥ | ចំណុចដៅ គ.អ.ច.ក. | | | | ជាក់ស្តែង | | | | វឌ្ឍនភាព |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | |
| **៧.១** | **ត្រឹមឆ្នាំ២០៣០ ធានាការទទួលបានជាសាកលនូវសេវាថាមពលទំនើប អាចទុកចិត្តបាន និងតម្លៃសមរម្យ។** | | | | | | | | | | | **មិនមានទិន្នន័យ** |
| ៧.១.១ | សមាមាត្រនៃប្រជាជន ដែលទទួលបានអគ្គិសនីប្រើប្រាស់។ | លាននាក់ | ៧,៧៤ | ៩,២១ | ៩,៤៩ | ៩,៧៧ | ១០,០៦ | - | - | - | - | មិនមានទិន្នន័យ |
| ៧.១.២ | សមាមាត្រនៃប្រជាជនដែលពឹងផ្អែកជាចម្បងលើ បច្ចេកវិទ្យានិងឥន្ធនៈស្អាត។ | លាននាក់ | ៦,១៦ | ៦,០៧ | ៦,០៧ | ៦,០៨ | ៦,០៩ | - | - | - | - | មិនមានទិន្នន័យ |
| **៧.២** | **ត្រឹមឆ្នាំ២០៣០បង្កើនចំណែកនៃថាមពលកកើតឡើងវិញក្នុងថាមពលចម្រុះជាសាកល** | | | | | | | | | | | **មិនមានទិន្នន័យ** |
| ៧.២.១ | សមាមាត្រនៃថាមពលកកើតឡើងវិញក្នុងថាមពលដែលប្រើប្រាស់សរុប។ | Ktoe | ២ ៣៧៥ | ២ ៤៩៨ | ២ ៦២១ | ២ ៧៥០,១ | ២ ៨៨៥ | - | - | - | - | មិនមានទិន្នន័យ |
| **៧.៣** | **ត្រឹមឆ្នាំ២០៣០ បង្កើនទ្វេដងនៃអត្រាធ្វើឱ្យប្រសើរឡើងនូវប្រ សិទ្ធភាពថាមពលជាសកល** | | | | | | | | | | | **មិនមានទិន្នន័យ** |
| ៧.៣.១ | សមាមាត្រនៃថាមពលបឋម ធៀបនឹងផលិតផលក្នុងស្រុកសរុប។ | % នៃ ផ.ស.ស. | ០,៣៩ | ០,៣៨ | ០,៣៧ | ០,៣៧ | ០,៣៦ | - | - | - | - | មិនមានទិន្នន័យ |

*ប្រភព៖ ក្របខ័ណ្ឌ គ.អ.ច.ក. និង ក្រសួង ស្ថាប័នពាក់ព័ន្ធ*

ក្នុងតារាង៤.៧ ខាងលើ មិនបានបង្ហាញពីវឌ្ឍនភាពនៃការសម្រេចបានក្នុងគោលដៅទី៧ នៃគ.អ.ច.ក. ទេ ដោយសារសូចនាករទាំង៤ នេះ មានការលំបាកក្នុងការប្រមូលទិន្ន័យ និងមានភាព

ខុសគ្នាពីសូចនាករក្នុងវិស័យថាមពលអគ្គិសនី។ ទោះជាដូចនេះក្តី ក្រសួងរ៉ែ និង ថាមពល សូមបង្ហាញពីសមិទ្ធផលតាមរយៈសូចនាករមួយចំនួន ដូចបង្ហាញជូនក្នុងតារាង ៤.៧.១ ខាងក្រោម។

**តារាង ៤.៧.១៖ សូចនាករសមិទ្ធផលសំខាន់ៗ ក្នុងវិស័យរ៉ែ និង ថាមពល**

| ល.រ | សូចនាករ | ឯកតា | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ |
|---|---|---|---|---|---|---|
| ១ | សន្ទស្សន៍នៃភូមិដែលទទួលបានអគ្គិសនីដែលអាចទុកចិត្តបាន មានថ្លៃសមរម្យប្រើប្រាស់ | % | ៧៤,៤៣ | ៨១,៥៨ | ៨៦,៨៥ | ៩២,៦៨ |
| ២ | សន្ទស្សន៍នៃខ្នងផ្ទះរបស់ប្រជាពលរដ្ឋ ដែលទទួលបានសេវាផ្គត់ផ្គង់ថាមពលអគ្គិសនីទុកចិត្តបាន មានថ្លៃសមរម្យ | % | ៥៨,២៣ | ៦៨,៦៤ | ៧២,១៦ | ៧៤,៧៨ |
| ៣ | សន្ទស្សន៍នៃការប្រើប្រាស់ប្រភពថាមពលកកើតឡើងវិញ | % | ៣៧,១០ | ៣៤,២៨ | ៤៩,៤៦ | ៣៤,៨៤ |
| ៤ | សន្ទស្សន៍នៃថាមពលបឋម ធៀបនឹងផលិតផលក្នុងស្រុកសរុប | toe/thousand 2010 USD | ០,៣២ | ០,៣១ | ០,៣០ | ០,៣០ |

*ប្រភព៖ ក្រសួងរ៉ែ និង ថាមពល*

## បញ្ហាប្រឈម

ប្រទេសកម្ពុជានៅត្រូវការធនធានហិរញ្ញវត្ថុច្រើនថែមទៀត ដើម្បីវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ដូចជា ការផលិតថាមពលអគ្គិសនី ការសាងសង់បណ្តាញអគ្គិសនី ការសាងសង់អនុស្ថានីយ និងបច្ចេកវិទ្យាគ្រប់គ្រងថាមពល ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាពនៃការប្រើប្រាស់ថាមពលស្អាត ប្រសិទ្ធភាពថាមពល និងគុណភាពផ្គត់ផ្គង់គ្រប់គ្រាន់ ជាពិសេសសម្រាប់តំបន់ជនបទ។ ទោះបីជាមានវឌ្ឍនភាពយ៉ាងឆាប់រហ័សក្នុងការអភិវឌ្ឍថាមពលនៅកម្ពុជាក៏ដោយ ក៏នៅមានបញ្ហាមួយចំនួន ដូចជា ប្រភពថាមពលនិងការតភ្ជាប់បណ្តាញ កង្វះធនធានហិរញ្ញវត្ថុ និង ការប្រើប្រាស់នៅមានកម្រិតនៃសក្តានុពលប្រភពថាមពលកកើតឡើងវិញ។ លទ្ធភាពទទួលបានប្រេងឥន្ធនៈសម្រាប់ចម្អិនអាហារនៅតែជាបញ្ហាប្រឈមធ្វើឱ្យប្រជាជនជាច្រើននៅតែចម្អិនអាហារដោយប្រើប្រាស់អុស ដែលជាប្រភពនៃការបំពុលខ្យល់ក្នុងផ្ទះ ជាពិសេស ក្នុងចំណោមក្រុមគ្រួសារងាយរងគ្រោះនៅតំបន់ជនបទនិងតំបន់ដាច់ស្រយាល។

## គោលនយោបាយឬយុទ្ធសាស្ត្រសំខាន់ៗ

ដើម្បីឆ្ពោះទៅសម្រេចបាន តាមការកំណត់ នៃគោលដៅនានារបស់រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាគោលដៅរបស់ គ.អ.ច.ក. ក្រសួងរ៉ែ និង ថាមពល បានដាក់ចេញវិធានការគោលនយោបាយជាមូលដ្ឋានចំនួន៣ ដូចខាងក្រោម៖

**ទី១-បន្តការអភិវឌ្ឍ សមត្ថភាពផលិត បញ្ជូន ចែកចាយ និងការភ្ជាប់បណ្តាញអគ្គិសនី៖** នៅក្នុងការបន្តការអភិវឌ្ឍសមត្ថភាព ផលិត បញ្ជូន ចែកចាយ និងភ្ជាប់បណ្តាញអគ្គិសនី វិធានការគោលនយោបាយលម្អិតនានាត្រូវបានដាក់ចេញឱ្យអនុវត្ត គឺ៖

- បន្តអភិវឌ្ឍប្រភពថាមពល ក្នុងគោលដៅធ្វើឱ្យប្រភពអគ្គិសនីសម្រាប់ផ្គត់ផ្គង់មានគ្រប់គ្រាន់ និងកើនទាន់កំណើននៃសេចក្តីត្រូវការប្រើប្រាស់នៅក្នុងស្រុក ដោយលើកទឹកចិត្តឱ្យប្រើប្រាស់បច្ចេកវិទ្យាថ្មី និងថាមពលស្អាត ក្នុងលក្ខខណ្ឌរក្សាការបង្កើនប្រសិទ្ធភាពសេដ្ឋកិច្ច បន្ថយថ្លៃដើម មានចីរភាពសម្រាប់រយៈពេលយូរអង្វែង អាចបង្កើនស្ថិរភាពនៃការផ្គត់ផ្គង់បន្ថែម និងបង្កើនកម្រិតសន្តិសុខថាមពលនៅកម្ពុជា។
- បន្តអភិវឌ្ឍបណ្តាញបញ្ជូន ក្នុងគោលដៅធ្វើឱ្យបណ្តាញបញ្ជូននិងអនុស្ថានីយអាចគ្របដណ្តប់គ្រប់ទីកន្លែងទូទាំងប្រទេស អាចទទួលប្រភពអគ្គិសនីទាំងឡាយដែលអភិវឌ្ឍមករួមបញ្ចូលគ្នា និងអាចបញ្ជូនប្រភពនេះទៅឱ្យគ្រប់តំបន់ចែកចាយ និងគ្រប់អ្នកប្រើប្រាស់ធំៗទូទាំងប្រទេស ដែលធ្វើឱ្យប្រព័ន្ធនេះមានភាពប្រទាក់គ្នាទៅវិញទៅមក និងអាចបង្កើនស្ថិរភាពនៃការផ្គត់ផ្គង់ឱ្យអ្នកប្រើប្រាស់។
- បន្តអភិវឌ្ឍបណ្តាញចែកចាយ ក្នុងគោលដៅធ្វើឱ្យបណ្តាញចែកចាយទាំងនេះអាចភ្ជាប់ប្រភពអគ្គិសនីជាមួយប្រព័ន្ធបណ្តាញជាតិ អាចគ្របដណ្តប់ការចែកចាយឱ្យបានគ្រប់ភូមិទូទាំងប្រទេស ដើម្បីឱ្យអ្នកប្រើប្រាស់គ្រប់ប្រភេទ គ្រប់ទីកន្លែង មានលទ្ធភាពភ្ជាប់បណ្តាញអគ្គិសនីប្រើប្រាស់បានដោយងាយស្រួល និង ដើម្បីឱ្យអ្នកប្រើប្រាស់ទទួលបានសេវានិងថ្លៃដូចគ្នា។

**ទី២- កែលម្អការផ្តល់សេវាផ្គត់ផ្គង់អគ្គិសនី៖** នៅក្នុងការកែលម្អការផ្តល់សេវាផ្គត់ផ្គង់អគ្គិសនី មានមុខសញ្ញាចំនួន៤ ដែលវិស័យថាមពលអគ្គិសនីត្រូវយកចិត្តទុកដាក់ធ្វើការកែលម្អឡើងវិញ ដើម្បីអាចសម្រេចបានតាមគោលដៅដែលបានកំណត់ ក្នុងនោះវិធានការគោលនយោបាយលម្អិត តាមមុខសញ្ញានីមួយៗមាន ដូចខាងក្រោម៖

- **ការផ្តល់ភាពគ្រប់គ្រាន់៖** ផ្តល់ឱ្យបានគ្រប់គ្រាន់នូវការផ្គត់ផ្គង់ឱ្យដល់អ្នកប្រើប្រាស់ តាមរយៈការធ្វើឱ្យអ្នកប្រើប្រាស់គ្រប់ប្រភេទនៅគ្រប់តំបន់ទូទាំងប្រទេស អាចទទួលបានអានុភាពថាមពលទៅតាមទំហំដែលគេត្រូវការប្រើប្រាស់ ក្នុងរយៈពេល២៤ម៉ោង លើ២៤ម៉ោង។
- **ការផ្តល់គុណភាព សុវត្ថិភាព និងភាពអាចទុកចិត្តបាន៖** ផ្គត់ផ្គង់ថាមពលឱ្យដល់អ្នកប្រើប្រាស់នៅគ្រប់តំបន់នៅទូទាំងប្រទេស មានគុណភាព និងសុវត្ថិភាព ស្របតាមស្តង់ដាកំណត់ និងត្រូវខិតខំបន្ថយភាពអាក់អួលក្នុងការផ្គត់ផ្គង់ឱ្យថយចុះជាអតិបរមា ដើម្បីឱ្យអ្នកប្រើប្រាស់អាចទុកចិត្តបានលើការផ្គត់ផ្គង់នេះ។
- **ការផ្តល់ថ្លៃសមរម្យ៖** រៀបចំផែនការបន្ថយថ្លៃលក់អគ្គិសនីឱ្យបានសមស្របតាមប្រភេទអ្នកប្រើប្រាស់នីមួយៗ ដូចជា ឧស្សាហកម្ម ពាណិជ្ជកម្ម រដ្ឋបាល និងលំនៅដ្ឋាន និងធ្វើការអនុគ្រោះថ្លៃ

ដល់លំនៅដ្ឋានមានចំណូលទាប ដើម្បីឱ្យពួកគាត់មានលទ្ធភាពប្រើប្រាស់អគ្គិសនីក្នុងកម្រិតមួយសមស្រប ក្នុងលក្ខខណ្ឌរក្សាឱ្យបាននូវស្ថិរភាពនៃការធ្វើអាជីវកម្មនានាក្នុងវិស័យថាមពល។

- **ការផ្តល់ភាពយុត្តិធម៌ក្នុងការវាស់វែងនិងកត់ត្រា៖** ពិនិត្យមើលការវាស់វែងនិងកត់ត្រាបរិមាណថាមពលផ្គត់ផ្គង់ ឱ្យបានត្រឹមត្រូវ តាមរយៈបរិក្ខារប្រព័ន្ធនាឡិកាស្ទង់ដែលសុក្រឹតតាមស្តង់ដាកំណត់។ ក្នុងករណីមានការសង្ស័យ មិនទុកចិត្ត ត្រូវមានការពិនិត្យនិងវាយតម្លៃដោយអាជ្ញាកណ្តាលស្របទៅតាមបទដ្ឋានបច្ចេកទេស និងនីតិវិធីជាធរមាន។

**ទី៣- ពង្រឹងយន្តការគ្រប់គ្រងវិស័យថាមពលអគ្គិសនី៖** នៅក្នុងយន្តការពង្រឹងការគ្រប់គ្រងវិស័យថាមពលអគ្គិសនី មានមុខសញ្ញាចំនួន៤ ដែលវិស័យថាមពលអគ្គិសនីត្រូវយកចិត្តទុកដាក់ពង្រឹងឡើងវិញ ដើម្បីចូលរួមសម្រេចឱ្យបានតាមគោលដៅដែលបានកំណត់ ក្នុងនោះ វិធានការគោលនយោបាយលម្អិតតាមមុខសញ្ញានីមួយៗ មានដូចខាងក្រោម៖

- ពង្រឹងយន្តការស្ថាប័ន ក្នុងគោលដៅធ្វើឱ្យទំនាក់ទំនង តួនាទី ភារកិច្ច ឋានានុក្រម និងឯករាជ្យភាព រវាងស្ថាប័ន និងអង្គភាពក្នុងវិស័យថាមពល ប្រព្រឹត្តទៅដោយមានភាពច្បាស់លាស់ មានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងប្រកបដោយវិជ្ជាជីវៈ។
- ពង្រឹងយន្តការវិនិយោគ ក្នុងគោលដៅទាក់ទាញឱ្យមានការចូលរួមការវិនិយោគពីវិស័យឯកជនបន្ថែមលើលទ្ធភាពវិនិយោគរបស់សហគ្រាសរដ្ឋ ដើម្បីពង្រីកការអភិវឌ្ឍឱ្យស្របតាមផែនការមេដែលបានសិក្សាច្បាស់លាស់ និងបានឆ្លងកាត់ការពិភាក្សាដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ និង ធ្វើឱ្យការវិនិយោគនីមួយៗផ្តល់នូវប្រសិទ្ធភាពបច្ចេកទេសនិងសេដ្ឋកិច្ច ដើម្បីចូលរួមសម្រេចបានគោលដៅវិស័យថាមពលកម្ពុជា។
- ពង្រឹងយន្តការអាជីវកម្ម តាមរយៈ ការបើកទូលាយឱ្យមានការចូលរួមពីផ្នែកឯកជន ក្នុងការធ្វើអាជីវកម្មអគ្គិសនី។ ទន្ទឹមនឹងនេះ ក៏ត្រូវរក្សាការគ្រប់គ្រងរបស់អាជ្ញាធរអគ្គិសនីកម្ពុជាលើអាជីវកម្មក្នុងបណ្តាញជាតិ ដែលជាស្នូលនៃអាជីវកម្មទាំងមូល ដើម្បីឱ្យអគ្គិសនីកម្ពុជា អាចទ្រទ្រង់មូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ (ម.អ.ជ) ក្នុងការឧបត្ថម្ភធន ក្នុងគោលដៅកាត់បន្ថយគម្លាតថ្លៃ និងផ្ទេរទុន សម្រាប់ជួយអភិវឌ្ឍនៅតំបន់ដាច់ស្រយាល ដែលអាជីវកម្មពុំមានប្រសិទ្ធភាពសេដ្ឋកិច្ច។
- ពង្រឹងយន្តការពាក់ព័ន្ធផ្សេងទៀតក្នុងនោះ (១) កាត់បន្ថយផលប៉ះពាល់បរិស្ថានធម្មជាតិនិងសង្គមឱ្យបានជាអតិបរមា (២) ចូលរួមប្រើប្រាស់ប្រភពថាមពលស្អាតនិងចីរភាព ក្នុងកម្រិតដែលមិនប៉ះពាល់ដល់ប្រតិបត្តិការផ្គត់ផ្គង់និងដល់ផែនការបន្ថយថ្លៃ និង (៣) ចូលរួមក្នុងកិច្ចសហប្រតិបត្តិការវិស័យថាមពលក្នុងក្របខណ្ឌតំបន់ និងក្របខណ្ឌអន្តរជាតិ។

# គោលដៅទី៨៖ ធានាកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពនិងបរិយាប័ន្ន មានមុខរបរពេញលេញនិងផលិតភាព និងមានការងារសមរម្យសម្រាប់ប្រជាជនគ្រប់រូប

## វឌ្ឍនភាព

កម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងរង្វង់៧,៧% ជាមធ្យមក្នុង១ឆ្នាំ ក្នុងរយៈពេល ២ទសវត្សរ៍ចុងក្រោយ និងត្រូវបានចាត់ថ្នាក់ជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប នៅឆ្នាំ ២០១៥ ដោយផលិតផលក្នុងស្រុកសរុប (ផ.ស.ស.) សម្រាប់មនុស្សម្នាក់បានកើនឡើងដល់ប្រមាណ ១ ៥៦៣ដុល្លារអាមេរិក ក្នុងឆ្នាំ២០១៨ និងបន្តកើនឡើងដល់១ ៧០០ដុល្លារអាមេរិក ក្នុងឆ្នាំ២០១៩។ ផលលាភនៃកំណើនខ្ពស់នេះ គឺការបង្កើតការងារកាន់តែច្រើននិងមានគុណភាព សម្រាប់ប្រជាពលរដ្ឋ ដែលធ្វើឱ្យអត្រាចូលរួមក្នុងកម្លាំងពលកម្ម និងភាពមានការងារធ្វើមានកម្រិតខ្ពស់ ហើយអត្រាគ្មានការងារធ្វើមានកម្រិតទាប ក្នុងរង្វង់១% នៅក្នុងឆ្នាំ២០១៩។ ប្រជាជនដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្រជាតិ បានធ្លាក់ចុះប្រមាណ១% ក្នុង១ឆ្នាំ ពី ៣៥%ក្នុ ងឆ្នាំ២០០៥ មកនៅប្រមាណ១០% ក្នុងឆ្នាំ២០១៨។

ផ្អែកតាមក្រសួងទេសចរណ៍ ការចូលរួមចំណែកផ្ទាល់របស់វិស័យទេសចរណ៍ក្នុង ផ.ស.ស. សម្រេចបានប្រមាណ១២,១% ក្នុងឆ្នាំ២០១៩ ធៀបនឹងចំណុចដៅ១៣%។ នៅឆ្នាំ២០១៩ វិស័យទេសចរណ៍ បានរួមចំណែកផ្តល់ការងារចំនួន៦៣០ ០០០កន្លែង ឬ ៥,៨% នៃការងារសរុប ដែលនៅមានកម្រិតទាបជាងចំណុចដៅដែលបានកំណត់ ៧% (តារាង ៤.៨)។ នៅឆ្នាំ២០១៩ នេះ អត្រាកំណើននៃការចុះបញ្ជីពាណិជ្ជកម្ម ចុះបញ្ជីម៉ាក និងអត្រាកំណើននៃការចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ ស្ថិតលើគន្លងទៅសម្រេចបានចំណុចដៅដែលបានកំណត់ (តារាង ៤.៨)។

ផ្អែកលើកំណើនវិនិយោគក្នុងវិស័យសាធារណៈនិងឯកជន សេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករថានឹងបន្តកើនឡើង ដោយមានការផ្លាស់ប្តូររចនាសម្ព័ន្ធក្នុងការអភិវឌ្ឍឧស្សាហកម្មពី២៧,៧% ក្នុងឆ្នាំ ២០១៥ ទៅ៣២,៨% ក្នុងឆ្នាំ២០១៨ និងទៅ៣៨,២% ក្នុងឆ្នាំ២០២២។ ទន្ទឹមនឹងនេះ រចនាសម្ព័ន្ធទីផ្សារការងារក៏មានការផ្លាស់ប្តូរដែរ ដោយចំណែកការងារក្នុងវិស័យកសិកម្ម បានធ្លាក់ចុះមកនៅត្រឹម ៣៤,៦% ហើយចំណែករបស់វិស័យឧស្សាហកម្មបានកើនឡើងដល់២៨,១% និង វិស័យសេវាកម្មកើនឡើងដល់ ៣៧,២% ក្នុងឆ្នាំ២០១៩។ ការប្រែប្រួលរចនាសម្ព័ន្ធទីផ្សារការងារនេះ នឹងមាននិន្នាការបន្តទៅមុខស្របតាមរចនាសម្ព័ន្ធកំណើនសេដ្ឋកិច្ចជាតិ។ វិស័យហិរញ្ញវត្ថុនិងធនាគារ បានកើនឡើងគួរឱ្យកត់សម្គាល់ក្នុងទសវត្សរ៍ចុងក្រោយនេះ ហើយកំណើនឥណទានស្ថិតក្នុងកម្រិតអាចគ្រប់គ្រងបាន។ ក្នុងរយៈពេល ៣ឆ្នាំចុងក្រោយ វិស័យសំណង់និងអចលនទ្រព្យបានកើនឡើងយ៉ាងខ្លាំង។

## តារាង ៤.៨៖ វឌ្ឍនភាពគោលដៅទី៨ នៃ គ.អ.ច.ក.

| | ចំណុចដៅ/សូចនាករ | ឯកតា | ២០១៥ | ចំណុចដៅ គអ.ច.ក. | | | | ជាក់ស្តែង | | | | វឌ្ឍនភាព |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | |
| ៨.១ | **រក្សាស្ថិរភាព កំណើនសេដ្ឋកិច្ច ឱ្យស្របតាមលក្ខខណ្ឌជាតិ ជាពិសេសកំណើនផលិតផលក្នុងស្រុកសរុបប្រចាំឆ្នាំយ៉ាងតិច៧% នៅកម្ពុជា។** | | | | | | | | | | | **លើសចំណុចដៅ** |
| ៨.១.១ | អត្រាកំណើនផលិតផលក្នុងស្រុកប្រចាំឆ្នាំ។ | % | ៧,០ | ៧,០ | ៧,០ | ៧,០ | ៧,០ | ៦,៩ | ៧,០ | ៧,៥ | ៨,១ | លើសចំណុចដៅ |
| ៨.២ | **សម្រេចឱ្យបានផលិតភាពសេដ្ឋកិច្ចកម្រិតខ្ពស់ជាងមុន តាមរយៈ ការធ្វើពិពិធកម្ម ការបង្កើនកម្រិត បច្ចេកវិទ្យានិងនវានុវត្តន៍ ការផ្តោតការយកចិត្តទុកដាក់លើតម្លៃបន្ថែមខ្ពស់ និងវិស័យនានាដែលផ្តល់ការងារច្រើន។** | | | | | | | | | | | **ស្ថិតលើគន្លងទៅសម្រេចបាន** |
| ៨.២.២ | អត្រាកំណើននៃការចុះបញ្ជីពាណិជ្ជកម្ម ការចុះបញ្ជីម៉ាក ការចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ ដោយស្វ័យប្រវត្តិកម្ម។ | | | | | | | | | | | ស្ថិតលើគន្លងទៅសម្រេចបាន |
| ៨.២.២.១ | អត្រាកំណើននៃការចុះបញ្ជីពាណិជ្ជកម្ម ដោយស្វ័យប្រវត្តិកម្ម។ | % | ២២២,៣ | ១៦៥,៣ | ១៧៧,០៥ | ១៨១,៧៥ | ១៨៣,៣២ | ១៩៦ | ២២៥ | ២៩២ | ១៩៩ | ស្ថិតលើគន្លងទៅសម្រេចបាន |
| ៨.២.២.២ | អត្រាកំណើននៃការចុះបញ្ជីម៉ាកដោយស្វ័យប្រវត្តិកម្ម។ | % | ២២៥,៤៧ | ១៨៧,១៧ | ១៩០៦៣ | ១៨៩,៨៥ | ១៨៩,៥៩ | ២០៤ | ១៨៩ | ២០៦ | ២០៥ | ស្ថិតលើគន្លងទៅសម្រេចបាន |
| ៨.២.២.៣ | អត្រាកំណើននៃការចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ ដោយស្វ័យប្រវត្តិកម្ម។ | % | ២១០,០០ | ២២១,៩៣ | ១៩៩,៨៦ | ២១៧,១៣ | ២២២,៨៩ | ២២២ | ២២២ | ២០៦ | ២០៤ | ស្ថិតលើគន្លងទៅសម្រេចបាន |
| ៨.២.៣ | ការកែច្នៃឬអភិវឌ្ឍផលិតផល ទាំងទំនិញនិងសេវាកម្ម ឱ្យអស់សក្តានុពល តាមទស្សនាទាននៃការជំរុញចលនាភូមិ១ផលិតផល១។ | | | | | | | | | | | គ្មានទិន្នន័យ |
| ៨.២.៣.១ | ចំនួនប្រភេទផលិតផល ទំនិញ និងសេវាកម្ម ដែលបានកែច្នៃឬអភិវឌ្ឍនិងបានបញ្ចូលទៅក្នុងការជំរុញចលនាភូមិ១ផលិតផល១។ | ចំនួនប្រភេទផលិតផល | ៧៥ (២០១៨) | | | ៧៥ | ១២៥ | - | - | - | | គ្មានទិន្នន័យ |
| ៨.២.៣.២ | ចំនួនប្រភេទផលិតផលទំនិញនិងសេវា ដែលបានកែច្នៃឬអភិវឌ្ឍ ហើយត្រូវបានលើកម្ពស់ស្តង់ដាតាមទស្សនាទាន ភូមិ១ផលិតផល១ ពីកម្រិតទាបទៅខ្ពស់។ | ចំនួនប្រភេទផលិតផល | ៥០, (២០១៩) | | | | ៥០ | - | - | - | | គ្មានទិន្នន័យ |
| ៨.៣ | **លើកកម្ពស់គោលនយោបាយតម្រង់ទិសការអភិវឌ្ឍ ដែលគាំទ្រសកម្មភាពផលិតកម្ម ការបង្កើតការងារឱ្យបានសមរម្យ សហគ្រិនភាព ភាពកៃច្នៃនិងនវានុវត្តន៍ និងលើកទឹកចិត្តឱ្យមានការបង្កើត និងជំរុញកំណើនសហគ្រាសធុន មីក្រូ តូច និងមធ្យម តាមរយៈ ការទទួលបានសេវាហិរញ្ញវត្ថុ។** | | | | | | | | | | | **ស្ថិតលើគន្លងទៅសម្រេចបាន** |
| ៨.៣.១ | អត្រាកំណើននៃចំនួនក្រុមហ៊ុនចុះបញ្ជីជាសមាជិក សភាពាណិជ្ជកម្ម។ | % | - | - | - | - | ១៦,០ | ១១,០ | ៣៣,០ | ២១,០ | ១៥,០ | ស្ថិតលើគន្លងទៅសម្រេចបាន |
| ៨.៩ | **ត្រឹមឆ្នាំ២០៣០ បង្កើតនិងអនុវត្តគោលនយោបាយ សម្រាប់លើកកម្ពស់ទេសចរណ៍ប្រកបដោយចីរភាព ដែលបង្កើតការងារនិងលើកកម្ពស់វប្បធម៌និងផលិតផលក្នុងស្រុក។** | | | | | | | | | | | **ទាបជាងចំណុចដៅ** |
| ៨.៩.១ | អត្រានៃការរួមចំណែកដោយផ្ទាល់ពីវិស័យទេសចរណ៍ទៅក្នុងផលិតផលក្នុងស្រុកសរុប។ | % | ១២,៥ (២០១៦) | ១២,៥ | ១២,៨ | ១២,៨ | ១៣,០ | ១១,៩ | ១២,៣ | ១២,៧ | ១២,១ | ស្ថិតលើគន្លងទៅសម្រេចបាន |
| ៨.៩.២ | សមាមាត្រនៃចំនួនកម្មករនិយោជិត ធ្វើការក្នុងវិស័យទេសចរណ៍និងចំនួនអ្នកធ្វើការសរុប។ | % | ៧,០ (២០១៦) | ៧,០ | ៧,០ | ៧,០ | ៧,០ | ៤,៧ | ៥,២ | ៥,៧ | ៥,៨ | ទាបជាងចំណុចដៅ |
| ៨.a | **បង្កើនហិរញ្ញប្បទានសម្រាប់គាំទ្រពាណិជ្ជកម្មកម្ពុជា សម្រាប់ប្រទេសកម្ពុជា តាមរយៈ ក្របខ័ណ្ឌលើកកម្ពស់ការធ្វើសមាហរណកម្មសម្រាប់ជំនួយបច្ចេកទេសពាក់ព័ន្ធនឹងពាណិជ្ជកម្ម។** | | | | | | | | | | | **លើសចំណុចដៅ** |
| ៨.a.១ | ការប្តេជ្ញានិងផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់វិស័យពាណិជ្ជកម្ម។ | %នៃ ផ.ស.ស. | ០,០១៨ (២០១៦) | ០,០១៨ | ០,០១៧ | ០,០១៦ | ០,០១៥ | ០,០៣០ | ០,១០០ | ០,០៣០ | ០,០៤ | លើសចំណុចដៅ |

*ប្រភព៖ ក្របខ័ណ្ឌ គ.អ.ច.ក. និងក្រសួង ស្ថាប័ន*

## បញ្ហាប្រឈម

ទោះបីជាមានវឌ្ឍនភាព គួរឱ្យកត់សម្គាល់ដូចបានរៀបរាប់ខាងលើក្តី គោលដៅទី៨ នៃ គ.អ.ច.ក. បានជួបប្រទះនូវបញ្ហាប្រឈមមួយចំនួន ដែលតម្រូវឱ្យមានការដោះស្រាយ ដូចខាងក្រោម៖

១. កម្ពុជាត្រូវធ្វើពិពិធកម្មនិងពង្រឹកមូលដ្ឋានកម្មន្តសាល ដោយងាកចេញពីឧស្សាហកម្មដែលប្រើប្រាស់ពលកម្មច្រើន ជាពិសេសឧស្សាហកម្មកាត់ដេរ ទៅកាន់ឧស្សាហកម្មដែលត្រូវការជំនាញបច្ចេកវិទ្យាទំនើប និងមានតម្លៃបន្ថែមខ្ពស់។ ការងារនេះនឹងតម្រូវឱ្យមានការពង្រឹងធនធានមនុស្ស តាមរយៈ ការកែលម្អវិស័យអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ។

២. ទោះបីជាមានការកើនឡើងគួរឱ្យកត់សម្គាល់ ពាក់ព័ន្ធនឹងចំនួនក្រុមហ៊ុនដែលបានចុះបញ្ជីក៏ដោយ ក៏នៅមានសហគ្រាសធុនតូចនិងមធ្យមមួយចំនួន នៅមិនទាន់ចុះបញ្ជីផ្លូវការស្រប ពេលដែលក្រុមហ៊ុនដែលបានចុះបញ្ជីផ្លូវការជាច្រើន នៅមិនទាន់បានធ្វើបច្ចុប្បន្នភាពតាមពេលវេលាកំណត់នៅឡើយ។ ជាមួយគ្នានេះ កម្ពុជានៅមានកង្វះមន្ត្រីជំនាញ ពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា ដែលទាមទារសមត្ថភាពអាចចាត់វិធានការភ្លាមៗលើបញ្ហាទាំងនេះ។ម្យ៉ាងវិញទៀត នៅមានការខ្វះខាតឧបករណ៍សម្រាប់គាំទ្រដំណើរការនេះ។

៣. ការអភិវឌ្ឍឧស្សាហកម្មបានជួបបញ្ហាប្រឈមមួយចំនួន ដែលក្នុងនោះរួមមាន កង្វះខាតអគ្គិសនីប្រកបដោយគុណភាព កម្លាំងពលកម្មមានជំនាញ និងឡូជីស្ទីក។ *គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥* បានដាក់ចេញនូវវិធានការអន្តរាគមន៍ជាច្រើន និងវិធានការប្រមាណជាង១០០ ទៀត ប៉ុន្តែវឌ្ឍនភាពនៃការអនុវត្តវិធានការអន្តរាគមន៍ និងវិធានការទាំងនេះ នៅមានកម្រិតនៅឡើយ។

៤ ពាក់ព័ន្ធនឹងភូមិមួយផលិតផលមួយ មានបញ្ហាមួយចំនួនដែលត្រូវដោះស្រាយ រួមមាន(១) ការគាំទ្រនៅមានកម្រិតពីអាជ្ញាធរថ្នាក់ក្រោមជាតិ ក្នុងការលើកកម្ពស់ចលនាភូមិមួយផលិតផលមួយ (២) កិច្ចសហការនិងការសម្របសម្រួលនៅមានកម្រិត (៣) កង្វះធនធានមនុស្ស (៤) កង្វះថវិកាសម្រាប់លើកកម្ពស់ចលនាភូមិមួយផលិតផលមួយ (៥) កិច្ចសហការនៅមានកម្រិតរវាងសហគ្រាសធុនតូចនិងមធ្យម ជាមួយអគ្គលេខាធិការដ្ឋានភូមិមួយផលិតផលមួយ ក្នុងការលើកកម្ពស់ផលិតផលខ្មែរ និង (៦) នៅមានគម្លាតក្នុងភាពប្រកួតប្រជែងរវាងផលិតផលខ្មែរនិងផលិតផលបរទេស ក្នុងការដាក់តាំងពិព័រណ៍នៅតាមរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

៥ ក្នុងវិស័យទេសចរណ៍ ការអភិវឌ្ឍក្នុងវិស័យនេះបានជួបប្រទះការលំបាក ដោយសារកង្វះខាតហេដ្ឋារចនាសម្ព័ន្ធសម្រាប់គាំទ្រដល់កំណើននិងពិពិធកម្មក្នុងវិស័យ គុណភាពសេវា និងផលិតផល ដែលគាំទ្រដល់វិស័យនេះ នៅមានកម្រិត។

## គោលនយោបាយ ឬយុទ្ធសាស្ត្រសំខាន់ៗ

ទន្ទឹមនឹងការផ្តោតការយកចិត្តទុកដាក់ជាសំខាន់លើការជំរុញកំណើនសេដ្ឋកិច្ច រាជរដ្ឋាភិបាលកម្ពុជាក៏ត្រូវធានាឱ្យកំណើនសេដ្ឋកិច្ចនេះ ប្រកបដោយចីរភាព និងបរិយាប័ន្ន តាមរយៈការមានមុខរបរពេញលេញនិងការងារសមរម្យនិងមានផលិតភាពខ្ពស់ សម្រាប់ប្រជាជនគ្រប់រូប និងមានការគិតគូរដល់ការការពារបរិស្ថានផងដែរ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយ និងយុទ្ធសាស្ត្រសំខាន់ៗមួយចំនួន ដើម្បីជាផែនទីបង្ហាញផ្លូវ និងគាំទ្រដល់ការអនុវត្តសកម្មភាពរបស់ខ្លួន។ ជាក់ស្តែង *គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥* ត្រូវបានរៀបចំឡើងនិងអនុមតិកាលពីខែមីនា ឆ្នាំ២០១៥ ដើម្បីជាមគ្គុទេសក៍ជំរុញការអភិវឌ្ឍវិស័យ

ឧស្សាហកម្មនៅកម្ពុជា សំដៅរួមចំណែកដល់ការរក្សាកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយចីរភាព និងបរិយាប័ន្ន តាមរយៈ ការធ្វើពិពិធកម្មសេដ្ឋកិច្ច ការពង្រឹងភាពប្រកួតប្រជែង និងការលើកកម្ពស់ផលិតភាព។ ជាមួយគ្នានេះ ដើម្បីសម្រេចបានចំណុចដៅនៃ គ.អ.ច.ក. ពាក់ព័ន្ធនឹងមុខរបរពេញលេញ ផលិតភាព និងមានការងារសមរម្យសម្រាប់ប្រជាជនគ្រប់រូប រាជរដ្ឋាភិបាលកម្ពុជាក៏បានដាក់ចេញ និងពង្រឹងការអនុវត្ត*គោលនយោបាយជាតិស្តីពីមុខរបរនិងការងារ ឆ្នាំ២០១៥-២០២៥ កម្មវិធីការងារសមរម្យសម្រាប់ប្រទេសកម្ពុជា ឆ្នាំ២០១៩-២០២៣ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ឆ្នាំ២០១៩-២០២៣* ក្នុងគោលបំណងលើកកម្ពស់កម្រិតជីវភាពរស់នៅ សេចក្តីថ្លៃថ្នូររបស់ពលរដ្ឋគ្រប់រូប ភាពសុខដុមរមនាក្នុងសង្គម តាមរយៈ ការបង្កើតការងារសមរម្យ និងមានផលិតភាពខ្ពស់ ដល់ពលរដ្ឋកម្ពុជាគ្រប់រូប ប្រកបដោយសមធម៌ ។

លើសពីនេះទៀត គោលនយោបាយ "China Ready" ដែលបានដាក់ចេញកាលពីខែឧសភា ឆ្នាំ២០១៦ មានគោលដៅបង្កើននូវសក្តានុពលទេសចរណ៍ ក្នុងអំឡុងពេលដែលមានការកើនឡើងនូវចំនួនភ្ញៀវទេសចរជនជាតិចិន តាមរយៈ ការលើកទឹកចិត្តឱ្យអាជីវកម្មក្នុងវិស័យទេសចរណ៍នៅកម្ពុជា ឱ្យជួលបុគ្គលិកដែលចេះនិយាយភាសាចិនបកប្រែ បញ្ជីមុខម្ហូប និងខិត្តបណ្ណផ្សព្វផ្សាយនានាទៅជាភាសាចិន សម្រួលការទូទាត់ប្រាក់ជារូបិយបណ្ណយ៉ន់ចិន និង ផ្តល់នូវជម្រើសសេវាអេកូទេសចរណ៍ផ្សេងៗ។

នៅខែតុលា ឆ្នាំ២០១៩ រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតគម្រោងសាកល្បង "*មូលនិធិអភិវឌ្ឍន៍ជំនាញ*"ដើម្បីជំរុញការអភិវឌ្ឍជំនាញប្រកបដោយគុណភាព និងឆ្លើយតបទៅនឹងតម្រូវការទីផ្សារ ក៏ដូចជា ការអភិវឌ្ឍវិស័យឧស្សាហកម្មនៅកម្ពុជា តាមរយៈយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន ក្នុងគោលដៅទាក់ទាញការវិនិយោគដែលអាចផ្តល់តម្លៃបន្ថែមខ្ពស់ ទ្រទ្រង់ដល់ជវភាពនៃកំណើនសេដ្ឋកិច្ចរបស់កម្ពុជា ព្រមទាំងបន្តពង្រឹងការអនុវត្ត*គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ឆ្នាំ២០១៧-២០២៥* ឱ្យប្រកបដោយប្រសិទ្ធភាពខ្ពស់និងបង្កើនគុណភាពការងារ និងគុណភាពនៃជីវិត។

នៅឆ្នាំ២០១៨ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញអនុក្រឹត្យស្តីពីការលើកទឹកចិត្តផ្នែកពន្ធដារ សម្រាប់សហគ្រាសធុនតូចនិងមធ្យម ក្នុងវិស័យអាទិភាព ដើម្បីផ្តល់ការបន្ធូរបន្ថយ និងការអនុគ្រោះពន្ធមួយចំនួន សំដៅលើកកម្ពស់ដល់ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម។ បន្ថែមលើនេះ ក្នុងឆ្នាំ២០១៩ រាជរដ្ឋាភិបាលក៏បានដាក់ចេញនូវអនុក្រឹត្យស្តីពីការលើកទឹកចិត្តផ្នែកគយ សម្រាប់សហគ្រាសធុនតូចនិងមធ្យម ផងដែរ។ លើសពីនេះទៀត ក្នុងឆ្នាំ២០១៩ នេះដែរ រាជរដ្ឋាភិបាលកម្ពុជាដោយមានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសេនាធិការ ក៏បានបង្កើតធនាគារអភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យមកម្ពុជា មូលនិធិអភិវឌ្ឍន៍សហគ្រិនភាព និង មជ្ឈមណ្ឌលលើកកម្ពស់សហគ្រិនភាពដោយមាន "*សហគ្រិនខ្មែរ*" ជាប្រតិបត្តិករ។

នៅដើមឆ្នាំ២០១៩ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតក្រុមការងារបច្ចេកទេសសម្រាប់រៀបចំសេចក្តីព្រាង *ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ចឌីជីថលកម្ពុជា* ក្នុងគោលបំណងសិក្សា និងប្រមូលឯកសារនិងធាតុចូលសំខាន់ៗ ព្រមទាំងបំពេញតួនាទីគាំទ្រផ្សេងទៀត ក្នុងការរៀបចំសេចក្តីព្រាង *ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ចឌីជីថលកម្ពុជា* ស្របតាមគោលបំណងជំរុញ និងសម្រួលដល់ការរីកចម្រើនផ្នែកបច្ចេកវិទ្យានៅកម្ពុជា។ លើសពីនេះទៀត បន្ថែមពីលើការគិតគូរលើយេនឌ័រ និងការសម្របខ្លួននឹងការប្រែប្រួលអាកាសធាតុ រាជរដ្ឋាភិបាលកម្ពុជាក៏បានចាប់ផ្តើមបញ្ជ្រាបបច្ចេកវិទ្យា ទៅក្នុងគម្រោងអភិវឌ្ឍន៍ ដោតមានការគាំទ្រនិងផ្តល់ហិរញ្ញប្បទានពីដៃគូអភិវឌ្ឍ។

ថ្មីៗនេះ វិធានការកំណែទម្រង់មុខស្រួចជាកញ្ចប់ចំនួន១៧ រួមទាំងសកម្មភាពដែលបានរៀបរាប់ខាងលើ ត្រូវបានផ្តួចផ្តើមឡើងក្នុងវេទិការវាងរាជរដ្ឋាភិបាលនិងវិស័យឯកជន ក្នុងគោលបំណងពង្រឹងភាពប្រកួតប្រជែងរបស់កម្ពុជា តាមរយៈការកាត់បន្ថយថ្លៃឡូជីស្ទីក និងការទាក់ទាញវិនិយោគផ្ទាល់បរទេស ។

## គោលដៅទី៩៖ កសាងហេដ្ឋារចនាសម្ព័ន្ធដែលធន់នឹងការប្រែប្រួលអាកាសធាតុ លើកកម្ពស់ឧស្សាហូនីយកម្មប្រកបដោយចីរភាពនិង បរិយាប័ន្ន និងលើកកម្ពស់នវានុវត្តន៍

### វឌ្ឍនភាព

ចំណែក ផ.ស.ស. របស់វិស័យឧស្សាហកម្មបានកើនឡើងលើសចំណុចដៅ ដោយបានកើនឡើងពី២៧,៧% ក្នុងឆ្នាំ២០១៥ ដល់៣២,៨% ក្នុងឆ្នាំ២០១៨ និងដល់ប្រមាណ៣៣% ក្នុងឆ្នាំ២០១៩ ដែលមានកម្លាំងពលកម្មចូលរួមក្នុងវិស័យនេះចំនួន២៤,៩% នៃកម្លាំងពលកម្មសរុប ប៉ុន្តែមានកំណើនយឺតនៅក្នុងវិស័យកម្មន្តសាល ដោយបានកើនពី១៦% នៃ ផ.ស.ស. ក្នុងឆ្នាំ២០១៥ ទៅ១៦,៨% នៃ ផ.ស.ស. ក្នុងឆ្នាំ២០១៨ និងដល់រង្វង់ប្រមាណ១៧% ក្នុងឆ្នាំ២០១៩។ អនុវិស័យសំណង់បានក្លាយជាវិស័យដែលមានកំណើនលឿនជាងគេ។ ពាណិជ្ជកម្មអន្តរជាតិ សម្រេចបានដល់១២៤% នៃ ផ.ស.ស. នៅឆ្នាំ២០១៨ ហើយការរីកចម្រើនខ្លាំងក្នុងវិស័យអចលនទ្រព្យក្នុងរយៈពេល៤ឆ្នាំចុងក្រោយនេះ។ បរិមាណនៃការដឹកជញ្ជូនឆ្លងកាត់កំពង់ផែធំៗទាំង២នៅកម្ពុជា បានកើនឡើងគួរឱ្យកត់សម្គាល់ គឺលើសចំណុចដៅ ដោយកើនពី៦,២លានតោន ក្នុងឆ្នាំ២០១៥ ដល់៨,១លានតោន ក្នុងឆ្នាំ២០១៨ និង ដល់១០,៣២លានតោន ក្នុងឆ្នាំ២០១៩។ ចំនួនអ្នកដំណើរផ្លូវអាកាសអន្តរជាតិនិងក្នុងស្រុកបានកើនឡើងលើសចំណុចដៅដែលបានកំណត់។

ការវិនិយោគរបស់រាជរដ្ឋាភិបាលកម្ពុជា ដៃគូអភិវឌ្ឍ និងវិស័យឯកជន បានបន្តផ្តោតការយកចិត្តទុកដាក់លើហេដ្ឋារចនាសម្ព័ន្ធ ដូចជា ផ្លូវថ្នល់ ផ្លូវដែក ស្ពាន កំពង់ផែ ទូរគមនាគមន៍ ថាមពលវារីអគ្គិសនី រោងចក្រថាមពលពន្លឺព្រះអាទិត្យ បណ្តាញបញ្ជូនថាមពល និងប្រព័ន្ធធារាសាស្រ្ត។ ទាំងនេះ

បានចូលរួមចំណែកធ្វើឱ្យរោងចក្រកាត់ដេរផ្លាស់ប្តូរទីតាំងពីរាជធានីទៅកាន់តំបន់ជនបទ ដោយបានធ្វើឱ្យរោងចក្រទាំងនោះបានរំកិលខិតទៅជិតប្រភពកម្លាំងពលកម្ម និងបានកាត់បន្ថយបន្ទុកមួយចំនួនលើហេដ្ឋារចនាសម្ព័ន្ធទីក្រុង។

## តារាង ៤.៩៖ វឌ្ឍនភាពគោលដៅទី៩ នៃ គ.អ.ច.ក.

| | ចំណុចដៅ/សូចនាករ | ឯកតា | ២០១៥ | ចំណុចដៅ គ.អ.ច.ក. | | | | ជាក់ស្តែង | | | | វឌ្ឍនភាព |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | |
| **៩.១** | **អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដែលមានគុណភាព អាចជឿជាក់បាន ធន់នឹងការប្រែប្រួលអាកាសធាតុនិងចីរភាព រួមទាំង ហេដ្ឋារចនាសម្ព័ន្ធតំបន់និងឆ្លងកាត់ព្រំដែនប្រទេស ដើម្បីគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចនិងលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជន ជាមួយនឹងការផ្តោតការយកចិត្តទុកដាក់លើការទទួលបានដោយសមរម្យនិងសមធម៌សម្រាប់ប្រជាជនគ្រប់រូប។** | | | | | | | | | | | **លើសចំណុចដៅ** |
| ៩.១.១ | បរិមាណទំនិញឆ្លងកាត់ផែប្រចាំឆ្នាំ។ | ពាន់តោន | ៦ ២៥០ | ៦ ១៨០ | ៦ ៨៩៤ | ៧ ២៥៩ | ៧ ៦១៤ | ៦ ៤៥០ | ៧ ១២២ | ៨ ៩៥៨ | ១០ ៣២២ | លើសចំណុចដៅ |
| | កំពង់ផែស្វយ័តក្រុងព្រះសីហនុ | ពាន់តោន | ៣ ៨៥០ | ៤,០៩០ | ៤,២៩៤ | ៤,៥០៩ | ៤ ៧៣៤ | ៤ ០៤០ | ៤ ៣៦៤ | ៥ ៨២៣ | ៦ ៥៣៣ | លើសចំណុចដៅ |
| | កំពង់ផែស្វយ័តភ្នំពេញ | ពាន់តោន | ២ ៤០០ | ២ ០៩០ | ២ ៦០០ | ២ ៧៥០ | ២ ៨៨០ | ២ ៤១០ | ២ ៧៥៨ | ៣ ១៣៥ | ៣ ៧៨៩ | លើសចំណុចដៅ |
| ៩.១.២ | ចំនួនអ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក និងអន្តរជាតិ)។ | ពាន់ នាក់ | ៦ ០៤២ | ៦ ៦២៦ | ៧ ៣១០ | ៨ ០៦៩ | ៨ ៩១០ | ៦ ៦២៥ | ៨ ២៣៧ | ១០ ៥៥៣ | ១១ ៥៥៥ | លើសចំណុចដៅ |
| | អ្នកដំណើរក្នុងស្រុក | ពាន់ នាក់ | ៤៣៦ | ៤២៣ | ៤៣៣ | ៤៤២ | ៤៥២ | ៤២៤ | ៥៧២ | ១ ២១៥ | ១ ២៩៤ | លើសចំណុចដៅ |
| | អ្នកដំណើរអន្តរជាតិ | ពាន់ នាក់ | ៥ ៦០៦ | ៦ ២០១ | ៦ ៨៧៧ | ៧ ៦២៧ | ៨ ៤៥៨ | ៦ ២០១ | ៧ ៦៦៦ | ៩ ៣៣៨ | ១០ ២៦១ | លើសចំណុចដៅ |
| ៩.១.៣ | បរិមាណទំនិញដឹកជញ្ជូនតាមផ្លូវអាកាស(ក្នុងស្រុកនិងអន្តរជាតិ)។ | តោន | ៣៧ ១៥០ | ៤៦ ៤៦១ | ៥៣ ៩៨៨ | ៦២ ៧៥២ | ៧២ ៩៤៣ | ៤៦,៤៦ | ៦៤,៦៣ | ៧៤,៦៦ | ៧៨ ៩៥៩ | **ស្ថិតលើគន្លងទៅសម្រេចបាន** |
| | បរិមាណទំនិញដឹកជញ្ជូនក្នុងស្រុក | តោន | ២៥២ | ១៥៣ | ១៣២ | ១១៤ | ៩៩ | ១៥៣ | ៧៦ | ៨៣៤ | ១ ៣១៤ | លើសចំណុចដៅ |
| | បរិមាណទំនិញដឹកជញ្ជូនអន្តរជាតិ | តោន | ៣៦ ៨៩៨ | ៤៦ ៣០៨ | ៥៣ ៨៥៦ | ៦២ ៦៣៨ | ៧២ ៨៤៤ | ៤៦ ៣០៩ | ៦៣ ៨៧៣ | ៧៣ ៨២១ | ៧៧ ៦៤៥ | ស្ថិតលើគន្លងទៅសម្រេចបាន |
| **៩.២** | **លើកកម្ពស់ឧស្សាហូបនីយកម្មប្រកបដោយបរិយាបន្ននិងចីរភាព និងត្រឹមឆ្នាំ២០៣០ បង្កើនឱ្យបានច្រើន ឧស្សាហកម្មដែលរួមចំណែកបង្កើតការងារនិងផលិតផលក្នុងស្រុកសរុប ឱ្យស្របតាមកាលៈទេសៈជាតិ និងបង្កើនការរួមចំណែកនេះទ្វេដង នៅក្នុងបណ្តាប្រទេសដែលមានការអភិវឌ្ឍតិចតួច។** | | | | | | | | | | | **លើសចំណុចដៅ** |
| ៩.២.១ | សមាមាត្រនៃចំនួននិយោជិតកម្ពុជាក្នុងវិស័យសហគ្រាសកម្មន្តសាល ធៀបនឹងចំនួនការងារសរុបក្នុងប្រទេស។ | % | ១០,០០ | ១០,០០ | ១២,០០ | ១៣,០០ | ១៤,០០ | ២១,៩០ | ២៣,៨៣ | ២៣,៩២ | ២៤,៤ | លើសចំណុចដៅ |
| **៩.៥** | **លើកកម្ពស់ការស្រាវជ្រាវវិទ្យាសាស្ត្រ បង្កើនសមត្ថភាពបច្ចេកវិទ្យារបស់វិស័យឧស្សាហកម្មនៅគ្រប់ប្រទេស ជាពិសេស បណ្តាប្រទេសកំពុងអភិវឌ្ឍ ក្នុងនោះ ត្រឹមឆ្នាំ២០៣០ លើកទឹកចិត្ត នវានុវត្តន៍ និងបង្កើនចំនួននៃពលករ ស្រាវជ្រាវនិងការអភិវឌ្ឍ ក្នុងប្រជាជន១លាននាក់ និងការចំណាយដល់ការស្រាវជ្រាវនិងការអភិវឌ្ឍផ្នែកសាធារណៈនិងឯកជន។** | | | | | | | | | | | **ស្ថិតលើគន្លងទៅសម្រេចបាន** |
| ៩.៥.១ | សមាមាត្រនៃចំណាយលើការស្រាវជ្រាវនិងអភិវឌ្ឍធៀបនឹងផលិតផលក្នុងស្រុកសរុប។ | % | ០,១២ (២០១៦) | ០,១២ | ០,១៣ | ០,១៤ | ០,១៦ | ០,០៩ | ០,១១ | ០,១៣ | ០,១៥ | ស្ថិតលើគន្លងទៅសម្រេចបាន |
| **៩.a** | **សម្របសម្រួលឱ្យមានការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដែលមានភាពបន្សាំ និងប្រកបដោយចីរភាពនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍ តាមរយៈការលើកកម្ពស់ការគាំទ្រហិរញ្ញវត្ថុ បច្ចេកវិទ្យា និងបច្ចេកទេសដល់បណ្តាប្រទេសនៅទ្វីបអាហ្វ្រិក បណ្តាប្រទេសដែលមានការអភិវឌ្ឍតិចតួច បណ្តាប្រទេសដែលពុំមានព្រំដែនជាប់ សមុទ្រកំពុងអភិវឌ្ឍ និងបណ្តារដ្ឋដែនកោះ តូចៗកំពុងអភិវឌ្ឍ។** | | | | | | | | | | | **លើសចំណុចដៅ** |
| ៩.a.១ | ការគាំទ្រផ្លូវការសរុបពីអន្តរជាតិ(ជំនួយអភិវឌ្ឍន៍ ផ្លូវការ និងលំហូរផ្លូវការផ្សេងទៀត) ដល់ការកសាងនិងជួសជុលហេដ្ឋារចនាសម្ព័ន្ធ | % ផ.ស.ស. | ១,៦៥ (២០១៦) | ១,៦៥ | ១,៥៤ | ១,៤៤ | ១,៣៤ | ២,០០ | ២,៣១ | ១,៩៨ | ២,៥២ | លើសចំណុចដៅ |
| **៩.c** | **បង្កើនឱ្យបានច្រើននូវការទទួលបានសេវាទូរគមនាគមន៍បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន និងខិតខំប្រឹងប្រែង ផ្តល់នូវការទទួលបានឱ្យបានសមរម្យនិងជាសកលនូវ សេវាអ៊ិនធឺណិតនៅប្រទេសកម្ពុជា ត្រឹមឆ្នាំ២០២០** | | | | | | | | | | | **លើសចំណុចដៅ** |
| ៩.c.១ | សមាមាត្រនៃប្រជាជនប្រើប្រាស់បណ្តាញសេវាអ៊ិនធឺណិត | % | ៤៤,៦៦ | ៥២,៤៧ | ៥៥,៣៨ | ៥៦,១៥ | ៥៦,៩៩ | ៥២,៤៣ | ៦៩,២៤ | ៨២,៦៨ | ១០០,៣៨ | **លើសចំណុចដៅ** |
| | ១)អ៊ិនធឺណិតចល័ត | % | ៤៤,១១ | ៥១,៨៣ | ៥៤,៦៤ | ៥៥,១៩ | ៥៥,៧៤ | ៥១,២០ | ៦៧,៥៣ | ៨៣,៧៥ | ៩៩,០០ | លើសចំណុចដៅ |
| | ២)អ៊ិនធឺណិតអចល័ត | % | ០,៥៥ | ០,៦៤ | ០,៧៤ | ០,៩៦ | ១,២៥ | ០,៦៣ | ០,៨៧ | ០,៩៥ | ១,៣៨ | លើសចំណុចដៅ |

*ប្រភព៖ ក្របខ័ណ្ឌ គ.អ.ច.ក. និង ក្រសួង ស្ថាប័ន*

រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំ *គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥* ដោយមានវិធានការគន្លឹះ៤ ជាក់ស្តែង និងវិធានការគោលនយោបាយនិងផែនការសកម្មភាពចំនួន១១៩ សម្រាប់ដោះស្រាយបញ្ហាអាទិភាពនានាពីកម្រិតជំនាញដល់បច្ចេកវិទ្យា ដោយផ្តល់ហិរញ្ញវត្ថុនិងការសម្របសម្រួលសម្រាប់ពាណិជ្ជកម្មនិងការវិនិយោគ។ កម្ពុជាបានបន្តទទួលបាន

ការវិនិយោគផ្ទាល់ពីបរទេសយ៉ាងច្រើនក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ប៉ុន្តែភាគច្រើនផ្តោតលើការអភិវឌ្ឍវិស័យអចលនទ្រព្យ ទេសចរណ៍ និងឧស្សាហកម្ម ។

ការទទួលបាននូវសេវាអ៊ិនធឺណិត បានកើនឡើងគួរឱ្យកត់សម្គាល់ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ទាំងនៅទីក្រុងនិងតំបន់ជនបទ ជាពិសេស ការទទួលបាននូវសេវា 3G និង 4G ដោយសារហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ត្រូវបានពង្រីកយ៉ាងឆាប់រហ័ស។ រាជរដ្ឋាភិបាលកម្ពុជាបានជំរុញការវិនិយោគលើការតភ្ជាប់អ៊ិនធឺណិតតាមរយៈខ្សែកាប្លិ៍អុបទិកលើគោក ជាមួយប្រទេសជិតខាង និងការពង្រីកបណ្តាញក្នុងប្រទេស។ មកដល់ឆ្នាំ២០១៩ នេះ ខ្សែកាប្លិ៍អុបទិចលើគោកបានកើនឡើងដល់៤៤ ២៥១ គីឡូម៉ែត រួមជាមួយនឹងបណ្តាញខ្សែកាប្លិ៍អុបទិកក្រោមបាតសមុទ្រចំនួន២ ដែលមានប្រវែងសរុប ៦៤០គីឡូម៉ែត្រ ស្ថិតក្នុងដែនសមុទ្រកម្ពុជា។ ជាមួយគ្នានេះ ការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ក៏មានសន្ទុះកើនឡើងគួរឱ្យកត់សម្គាល់ផងដែរ។ ចំនួនអ្នកជាវសេវាទូរស័ព្ទចល័ត បានកើនឡើងពី១៩លាន ស៊ីមកាត ក្នុងឆ្នាំ២០១២ ដល់២១លានស៊ីមកាត នៅឆ្នាំ២០១៩ ស្មើនឹង ១៣៣,០៧ % នៃចំនួនប្រជាពលរដ្ឋ។

## បញ្ហាប្រឈម

កម្ពុជានៅតែប្រឈមមុខនឹងការចំណាយខ្ពស់លើការដឹកជញ្ជូន ការសម្របសម្រួលស្ថាប័ននៅខ្សោយ កង្វះខាតហេដ្ឋារចនាសម្ព័ន្ធដែលមានគុណភាព ដែលធ្វើឱ្យប៉ះពាល់ដល់លទ្ធភាពទៅដល់ទីផ្សាររបស់អ្នកផលិត ជម្រើសនៃទីតាំងរបស់សហគ្រាសនៅទូទាំងប្រទេស ការអភិវឌ្ឍជំនាញនិងបច្ចេកវិទ្យា រួមទាំង បច្ចេកវិទ្យាឌីជីថល នៅមានកម្រិត ដែលអាចប៉ះពាល់ដល់កំណើននៃអនុវិស័យកម្មន្តសាល និងការអនុវត្ត*គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥*។

## គោលនយោបាយឬយុទ្ធសាស្ត្រសំខាន់ៗ

វិធានការកំណែទម្រង់ចំនួន១៧ ដែលសំដៅលើ ការបង្កើនសមត្ថភាពប្រកួតប្រជែងរបស់កម្ពុជា ការលើកកម្ពស់សគ្រាសធុនតូចនិងមធ្យម និង ការទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស ត្រូវបានធ្វើឡើងដោយសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី កាលពីថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៩ នៅក្នុងវេទិការវាងរាជរដ្ឋាភិបាល-វិស័យឯកជន។ វិធានការទាំងនោះមានដូចជា ការកាត់បន្ថយចំណាយលើភស្តុភាររហូតដល់ការកាត់បន្ថយថ្លៃអគ្គិសនី ការធ្វើឱ្យប្រសើរឡើងនូវច្បាប់ការងារ ការបង្កើនលទ្ធភាពទទួលបានហិរញ្ញប្បទានរបស់សហគ្រាសធុនតូចនិងមធ្យម និងការរៀបចំសេចក្តីព្រាងច្បាប់ថ្មីស្តីពីវិនិយោគ និងសេចក្តីព្រាងច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេស។

ជាមួយគ្នានេះ ក្នុងការកែទម្រង់សហគ្រាសធុនតូចនិងមធ្យម ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បានរៀបចំសេចក្តីព្រាងផែនការអភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យម រយៈពេល ៥ឆ្នាំ ដែលនឹងដាក់ឱ្យប្រើប្រាស់នៅឆ្នាំ២០២០។ ផែនការនេះនឹងផ្តល់នូវការបន្សុីគ្នាចំពោះការងារបច្ចុប្បន្ន ដែលភ្ជាប់ទៅនឹង *គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥* និងកិច្ចខិតខំប្រឹងប្រែងដោយស្ថាប័នវិស័យរបស់អាស៊ាន ក្នុងការគាំទ្រសហគ្រាសធុនតូចនិងមធ្យមនៅក្នុងតំបន់ តាមរយៈ ការអនុវត្តផែនការសកម្មភាពយុទ្ធសាស្ត្រស្តីពី ការអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យម ២០១៦-២០២៥ ដើម្បីលើកកម្ពស់សហគ្រាសធុនតូចនិងមធ្យមក្នុងតំបន់ និងដើម្បីសម្រេចឱ្យបានសហគ្រាសធុនតូចនិងមធ្យមដែលមាននវានុវត្តន៍ និងភាពប្រកួតប្រជែង។

មូលនិធិអភិវឌ្ឍន៍ជំនាញ ត្រូវបានបង្កើតឡើងនៅឆ្នាំ២០១៨ ដោយផ្តោតលើវិស័យអាទិភាព ចំនួន ៥ ដូចជា កម្មន្តសាល សំណង់ បច្ចេកវិទ្យាទូរគមនាគមន៍និងព័ត៌មាន អេឡិចត្រូនិក និងទេសចរណ៍ ដែលមានគោលបំណងដើម្បីដោះស្រាយគម្លាតជំនាញនៅក្នុងសេដ្ឋកិច្ចកម្ពុជា។ ក្នុងឆ្នាំដដែល រាជរដ្ឋាភិបាលក៏បានចេញផ្សាយនូវអនុក្រឹត្យមួយ ស្តីពីការលើកលែងការបង់ពន្ធដល់សហគ្រាសធុនតូចនិងមធ្យម សម្រាប់រយៈពេល៥ឆ្នាំ។ លើសពីនេះទៀត ធនាគារអភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យម និងមូលនិធិអភិវឌ្ឍន៍សហគ្រិន និងមជ្ឈមណ្ឌលលើកកម្ពស់ភាពជាសហគ្រិន ត្រូវបានបង្កើតឡើងដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលចាប់ផ្តើមដំណើរការនៅក្នុងឆ្នាំ២០១៩។

នៅចុងឆ្នាំ២០១៧ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានបង្កើតអង្គភាពភាពជាដៃគូរវាងរដ្ឋនិងឯកជន ក្នុងគោលបំណងជំរុញគម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន ដែលត្រូវបានផ្តល់ហិរញ្ញប្បទានដោយក្រុមហ៊ុនឯកជន។ កិច្ចសន្យាអាចនឹងត្រូវបានធ្វើឡើងរវាងរាជរដ្ឋាភិបាល (ដូចជាក្រសួងពាក់ព័ន្ធ) ជាមួយដៃគូឯកជន ក្នុងការរៀបចំ ការកសាង ប្រតិបត្តិការ និងការថែទាំគម្រោងវិនិយោគ រួមទាំងគម្រោងសាងសង់ ប្រតិបត្តិការ និងផ្ទេរ និង គម្រោងសម្បទាន ដែលមានតម្លៃច្រើនជាង១០លានដុល្លារអាមេរិក សម្រាប់ប្រសិទ្ធភាពនៃការគ្រប់គ្រង។

ជាមួយនឹង*គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥* និងយុទ្ធសាស្ត្រគាំទ្រផ្សេងៗទៀត រាជរដ្ឋាភិបាលកម្ពុជាបានសហការជាមួយដៃគូអភិវឌ្ឍនានា ដើម្បីអនុវត្តកម្មវិធីនិងគម្រោងនានា ជាពិសេស កម្មវិធីភាពជាដៃគូ ២០១៨-២០២៣ របស់អង្គការសហប្រជាជាតិអភិវឌ្ឍវិស័យឧស្សាហកម្ម កិច្ចសហប្រតិបត្តិការជាមួយភ្នាក់ងារកម្មសិទ្ធិបញ្ញា គណៈកម្មការសម្របសម្រួលអាស៊ានស្តីពីស្តង់ដានិងគុណភាព និងគណៈកម្មការស្តីពីវិទ្យាសាស្ត្រ បច្ចេកទេស និងនវានុវត្តន៍របស់អាស៊ាន ជាដើម។

# គោលដៅទី១០៖ កាត់បន្ថយវិសមភាពនៅក្នុងប្រទេសនិងក្នុងចំណោមបណ្តាប្រទេសនានា

## វឌ្ឍនភាព

ការចុះបញ្ជីដីធ្លីមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់។ គិតមកដល់ត្រឹមដំណាច់ឆ្នាំ២០១៩ រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានចុះបញ្ជីដី និងចេញបណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋបានចំនួន៥ ៥៨៤ ០៣៤បណ្ណ ស្មើ៧៩,៧៧% នៃផែនការចំនួន ៧លានក្បាល ក្នុងនោះការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធសម្រេចបាន៤ ៩៦៦ ៥៩១បណ្ណ និងចែកបណ្ណជូនប្រជាពលរដ្ឋចំនួន៤ ៦១៨ ៧៧១បណ្ណ ហើយការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំសម្រេចបាន ៦១៧ ៤៤៣បណ្ណ។ ជាមួយគ្នានេះ ការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច សម្រេចបានចំនួន ៣០សហគមន៍ ស្មើ៨១៩បណ្ណ ទំហំ២៨ ៥២២,៥២ហិកតា សម្រាប់៣ ០៣៣គ្រួសារ។

រាជរដ្ឋាភិបាលកម្ពុជាបានអនុមតិនូវគោលនយោបាយជាតិស្តីពីលំនៅដ្ឋាន និងគោលនយោបាយស្តីពីការលើកទឹកចិត្ត និងការបង្កើតកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍលំនៅដ្ឋានដែលមានតម្លៃសមរម្យ។ បច្ចុប្បន្ន មានគម្រោងអភិវឌ្ឍលំនៅដ្ឋានតម្លៃសមរម្យ ចំនួន៥ គម្រោង កំពុងដំណើរការសាងសង់ ដែលមានលំនៅដ្ឋានចំនួន៨ ៣៣១ខ្នង និង៧ ២៥៦ខ្នង ចំណែកឯកជន ក្នុងនោះ ២ទីតាំង ស្ថិតនៅរាជធានីភ្នំពេញ ២ទីតាំង ស្ថិតនៅខេត្តកណ្តាល និង ១ទីតាំងស្ថិតនៅខេត្តបន្ទាយមានជ័យ។ ជាមួយគ្នានេះ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានបង្កើតប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យាសម្រាប់គ្រប់គ្រងទិន្នន័យសំណង់ អចលនទ្រព្យ ដោយភ្ជាប់ទៅនឹងប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS) នៃប្រព័ន្ធផែនទីហ្គូហ្គល (Google Map)។

រាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់ចំពោះគ្រួសារយោធិន និងនគរបាល គ្រួសារយុទ្ធជនពលីនិងអតីតយុទ្ធជនពិការ ដែលកំពុងរស់នៅក្នុងភាពក្រីក្រគ្មានដីនិងផ្ទះសម្បែង តាមបណ្តោយព្រំដែន និងប្រជាពលរដ្ឋក្រីក្រដែលខ្វះដី និងត្រូវការដីពិតប្រាកដ តាមរយៈកម្មវិធីសម្បទានដីសង្គមកិច្ច ដែលគិតពីពេលចាប់ផ្តើមរហូតដល់ខែវិច្ឆិកា ឆ្នាំ២០១៩ រាជរដ្ឋាភិបាលកម្ពុជាបានបែងចែកដីសរុបចំនួន១ ៣៤៤ ៨៨៩ហិកតា ជូន៤៨០ ៨៦២គ្រួសារ និងចែកផ្ទះបានចំនួន៧ ២៣៦ខ្នង។

នៅក្នុងផ្នែកទំនាក់ទំនងពាណិជ្ជកម្ម រាជរដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងប្រែងធ្វើពាណិជ្ជកម្មជាលក្ខណៈអន្តរជាតិ ដែលជាកត្តាជំរុញដ៏សំខាន់មួយក្នុងការកាត់បន្ថយវិសមភាពក្នុងចំណោមប្រទេសនានា។ អត្រាកិច្ចព្រមព្រៀងពាណិជ្ជកម្មមានការកើនឡើង ដែលក្នុងនោះចំនួនកិច្ចព្រមព្រៀងពាណិជ្ជកម្មមានចំនួន៧៦ ក្នុងឆ្នាំ២០១៦ និងមានចំនួន២០៩ ក្នុងឆ្នាំ២០១៩ ជាមួយអត្រាកំណើនជាមធ្យម ២១%។

## តារាង ៤.១០÷ វឌ្ឍនភាពគោលដៅទី១០ នៃ គ.អ.ច.ក.

| | ចំណុចដៅ/សូចនាករ | ឯកតា | ២០១៥ | ចំណុចដៅ គអ.ច.ក. | | | | ជាក់ស្តែង | | | | វឌ្ឍនភាព |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | |
| ១០.១ | ត្រឹមឆ្នាំ២០៣០សម្រេចឱ្យបានចំណូលរបស់ប្រជាជនចំនួន ៤០% នៃប្រជាជនទាំងអស់ ដែលមានចំណូលទាបជាងគេនូវកំណើនជាបន្តបន្ទាប់និងដោយចីរភាពក្នុងអត្រាខ្ពស់ជាងកម្រិតមធ្យមរបស់ជាតិ។ | | | | | | | | | | | គ្មានទិន្នន័យ |
| ១០.១.១ | អត្រានៃការចំណាយ/ការប្រើប្រាស់ ឬចំណូលរបស់គ្រួសារសម្រាប់មនុស្សម្នាក់ ក្នុងចំណោមប្រជាជន៤០ភាគរយដែលមានចំណូលទាបជាងគេ ធៀបនឹងការចំណាយ/ការប្រើប្រាស់ ឬចំណូលមធ្យមរបស់ប្រជាជន។ | % | ៥,២០ (២០១៦) | - | - | - | | - | - | - | | គ្មានទិន្នន័យ |
| ១០.២ | ត្រឹមឆ្នាំ២០៣០ ផ្តល់ភាពអង់អាចនិងជំរុញបរិយាបន្នសង្គម សេដ្ឋកិច្ច និងនយោបាយ សម្រាប់ប្រជាជនគ្រប់រូប ដោយមិនគិតពីស្ថានភាព អាយុ ភេទ ការបាត់បង់សមត្ថភាពពលកម្ម ពូជសាសន៍ ជនជាតិភាគតិច ជនជាតិដើម សាសនា សេដ្ឋកិច្ច ឬស្ថានភាពផ្សេងទៀត។ | | | | | | | | | | | គ្មានទិន្នន័យ |
| ១០.២.១ | សមាមាត្រនៃប្រជាជនដែលរស់នៅក្រោម ៥០ភាគរយ នៃមេដ្យានចំណូល តាម អាយុ ភេទ និងជនពិការ | % | ៥៣,១ | ៥១,៥ | | | | - | - | - | | គ្មានទិន្នន័យ |
| ១០.៤ | ឯកភាពលើគោលនយោបាយនានា ជាពិសេស គោលនយោបាយស្តីពីសារពើពន្ធ ប្រាក់បៀវត្សរ៍ ការគាំពារសង្គម និង សម្រេចឱ្យបានជាបន្តបន្ទាប់សមភាពច្រើនជាងមុន។ | | | | | | | | | | | ស្ថិតលើគន្លងទៅសម្រេចបាន |
| ១០.៤.១ | និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ។ | នាក់ | ៥២ ២៧៤ (២០១៦) | ៥២ ២៧៤ | ៥៤ ០៩២ | ៥៥ ៧០២ | ៥៧ ២៨២ | ៤៨ ៣៩២ | ៥៣ ៧៨៥ | ៥៦ ៣៥៣ | ៥៧ ៣០២ | ស្ថិតលើគន្លងទៅសម្រេចបាន |
| ១០.a | អនុវត្តគោលការណ៍និងប្រព្រឹត្តកម្មពិសេសនិងដោយឡែកសម្រាប់បណ្តាប្រទេសកំពុងអភិវឌ្ឍជាពិសេសបណ្តាប្រទេសដែលមានការអភិវឌ្ឍតិចតួចឱ្យស្របតាមកិច្ចព្រមព្រៀងពាណិជ្ជកម្មពិភពលោក។ | | | | | | | | | | | ទាបជាងចំណុចដៅ |
| ១០.a.១ | អត្រាកំណើននៃចំនួនកិច្ចព្រមព្រៀងពាណិជ្ជកម្មជាមួយអន្តរជាតិ។ | % | ២០ | ២១ | ១៩ | ២១ | ២២ | ៣៨ | ២៥ | ២២ | ១៩ | ទាបជាងចំណុចដៅ |
| ១០.b | លើកទឹកចិត្តចំពោះជំនួយអភិវឌ្ឍផ្លូវការ និងលំហូរហិរញ្ញវត្ថុ រួមទាំងការវិនិយោគផ្ទាល់ពីបរទេស ដល់បណ្តារដ្ឋដែលមានតម្រូវការជាងគេ ជាពិសេសបណ្តាប្រទេសដែលមានការអភិវឌ្ឍតិចតួច បណ្តាប្រទេសនៅក្នុងទ្វីបអាហ្វ្រិក បណ្តារដ្ឋដែនកោះតូចៗដែលកំពុងអភិវឌ្ឍនិងបណ្តាប្រទេសដែលពុំមានព្រំប្រទល់ជាប់សមុទ្រកំពុងអភិវឌ្ឍឱ្យស្របតាម ផែនការនិងកម្មវិធីជាតិនានារបស់ប្រទេសនីមួយៗ | | | | | | | | | | | លើសចំណុចដៅ |
| ១០.b.១ | បរិមាណហិរញ្ញប្បទានសហប្រតិបត្តិការសរុប សម្រាប់កម្ពុជា។ | លានដុល្លារ | ១ ៤២៥,០ | ១ ៤២៥,០ | ១ ៤២៥,០ | ១ ៤២៥,០ | ១ ៤២៥,០ | ១ ២៨៧,១ | ១ ៥២២,២ | ១ ៤៩០,៦ | ១ ៨៨៧,៩ | លើសចំណុចដៅ |

*ប្រភព÷ ក្របខ័ណ្ឌ គ.អ.ច.ក. និង ក្រសួង ស្ថាប័ន*

## បញ្ហាប្រឈម

ពុំមានការសិក្សាទូលំទូលាយអំពីមូលហេតុនិងផលប៉ះពាល់នៃវិសមភាពនៅកម្ពុជាទេ។ ការសិក្សារបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងធនាគារពិភពលោកបានបង្ហាញថា មានគម្លាតពីការប្រើប្រាស់យ៉ាងធំរវាងគ្រួសារនៅតាមតំបន់ទីប្រជុំជននិងតំបន់ជនបទ។ វិសមភាព ជាពិសេស គម្លាតនៃការអភិវឌ្ឍរវាងតំបន់ទីប្រជុំជននិងតំបន់ជនបទនៅក្នុងប្រទេស បាននាំឱ្យមានលំហូរដ៏ធំនៃការធ្វើចំណាកស្រុកពលកម្មឆ្លងដែននិងឆ្លងកាត់ព្រំដែន។ ចំនួនពលករចំណាកស្រុកក្នុងប្រទេសមានប្រហែល១លាននាក់ ហើយចំនួនពលករចំណាកស្រុកឆ្លងកាត់ព្រំដែនបានកើនឡើងដល់ជាង១លាននាក់។ រាជរដ្ឋាភិបាលកម្ពុជាក៏បានទទួលស្គាល់ផងដែរពីសារសំខាន់នៃការគ្រប់គ្រងលំហូរប្រជាជនឱ្យបានល្អប្រសើរ និងដំណើរការនគរូបនីយកម្ម។

ការគ្របដណ្តប់នៃសេវាសង្គមនៅមានកម្រិតនៅឡើយ។ រវាងអត្តសញ្ញាណបណ្ណនិងបណ្ណសមធម៌នៃអត្តសញ្ញាណកម្មគ្រួសារក្រីក្រ នៅមិនទាន់បានភ្ជាប់គ្នាទៅក្នុងប្រព័ន្ធមួយ ដើម្បីគ្រប់គ្រងព័ត៌មានស្តីពីជនក្រីក្រនិងជនងាយរងគ្រោះ នៅឡើយ។ កម្ពុជានៅមានកង្វះសមត្ថភាពក្នុងការវាយតម្លៃពីពិការភាព ហើយជាលទ្ធផល ជនពិការមួយចំនួនស្ថិតនៅក្រៅប្រព័ន្ធនៅឡើយ។ កំណែទម្រង់កិច្ច

គាំពារសង្គមមានការសន្យាជាច្រើនក្នុងការរក្សាវិសមភាព ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យនិងការលើកកម្ពស់ការបែងចែកឡើងវិញ រួមជាមួយនឹង បណ្តាញសុវត្ថិភាពសង្គមដើម្បីគាំទ្រសកម្មភាពសេដ្ឋកិច្ច។

ទីផ្សារការងារក៏ជាគន្លឹះនៃការដាក់បញ្ចូលគ្នានៃសេដ្ឋកិច្ចនៅកម្ពុជា ដោយមានអ្នកចូលរួមកម្រិតខ្ពស់ដោយមិនគិតពីយេនឌ័រ។ រាជរដ្ឋាភិបាលកម្ពុជាបានសម្របសម្រួលការងារនេះ តាមរយៈការអនុញ្ញាតឱ្យមានទីផ្សារការងារសេរី រួមជាមួយនឹងក្របខ័ណ្ឌគតិយុត្តជាមូលដ្ឋាន និងបទប្បញ្ញត្តិស្តីពីប្រាក់ឈ្នួលអប្បបរមាក្នុងការងារ។

ទោះបីជាកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលកម្ពុជា ដើម្បីពន្លឿនការធ្វើពាណិជ្ជកម្មអន្តរជាតិ ការពង្រឹងនិងការបង្កើនសមាហរណកម្មពាណិជ្ជកម្មទៅក្នុងតំបន់និងក្នុងពិភពលោក តាមរយៈកិច្ចព្រមព្រៀងពាណិជ្ជកម្មក្តី ក៏កម្ពុជានៅជួបនឹងបញ្ហាប្រឈមមួយចំនួន រួមមាន (១) ប្រភេទនិងបរិមាណផលិតផលសម្រាប់ទីផ្សារអន្តរជាតិនៅមានតិចតួច (២) ការគ្រប់គ្រងគុណភាពនិងតម្រូវការតាមស្តង់ដាមិនទាន់មានលក្ខណៈទូលំទូលាយនៅឡើយ (៣) តម្លៃនាំចេញនៅមានកម្រិតខ្ពស់នៅឡើយ (ចំណាយផលិតកម្មខ្ពស់) និង (៤) ឧបសគ្គមិនមែនពន្ធលើផលិតផលកម្ពុជា។

## គោលនយោបាយយុទ្ធសាស្ត្រសំខាន់ៗ

ដើម្បីកាត់បន្ថយវិសមភាពក្នុងសង្គម រាជរដ្ឋាភិបាលកម្ពុជានឹងបន្តផ្តោតការយកចិត្តទុកដាក់លើការអភិវឌ្ឍជនបទ ដែលជាការគាំទ្រដល់ប្រជាជនក្រីក្រ។ យោងតាមការសិក្សារបស់ធនាគារអភិវឌ្ឍន៍អាស៊ី បញ្ហាចម្បងៗនៃអភិវឌ្ឍន៍ជនបទ រួមមានអសន្តិសុខក្នុងការកាន់កាប់ដីធ្លី ផលិតភាពទាបរបស់ដីធ្លីនិងធនធានមនុស្ស ការធ្លាក់ចុះទីផ្សារនិងបញ្ហាសម្របសម្រួល និងការផ្តល់ហិរញ្ញប្បទាននៅមានកម្រិតសម្រាប់ការអភិវឌ្ឍនៅជនបទ។

ការអប់រំ និងការថែទាំសុខភាពប្រកបដោយបរិយាប័ន្ន គឺជាវិស័យដ៏សំខាន់ក្នុងការអភិវឌ្ឍជនបទ។ ការបង្កើនការវិនិយោគសាធារណៈក្នុងវិស័យទាំងពីរនេះគឺជាចាំបាច់។ ជាមួយគ្នានេះ កិច្ចគាំពារសង្គមរួមទាំងបណ្តាញសុវត្ថិភាពសង្គម និងគោលនយោបាយធានារ៉ាប់រងសង្គម ចាំបាច់ត្រូវតែពង្រឹង។

រាជរដ្ឋាភិបាលកម្ពុជានឹងបន្តពង្រឹងនិងបង្កើនទំនាក់ទំនងនិងកិច្ចព្រមព្រៀងពាណិជ្ជកម្ម ដើម្បីពន្លឿនការធ្វើសមាហរណកម្មពាណិជ្ជកម្មទៅក្នុងតំបន់និងក្នុងពិភពលោក កំណត់ប្រធានបទកិច្ចព្រមព្រៀងពាណិជ្ជកម្មជាអាទិភាព និងលើកកម្ពស់ទំនាក់ទំនងពាណិជ្ជកម្មលើឆាកអន្តរជាតិ ប្រកបដោយសមភាព និងសមធម៌។

# គោលដៅទី១១៖ ធ្វើឱ្យទីក្រុងនិងកន្លែងតាំងទីលំនៅថ្មីៗសម្រាប់ប្រជាជនមានលក្ខណៈបរិយាប័ន្ន សុវត្ថិភាព ធន់នឹងការប្រែប្រួលអាកាសធាតុ និងចីរភាព

## វឌ្ឍនភាព

ក្រសួងបរិស្ថានបានផ្ទេរមុខងារចំនួន៦ ទៅថ្នាក់ក្រោមជាតិ ស្តីពីការគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន ការគ្រប់គ្រងប្រព័ន្ធលូ ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់នៅតំបន់ទីប្រជុំជន និងការការពារធនធានធម្មជាតិ។ ទន្ទឹមនេះ ក្រសួងបរិស្ថានក៏បានអនុវត្តវិធានការទប់ស្កាត់ និងកាត់បន្ថយការបំពុលខ្យល់ ដូចជា ការតាមដាននិងត្រួតពិនិត្យគុណភាពខ្យល់សាធារណៈ (Ambient Air Quality) នៅតាមតំបន់ទីប្រជុំជនរាជធានី ខេត្ត គោលដៅចំនួន៣៣ទីតាំង ការត្រួតពិនិត្យការបញ្ចេញផ្សែងពីរោងចក្រ សហគ្រាស ទីតាំងអាជីវកម្ម រួមជាមួយនឹងការតម្រូវឱ្យបំពាក់ឧបករណ៍សម្អាត និងតាមដានដោយស្វ័យប្រវត្តិ (Continuosuly Emission Monitoring System, CEMS) លើការបញ្ចេញផ្សែងចូលទៅក្នុងបរិយាកាស និងការធ្វើអធិការកិច្ចលើបទល្មើសបំពុលបរិស្ថាន។

ជាមួយគ្នានេះ ក្រសួងបរិស្ថានបានធ្វើប្រតិភូកម្មមុខងារ ការគ្រប់គ្រងតំបន់ការពារធម្មជាតិជូនរដ្ឋបាល ក្រុង ស្រុក ដែលមានតំបន់ការពារធម្មជាតិ ដោយប្រគល់ភារកិច្ចក្នុងការផ្សព្វផ្សាយច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ពង្រឹងការគ្រប់គ្រងតំបន់ការពារធម្មជាតិ ពង្រឹងការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ និង គ្រប់គ្រងស្ថានភាពរស់នៅរបស់ប្រជាពលរដ្ឋដែលស្ថិតនៅក្នុងនិងនៅក្បែរតំបន់នោះ ឱ្យស្របតាមផែនការយុទ្ធសាស្ត្រសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ ២០១៧ -២០៣១។

ក្រសួងបរិស្ថានបានធ្វើការលើកកម្ពស់ការយល់ដឹងជាសាធារណៈ អំពីផលប៉ះពាល់ និងហានិភ័យដល់បរិស្ថាន ពីការប្រើប្រាស់ថង់ប្លាស្ទិក និងបានចេញបទប្បញ្ញត្តិ និងវិធានការ មានជាអាទិ៍ (១) ការរឹតបន្តឹងលើការនាំចូលនិងការផលិតថង់ប្លាស្ទិក ដោយកំណត់កម្រិតទំហំ និងកម្រាស់ (២) ការតម្រូវឱ្យមានការគិតថ្លៃដល់អតិថិជនដែលសុំប្រើប្រាស់ថង់ប្លាស្ទិកសម្រាប់ដាក់ទំនិញរបស់ពួកគាត់ពីផ្សារទំនើប និងមជ្ឈមណ្ឌលពាណិជ្ជកម្មនានា និង (៣) ការលើកទឹកចិត្តឱ្យមានការនាំចូលនិងការផលិតថង់ប្លាស្ទិកដែលងាយពុកផុយទៅក្នុងបរិស្ថាន និងលើកកម្ពស់ការកែច្នៃសំណល់ប្លាស្ទិក។ ទន្ទឹមនឹងនេះ ក្រសួងបរិស្ថានបានជំរុញនិងអនុវត្តកម្មវិធីមេត្រីភាពបរិស្ថាន នៅតាមគ្រឹះស្ថានសិក្សារបស់រដ្ឋ ដោយបានកំណត់គោលដៅ និងដាក់ចេញនូវចលនាប្រឡងប្រណាំងសាលាស្អាត ភាពបៃតងក្នុងសាលា និងបរិយាកាសសិក្សាល្អ ដើម្បីឆ្លើយតបទៅនឹងការអភិវឌ្ឍប្រកបដោយចីរភាព។

ម្យ៉ាងវិញទៀត ក្រសួងសាធារណការនិងដឹកជញ្ជូន បានរៀបចំផែនការមេស្តីពីការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធលូដែលនឹងត្រូវអនុវត្តនៅតាមបណ្តាទីក្រុងនានា ដែលជាការឆ្លើយតបទៅនឹង *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤*។

## តារាង ៤.១១÷ វឌ្ឍនភាពគោលដៅទី១១ នៃ គ.អ.ច.ក.

| | ចំណុចដៅ/សូចនាករ | ឯកតា | ២០១៥ | ចំណុចដៅ គ.អ.ច.ក. | | | | ជាក់ស្តែង | | | | វឌ្ឍនភាព |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | |
| ១១.៦ | ត្រឹមឆ្នាំ២០៣០ កាត់បន្ថយការបំពុលបរិស្ថានដោយមនុស្សម្នាក់ នៅតំបន់ទីក្រុង តាមរយៈការផ្តោតការយកចិត្តទុកដាក់លើ គុណភាពខ្យល់ និងការគ្រប់គ្រងសំណល់នៅតំបន់ទីក្រុង និងតំបន់ផ្សេង ទៀត។ | | | | | | | | | | | លើសចំណុចដៅ |
| ១១.៦.១ | បរិមាណសំរាមសំណល់រឹងដែលបានប្រមូលបានជាប្រចាំនៅតំបន់ទីប្រជុំជន ទីក្រុង និងត្រូវបានបញ្ចេញចោលក្នុងតំបន់ទីប្រជុំជន និងនៅតាមទីក្រុង។ | លានតោន | ១,២ | ១,២៥ | ១,២៨ | ១,៣០ | ១,៣៣ | ១,២៦ | ១,៥ | ១,៧២ | ១,៩៨ | លើសចំណុចដៅ |
| ១១.៦.២ | ភាគរយនៃការកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិច។ | % | ១០,០ | ១០,០ | ១០,០ | ១០,០ | ២០,០ | ១០,៥ | ១០,៧ | ១០,៨ | ១២,៨ | ទាបជាងចំណុចដៅ |
| ១១.៦.៣ | ភាគរយនៃសំណល់រឹងត្រូវបានគ្រប់គ្រងតាមគោលការណ៍បច្ចេកទេស។ | % | ៥០,០ | ៥០,០ | ៥០,០ | ៥០,០ | ៥៥,០ | ៥២,៤ | ៥៦,៧ | ៥៨,១ | ៦១,៥ | លើសចំណុចដៅ |
| ១១.៦.៤ | កម្រិតជាមធ្យមប្រចាំឆ្នាំនៃប៉ារ៉ាម៉ែត្រ CO NO2 SO2 TSP PM2.5 and PM10។ | µm/m3 | ៤,០ | ៤,០ | ៤,០ | ៤,០ | ៤,០ | - | ១៣,៦២ | ១៩,១៤ | ២១,៣ | លើសចំណុចដៅ |

*ប្រភព÷ ក្រុមប្រឹក្សា គ.អ.ច.ក. និង ក្រសួង ស្ថាប័ន*

## បញ្ហាប្រឈម

ទោះបីជាមានការផ្ទេរមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិជាអ្នកអនុវត្តក្តី ប៉ុន្តែបញ្ហាប្រឈមមួយចំនួនក្នុងការធ្វើឱ្យសម្រេចបានចំណុចដៅនានាក្នុងគោលដៅនេះ គឺសមត្ថភាពក្នុងការអនុវត្តមុខងារ ការយល់ដឹងរបស់ប្រជាជននិងភាគីដែលមានចំណែកពាក់ព័ន្ធ ពាក់ព័ន្ធនឹងការយកចិត្តទុកដាក់ និងការបញ្ចេញសំរាម សំណល់រឹង នៅមានកម្រិត ហើយការអនុវត្តវិធានការច្បាប់នៅមិនទាន់មានភាពរឹងមាំនៅឡើយ។ ទន្ទឹមនេះ មជ្ឈមណ្ឌលអប់រំផ្សព្វផ្សាយការយល់ដឹងអំពីសំរាម សំណល់រឹង និងការអនុវត្តការគ្រប់គ្រងសំរាមប្រកបដោយសុវត្ថិភាពបរិស្ថាន (ការញែក និងគោលការណ៍អនុវត្ត 3R) នៅពុំទាន់ត្រូវបានរៀបចំសម្រាប់អនុវត្តនៅឡើយទេ។

## គោលនយោបាយឬយុទ្ធសាស្ត្រសំខាន់ៗ

ក្រសួងបរិស្ថានបានកំណត់គោលដៅ និងយុទ្ធសាស្ត្រ ក្នុងការបន្តភាពជាដៃគូជាមួយដៃគូអភិវឌ្ឍ និងវិស័យឯកជន ដើម្បីពង្រឹងនិងជំរុញការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ការប្រមូលរៀបចំទិន្នន័យជាតិស្តីពីប្រភពបំពុល បរិមាណនៃការបង្កើតនិងការបញ្ចេញសារធាតុបំពុលខ្យល់ សំរាម សំណល់រឹង សំណល់រាវ សំណល់ឧស្សាហកម្ម និង ការត្រួតពិនិត្យការបញ្ចេញសារធាតុបំពុលខ្យល់ពីប្រភពបំពុលចូលទៅក្នុងបរិយាកាស។ រាជរដ្ឋាភិបាលកម្ពុជាបានចេញនូវអនុក្រឹត្យចំនួន៥ រួមមាន អនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន អនុក្រឹត្យស្តីពីការបង្កើតមូលនិធិបរិស្ថាននិងសង្គម អនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់បរិក្ខាអគ្គិសនីនិងអេឡិចត្រូនិក អនុក្រឹត្យស្តីពីការគ្រប់គ្រងថង់ប្លាស្ទិក និង អនុក្រឹត្យស្តីពីការគ្រប់គ្រងប្រព័ន្ធលូនិងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់។

គោលដៅយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា ពាក់ព័ន្ធនឹងការរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គឺដើម្បីលើកកម្ពស់ការអភិវឌ្ឍទីក្រុងប្រកបដោយបរិយាកាសល្អ និងរស់នៅស្អាត ជាមួយ

នឹងការលើកកម្ពស់សុខុមាលភាពរបស់ប្រជាជន និងប្រសិទ្ធភាពសង្គម សេដ្ឋកិច្ច។ រាជរដ្ឋាភិបាលបានអនុមតិនិងដាក់ឱ្យអនុវត្ត *គោលនយោបាយជាតិស្តីពីការរៀបចំដែនដី ច្បាប់ស្តីពីការរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អនុក្រឹត្យស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងតំបន់ទីប្រជុំជន* និង គោលការណ៍ណែនាំ និងលិខិតបទដ្ឋានគតិយុត្តជាច្រើនទៀត ដើម្បីគាំទ្រដល់ការងារអភិវឌ្ឍន៍ទីក្រុងប្រកបដោយបរិយាប័ន្ន សុវត្ថិភាព ភាពធន់ និងចីរភាព។ ជាលទ្ធផល គិតត្រឹមខែវិច្ឆិកា ឆ្នាំ២០១៩ រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សម្រេចបាន (១) ថ្នាក់រាជធានី ខេត្ត៖ ប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញ ផែនការរៀបចំដែនដីខេត្តបាត់ដំបង និងខេត្តព្រះសីហនុ (២) ថ្នាក់ក្រុង ស្រុក ខណ្ឌ និងទីប្រជុំជន៖ ប្លង់គោលប្រើប្រាស់ដីនៅតំបន់ទីប្រជុំជន ទីរួមខេត្តត្បូងឃ្មុំ ក្រុងបាត់ដំបង ក្រុងតាខ្មៅ ក្រុងកំពត ក្រុងកែប ក្រុងសៀមរាប ក្រុងខេមរភូមិន្ទ ក្រុងបូកគោ ក្រុងបាវិត ក្រុងប៉ោយប៉ែត ក្រុងស្ទឹងត្រែង ទីប្រជុំជនជ្រៃធំនៃស្រុកកោះធំ និងទីប្រជុំជនស្រុកស្វាយអន្ទរ និង (៣) ថ្នាក់ឃុំ សង្កាត់៖ ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ចំនួន៨២។

**ករណីសិក្សាទី៣ : ក្រុងបាត់ដំបង**

ក្រុងបាត់ដំបងត្រូវបានជ្រើសរើសជាទីក្រុងសាកល្បងមួយ ក្នុងចំណោមទីក្រុងសាកល្បងចំនួន៥ នៅក្រោមគម្រោងគណៈកម្មាធិការសេដ្ឋកិច្ចនិងសង្គមរបស់អង្គការសហប្រជាជាតិសម្រាប់តំបន់អាស៊ីនិងប៉ាស៊ីហ្វិក និងអង្គការលំនៅដ្ឋានរបស់អង្គការសហប្រជាជាតិ ដែលមានឈ្មោះថា "ការធ្វើសមាហរណកម្ម គ.អ.ច. ទៅជាសកម្មភាពក្នុងតំបន់ដើម្បីគាំទ្រដល់ការអនុវត្តរបៀបវារៈឆ្នាំ២០៣០ នៅតំបន់អាស៊ីនិងប៉ាស៊ីហ្វិក" (២០១៨-២០២១)។ គម្រោងនេះផ្តោតលើការតស៊ូមតិ និងការអភិវឌ្ឍសមត្ថភាពសម្រាប់រដ្ឋបាលមូលដ្ឋាន និងអ្នកពាក់ព័ន្ធនៅទីក្រុងផ្សេងៗទៀតក្នុងខេត្តបាត់ដំបងពាក់ព័ន្ធនឹងគោលការណ៍ គោលដៅ និងមធ្យោបាយនៃការអនុវត្តរបៀបវារៈឆ្នាំ២០៣០ ហើយកំពុងត្រូវបានអនុវត្តនៅក្នុងខេត្តបាត់ដំបង ជាមួយនឹងដៃគូក្នុងស្រុកពីក្រុមអ្នកមានចំណែកពាក់ព័ន្ធផ្សេងៗ។ គម្រោងនេះនឹងគាំទ្រដល់ការសាកល្បង "គម្រោងបង្ហាញ" នៅក្នុងទីក្រុងដែលនឹងត្រូវកំណត់ដោយបណ្តាញអ្នកមានចំណែកពាក់ព័ន្ធ។

ក្រុងបាត់ដំបងបានជ្រើសរើសការគ្រប់គ្រង សំរាមសំណល់រឹង ការអភិវឌ្ឍជីវភាពរស់នៅនិងសេដ្ឋកិច្ចក្នុងមូលដ្ឋានទឹកកខ្វក់ និងអាទិភាពនៃកិច្ចខិតខំប្រឹងប្រែងផ្តល់លំនៅដ្ឋានគំរូដែលមានតម្លៃសមរម្យនៅក្នុងទីក្រុង។ ការផ្តោតការយកចិត្តទុកដាក់លើការកំណត់ដំណោះស្រាយរួមចំពោះបញ្ហាសំរាម សំណល់រឹងក្នុងក្រុងបាត់ដំបង ពាក់ព័ន្ធជាពិសេសក្នុងបរិការណ៍នៃគោលដៅនិងសូចនាករនានា ដែលត្រូវបានអនុមតិដោយរាជរដ្ឋាភិបាលថ្នាក់ក្រោម ក្នុងគោលដៅទី១១ នៃ គ.អ.ច.ក. ចំណុចដៅ ១១.៦ "កាត់បន្ថយការបំពុលបរិស្ថានដោយមនុស្សម្នាក់នៅតំបន់ទីក្រុង តាមរយៈការផ្តោតការយកចិត្តទុកដាក់លើគុណភាពខ្យល់ និងការគ្រប់គ្រងសំណល់នៅទីក្រុង និងតំបន់ផ្សេងៗទៀត" សូចនាករ ១១.៦.១ "បរិមាណសំរាមសំណល់រឹងដែលបានប្រមូលបានជាប្រចាំនៅតំបន់ទីប្រជុំជន ទីក្រុង និងត្រូវបានបញ្ចេញចោលទៅទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជន"។

ដំណើការនៃការធ្វើមូលដ្ឋានីយកម្ម គ.អ.ច. នេះ គឺជាផ្នែកមួយសំខាន់ ហើយវិធីសាស្ត្រផ្តល់លំនៅដ្ឋានគំរូដែលមានតម្លៃសមរម្យ គឺជាការដោះស្រាយញ្ហាជាប្រព័ន្ធនៅថ្នាក់មូលដ្ឋាន នៅក្នុងគោលដៅទី១៧ ដោយស្នើឱ្យមានការពង្រឹងស្ថាប័ននិងការចូលរួមពីភាគីចម្រុះដែលមានចំណែកពាក់ព័ន្ធមកពីគោលដៅទី១៦ និងយកគំនិតពី "មធ្យោបាយនៃការអនុវត្ត" ពីចំណុចដៅផ្សេងទៀត នៃគ្រប់គោលដៅរបស់ គ.អ.ច.។ គោលបំណងគឺដើម្បីពង្រឹងសមត្ថភាពរបស់រដ្ឋបាលមូលដ្ឋាន

និងភាគីដែលមានចំណែកពាក់ព័ន្ធសំខាន់ៗ នៅតាមទីក្រុងដើម្បីសម្រេចឱ្យបាននូវភាពជាដៃគូប្រកបដោយប្រសិទ្ធភាពនៅថ្នាក់ទីក្រុងដោយលើកកម្ពស់ការអភិវឌ្ឍសមត្ថភាពសំខាន់ៗចំនួន៣ ដូចខាងក្រោម៖

(i) អភិបាលកិច្ចរួមគ្នានិងការប្រែប្រួលអាកាសធាតុ៖ គម្រោងនេះមានគោលដៅពង្រឹងការធ្វើផែនការដោយមានការចូលរួម ការអនុវត្ត និង "ការតាមដានត្រួតពិនិត្យ និង ការវាយតម្លៃ" នៅថ្នាក់មូលដ្ឋានក្នុងក្រុងបាត់ដំបង តាមរយៈ ព័ត៌មានដែលមានប្រសិទ្ធភាពពីបណ្តាញអ្នកមានចំណែកពាក់ព័ន្ធចម្រុះ ដែលនឹងរួមបញ្ចូលទាំងអ្នកមានចំណែកពាក់ព័ន្ធមកពីស្ថាប័នរាជរដ្ឋាភិបាលថ្នាក់មូលដ្ឋាននិងថ្នាក់ជាតិ អង្គការសង្គមស៊ីវិលនិងសហគមន៍ ផ្នែកឯកជន និងសហគមន៍ស្រាវជ្រាវនិងអប់រំ។ គោលបំណង គឺដើម្បីឱ្យអ្នកមានចំណែកពាក់ព័ន្ធទាំងអស់ ដកស្រង់បទពិសោធន៍និងធ្វើសកម្មភាពរួមគ្នាក្នុងភាពជាដៃគូ និងសម្រេចបាននូវលទ្ធផលប្រកបដោយបរិយាប័ន្ន និងឈានទៅសម្រេចបាន នូវគោលការណ៍ "មិនមានអ្នកណាម្នាក់មិនត្រូវបានទុកឱ្យនៅឯកោ"។

(ii) ពង្រឹងមូលដ្ឋានភស្តុតាងសម្រាប់ការសម្រេចចិត្ត៖ គម្រោងនេះនឹងជួយដល់ការប្រមូលនិងវិភាគទិន្នន័យដែលមានគុណភាពខ្ពស់ ទាន់ពេលវេលា និងគួរឱ្យទុកចិត្តលើអាទិភាពនៃកិច្ចខិតខំប្រឹងប្រែងផ្តល់លំនៅដ្ឋានគំរូ របស់ក្រុងបាត់ដំបង ដែលស្របតាមសូចនាករ គ.អ.ច. ក៏ដូចជាកំណត់និងប្រើប្រាស់ទិន្នន័យដែលមានស្រាប់។ គោលបំណងគឺដើម្បីគាំទ្រដល់ការបង្កើត "មូលដ្ឋានភស្តុតាង" (តម្លៃគោលនិងការវាស់វែងពីវឌ្ឍនភាព) ដែលអាចនឹងរាប់បញ្ចូលទាំងការវាយតម្លៃភាពងាយរងគ្រោះនិងការវិភាគលើយេនឌ័រ ដើម្បីជួយកំណត់វិធីសាស្ត្រជោគជ័យបំផុតសម្រាប់ការធ្វើមូលដ្ឋាននីយកម្ម គ.អ.ច. នៅតាមទីក្រុងនីមួយៗ។

(iii) ការកំណត់ការបញ្ចូលដំណោះស្រាយ ដោយប្រើប្រាស់ប្រព័ន្ធនៃការគិតពិចារណា៖ គម្រោងនេះ មានគោលបំណងដើម្បីអភិវឌ្ឍសមត្ថភាពបណ្តាញអ្នកមានចំណែកពាក់ព័ន្ធនៅក្រុងបាត់ដំបង ដើម្បីវិភាគ រៀបចំផែនការ និងអនុវត្តរួមគ្នាតាមបែបជាប្រព័ន្ធ។ ការងារនេះតម្រូវឱ្យបង្កើនផលប្រយោជន៍រួមឱ្យបានជាអតិបរិមា បង្កើនតម្លៃបន្ថែម តាមរយៈការរួមបញ្ចូលគ្នា និងដោះស្រាយបញ្ហាប្រកបដោយប្រសិទ្ធភាព តាមរយៈសរសរស្តម្ភទាំង៣នៃការអភិវឌ្ឍប្រកបដោយចីរភាព។ ការអភិវឌ្ឍសមត្ថភាពនេះពឹងផ្អែកទៅលើលទ្ធផលនៃចំណុចទាំងនេះបញ្ចូលគ្នា ពីព្រោះវិធីសាស្ត្រក្នុងការយល់ដឹងអំពីបញ្ហាប្រឈម និងការកំណត់អន្តរាគមន៍ ត្រូវធ្វើឡើងតាមរយៈការវិភាគបញ្ហា និងសកម្មភាពរៀបចំផែនការដោយបណ្តាញអ្នកមានចំណែកពាក់ព័ន្ធចម្រុះ ("កិច្ចសហការ") និងការប្រើប្រាស់មូលដ្ឋានទិន្នន័យថ្មីរបស់ទីក្រុង (តម្រង់ទៅនឹងសូចនាករ គ.អ.ច. ពាក់ព័ន្ធ) ដើម្បីធ្វើសេចក្តីសម្រេចចិត្តផ្អែកលើភស្តុតាង និងតាមដានវឌ្ឍនភាព ("ពង្រឹងភស្តុតាង")។

លទ្ធផលចម្បងដែលរំពឹងទុករបស់គម្រោងនេះគឺ ពង្រឹងការយល់ដឹងនិងសមត្ថភាពស្ថាប័នរបស់ក្រុងបាត់ដំបង ក្នុងការជំរុញសកម្មភាពពាក់ព័ន្ធនឹង គ.អ.ច. របស់អ្នកមានចំណែកពាក់ព័ន្ធចម្រុះ នៅកម្រិតមូលដ្ឋាន តាមរយៈ ការបញ្ចូលការអនុវត្តច្រើនថែមទៀត ពាក់ព័ន្ធនឹងការអភិវឌ្ឍតំបន់ទីប្រជុំជន និងផែនការប្រើប្រាស់ដីនៅក្នុងទីក្រុង។

## គោលដៅទី១២៖ ធានាឱ្យ មានចីរភាពក្នុងទម្រង់នៃការប្រើប្រាស់និងផលិតកម្មវឌ្ឍនភាព

## វឌ្ឍនភាព

កម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិមួយចំនួន ពាក់ព័ន្ធនឹងការគ្រប់គ្រងសារធាតុគីមីពុល និងសំណល់គ្រោះថ្នាក់ មានជាអាទិ៍ (១) អនុសញ្ញាបាសែល ស្តីពីការត្រួតពិនិត្យចលនាឆ្លងដែន

សំណល់គ្រោះថ្នាក់ និងការបោះចោលសំណល់គ្រោះថ្នាក់ នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៦ (២) អនុសញ្ញាស្តុកខុម ស្តីពីសារធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុ (POPs) នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ ២០០៦ (៣) អនុសញ្ញាទីក្រុងវីយ៉ែន ស្តីពីកិច្ចការពារស្រទាប់អូហ្សូន នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ ២០០១ និងពិធីសារម៉ុងរ៉េអាល់ ស្តីពីសារធាតុបំផ្លាញស្រទាប់អូហ្សូន នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ ២០០១ (៤) អនុសញ្ញារ៉ូថឺដាម ស្តីពីនីតិវិធីនៃការយល់ព្រមផ្តល់ព័ត៌មានជាមុនចំពោះសារធាតុគីមី និង ថ្នាំកសិកម្មគ្រោះថ្នាក់ក្នុងពាណិជ្ជកម្មអន្តរជាតិ នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១២។ ទន្ទឹមនឹងនេះ កម្ពុជា ក៏បានចុះហត្ថលេខាលើអនុសញ្ញាមីណាម៉ាតា ស្តីពីបារត នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៣ និងបាន ចូលរួមអនុវត្តយុទ្ធសាស្ត្រអន្តរជាតិគ្រប់គ្រងសារធាតុគីមីពុល និងប្រព័ន្ធសុខដុមនីយកម្មសាកលលើការ ចាត់ថ្នាក់ និងការដាក់ស្លាកសញ្ញាសារធាតុគីមី ។

ដើម្បីសម្របសម្រួលការអនុវត្តកាតព្វកិច្ចក្រោមកិច្ចព្រមព្រៀងពហុភាគី វិស័យបរិស្ថាន ពាក់ព័ន្ធនឹងសារធាតុគីមីពុល និងសំណល់គ្រោះថ្នាក់ រាជរដ្ឋាភិបាលកម្ពុជាបានចាត់តាំង (១) ក្រសួង បរិស្ថានជាស្ថាប័នបង្គោលមានតួនាទីសម្របសម្រួលការអនុវត្តអនុសញ្ញាបាសែល អនុសញ្ញាស្តុកខុម អនុសញ្ញាទីក្រុងវីយ៉ែន ពិធីសារម៉ុងរ៉េអាល់ និងអនុសញ្ញាមីណាម៉ាតា (២) ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាស្ថាប័នបង្គោលមានតួនាទីសម្របសម្រួលការអនុវត្តអនុសញ្ញារ៉ូថឺដាម។

នៅក្នុងការអនុវត្តកាតព្វកិច្ចក្រោមកិច្ចព្រមព្រៀងពហុភាគីវិស័យបរិស្ថានទាំងនេះ កម្ពុជា បានរៀបចំលិខិតបទដ្ឋានគតិយុត្ត ផែនការជាតិ និងគោលការណ៍ណែនាំ សម្រាប់គ្រប់គ្រងសារធាតុគីមី ពុល និងសំណល់គ្រោះថ្នាក់ រួមមាន៖ (១) អនុក្រឹត្យ ស្តីពីការគ្រប់គ្រងសារធាតុបំផ្លាញស្រទាប់អូហ្សូន (២) អនុក្រឹត្យ ស្តីពីការគ្រប់គ្រងលើការចាត់ថ្នាក់ និងការដាក់ស្លាកសញ្ញាសារធាតុគីមី (៣) អនុក្រឹត្យ ស្តីពីការដាក់ឱ្យប្រើប្រាស់បញ្ជីទំនិញហាមឃាត់ និងទំនិញជាប់កម្រិតកំណត់ (៤) អនុក្រឹត្យ ស្តីពីការ គ្រប់គ្រងថង់ប្លាស្ទិក (៥) អនុក្រឹត្យ ស្តីពីការគ្រប់គ្រងសំណល់បរិក្ខាអគ្គិសនី និងអេឡិចត្រូនិក (៦) អនុក្រឹត្យ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន (៧) ផែនការជាតិសម្រាប់ការអនុវត្តអនុសញ្ញា ស្តុកខុម (៨) ផែនការជាតិសម្រាប់ការអនុវត្តអនុសញ្ញារ៉ូថឺដាម (៩) ផែនការជាតិលុបបំបាត់សារធាតុ បំផ្លាញស្រទាប់អូហ្សូន (១០)ផែនការជាតិ ស្តីពីការគ្រប់គ្រងសារធាតុហាយដ្រូក្លរ៉ូហ្វ័យអរ៉ូកាបូន (១១) កម្មវិធីជាតិ ស្តីពីការគ្រប់គ្រងសារធាតុត្រជាក់ (១២) គោលការណ៍ណែនាំ ស្តីពីការគ្រប់គ្រងសំណល់ បរិក្ខាអគ្គិសនីនិងអេឡិចត្រូនិក។ ជាមួយគ្នានេះ កម្ពុជាក៏បានរៀបចំសារពើភ័ណ្ឌស្តីពីសារធាតុបំពុល សរីរាង្គមិនងាយបំបែកធាតុ សារពើភ័ណ្ឌស្តីពីបារត សារពើភ័ណ្ឌស្តីពីសំណល់បរិក្ខារអគ្គិសនី និង អេឡិចត្រូនិក កម្រងព័ត៌មានជាតិស្តីពីសារធាតុគីមី និងបញ្ជីថ្នាំកសិកម្មដែលហាមឃាត់ ព្រមទាំងអនុវត្ត ប្រព័ន្ធស្វ័យត្រួតពិនិត្យនិងរាយការណ៍តាមអនឡាញ និងអនុវត្តសាកល្បងនូវប្រព័ន្ធ PRTR លើរោងចក្រ សហគ្រាសដែលមានសក្តានុពលបំពុលខ្ពស់។

## តារាង ៤.១២៖ វឌ្ឍនភាពគោលដៅទី១២ នៃ គ.អ.ច.ក.

| | ចំណុចដៅ/សូចនាករ | ឯកតា | ២០១៥ | ចំណុចដៅ គ.អ.ច.ក. | | | | ជាក់ស្តែង | | | | វឌ្ឍនភាព |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | |
| ១២.៤ | ត្រឹមឆ្នាំ២០២០ សម្រេចឱ្យបាន ការគ្រប់គ្រងបរិស្ថានល្អ ពាក់ព័ន្ធនឹងការបោះបង់ចោល សារធាតុគីមីនិងសំណល់គ្រប់ប្រភេទ តាមរយៈ ការកែច្នៃឡើងវិញឱ្យស្របតាមក្របខ័ណ្ឌកិច្ចព្រមព្រៀងអន្តរជាតិ និងកាត់បន្ថយឱ្យបាន ច្រើននូវការបញ្ចេញសំណល់ទាំងនោះទៅក្នុងបរិយាកាស ក្នុងទឹក និងក្នុងដី ដើម្បីកាត់បន្ថយ ឱ្យទាបបំផុតនូវផលប៉ះពាល់អវិជ្ជមាន លើសុខភាពប្រជាជននិងបរិស្ថាន។ | | | | | | | | | | | ទាបជាងចំណុចដៅ |
| ១២.៤.១ | អត្រានៃការសាយភាយសារធាតុ បំពុលសរីរាង្គមិនងាយបំបែកធាតុសាយភាយចូលទៅក្នុងបរិស្ថាន។ | % | ០,០ | ០,០ | ០,០ | ២,០ | ២,០ | ០,០ | ០,០ | ១,០ | ១,០ | ទាបជាងចំណុចដៅ |
| ១២.៤.២ | ភាគរយនៃការកាត់បន្ថយការសាយភាយសារធាតុបារតសាយភាយចូលទៅក្នុងបរិស្ថាន។ | % | - | - | - | ២,០ | ៣,០ | ០,០ | ០,០ | ២,០ | ២,០ | ទាបជាងចំណុចដៅ |
| ១២.៤.៣ | ភាគរយនៃការគ្រប់គ្រងសំណល់គ្រោះថ្នាក់ សំណល់ជីវសាស្ត្រ និងវិទ្យុសកម្ម។ | % | - | - | - | ៣,០ | ៣,០ | ០,០ | ០,០ | ២,០ | ២,០ | ទាបជាងចំណុចដៅ |
| ១២.៥ | ត្រឹមឆ្នាំ២០៣០ កាត់បន្ថយឱ្យបាន ច្រើនការបង្កើតសំណល់ តាមរយៈការការពារ ការកាត់បន្ថយ ការកែច្នៃឡើងវិញនិងការប្រើប្រាស់ឡើងវិញ | | | | | | | | | | | លើសចំណុចដៅ |
| ១២.៥.១ | អត្រានៃការកែច្នៃឡើងវិញនូវវត្ថុធាតុដើមដែលបានប្រើប្រាស់។ | ពាន់តោន | ១៦៣ | ១៦៣,៤ | ១៧៥,០ | ១៧៨,០ | ១៨០,០ | ២៤៧,០ | ៣០៤,០ | ២៩០,០ | ២៩៥,២ | លើសចំណុចដៅ |

*ប្រភព៖ ក្របខ័ណ្ឌ គ.អ.ច.ក. និង ក្រសួង ស្ថាប័ន*

## បញ្ហាប្រឈម

នៅក្នុងដំហានឆ្ពោះទៅសម្រេចបានគោលដៅទី១២ នៃ គ.អ.ច.ក. កម្ពុជាមានបញ្ហាប្រឈមមួយចំនួន ដូចជា សមត្ថភាពជំនាញបច្ចេកទេសនៅមានកម្រិត ពាក់ព័ន្ធនឹងការរៀបចំលិខិតបទដ្ឋានគតិយុត្ត ការគ្រប់គ្រងសារធាតុគីមីពុលនិងសំណល់គ្រោះថ្នាក់ និងការអនុវត្តសកម្មភាពជាកាតព្វកិច្ចនៅក្រោមបទប្បញ្ញត្តិនៃអនុសញ្ញានានា ដូចជា ការកាត់បន្ថយ ការផលិត ការនាំចូល ការប្រើប្រាស់ និងការឈានទៅលុបបំបាត់ការប្រើប្រាស់សារធាតុគីមី ដែលមានហានិភ័យខ្ពស់ចំពោះសុខភាពនិងបរិស្ថាន។ បញ្ហាប្រឈមមួយទៀតគឺ សូចនាកររបស់ គ.អ.ច.ក. ត្រូវបានកំណត់ទៅនឹងការងារពាក់ព័ន្ធនឹងបរិស្ថាន ខណៈដែលការផ្តោតសំខាន់របស់ គ.អ.ច. សកល ផ្តោតលើការគ្រប់គ្រងសារធាតុគីមី និងសំណល់គ្រោះថ្នាក់ ការប្រើប្រាស់ឡើងវិញនូវផលិតផល សម្ភារៈ ដើម្បីរក្សានូវប្រព័ន្ធអេកូឡូស៊ី។

ការគាំទ្រផ្នែកហិរញ្ញវត្ថុនិងបច្ចេកទេសនៅតែប្រឈមនឹងការខ្វះខាត ដើម្បីសម្រេចបានចំណុចដៅនានាក្នុងគោលដៅនេះ។

## គោលនយោបាយឬយុទ្ធសាស្ត្រសំខាន់ៗ

ដើម្បីឆ្លើយតបទៅនឹងគោលដៅទី១២ នៃ គ.អ.ច.ក. និងក្នុងគោលដៅបំពេញកាតព្វកិច្ចជាភាគីសមាជិកនៃអនុសញ្ញាបាសែល អនុសញ្ញាស្តុកខុម អនុសញ្ញាទីក្រុងរ៉ូយ៉ែន ពិធីសារម៉ុងរ៉េអាល់ អនុសញ្ញារ៉ូប៊ីដាម រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តជំរុញអនុវត្តផែនការសកម្មភាព ដែលបានកំណត់នៅក្នុងផែនការជាតិសម្រាប់អនុវត្តអនុសញ្ញាទាំងនោះ ក្នុងគោលបំណងទប់ស្កាត់និងកាត់បន្ថយការបោះចោលសារធាតុគីមីគ្រោះថ្នាក់ សំណល់គ្រោះថ្នាក់ និងការសាយភាយជាតិពុលចូលទៅក្នុងបរិស្ថាន សំដៅការពារគុណភាពបរិស្ថាន ជីវៈចម្រុះ ប្រព័ន្ធអេកូឡូស៊ី និងសុខភាពសាធារណៈ។ សកម្មភាពទាំងនោះរួមមាន (១) ការរៀបចំគោលការណ៍ណែនាំអំពីការគ្រប់គ្រងសារធាតុគីមីនិងសំណល់គ្រោះថ្នាក់នៅ

តាមវិស័យ (២) ការធ្វើបច្ចុប្បន្នភាពទិន្នន័យសារធាតុគីមីគ្រោះថ្នាក់និងសំណល់គ្រោះថ្នាក់ ដែលបានបង្កើតឬផលិត ប្រើប្រាស់ និងបោះចោល (៣) ការបន្តលើកកម្ពស់ការយល់ដឹងជាសាធារណៈពីការគ្រប់គ្រងផលប៉ះពាល់ដែលបង្កឡើងដោយសារធាតុគីមីគ្រោះថ្នាក់ និងសំណល់គ្រោះថ្នាក់។

ទន្ទឹមនឹងនេះ នៅក្នុងបរិការណ៍នៃការត្រៀមផ្តល់សច្ចាប័នចូលជាសមាជិកនៃអនុសញ្ញាមីណាម៉ាតា ស្តីពីសារធាតុបារត ក្រសួងបរិស្ថានបានបញ្ចប់ការធ្វើសារពើភ័ណ្ឌការប្រើប្រាស់បារត និងការសិក្សាវាយតម្លៃផលប៉ះពាល់ពីការប្រើប្រាស់សារធាតុបារតក្នុងអាជីវកម្មរ៉ែមាសខ្នាតតូច និងលក្ខណៈគ្រួសារ។

ការប្រើប្រាស់និងផលិតកម្មប្រកបដោយចីរភាព ត្រូវបានបញ្ចូលទៅក្នុងក្រមបរិស្ថាននិងធនធានធម្មជាតិ ក្រោមយន្តការគ្រប់គ្រងបរិស្ថាននិងចីរភាព ដោយមានគោលបំណងលើកកម្ពស់ ការទទួលយក ការអនុវត្ត ការប្រើប្រាស់ និងការផលិត ប្រកបដោយចីរភាព ព្រមទាំងលទ្ធកម្មប្រកបដោយចីរភាព។

ប្រសិទ្ធភាពធនធានកំពុងត្រូវបានអនុវត្ត ដើម្បីធានាឱ្យបាននូវការប្រើប្រាស់និងការផលិតប្រកបដោយចីរភាព ដែលអាចសម្រេចបានជាមួយនឹងការចំណាយវិនិយោគ និងកិច្ចខិតខំប្រឹងប្រែង។ បន្ទាប់ពីការអនុម័តក្រមបរិស្ថាននិងធនធានធម្មជាតិ ការប្រើប្រាស់និងការផលិតប្រកបដោយបរិយាប័ន្ននឹងធ្វើសមាហរណកម្មទៅក្នុងវិស័យផ្សេងៗ ដូចជាឧស្សាហកម្ម ទេសចរណ៍ ថាមពល ជាដើម។

## គោលដៅទី១៣៖ ចាត់វិធានការជាបន្ទាន់ ដើម្បីប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់

### វឌ្ឍនភាព

កម្ពុជា គឺជាប្រទេសងាយរងគ្រោះបំផុតចំពោះការប្រែប្រួលអាកាសធាតុនៅក្នុងតំបន់ និងក្នុងចំណោមបណ្តាប្រទេសចំនួន១០នៅទូទាំងពិភពលោក។ ក្រសួងបរិស្ថាននិងអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព បានប្តេជ្ញាអនុវត្តឱ្យសម្រេចបាននូវសូចនាកររបស់ គ.អ.ច.ក. ជាពិសេស គោលដៅទី១៣ របស់ គ.អ.ច.ក. (សកម្មភាពអាកាសធាតុ)។ សមិទ្ធផលដែលសម្រេចបានគួរឱ្យកត់សម្គាល់ រួមមាន ការបង្កើតក្រុមការងារបច្ចេកទេសប្រែប្រួលអាកាសធាតុ ដើម្បីអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជានៅក្នុងវិស័យបរិស្ថាន ការធ្វើសមាហរណកម្មការប្រែប្រួលអាកាសធាតុទៅក្នុង*យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣* របស់រាជរដ្ឋាភិបាលកម្ពុជា ការផ្តល់អាទិភាពលើការអភិវឌ្ឍប្រកបដោយចីរភាពនិងបរិយាប័ន្ន រួមទាំង ការធានាចីរភាពបរិស្ថាននិងការរៀបចំខ្លួនឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ការបង្កើនចំណាយសាធារណៈប្រចាំឆ្នាំ សម្រាប់កម្មវិធីទប់ទល់នឹងការប្រែប្រួលអាកាសធាតុនិងផែនការសកម្មភាពប្រែប្រួលអាកាសធាតុតាមវិស័យ យុទ្ធសាស្ត្រនិងគោលនយោបាយកំណើនសេដ្ឋកិច្ចបៃតង ការផ្តល់

សច្ចាប័នលើកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីអាកាសធាតុ ការផ្តល់សច្ចាប័នលើកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីសម្ព័ន្ធភាពថាមពលព្រះអាទិត្យអន្តរជាតិ និងការចូលរួមចំណែករបស់ជាតិដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (NDC)។

ការចូលរួមចំណែករបស់ជាតិ ដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ដែលបានផ្តល់ជូនរបាយការណ៍លើកទី១ ទៅលេខាធិការដ្ឋានអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ និងកំពុងរៀបចំរបាយការណ៍បច្ចុប្បន្នភាព ដោយបានឆ្លុះបញ្ចាំងពីលទ្ធផលពាក់ព័ន្ធនឹងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដូចខាងក្រោម៖

- អាចកាត់បន្ថយបានប្រហែល២៧% (៣ ១០០ Gg CO2eq) នៃការបញ្ចេញឧស្ម័នសរុប ១១ ៦០០ Gg CO2eq នៅឆ្នាំ២០៣០ ក្នុងវិស័យថាមពល កម្មន្តសាល និងដឹកជញ្ជូន។
- អាចរក្សាគម្របព្រៃឈើបាន៤៨,១៥% នៃផ្ទៃដីសរុប ហើយដែលត្រូវបានព្យាករណ៍ថាអាចកាត់បន្ថយការបញ្ចេញឧស្ម័នបាន៤,៧ tCO2eq /ហិចតា/ឆ្នាំ។
- កំណត់គោលដៅកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ឱ្យមកនៅទាបបំផុតនៅត្រឹម៧ ៨៩៧ GgCO2 នៅឆ្នាំ២០៣០ ធៀបនឹង១៨ ៩៩២ GgCO2 នៅឆ្នាំ២០១០។

## តារាង ៤.១៣៖ វឌ្ឍនភាពគោលដៅទី១៣ នៃ គ.អ.ច.ក.

| | ចំណុចដៅ/សូចនាករ | ឯកតា | ២០១៥ | ចំណុចដៅ គអ.ច.ក. | | | | ជាក់ស្តែង | | | | វឌ្ឍនភាព |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | |
| **១៣.១** | **ពង្រឹងសមត្ថភាពធន់ទ្រាំនិងភាពបន្សាំទៅនឹងគ្រោះធម្មជាតិនិងគ្រោះមហន្តរាយពាក់ព័ន្ធនឹងអាកាសធាតុ សម្រាប់គ្រប់ប្រទេស។** | | | | | | | | | | | **ស្ថិតិលើគន្លង ទៅសម្រេចបាន** |
| ១៣.១.១ | ភាគរយនៃឃុំ/សង្កាត់ងាយរងគ្រោះទៅនឹងការប្រែប្រួលអាកាសធាតុ។ | % | ៤៧ | ៤៣ | - | - | ៣៩ | ៤៣ | ៤២ | ៤០ | ៣៦,៣ | ស្ថិតិលើគន្លង ទៅសម្រេចបាន |
| **១៣.២** | **បញ្ជ្រាបវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ក្នុងគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការជាតិ** | | | | | | | | | | | **ស្ថិតិលើគន្លង ទៅសម្រេចបាន** |
| ១៣.២.១ | ភាគរយនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីសកម្មភាពកាត់បន្ថយ នៅពេលដែលប្រៀបធៀបសេណារីយ៉ូបញ្ចេញឧស្ម័នតាមទម្លាប់។ | % | ៣,៥ (២០១៦) | ៣,៥ | ៤,៨០ | ៦,១០ | ៧,៤០ | ៣,៨៥ | ៥,២៨ | ៦,៧១ | ៧,៤៣ | ស្ថិតិលើគន្លង ទៅសម្រេចបាន |
| ១៣.២.២ | ភាគរយនៃការប្រែប្រួលចំណាយសាធារណៈសម្រាប់ការប្រែប្រួលអាកាសធាតុ។ | % | - | ១,២ | ០,៩ | - | | ០,៩ | ១,០ | - | | គ្មានទិន្នន័យ |
| **១៣.៣** | **លើកកម្ពស់ការអប់រំ ការយល់ដឹង និងសមត្ថភាពមនុស្សនិង ស្ថាប័ន ស្តីពីការបន្ធូរបន្ថយការប្រែប្រួលអាកាសធាតុ ការបន្សាំ ការកាត់បន្ថយផលប៉ះពាល់ និងការការត្រៀមបង្ការជាមុន។** | | | | | | | | | | | **ទាបជាងចំណុចដៅ** |
| ១៣.៣.១ | កម្រិតស្ថាប័នដែលបានត្រៀមសម្រាប់ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ដោយបង្ហាញជាភាគរយនៃសមត្ថភាពស្ថាប័នដែលបានបញ្ជ្រាបផ្នែកទាំងប្រាំនៃការប្រែប្រួលអាកាសធាតុ។ | % | - | ២៧ | - | ៤៥ | ៥៣ | - | ៤២ | ៤៩ | ៤៨,២ | ស្ថិតិលើគន្លង ទៅសម្រេចបាន |
| ១៣.៣.២ | ភាគរយនៃគ្រួសារកសិករដាំដុះដំណាំ ចិញ្ចឹមសត្វ ចិញ្ចឹមត្រី អ្នកនេសាទ និងប្រជាសហគមន៍មូលដ្ឋាន ដែលទទួលការផ្សព្វផ្សាយនិងបណ្តុះបណ្តាល ពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ។ | % | ០,០៦ | ០,០៦ | ០,១២ | ០,១៨ | ០,២៤ | ០,០១ | ០,០២ | ០,០២ | ០,០៣ | ទាបជាង ចំណុចដៅ |

*ប្រភព៖ ក្របខ័ណ្ឌ គ.អ.ច.ក. និង ក្រសួង ស្ថាប័ន*

ក្រសួងបរិស្ថានក៏បានសម្របសម្រួលក្នុងការអនុវត្តសកម្មភាពជាអាទិភាពមួយចំនួន ជាមួយក្រសួង ស្ថាប័ននានា ដើម្បីធ្វើឱ្យកម្ពុជាធន់នឹងការប្រែប្រួលអាកាសធាតុ រួមមាន៖

- ការគ្រប់គ្រងនិងអភិវឌ្ឍនធនធានទឹក រួមទាំងការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រ។

- ការគ្រប់គ្រងទឹកជំនន់ ទឹកប្រៃ និងគ្រោះរាំងស្ងួត។
- ការការពារនិងអភិរក្សធនធានទឹក។
- ការគ្រប់គ្រងព័ត៌មានស្តីពីធនធានទឹកនិងឧតុនិយម។
- ការអនុវត្តនូវបច្ចេកទេសកសិកម្មដែលធន់នឹងអាកាសធាតុ
- ការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផែនការយុទ្ធសាស្ត្រតាមវិស័យនានា ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។
- ការពង្រឹងសមត្ថភាពនិងចំណេះដឹងពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ជូនទៅដល់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ និង
- ការសម្របសម្រួល និងកៀរគរហិរញ្ញប្បទានសម្រាប់គាំទ្រដល់សកម្មភាពអាកាសធាតុ។

## បញ្ហាប្រឈម

គោលដៅទី១៣ នៃ គ.អ.ច.ក. មានបញ្ហាប្រឈមមួយចំនួន ដូចខាងក្រោម៖

- ប្រភពនិងប្រភេទទិន្នន័យនៅមានកម្រិតសម្រាប់វាស់វែងសមិទ្ធផលនិងវឌ្ឍនភាពរបស់សូចនាករនីមួយៗ។
- សមត្ថភាពនិងធនធាននៅមានកម្រិត រួមទាំងធនធានមនុស្ស ហិរញ្ញប្បទាន និងការគាំទ្របច្ចេកទេស ក្នុងការអនុវត្តសូចនាករនិងសកម្មភាពដែលបានស្នើឡើងក្នុង គ.អ.ច.ក.។
- ការចូលរួមរបស់យេនឌ័រនៅក្នុងសកម្មភាពការប្រែប្រួលអាកាសធាតុ នៅមានកម្រិត។
- ការអនុវត្តយន្តការក្នុងការសម្របសម្រួលរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីអនុវត្ត គ.អ.ច.ក. នៅថ្នាក់ក្រោមជាតិ នៅមិនទាន់មានភាពល្អប្រសើរនៅឡើយ។

## បទពិសោធន៍ល្អ

- មានការសម្របសម្រួលនិងសហការល្អ ជាមួយស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ តំបន់អាស៊ាន និងអន្តរជាតិ ព្រមទាំងកៀរគរការគាំទ្រទាំងផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុ។
- ពង្រឹងតួនាទីនិងការទទួលខុសត្រូវរបស់ក្រុមការងារ គ.អ.ច.ក. ដើម្បីធានាថា សូចនាករនីមួយៗត្រូវបានអនុវត្ត និងតាមដានត្រួតពិនិត្យ។
- ផ្ទេរធនធានសម្រាប់អនុវត្តសូចនាករ គ.អ.ច.ក.នៅថ្នាក់ក្រោមជាតិ។

## គោលនយោបាយឬយុទ្ធសាស្ត្រសំខាន់ៗ

ការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលកម្ពុជា ក្នុងការបញ្ជ្រាបចីរភាពបរិស្ថានធនធានធម្មជាតិ និងការប្រែប្រួលអាកាសធាតុ ទៅក្នុងក្របខ័ណ្ឌអភិវឌ្ឍន៍ជាតិ ត្រូវបានបង្ហាញតាមរយៈការបង្កើតក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព នៅថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៥ ដែលមានសម្តេចអគ្គមហាសេនាបតីតេជោ

នាយករដ្ឋមន្ត្រី ជាប្រធានកិត្តិយស រដ្ឋមន្ត្រីក្រសួងបរិស្ថានជាប្រធាន និងមានតំណាងក្រសួង ស្ថាប័ន អភិបាលរាជធានី ខេត្ត ជាសមាជិក។

បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តកំណែទម្រង់រចនាសម្ព័ន្ធស៊ីជម្រៅ និងកំពុងបង្កើនវិធានការជាប្រព័ន្ធ ដើម្បីកំណត់ការទទួលខុសត្រូវនិងកិច្ចសហប្រតិបត្តិការច្បាស់លាស់រវាងក្រសួង និងស្ថាប័នពាក់ព័ន្ធ ដើម្បីជំរុញឱ្យសម្រេចបាននូវតួនាទីនិងការទទួលខុសត្រូវក្នុងការការពារបរិស្ថាន អភិរក្សជីវៈចម្រុះ និងការអភិវឌ្ឍប្រកបដោយចីរភាព។

ការរៀបចំនិងការអនុវត្តផែនការយុទ្ធសាស្ត្រនិងសកម្មភាពជាតិស្តីពីបរិស្ថាន ២០១៦-២០២៣ គឺដើម្បីបំពេញបន្ថែមដល់យុទ្ធសាស្ត្រថ្នាក់ជាតិ ផែនការសកម្មភាព និងកម្មវិធី។ ផែនការយុទ្ធសាស្ត្រនិងសកម្មភាពជាតិស្តីពីបរិស្ថាន ២០១៦-២០២៣ បានផ្តោតលើការបន្តកិច្ចខិតខំប្រឹងប្រែង ដើម្បីពង្រឹងកិច្ចសហការក្នុងការលើកកម្ពស់ការសម្របសម្រួលក្នុងកម្រិតអន្តរវិស័យ។ ផែនការយុទ្ធសាស្ត្រ និងសកម្មភាពនេះ ក៏បានសង្កត់ធ្ងន់លើប្រធានបទរួម ដូចជា ការអភិវឌ្ឍយេនឌ័រ និងការអនុវត្តគោលនយោបាយពាក់ព័ន្ធនិងឧបករណ៍សេដ្ឋកិច្ច និង ការបញ្ជ្រាបចីរភាពបរិស្ថាននិងធនធានធម្មជាតិទៅក្នុងក្របខ័ណ្ឌអភិវឌ្ឍន៍របស់ប្រទេស។ សេចក្តីព្រាងចុងក្រោយនៃក្រមបរិស្ថាននិងធនធានធម្មជាតិ គឺ ជាគោលនយោបាយជាតិសម្រាប់កំណែទម្រង់បរិស្ថាន។

ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា ២០១៤-២០២៣ ត្រូវបានអនុមតិដោយរាជរដ្ឋាភិបាលកម្ពុជានៅខែវិច្ឆិកា ឆ្នាំ២០១៣ និងស្របតាមការប្តេជ្ញាដែលបានធ្វើឡើងនៅសន្និសីទ Rio+២០ ស្តីពីការអភិវឌ្ឍប្រកបដោយចីរភាព ដែលរួមចំណែកដល់ការសម្រេចបាននូវគោលដៅអភិវឌ្ឍប្រកបដោយចីរភាពសកល និង គ.អ.ច.ក.។ ជាមួយគ្នានេះ ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា បានរួមចំណែកដល់គោលដៅទី១២ នៃ គ.អ.ច.ក. ធានាឱ្យមានចីរភាពក្នុងទម្រង់នៃការប្រើប្រាស់និងផលិតកម្មវឌ្ឍនភាព និង គោលដៅទី១៣ នៃ គ.អ.ច.ក. ចាត់វិធានការបន្ទាន់ដើម្បីប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុនិងផលប៉ះពាល់។ ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា កំពុងអនុញ្ញាតឱ្យមានការធ្វើសមាហរណកម្មការប្រែប្រួលអាកាសធាតុទៅក្នុងផែនការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាពិសេស ទៅក្នុង ផ.យ.អ.ជ. និងផែនការអភិវឌ្ឍន៍តាមវិស័យរបស់ក្រសួងពាក់ព័ន្ធទាំងអស់។

ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា ឆ្នាំ២០១៤-២០២៣ ដែលមានទំនាក់ទំនងជាមួយនឹងយុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍ជាតិ ដូចជា *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ ផ.យ.អ.ជ. ២០១៩-២០២៣* គោលនយោបាយជាតិ និង ផែនការយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍ ២០១៣-២០៣០ ក្របខ័ណ្ឌហិរញ្ញប្បទាន ផែនការជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងផែនការសកម្មភាពតាមវិស័យ ត្រូវបានរៀបចំឡើង។ ដើម្បីបំពេញបន្ថែមលើផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា ឆ្នាំ២០១៤-២០២៣ ក្របខ័ណ្ឌហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុ និងក្របខ័ណ្ឌតាមដានត្រួតពិនិត្យនិងវាយតម្លៃ ត្រូវបានបង្កើតឡើង។

នៅខែធ្នូ ឆ្នាំ២០១៧ ក្រសួងបរិស្ថានបានអនុមតិក្របខ័ណ្ឌតាមដានត្រួតពិនិត្យនិងវាយតម្លៃការប្រែប្រួលអាកាសធាតុជាតិ ដើម្បីតាមដានត្រួតពិនិត្យពីវឌ្ឍនភាពរបស់ប្រទេស ពាក់ព័ន្ធនឹងការដោះស្រាយបញ្ហាប្រឈមដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ ដែលរួមបញ្ចូលទាំងទ្រឹស្តីនៃការផ្លាស់ប្តូរ។ ឯកសារនេះផ្តល់នូវក្របខ័ណ្ឌមួយ ដើម្បីវាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា នៅថ្នាក់ជាតិ ដែលរួមបញ្ចូលទាំងសូចនាករ ទិន្នន័យដើមគ្រា និងចំណុចដៅ។

ក្របខ័ណ្ឌតាមដានត្រួតពិនិត្យនិងវាយតម្លៃ ប្រើប្រាស់វិធីសាស្ត្រតាមដានត្រួតពិនិត្យការបន្សាំ និងវាស់វែងការអភិវឌ្ឍ ដែលជាគោលការណ៍មួយអាចប្រើប្រាស់ដើម្បីវាយតម្លៃថា តើការន្សាំការប្រែប្រួលអាកាសធាតុ អាចនាំទៅរកការអភិវឌ្ឍប្រកបដោយប្រសិទ្ធភាព ហើយការធ្វើអន្តរាគមន៍លើការអភិវឌ្ឍ អាចជួយបង្កើនសមត្ថភាពរបស់សហគមន៍ក្នុងបន្សាំនឹងការប្រែប្រួលអាកាសធាតុ បានឬទេ។

ក្រសួងធនធានទឹកនិងឧតុនិយម នឹងបន្តធានាចីរភាពធនធានទឹក សម្រាប់វិស័យកសិកម្ម សម្រាប់ការផ្គត់ផ្គង់នៅតំបន់ទីក្រុងនិងជនបទ សម្រាប់បង្កើតថាមពលវារីអគ្គិសនី សម្រាប់ការនេសាទ ការដឹកជញ្ជូន និងទេសចរណ៍។ ក្រសួងនឹងបង្កើតយុទ្ធសាស្ត្រនិងផែនការសកម្មភាពសម្រាប់ធនធានទឹក និងឧតុនិយម ២០១៩-២០២៣ ដើម្បីអនុវត្ត *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤* និង *ផ.យ.អ.ជ. ២០១៩-២០២៣*។

លេខាធិការដ្ឋាន គ.ជ.អ.ប បានក្លាយឱ្យទៅជាស្ថាប័នទទួលបានមូលនិធិបៃតងនិងការប្រែប្រួលអាកាសធាតុ (GCF) និងបានរៀបចំគោលនយោបាយស្តីពីសុវត្ថិភាពបរិស្ថាននិងសង្គម សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ នៅថ្នាក់ក្រោមជាតិ។

## គោលដៅទី១៤៖ អភិរក្សនិងប្រើប្រាស់ប្រកបដោយចីរភាពនូវមហាសមុទ្រ សមុទ្រ និងធនធានសមុទ្រ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព

### វឌ្ឍនភាព

ដើម្បីអភិរក្សនិងប្រើប្រាស់ មហាសមុទ្រ សមុទ្រ និងធនធានសមុទ្រប្រកបដោយចីរភាព *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤* បានកំណត់នូវអាទិភាពមួយចំនួន ដូចជា បន្តអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីកំណើនបៃតង ២០១៣-២០៣០ ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា ២០១៤-២០២៣ ផែនការយុទ្ធសាស្ត្រនិងសកម្មភាពជាតិស្តីពីបរិស្ថាន ២០១៦-២០២៣ យុទ្ធសាស្ត្រជាតិ REDD+ និងផែនការយុទ្ធសាស្ត្រជាតិសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ ២០១៧-២០៣១។ *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤* ក៏មានគោលដៅបង្កើនប្រសិទ្ធភាពនៃការការពារបរិស្ថាននិងការអភិរក្សធនធានធម្មជាតិ ប្រព័ន្ធអេកូឡូស៊ី ជីវៈចម្រុះ ព្រៃឈើ និងសត្វព្រៃ ព្រមទាំងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងពង្រឹងការគ្រប់គ្រងសំណល់រឹង ទឹកកខ្វក់ ឧស្ម័ននិងសារជាតុដែលមាន

គ្រោះថ្នាក់ ដោយការអនុវត្តគោលការណ៍ "កាត់បន្ថយ ប្រើប្រាស់ឡើងវិញ កែច្នៃ និងមិនប្រើប្រាស់" និងពង្រឹងយន្តការតាមដាននិងត្រួតពិនិត្យការបំពុល។

ឧទ្យានជាតិសមុទ្រកោះរ៉ុងត្រូវបានបង្កើតឡើង ដើម្បីធានា ការថែរក្សានិងការពារសោភ័ណ្ឌភាពធម្មជាតិ វប្បធម៌ ប្រព័ន្ធអេកូឡូស៊ី និងជីវៈចម្រុះ នៅលើកោះនិងជុំវិញ ការរក្សាលំនឹងបរិស្ថាន ការការពារនិងអភិរក្សធនធានធម្មជាតិ និង រួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយធម្មជាតិ និង លើកកម្ពស់ការចូលរួមរបស់សហគមន៍មូលដ្ឋាន ក៏ដូចជាពីសាធារណជនក្នុងការរួមចំណែកគ្រប់គ្រង ការពារ និងអភិរក្ស ជីវៈចម្រុះ និងធនធានធម្មជាតិ នៅក្នុងតំបន់។ ទន្ទឹមនឹងនេះ ដើម្បីគាំទ្រដល់គោលដៅការពារ អភិរក្សធនធានសមុទ្រប្រកបដោយចីរភាព និងធានានិរន្តរភាពនៃកំណើនការអភិវឌ្ឍសេដ្ឋកិច្ចជាតិនៅបណ្តាខេត្តតំបន់ឆ្នេរ ក្រសួងបរិស្ថានបានបន្តអនុវត្តផែនការសកម្មភាពគ្រប់គ្រងការបំពុលសមុទ្រពីដីគោក តាមរយៈការពង្រឹងសមត្ថភាពនិងការប្រគល់មុខងារគ្រប់គ្រងសំរាម សំណល់រឹង និងទឹកកខ្វក់នៅតំបន់ទីប្រជុំជន ឱ្យដល់រដ្ឋបាលថ្នាក់ក្រោមជាតិ (ក្រុង ស្រុក ខណ្ឌ សង្កាត់ និងឃុំ) រួមនឹងការផ្តល់ប្រឹក្សាបច្ចេកទេស ធនធានហិរញ្ញវត្ថុ សម្រាប់គាំទ្រការអនុវត្តមុខងារដែលបានប្រគល់។ ជាមួយគ្នានេះ ក្រសួងបរិស្ថានបានជំរុញឱ្យអនុវត្តការវាយតម្លៃផលប៉ះពាល់បរិស្ថាននិងសង្គម សម្រាប់គ្រប់គម្រោងអភិវឌ្ឍន៍ រួមទាំង គម្រោងឧស្សាហកម្ម ទេសចរណ៍ ថាមពល និង វារីវប្បកម្ម។ល។ ជាមួយគ្នានេះ ក្រសួងក៏បានកំណត់វិធានការទប់ស្កាត់ កាត់បន្ថយ និងស្តារបញ្ហាបំពុលបរិស្ថានពីគម្រោងអភិវឌ្ឍន៍ក្នុងផែនការគ្រប់គ្រងបរិស្ថាន (EMP) រួមជាមួយនឹងការពង្រឹងយន្តការតាមដានត្រួតពិនិត្យជាប្រចាំ លើការគ្រប់គ្រងបញ្ហាបំពុលបរិស្ថាន និងការបញ្ចេញសំណល់នៅគ្រប់ទីតាំងគម្រោងអភិវឌ្ឍន៍ ដើម្បីធានាថា បរិស្ថានសមុទ្រត្រូវបានការពារប្រកបដោយបរិយាប័ន្ន និងសម្រាប់ប្រើប្រាស់ប្រកបដោយចីរភាពដល់កូនចៅជំនាន់ក្រោយ។

ផែនការយុទ្ធសាស្ត្រនិងសកម្មភាពជាតិស្តីពីបរិស្ថាន ២០១៦-២០២៣ ត្រូវបានរៀបចំឡើង ដើម្បីកំណត់នូវតម្រូវការ និងកាលានុវត្តភាពសម្រាប់ចីរភាពបរិស្ថាននិងធនធានធម្មជាតិ ដែលជាកត្តាស្នូលនៅក្នុងក្របខណ្ឌអភិវឌ្ឍន៍ជាតិ។ ពាក់ព័ន្ធនឹងការការពារសមុទ្រនិងឆ្នេរសមុទ្រ យុទ្ធសាស្ត្រនេះ ក៏តម្រូវឱ្យមានការពង្រឹងការសម្របសម្រួលក្នុងការស្វែងរកប្រេងនិងឧស្ម័ន ដោយរួមទាំង ការរុករក និងការធ្វើអាជីវកម្ម ការដឹកជញ្ជូន និងសមត្ថភាពឆ្លើយតបជាបន្ទាន់ចំពោះគ្រោះថ្នាក់ដែលអាចកើតមាន ដូចជា ការលេចប្រេង និងទំនិញគ្រោះថ្នាក់។ ក្របខ័ណ្ឌតាមដានត្រួតពិនិត្យនិងវាយតម្លៃរបស់យុទ្ធសាស្ត្រនេះ មានសូចនាករ ដែលត្រូវបានដាក់បញ្ចូលក្នុងគោលដៅទី១៤ នៃ គ.អ.ច.ក.។

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ក៏បានបង្កើតក្របខ័ណ្ឌផ្តល់ហិរញ្ញប្បទានដល់ផែនការជាតិបន្សាំកម្ពុជា និងផែនការអនុវត្តន៍ នៅឆ្នាំ២០១៧ ដើម្បីបន្សីុជាមួយ ផែនការយុទ្ធសាស្ត្រនិងសកម្មភាពជាតិស្តីពីបរិស្ថាន ២០១៦-២០២៣ ក្នុងគោលបំណងកៀរគរធនធានសម្រាប់សកម្មភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុ ដែលរួមបញ្ចូលទាំងសកម្មភាពស្តារឡើងវិញនិងការពារឆ្នេរសមុទ្រនិង

តំបន់ឆ្នេរ។ ក្រសួងបរិស្ថានក៏បានរៀបចំផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា ២០១៤-២០២៣ ដែលគោលបំណងជានានូវភាពធន់នឹងការប្រែប្រួលអាកាសធាតុនៃប្រព័ន្ធអេកូឡូស៊ីសំខាន់ៗ (ដូចជា បឹងទន្លេសាប ទន្លេមេគង្គ ប្រព័ន្ធអេកូឡូស៊ីតំបន់ឆ្នេរ តំបន់ខ្ពង់រាប) ជីវៈចម្រុះ តំបន់ការពារ និងតំបន់បេតិកភណ្ឌវប្បធម៌។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រជលផល ២០១០-២០១៩ សម្រាប់គ្រប់គ្រងធនធានជលផលទឹកសាបនិងទឹកប្រៃ។ ក្របខ័ណ្ឌនេះមានគោលបំណងសំខាន់ក្នុងការគាំទ្រនិងបង្កើនសមត្ថភាពដឹកជញ្ជូនដីសើម (ជាពិសេស ដីស្រែ)។ ចំណុចដៅសម្រាប់ការការពារសេវាអេកូឡូស៊ី ជលផលទន្លេ និងបឹង ចាំបាច់ត្រូវទ្រទ្រង់នូវភាពបែបនិងចំនួនត្រី។ អន្តរាគមន៍យុទ្ធសាស្ត្រសំខាន់ៗផ្តោតលើ (១) ការពារនិងថែរក្សាប្រព័ន្ធអេកូឡូស៊ី ដើម្បីគាំទ្រដល់ការនេសាទត្រីនៅគ្រប់កម្រិតឱ្យបានគ្រប់គ្រាន់និងមាននិរន្តភាព សម្រាប់បំពេញតម្រូវការ (២) បង្កើនការចិញ្ចឹមត្រីតាមវាលស្រែ (៣) គាំទ្រដល់កំណើននៃការវារីវប្បកម្មខ្នាតតូច មធ្យម និងធំ (៤) អភិវឌ្ឍជលផលសមុទ្រ (៥) កែលម្អការកែច្នៃក្រោយការប្រមូលផល (៦) លើកកម្ពស់ផលិតកម្មត្រី និងផលិតផលនេសាទនៅក្នុងទីផ្សារជាតិនិងអន្តរជាតិ និង (៧) គាំទ្រដល់ការធ្វើពិពិធកម្មការចិញ្ចឹមជីវិតក្រៅពីការនេសាទ ជាពិសេស សម្រាប់ប្រជាជនក្រីក្រ និងជនងាយរងគ្រោះ ដើម្បីជួយពួកគេអាចរួចផុតពីភាពក្រីក្រ។

## តារាង ៤.១៤÷ វឌ្ឍនភាពគោលដៅទី១៤ នៃ គ.អ.ច.ក.

| | ចំណុចដៅ/សូចនាករ | ឯកតា | ២០១៥ | ចំណុចដៅ គអ.ច.ក. | | | | ជាក់ស្តែង | | | | វឌ្ឍនភាព |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | |
| ១៤.១ | ត្រឹមឆ្នាំ២០២៥ ការពារ និងកាត់បន្ថយឱ្យបានច្រើន ការបំពុលគ្រប់ប្រភេទនៅក្នុងសមុទ្រ ជាពិសេស ពីបណ្តាសកម្មភាពនានាដែលផ្តើមចេញពីលើដី រួមទាំង ការបំពុលដោយសំណល់ក្នុងសមុទ្រ និងអាហារបំប៉ន។ | | | | | | | | | | | ស្ថិតិលើគន្លង ទៅសម្រេចបាន |
| ១៤.១.១ | ភាគយនៃការកាត់បន្ថយការបំពុលសមុទ្រ តាមរយៈសកម្មភាពអភិរក្សសមុទ្រ។ | % | ៤០,០ | ៤០,០ | ៤០,០ | ៤០,០ | ៤០,០ | - | - | - | | គ្មានទិន្នន័យ |
| ១៤.២ | ត្រឹមឆ្នាំ២០២០ គ្រប់គ្រងឱ្យបានច្រើន និងការពារប្រព័ន្ធអេកូឡូស៊ីនៅក្នុងសមុទ្រនិងតាមឆ្នេរ ដើម្បីចៀសវាងផលប៉ះពាល់អវិជ្ជមាននានា រួមទាំង តាមរយៈការពង្រឹង ភាពធុនរបស់វា និងដំណើរការសកម្មភាព សម្រាប់ធ្វើឱ្យមាន ភាពដូចដើមវិញ ដើម្បីសម្រេចឱ្យបាន នូវមហាសាគរដែលមានផលិតភាពនិងសុខភាព។ | | | | | | | | | | | ស្ថិតិលើគន្លង ទៅសម្រេចបាន |
| ១៤.២.១ | មុខងារនិងសេវាសំខាន់ៗរបស់ប្រព័ន្ធអេកូឡូស៊ីសមុទ្រនិងតំបន់ឆ្នេរ ត្រូវបានថែរក្សានិងស្តារតាមការចាំបាច់។ | % | ៥០ (២០១៧) | | ៥០ | ៥០ | 50.0 | - | - | - | | គ្មានទិន្នន័យ |
| ១៤.២.២ | ភាគរយនៃផ្ទៃដីព្រៃលិចទឹក និងព្រៃកោងកាង ដែលត្រូវបានដាំឡើងវិញនិងការពារ។ | % | ៧,០ (២០១៧) | ៧,០ | ១០,០ | ១៥,០ | ២០,០ | ៦,៦៦ | ១៣,៣៣ | ២០,០ | ២២,០ | ស្ថិតិលើគន្លង ទៅសម្រេចបាន |
| ១៤.៥ | ត្រឹមឆ្នាំ២០២០ អភិរក្សយ៉ាងតិច ១០% នៃតំបន់ឆ្នេរនិងតំបន់ក្នុងសមុទ្រ ឱ្យស្របគ្នានឹងច្បាប់ជាតិនិងអន្តរជាតិ និងផ្អែកលើព័ត៌មានវិទ្យាសាស្ត្រ។ | | | | | | | | | | | ស្ថិតិលើគន្លង ទៅសម្រេចបាន |
| ១៤.៥.១ | ភាគរយនៃទំហំតំបន់អភិរក្សជលផល ទាំងតំបន់ឆ្នេរ និងទឹកសាប ដែលបានការពារ។ | % | ២០,០ (២០១៦) | ២០,០ | ២៥,០ | ៣០,០ | ៣៥,០ | ២០,០ | ២៥,០ | ៣០,០ | ៣៥,០ | ស្ថិតិលើគន្លង ទៅសម្រេចបាន |
| ១៤.៧ | ត្រឹមឆ្នាំ២០៣០ បង្កើនផលប្រយោជន៍ពីសេដ្ឋកិច្ចដល់បណ្តារដ្ឋដែនកោះតូចៗកំពុងអភិវឌ្ឍ និងបណ្តាប្រទេសដែលមានការអភិវឌ្ឍតិចតួច ពីការប្រើប្រាស់ធនធានក្នុងសមុទ្រប្រកបដោយចីរភាព រួមទាំងតាមរយៈ ការគ្រប់គ្រងប្រកបដោយចីរភាពនូវការនេសាទ ជលវប្បកម្ម និងទេសចរណ៍។ | | | | | | | | | | | ទាបជាងចំណុចដៅ |
| ១៤.៧.១ | ភាគរយនៃតម្លៃរបស់ផលិតផលជលផលនិងវារីវប្បកម្ម សមុទ្រធៀបនឹង ផ.ស.ស. | % | ៧,៥ (២០១៦) | ៧,៥ | ៧,៦ | ៧,៧ | ៧,៨ | ៧,៥ | ៧,០ | ៧,០ | ៧,០ | ទាបជាងចំណុចដៅ |
| ១៤.b | ផ្តល់នូវការទទួលបានធនធានសមុទ្រនិងទីផ្សារចំពោះអ្នកនេសាទជាសិល្បៈធុនតូច។ | | | | | | | | | | | ស្ថិតិលើគន្លង ទៅសម្រេចបាន |
| ១៤.b.១ | ភាគរយនៃធនធានសមុទ្រដែលអ្នកនេសាទខ្នាតតូចទទួលបាននិងលក់លើទីផ្សារមានស្ថិរភាព | % | ៧០,០ (២០១៦) | ៧០,០ | ៧០,០ | ៧០,០ | ៧០,០ | ៦០,០ | ៦៥,០ | ៦៨,០ | ៦៨,០ | ស្ថិតិលើគន្លង ទៅសម្រេចបាន |

*ប្រភព÷ ក្របខ័ណ្ឌ គ.អ.ច.ក. និង ក្រសួង ស្ថាប័ន*

## បញ្ហាប្រឈម

ទន្ទឹមនឹងកិច្ចខិតខំប្រឹងប្រែងរបស់ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តផែនការសកម្មភាព និងវិធានការគ្រប់គ្រងការបំពុលសមុទ្រពីដីគោក ប្រកបដោយបរិយាប័ន្ននិងការទទួលខុសត្រូវ កម្ពុជានៅមានបញ្ហាប្រឈមមួយចំនួនដែលធ្វើឱ្យរាំងស្ទះដល់ការសម្រេចបានគោលដៅទី១៤ នៃ គ.អ.ច.ក.។ បញ្ហាទាំងនោះរួមមាន៖ (១) ការកើនឡើងយ៉ាងខ្លាំងនូវការអភិវឌ្ឍសេដ្ឋកិច្ចនៅតាមបណ្តាខេត្តតំបន់ឆ្នេរ ជាពិសេស ខេត្តព្រះសីហនុលើការអភិវឌ្ឍទីក្រុង កំណើនទេសចរណ៍ ឧស្សាហកម្មផលិតកម្ម សេវាកម្មដឹកជញ្ជូនតាមសមុទ្រ និងវារីវប្បកម្ម (២) ការខ្វះខាតទាំងហេដ្ឋារចនាសម្ព័ន្ធទន់និងរឹង សម្រាប់ធានាដល់ការគ្រប់គ្រងសំណល់និងសារធាតុគីមីពុល ប្រកបដោយសុវត្ថិភាពបរិស្ថាន និងបរិយាប័ន្ន និង ការទប់ស្កាត់បញ្ហាបំពុលបរិស្ថានសមុទ្រ។

ការស្រាវជ្រាវនិងការអភិវឌ្ឍក្នុងផ្នែកវារីវប្បកម្មនៅមានកម្រិតនៅឡើយ ហើយទោះបីជាមានការប្រឹងប្រែងជាច្រើនត្រូវបានធ្វើឡើងដោយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីបង្ក្រាបសកម្មភាពនេសាទខុសច្បាប់ក៏ដោយ ក៏បញ្ហានេះនៅតែបន្តមាន។

ធនធានតំបន់ឆ្នេរប្រឈមមុខនឹងសម្ពាធបរិស្ថានមួយចំនួន រួមមាន ការនេសាទលើសបរិមាណ និងការធ្វើអាជីវកម្មព្រៃឈើ និងប្រព័ន្ធអេកូឡូស៊ីព្រៃកោងកាង ដែលនាំមកនូវការកើនឡើងនៃសំណឹកដី។ ការប្រែប្រួលអាកាសធាតុបានបន្ថែមលើបញ្ហាប្រឈមដែលមានស្រាប់ តាមរយៈការកើនឡើងនូវកម្រិតទឹកសមុទ្រ ការជ្រៀតចូលរបស់ទឹកប្រៃ និងសំណឹកឆ្នេរសមុទ្រ។ បញ្ហាទាំងនេះរួមចំណែកដល់ការរួមតូចនៃផ្ទៃដីដាំដំណាំ កាត់បន្ថយប្រភពទឹកសាប និងបាត់បង់ហេដ្ឋារចនាសម្ព័ន្ធឆ្នេរសមុទ្រ។

## គោលនយោបាយឬយុទ្ធសាស្ត្រសំខាន់ៗ

រាជរដ្ឋាភិបាលកម្ពុជា នៅក្នុងរបៀបវារៈគោលនយោបាយ ក្នុងនីតិកាលទី៦ នៃរដ្ឋសភាបានដាក់ចេញនូវ*យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ (២០១៨-២០២៣)* ដោយបានកំណត់ក្របខ័ណ្ឌវិស័យអាទិភាពចំនួន៤ ដែលក្នុងនោះ *ការអភិវឌ្ឍប្រកបដោយចីរភាពនិងបរិយាប័ន្ន* ត្រូវបានដាក់នៅក្នុង*យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤* សំដៅផ្តោតការយកចិត្តទុកដាក់លើ វិធានការទប់ស្កាត់ការបំពុលបរិស្ថាន និងការបំពុលសមុទ្រ។ ក្របខ័ណ្ឌវិស័យអាទិភាពទាំង៤រួមមាន (១) ការថែរក្សាប្រព័ន្ធអេកូឡូស៊ី ការការពារជីវចម្រុះតំបន់ឆ្នេរ និងចីរភាពប្រភពទឹក (២) ការរៀបចំនិងជំរុញការអនុវត្តផែនការមេហេដ្ឋារចនាសម្ព័ន្ធទីក្រុង និងតំបន់ទីប្រជុំជនសំខាន់ៗ សម្រាប់គាំទ្រដល់ការអភិវឌ្ឍ ជាពិសេសប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ និង (៣) ការបន្តពង្រឹងការគ្រប់គ្រងសំណល់រឹង រាវ ឧស្ម័ន

និងសារធាតុគីមីគ្រោះថ្នាក់ តាមរយៈគោលការណ៍ 3R ព្រមទាំងការពង្រឹងយន្តការតាមដានត្រួតពិនិត្យប្រភពបំពុល។

រាជរដ្ឋាភិបាលកម្ពុជាក៏នឹងបន្តការកសាងសមត្ថភាពសហគមន៍នេសាទ ដែលត្រូវបានបង្កើតឡើង ដើម្បីធានាមិនឱ្យមានបទល្មើសនេសាទទឹកសាបនិងទឹកប្រៃ និងបន្តពង្រឹងការគ្រប់គ្រងនិងអភិរក្សធនធានទឹកប្រកបដោយចីរភាព យោងតាមក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រជលផល ២០១៥-២០២៤ និងសេចក្តីថ្លែងការណ៍នយោបាយស្តីពី ការបង្ការបទល្មើសជលផល។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលនឹងបង្កើនការផលិតនិងការផ្គត់ផ្គង់វារីវប្បកម្ម ដោយផ្តល់ការគាំទ្រដល់កសិដ្ឋានចិញ្ចឹមត្រី តាមរយៈបច្ចេកទេស ពូជ ឥណទាន និងទីផ្សារ។

## គោលដៅទី១៥ : ការពារ ស្តារ និងជំរុញការប្រើប្រាស់ប្រកបដោយចីរភាពនូវប្រព័ន្ធអេកូឡូស៊ីលើដែនគោក គ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព ប្រយុទ្ធប្រឆាំងនឹងឱនភាពដី បញ្ឈប់និងបង្វែរទិសនៃការសឹករេចរិលគុណភាពដី និងបញ្ឈប់កុំឱ្យ បាត់បង់ជីវជាតិដីនិងជីវៈចម្រុះ

### វឌ្ឍនភាព

កម្ពុជាសម្រេចបាននូវវឌ្ឍនភាពល្អក្នុងការអភិវឌ្ឍ និង ក្នុងការអនុវត្តគោលនយោបាយយុទ្ធសាស្ត្រ និងបទប្បញ្ញត្តិស្តីពីជីវចម្រុះ/សេវាប្រព័ន្ធអេកូឡូស៊ី។ នៅឆ្នាំ២០១៥ កម្ពុជាបានបង្កើតនិងអនុវត្តគោលនយោបាយយុទ្ធសាស្ត្រនិងបទបញ្ជាចំនួន៦ ស្តីពីសេវាកម្មប្រព័ន្ធអេកូឡូស៊ី។ នៅឆ្នាំ២០១៦ ឆ្នាំ២០១៧ និងឆ្នាំ២០១៨ ចំនួនគោលនយោបាយ យុទ្ធសាស្ត្រ និងបទប្បញ្ញត្តិដែលបានរៀបចំនិងអនុវត្ត លើសពីចំនួនកំណត់នៅក្នុង គ.អ.ច.ក.។ ការវាយតម្លៃអំពីការគ្របដណ្តប់ព្រៃឈើនៅឆ្នាំ២០១៦ បង្ហាញថា កម្ពុជាមានគម្របព្រៃឈើចំនួន៤៨,១៥% ដោយមានការប្រែប្រួលប្រមាណ០,៧% ក្នុងមួយឆ្នាំ។ ដើម្បីដោះស្រាយបញ្ហានេះ តំបន់អភិរក្សកាន់តែច្រើនត្រូវបានបង្កើតឡើង។ បច្ចុប្បន្ននេះ តំបន់អភិរក្សបានគ្របដណ្តប់ប្រមាណ៤១% នៃផ្ទៃប្រទេស។ ផែនការយុទ្ធសាស្ត្រជាតិគ្រប់គ្រងតំបន់អភិរក្ស ២០១៧-២០៣១ ត្រូវបានដាក់ឱ្យប្រើប្រាស់។ រាជរដ្ឋាភិបាលកម្ពុជា តាមរយៈសេចក្តីជូនដំណឹងលេខ ៨៧.សជណ.ដប ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៩ បានអនុញ្ញាតឱ្យក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងក្រសួងបរិស្ថាន រៀបចំបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវ និងភិរក្សកេសរកូល សុខ អាន ភ្នំគូលែន ក្នុងគោលបំណងដើម្បី (១) សិក្សាស្រាវជ្រាវនិងកំណត់អត្តសញ្ញាណប្រភេទកេសរកូលព្រៃតាមបែបវិទ្យាសាស្ត្រ (២) អភិរក្ស សង្គ្រោះ និងស្តារប្រភេទកេសរកូលព្រៃ និងប្រភេទរុក្ខជាតិដែលកំពុងរងការគំរាមកំហែង និងជិតផុតពូជពីព្រៃធម្មជាតិ (៣) អប់រំផ្សព្វផ្សាយ និងបណ្តុះបណ្តាលចំណេះដឹងស្តីពីកេសរកូលព្រៃ និងប្រភេទរុក្ខជាតិនៅកម្ពុជា និង (៤) ផ្តល់ជាទីតាំងទស្សនីយភាពកេសរកូលព្រៃធម្មជាតិ និងជាកន្លែងលំហែកាយ ទស្សនាធម្មជាតិ និងការកំសាន្តនានា។

ប្រទេសកម្ពុជាបានបង្កើតគេហទំព័ររួមមួយសម្រាប់អនុសញ្ញារីយ៉ូ ដោយផ្ដោតការយកចិត្តទុកដាក់នៅក្នុងដំណាក់កាលដំបូងស្ដីពីការគ្រប់គ្រងតំបន់ការពារធម្មជាតិប្រកបដោយនិរន្តរភាព និងការស្ដារប្រព័ន្ធអេកូឡូស៊ី។ ក្រៅពីនេះ ប្រទេសកម្ពុជាបានរៀបចំផែនការកសាងសមត្ថភាពរយៈពេល ៥ឆ្នាំ ដើម្បីគាំទ្រដល់ការដាក់បញ្ចូលគ្នានូវគ្រប់ផ្នែកទាំងអស់ក្នុងចំណោមអនុសញ្ញារីយ៉ូទាំង៣ ក្នុងនោះរួមមាន កិច្ចប្រតិបត្តិការ មុខងារនៃគេហទំព័ររួម យន្តការសម្របសម្រួល និងការផ្លាស់ប្ដូរព័ត៌មាន។ ការលើកកម្ពស់ទំនាក់ទំនងគ្នាក្នុងចំណោមអនុសញ្ញារីយ៉ូទាំងបី នឹងផ្ដល់ផលប្រយោជន៍យ៉ាងច្រើនបន្ថែមទៀត ដូចជាប្រសិទ្ធភាពនៃការប្រើប្រាស់ធនធាន ជាដើម ។

## តារាង ៤.១៥÷ វឌ្ឍនភាពគោលដៅទី១៥ នៃ គ.អ.ច.ក.

| | ចំណុចដៅ/សូចនាករ | ឯកតា | ២០១៥ | ចំណុចដៅ គ.អ.ច.ក. | | | | ជាក់ស្ដែង | | | | វឌ្ឍនភាព |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | |
| ១៥.១ | ត្រឹមឆ្នាំ២០២០ ធានាការអភិរក្ស ការស្ដារនិងការប្រើប្រាស់ប្រកបដោយចីរភាពនូវប្រព័ន្ធអេកូឡូស៊ីក្នុងទឹកសាបនៅដែនកោះ និងនៅលើគោក និងសេវា ជាពិសេស ព្រៃឈើ ដីសើម ភ្នំ និងដីស្ងួត ឱ្យស្របតាមកតព្វកិច្ចក្រោម កិច្ចព្រមព្រៀងអន្តរជាតិ។ | | | | | | | | | | | ស្ថិតិលើគន្លង ទៅសម្រេចបាន |
| ១៥.១.១ | ភាគរយនៃផ្ទៃដីគ្របដណ្ដប់ដោយព្រៃឈើ ធៀបនឹងផ្ទៃដីសរុប | % | ៤៨,៨ (២០១៦) | ៤៨,៨ | | ៤៨,១ | | - | - | ៤៧,០ | ៤៧,០ | ស្ថិតិលើគន្លង ទៅសម្រេចបាន |
| ១៥.១.២ | ភាគរយនៃតំបន់ដែលមានជីវៈចម្រុះក្នុងទឹកនិងលើដីគោក ដែលគ្របដណ្ដប់ដោយតំបន់ការពារនិងតំបន់អភិរក្សជលផល បែងចែកតាមប្រភេទនៃប្រព័ន្ធអេកូឡូស៊ី | % | ១០ (២០១៦) | ១០,០ | ១២,០ | ១៥,០ | ១៧,០ | ១០,០ | ១២,០ | ១៥,០ | ១៧,០ | ស្ថិតិលើគន្លង ទៅសម្រេចបាន |
| ១៥.១.៣ | ផ្ទៃដីព្រៃឈើ និងប្រព័ន្ធអេកូឡូស៊ី ដែលត្រូវបានប្រើប្រាស់ប្រកបដោយចីរភាព | % | ៥០ (២០១៦) | ៥០ | | | | ៥៥,០ | - | - | ៥៥,០ | ស្ថិតិលើគន្លង ទៅសម្រេចបាន |
| ១៥.២ | ត្រឹមឆ្នាំ២០២០លើកកម្ពស់ការអនុវត្តការគ្រប់គ្រងប្រកបដោយចីរភាពនូវ ព្រៃឈើគ្រប់ប្រភេទ កាត់បន្ថយឱ្យបាន ពាក់កណ្ដាលនូវការបំផ្លាញព្រៃឈើព្រៃឈើដែលបាត់បង់ និងបង្កើនឱ្យបាន ច្រើនជាសកលការដាំដើមឈើ និងការដាំព្រៃឈើឡើងវិញ។ | | | | | | | | | | | ស្ថិតិលើគន្លង ទៅសម្រេចបាន |
| ១៥.២.១ | ភាគរយនៃតំបន់ព្រៃឈើដែលទទួលបានការការពារនិងគ្រប់គ្រងប្រកបដោយចីរភាព។ | % | ៤០,០ (២០១៧) | | ៤០,០ | ៤៥,០ | ៤៥,០ | - | - | ៤៦,៩៧ | ៤៧,៩៧ | ស្ថិតិលើគន្លង ទៅសម្រេចបាន |
| ១៥.៣ | ត្រឹមឆ្នាំ២០៣០ ប្រយុទ្ធប្រឆាំងនឹងការបំផ្លាញព្រៃឈើ ធ្វើឱ្យដុចដើមឡើងវិញដីដែលបាត់បង់ដីជាតិ រួមទាំង ដីដែលទទួលផលប៉ះពាល់ពី វាលរហោឋានកម្មភាពរាំងស្ងួត និងទឹកជំនន់ធ្វើឱ្យប្រសើរឡើងនូវ ពិភពលោកដែលមានដីមិនមានការខូចខាត។ | | | | | | | | | | | គ្មានទិន្នន័យ |
| ១៥.៣.១ | ផ្ទៃដីតំបន់ទេសភាពព្រៃឈើដែលបានស្ដារពីផលប៉ះពាល់ ដោយសារភាពរាំងស្ងួត ទឹកជំនន់ និងដែលបានបោះបង់ចោល។ | ពាន់ហិកតា | ២០,០ (២០១៦) | ២០,០ | - | - | | ៣៦,១ | - | - | | គ្មានទិន្នន័យ |
| ១៥.៥ | អនុវត្តចំណាត់ការចាំបាច់និងជាបន្ទាន់ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានលើលំនៅឋាន ធម្មជាតិ កាត់បន្ថយឱ្យបាន ពាក់កណ្ដាលនូវការបាត់បង់ជីវៈចម្រុះ និង ត្រឹមឆ្នាំ ២០២០ ការពារនិងបង្ការការបាត់បង់ផុតពូជនូវប្រភេទរុក្ខជាតិ /សត្វ ដែលគំរាមកំហែងផុតពូជ។ | | | | | | | | | | | ទាបជាងចំណុចដៅ |
| ១៥.៥.១ | ចំនួនផែនការសកម្មភាពសម្រាប់អភិរក្សប្រភេទសត្វព្រៃ និងរុក្ខជាតិជិតផុតពូជនិងមានដោយកម្រ ដែលត្រូវបានរៀបចំនិងអនុវត្ត។ | ចំនួនផែនការកម្មភាព | ១ (២០១៦) | ១ | ៤ | ៧ | ១០ | ១,០ | ២,០ | ៣,០ | ៤,០ | ទាបជាងចំណុចដៅ |
| ១៥.៧ | អនុវត្តសកម្មភាព ជាបន្ទាន់ដើម្បីបញ្ចប់ការបរបាញ់និងជួញដូរប្រភេទពូជ រុក្ខជាតិ និងពពួកសត្វដែលត្រូវបានការពារ និងដោះស្រាយ ទាំងតម្រូវការនិងការផ្គត់ផ្គង់ខុសច្បាប់នៃផលិតផលសត្វព្រៃ។ | | | | | | | | | | | ទាបជាងចំណុចដៅ |
| ១៥.៧.១ | ចំនួនករណីល្មើសច្បាប់ក្នុងការបរបាញ់ ការជួញដូរប្រភេទសត្វព្រៃនិងប្រភេទរុក្ខជាតិខុសច្បាប់ ដែលត្រូវបានកាត់បន្ថយ។ | ករណី | ១,៦០០ (២០១៦) | ១ ៦០០ | ១ ៥៥០ | ១ ៥០០ | ១ ៤៥០ | ១ ៤៩០ | ១ ៤២៨ | ១ ០៩៣ | ១ ២០១ | ទាបជាងចំណុចដៅ |
| ១៥.៩ | ត្រឹមឆ្នាំ២០២០ បញ្ចូលតម្លៃប្រព័ន្ធអេកូឡូស៊ីនិងជីវៈចម្រុះ ទៅក្នុងផែនការជាតិនិងផែនការមូលដ្ឋាន ដំណើរការនៃការអភិវឌ្ឍយុទ្ធសាស្ត្រនិងគណនេយ្យភាពសម្រាប់កាត់បន្ថយភាពក្រីក្រ។ | | | | | | | | | | | ស្ថិតិលើគន្លង ទៅសម្រេចបាន |
| ១៥.៩.២ | ចំនួនគោលនយោបាយយុទ្ធសាស្ត្រ និងលិខិតយុទ្ធបករណ៍ស្ដីពីសេវាកម្មប្រពន្ធ័ អេកូឡូស៊ីត្រូវបានតាក់តែង និងអនុវត្ត។ | ចំនួនគោលនយោបាយ | ២,០ | ២,០ | ២,០ | ២,០ | ២,០ | ២,០ | ២,០ | ២,០ | ២,០ | ស្ថិតិលើគន្លង ទៅសម្រេចបាន |
| ១៥.b | កៀរគរធនធាន ឱ្យបាន ច្រើនពីគ្រប់ប្រភពនិងនៅគ្រប់កម្រិត ដើម្បីផ្ដល់ហិរញ្ញប្បទាន សម្រាប់គ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព និងផ្ដល់នូវការឧបត្ថម្ភគ្រប់គ្រាន់សម្រាប់អនុវត្តការគ្រប់គ្រងបានល្អប្រសើរ រួមទាំងសម្រាប់ការអភិរក្ស និងការដាំព្រៃឈើឡើងវិញ។ | | | | | | | | | | | លើសចំណុចដៅ |
| ១៥.b.១ | ទំហំហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់ការអភិរក្ស និងការប្រើប្រាស់ប្រកបដោយចីរភាពជីវៈចម្រុះនិងប្រព័ន្ធអេកូឡូស៊ី។ | % នៃ ផ.ស.ស | ០,០៣៨ (២០១៦) | ០,០៣៨ | ០,០៣៨ | ០,០៣៦ | ០,០៣១ | ០,០៤២ | ០,០៤៤ | ០,០៨២ | ០,០៣៧ | លើសចំណុចដៅ |

*ប្រភព÷ ក្របខ័ណ្ឌ គ.អ.ច.ក. និង ក្រសួង ស្ថាប័ន*

តាមរយៈ សេចក្តីជូនដំណឹង លេខ ១១១៩.សជណ.ដប ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៦ បានអនុញ្ញាតឱ្យក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងក្រសួងបរិស្ថាន រៀបចំនិងអនុវត្ត "គោលការណ៍បង់ថ្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី" ដែលជាលក្ខណៈសាកល្បងនៅឧទ្យានជាតិព្រះជ័យវរ្ម័នពនរោត្តមភ្នំ "គូលែន" ក្នុងខេត្តសៀមរាប និងតំបន់ប្រើប្រាស់ច្រើនគោលបំណងព្រៃកទឹកសាបក្បាលឆាយ ក្នុងខេត្តព្រះសីហនុ ដោយផ្តោតជាសំខាន់លើ សារសំខាន់នៃការផ្គត់ផ្គង់ទឹកស្អាត។

## បញ្ហាប្រឈម

បញ្ហាប្រឈមចម្បងនៅក្នុងស្ថាប័នវិស័យព្រៃឈើ គឺសមត្ថភាពពាក់ព័ន្ធនឹង ការគ្រប់គ្រងធនធានព្រៃឈើ ការរៀបចំផែនការប្រើប្រាស់ដី និងការតាមដានត្រួតពិនិត្យនិងវាយតម្លៃធានព្រៃឈើ។ លើសពីនេះទៅទៀត សមត្ថភាពក្នុងការពង្រឹងការអនុវត្តច្បាប់ ក៏តម្រូវឱ្យមានការកសាងសមត្ថភាពបន្ថែមទៀតផងដែរ។ មន្ត្រីព្រៃឈើ ក៏ត្រូវការជំនាញ និងវិធីសាស្ត្រថ្មីៗ ដើម្បីពង្រឹងសមត្ថភាពក្នុងការប្រើប្រាស់វិធីសាស្ត្រទាំងនោះ សម្រាប់ការកែលម្អការគ្រប់គ្រងដីនិងធនធានព្រៃឈើ ការគ្រប់គ្រងធនធានធម្មជាតិដោយសហគមន៍ និងខ្សែចង្វាក់ផលិតកម្មបៃតង ព្រមទាំង ការរួមចំណែកដល់ការលើកកម្ពស់ជីវភាពនៅតំបន់ជនបទ។ ការប្រែប្រួលអាកាសធាតុ នគរូបនីយកម្ម និងឧស្សាហូបនីយកម្ម កំពុងជះឥទ្ធិពលអវិជ្ជមានដល់ធនធានធម្មជាតិ ក៏ដូចជា ប្រព័ន្ធអេកូឡូស៊ីរបស់ប្រទេស។ ដើម្បីធ្វើឱ្យប្រសើរឡើងនូវស្ថានភាពនេះ រាជរដ្ឋាភិបាលនឹងបង្កើនការដាំដើមឈើ ដើម្បីលើកកែលម្អការគ្របដណ្តប់ព្រៃឈើ។

កម្ពុជានៅមានកង្វះខាតលទ្ធភាពថវិកានិងបរិក្ខារសម្រាប់ការអនុវត្តសកម្មភាពពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ កំណើនបៃតង និងការការពារជីវៈចម្រុះ។ ដូចគ្នានេះដែរ គោលនយោបាយនិងច្បាប់ដើម្បីធានាចីរភាពធនធានធម្មជាតិនិងបរិស្ថាន មិនបានឆ្លើយតបគ្រប់គ្រាន់ទៅតាមតម្រូវការទេ។ លើសពីនេះទៀត សមត្ថភាពស្ថាប័ន ក្នុងការសម្របសម្រួលគោលនយោបាយ ឯកសារច្បាប់ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពនៅតែជាបញ្ហា។ កំណើនប្រជាជន ក៏ជាបញ្ហាប្រឈមមួយក្នុងការអភិរក្សព្រៃឈើប្រកបដោយចីរភាព។

ពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ កង្វះការចូលរួមពីគ្រប់ភាគីទាំងអស់ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។ ការបញ្ជ្រាបគោលការណ៍នៃការអភិវឌ្ឍប្រកបដោយចីរភាព រួមមាន ការប្រែប្រួលអាកាសធាតុ កំណើនបៃតង និងជីវៈចម្រុះ ទៅក្នុងយុទ្ធសាស្ត្រ និងផែនការសកម្មភាពតាមវិស័យដទៃទៀត មិនត្រូវបានអនុវត្តបានទូលំទូលាយទេ។

ការគ្រប់គ្រងទិន្នន័យ មានលក្ខណៈដាច់ដោយឡែក។ នាពេលបច្ចុប្បន្ន នៅតាមក្រសួង-ស្ថាប័ន និងអង្គការដៃគូនានា បាននឹងកំពុងធ្វើការប្រមូល ចងក្រង និងគ្រប់គ្រងទិន្នន័យពាក់ព័ន្ធនឹងជីវៈចម្រុះជាតិ រៀងៗខ្លួន ដែលបង្កឱ្យមានការលំបាកក្នុងការផ្ទៀងផ្ទាត់ទិន្នន័យទាំងនោះ។ ទោះជាដូច

នេះក្តី ប្រព័ន្ធគ្រប់គ្រងទិន្នន័យជីវៈចម្រុះជាតិ កំពុងស្ថិតក្នុងដំណាក់កាលរៀបចំបង្កើត ដែលប្រព័ន្ធនេះនឹងក្លាយជាយន្តការរួមមួយយ៉ាងសំខាន់ ក្នុងការប្រមូលចងក្រងនិងចែករំលែកទិន្នន័យនិងព័ត៌មានពាក់ព័ន្ធនិងជីវៈចម្រុះនេះឱ្យមានប្រសិទ្ធភាព។

សមត្ថភាពនៅថ្នាក់ក្រោមជាតិត្រូវពង្រឹងបន្ថែម ដើម្បីរៀបចំផែនការ និងអនុវត្តគោលនយោបាយយុទ្ធសាស្ត្រ និងផែនការសកម្មភាពឱ្យបានល្អជាងមុន។ ករណីជម្លោះនិងទំនាស់មួយចំនួនបានកើតមានឡើង ជាពិសេស ទំនាស់ដីធ្លីនៅជុំវិញតំបន់អភិរក្ស និងច្រករបៀងអភិរក្សជីវៈចម្រុះ ត្រូវបានដោះស្រាយ។ ផែនការសកម្មភាពស្តីពីការគ្រប់គ្រង ការបែងចែក និងកំណត់ព្រំដែនតំបន់អភិរក្សមិនទាន់មាននៅឡើយទេ ដែលជាហេតុនាំឱ្យមានការលំបាកក្នុងការធានាប្រសិទ្ធភាពនៃការគ្រប់គ្រងការការពារ និងការអភិរក្សជីវៈចម្រុះនៅតាមតំបន់អភិរក្ស។ ជាមួយគ្នានេះ ព័ត៌មាននិងទិន្នន័យស្តីពីជីវៈចម្រុះក៏មានកង្វះខាតដែរ។

## គោលនយោបាយឬយុទ្ធសាស្ត្រសំខាន់ៗ

ការរៀបចំយុទ្ធសាស្ត្រ ដើម្បីបង្កើនគម្របព្រៃឈើតាមរយៈការដាំដើមឈើនិងសកម្មភាពអភិរក្ស និងដើម្បីស្តារឡើងវិញនូវធនធានពន្ធុនៃដើមឈើនិងសត្វព្រៃ នៅក្នុងតំបន់អភិរក្សនិងច្រករបៀងអភិរក្សជីវៈចម្រុះ គឺជាការងារអាទិភាព។ ការអនុវត្តយុទ្ធសាស្ត្រជាតិ REDD+ ២០១៨-២០២៨ បានរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុក្នុងប្រទេស និងពិភពលោក តាមរយៈការបង្កើនការគ្រប់គ្រងធនធានធម្មជាតិនិងដីព្រៃ ការអភិរក្សជីវៈចម្រុះ និងការអភិវឌ្ឍប្រកបដោយចីរភាព។ លើសពីនេះទៀត កម្ពុជាបានអនុវត្តកម្មវិធី REDD+ នៅតាមបណ្តាខេត្តមួយចំនួន ដើម្បីបង្កើនការកាត់បន្ថយការបំភាយឧស្ម័នកាបូននិងការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព បង្កើនសារពើភ័ណ្ឌព្រៃឈើនិងរៀបចំវិធីសាស្ត្រថ្មីៗសម្រាប់ការអភិវឌ្ឍនិងការអភិរក្ស រួមទាំងអេកូទេសចរណ៍ និងយន្តការផ្តល់ហិរញ្ញប្បទាន។ កម្ពុជាក៏បានជំរុញឱ្យមានការអនុវត្តគោលនយោបាយនៃការបង់ថ្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី ដើម្បីជំរុញនិងធានានិរន្តរភាពហិរញ្ញវត្ថុសម្រាប់ការងារអភិរក្សជីវៈចម្រុះនិងប្រព័ន្ធអេកូឡូស៊ី និងការអភិវឌ្ឍប្រកបដោយចីរភាព។

កម្ពុជានឹងបន្តពង្រឹងកិច្ចសហប្រតិបត្តិការថ្នាក់ជាតិ តំបន់ និងអន្តរជាតិ ដើម្បីលើកកម្ពស់សកម្មភាពអប់រំបរិស្ថាន តាមរយៈ សកម្មភាពផ្សព្វផ្សាយបរិស្ថាន ការធ្វើបច្ចុប្បន្នភាពស្ថិតិបរិស្ថាននិងធនធានជីវៈចម្រុះ កម្មវិធីបរិស្ថានសម្រាប់ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព និងការជំរុញការចែករំលែកផលប្រយោជន៍ពីការប្រើប្រាស់ធនធានពន្ធុ។

# គោលដៅទី១៦៖ លើកកម្ពស់សង្គមដែលមានសន្តិភាពប្រកបដោយបរិយាប័ន្ន ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព ផ្តល់នូវការទទួលបានយុត្តិធម៌សម្រាប់ប្រជាជនគ្រប់រូប និងកសាងស្ថាប័នដែលមានប្រសិទ្ធភាព គណនេយ្យភាព និងបរិយាប័ន្ននៅគ្រប់កម្រិត

## វឌ្ឍនភាព

រាជរដ្ឋាភិបាលកម្ពុជា បានចូលរួមចំណែកយ៉ាងសកម្ម ក្នុងការថែរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ ដែលជាការបង្ហាញឱ្យឃើញរបស់កម្ពុជាដល់ពិភពលោកពីការផ្តល់តម្លៃជាសាកលនៃសន្តិភាព សន្តិសុខ និងមិត្តភាព។ នៅទសវត្សរ៍ឆ្នាំ១៩៩០ កម្ពុជាបានទទួលអត្ថប្រយោជន៍ពីការគាំទ្ររបស់កងរក្សាសន្តិភាពអង្គការសហប្រជាជាតិ ដើម្បីនាំមកនូវសន្តិភាព។ ប៉ុន្មានឆ្នាំក្រោយមក កម្ពុជាបានចាប់ផ្តើមបញ្ជូនកងទ័ពទៅចូលរួមក្នុងប្រតិបត្តិការថែរក្សាសន្តិភាពនៅទូទាំងពិភពលោក ដើម្បីជួយស្វែងរកសន្តិភាព និងសុវត្ថិភាពជូនប្រជាពលរដ្ឋក្នុងពិភពលោក ដែលត្រូវការជំនួយ។ ចាប់តាំងពីពាក់កណ្តាលឆ្នាំ២០០៦ មកដល់ពេលបច្ចុប្បន្ន កម្ពុជាមានមោទនភាពដែលបានរួមចំណែកក្នុងការបញ្ជូនកងទ័ពមួកខៀវក្រោមក្របខ័ណ្ឌអង្គការសហប្រជាជាតិ ទៅ ស៊ូដង់ ស៊ូដង់ខាងត្បូង ឆាដ លីបង់ ម៉ាលី អាហ្វ្រិកកណ្តាល ស៊ីរី និងកោះស៊ីប។ បច្ចុប្បន្ន កងកម្លាំងកម្ពុជាមានវត្តមាននៅក្នុងតំបន់បេសកកម្មក្នុង សាធារណៈរដ្ឋអាហ្វ្រិកកណ្តាល លីបង់ ស៊ូដង់ខាងត្បូង និងម៉ាលី។ កម្ពុជាគឺជាអ្នករួមចំណែកធំបំផុតនៃកងទ័ពមួកខៀវនៅក្នុងតំបន់អាស៊ាន។

រាជរដ្ឋាភិបាលកម្ពុជាបានខិតខំពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ និងសណ្តាប់ធ្នាប់សង្គម ដែលជាមូលដ្ឋានគ្រឹះ សម្រាប់ពង្រឹងអភិបាលកិច្ច នីតិរដ្ឋ និងការគោរពសិទ្ធិមនុស្ស ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាតិ។ អភិបាលកិច្ចល្អនៅតែជាស្នូលនៃអាទិភាពជាតិ ហើយការរីកចម្រើននៅតែបន្តអនុវត្តកំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលកម្ពុជាបានប្រឹងប្រែងធានាឱ្យបានយុត្តិធម៌សម្រាប់ទាំងអស់គ្នា (សូមមើលករណីសិក្សាទី២)។ វឌ្ឍនភាពដែលពាក់ព័ន្ធនឹងបញ្ហានេះ រួមបញ្ចូលទាំងកិច្ចខិតខំប្រឹងប្រែងសំខាន់ៗ ដែលត្រូវបានធ្វើឡើងដើម្បីកែលម្អច្បាប់ និងប្រព័ន្ធយុត្តិធម៌។ ក្របខ័ណ្ឌច្បាប់ចាំបាច់មួយចំនួនត្រូវបានបង្កើតឡើង ដើម្បីបង្កើនសមត្ថភាពឯករាជ្យភាពនិងភាពមិនលំអៀងនៃប្រព័ន្ធយុត្តិធម៌ដែលមានសារសំខាន់សម្រាប់ការពង្រឹងនីតិរដ្ឋ។ ច្បាប់សំខាន់ៗ រួមមាន ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមនីតិវិធីរដ្ឋប្បវេណី ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ជាមួយនឹង ផែនការប្រតិបត្តិយុទ្ធសាស្ត្ររយៈពេល៣ឆ្នាំ និងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត ដែលពាក់ព័ន្ធនឹងនយោបាយ

សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ត្រូវបានរៀបចំឡើង ដើម្បីរួមចំណែកដល់ការសម្រេចបាននូវសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន។ លើសពីនេះទៅទៀត ការផ្លាស់ប្តូរចៅក្រមនិងព្រះរាជអាជ្ញា ពីតំបន់មួយទៅតំបន់មួយផ្សេងទៀត ជាទៀងទាត់និងតាមអាណត្តិ បានរួមចំណែកយ៉ាងសំខាន់ ក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយក្នុងវិស័យតុលាការ។

រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តយ៉ាងសកម្មនូវវេទិការវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយនឹងវិស័យឯកជន ដោយបានជួយកាត់បន្ថយការលំបាករបស់អ្នកវិនិយោគ ក៏ដូចជា កាត់បន្ថយអំពើពុករលួយ ការស៊ីសំណូកគ្រប់ទម្រង់។ រាជរដ្ឋាភិបាលកម្ពុជាបានជំរុញការអនុវត្តយ៉ាងម៉ឺងម៉ាត់នូវវិធានការអប់រំ បង្ការ និងទប់ស្កាត់អំពើពុករលួយ ការអនុវត្តច្បាប់ប្រឆាំងអំពើពុករលួយ គួបផ្សំនឹងការអនុវត្តដ៏មានប្រសិទ្ធភាពនូវអភិក្រមទាំងប្រាំគឺ ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់។

## តារាង ៤.១៦÷ វឌ្ឍនភាពគោលដៅទី១៦ នៃ គ.អ.ច.ក.

| | ចំណុចដៅ/សូចនាករ | ឯកតា | ២០១៥ | ចំណុចដៅ គ.អ.ច.ក. | | | | ជាក់ស្តែង | | | | វឌ្ឍនភាព |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | |
| **១៦.៣** | **លើកកម្ពស់វិធានការច្បាប់ នៅកម្រិតជាតិនិងអន្តរជាតិ និងធានាការទទួលបានយុត្តិធម៌ស្មើភាពគ្នា សម្រាប់ប្រជាជនគ្រប់រូប។** | | | | | | | | | | | **ទាបជាងចំណុចដៅ** |
| ១៦.៣.១ | សមាមាត្រនៃប្រជាជនដែលបានចូលរួមក្នុងការផ្សព្វផ្សាយច្បាប់។ | ក្នុង ១០០ ០០០នាក់ | ១,៤៨ | ៣,៧១ | ៣,៧៤ | ៣,៧៧ | ៣,៨២ | ០,៥៧ | ១,១៨ | ១,៦៨ | ២,៣៩ | ទាបជាងចំណុចដៅ |
| **១៦.៧** | **ធានានូវការធ្វើសេចក្តីសម្រេចដោយមានការចូលរួមពីគ្រប់តំណាង ដោយមានការទទួលខុសត្រូវប្រកបដោយបរិយាប័ន្ននៅគ្រប់កម្រិត។** | | | | | | | | | | | **ស្ថិតលើគន្លងទៅសម្រេចបាន** |
| ១៦.៧.១ | សមាមាត្រនៃស្ត្រី ជាមន្ត្រីរាជការស៊ីវិលនៅតាមក្រសួងស្ថាប័ននានា។ | % | ៤០,០ (២០១៦) | ៤០,០ | ៤១,០ | ៤២,០ | ៤៣,០ | ៤០,០ | ៤០,០ | ៤១,០ | ៤១,០ | ស្ថិតលើគន្លងទៅសម្រេចបាន |
| **១៦.៩** | **ត្រឹមឆ្នាំ២០៣០ ផ្តល់អត្តសញ្ញាណបណ្ណដល់ប្រជាជនគ្រប់រូប រួមទាំង ការចុះបញ្ជីកំណើត។** | | | | | | | | | | | **ស្ថិតលើគន្លងទៅសម្រេចបាន** |
| ១៦.៩.១ | ភាគរយនៃកំណើត ដែលទទួលបានការចុះបញ្ជីកំណើតនិងទទួលបានសំបុត្រកំណើត (៩០%នៅទូទាំងប្រទេស ត្រឹមឆ្នាំ២០២៤)។ | % | ១១៤ | ១០៣ | ១០៦ | ១០៨ | ១១១ | ១០៣ | ១០៦ | ១០៨ | ១១១ | ស្ថិតលើគន្លងទៅសម្រេចបាន |

*ប្រភព÷ ក្របខ័ណ្ឌ គ.អ.ច.ក. និង ក្រសួង ស្ថាប័ន*

រាជរដ្ឋាភិបាលកម្ពុជាបានសង្កត់ធ្ងន់លើការលើកកម្ពស់សិទ្ធិមនុស្ស។ អត្រានៃចំនួនអ្នកទៅបោះឆ្នោត បានកើនឡើងគួរឱ្យកត់សម្គាល់សម្រាប់ការបោះឆ្នោតសកលឆ្នាំ២០១៨ ដែលអត្រានេះបានកើនឡើងពី៦៩,៦១% ក្នុងឆ្នាំ២០១៣ ដល់៨៣,០២%ក្នុងឆ្នាំ២០១៨។

រាជរដ្ឋាភិបាលកម្ពុជា បានចាត់វិធានការតាមផ្លូវច្បាប់ទាក់ទងនឹងសេរីភាពខាងការជួបជុំគ្នាដោយសន្តិវិធី ការប្រមូលផ្តុំ និងការបញ្ចេញមតិដោយសន្តិវិធី និងសិទ្ធិនយោបាយ ដែលបានអនុវត្តចាប់តាំងពីឆ្នាំ២០១៥ ដែលជាផ្នែកមួយយ៉ាងសំខាន់នៃការលើកកម្ពស់សេរីភាព ក្រោមច្បាប់និងសណ្តាប់ធ្នាប់សង្គមនៅក្នុងប្រទេស។ លើសពីនេះទៀត រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងមហាផ្ទៃ បានប្រកាសថា អង្គការសង្គមស៊ីវិលទាំងអស់ដែលបានចុះបញ្ជីជាមួយក្រសួងរួចហើយ អាចអនុវត្តសកម្មភាពដោយស្របច្បាប់នៅក្នុងប្រទេសកម្ពុជា។

រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានជាផ្លូវការដែលក្រសួងព័ត៌មានបានសហការជាមួយស្ថានទូតស៊ុយអែត និងអង្គការយូណេស្កូ និងបានបង្កើតក្រុមការងារបច្ចេកទេសចម្រុះ។ សេចក្តីព្រាងច្បាប់នេះត្រូវបានបញ្ចប់នៅកម្រិតក្រុមការងារបច្ចេកទេស ហើយបានធ្វើឱ្យមាននីត្យានុកូលភាព ស្របតាមស្តង់ដាអន្តរជាតិនិងស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ចរបស់កម្ពុជា។ នៅក្នុងឆ្នាំ២០១៩ នេះ សមិទ្ធផលនានា ពាក់ព័ន្ធនឹងការផ្សព្វផ្សាយនិងការទទួលបានព័ត៌មាន មានដូចខាងក្រោមៈ

- ការងារដឹកនាំ និងគ្រប់គ្រងវិស័យព័ត៌មាននិងសោតទស្សន៍ ត្រូវបានពង្រឹងនិងកែលំអជាបណ្តើរៗ តាមរយៈ ការកសាងសមត្ថភាពស្ថាប័ន ការកសាងធនធានមនុស្ស និងការធ្វើទំនើបកម្មមូលដ្ឋានសម្ភារៈបច្ចេកទេសនិងបច្ចេកវិទ្យាថ្មី ។
- វិសាលភាព គុណភាព និងប្រសិទ្ធភាព នៃប្រព័ន្ធផ្សព្វផ្សាយជាតិ ទាំងរដ្ឋនិងឯកជន ត្រូវបានពង្រីកកាន់តែទូលំទូលាយប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់ ។
- ប្រជាពលរដ្ឋខ្មែរនៅក្នុងប្រទេសប្រមាណ៨៥ % បានទទួលសេវាផ្តល់ព័ត៌មាន ផ្តល់ការអប់រំ និងការកំសាន្ត ប្រកបដោយគុណភាព និងសមធម៌ តាមរយៈមធ្យោបាយផ្សេងៗគ្នា ដូចជាទូរទស្សន៍ វិទ្យុ សារព័ត៌មានបោះពុម្ព និងមធ្យោបាយផ្សេងៗទៀត។
- បណ្តាញផ្សព្វផ្សាយនៅថ្នាក់ក្រោមជាតិ ជាពិសេស ស្ថានីយវិទ្យុ ត្រូវបានកសាងពង្រីកដល់១៦ ខេត្ត ក្រុង ដែលស្ថានីយទាំងនេះមានតួនាទីផ្សាយបន្តផ្ទាល់ពីព្រឹត្តិការណ៍សំខាន់ៗនៅកម្រិតជាតិ និងមានលទ្ធភាពផលិតកម្មវិធីផ្សាយផ្ទាល់សម្រាប់សហគមន៍ និងមូលដ្ឋានរបស់ខ្លួន ដោយផ្តោតសំខាន់ទៅលើប្រធានបទអប់រំ។
- ការរីកចម្រើនរបស់ប្រព័ន្ធផ្សព្វផ្សាយ ទាំងរដ្ឋនិងឯកជន នៅកម្ពុជាបច្ចុប្បន្ន ក៏បានរួមចំណែកយ៉ាងធំធេងក្នុងការលើកតម្កើងមោទនភាពនិងអត្តសញ្ញាណជាតិខ្មែរ និងលើកកម្ពស់កិត្យានុភាពរបស់ព្រះរាជាណាចក្រកម្ពុជា នៅលើឆាកអន្តរជាតិ។

រាជរដ្ឋាភិបាលកម្ពុជា បានប្តេជ្ញាយ៉ាងមុតមាំក្នុងការលើកកម្ពស់ភាពជាដៃគូជាមួយអង្គការសង្គមស៊ីវិលលើគ្រប់ទិដ្ឋភាពទាំងអស់នៃការអភិវឌ្ឍ ហើយការផ្តួចផ្តើមមួយចំនួនត្រូវបានអនុវត្តដោយក្រសួងមហាផ្ទៃ ដើម្បីលុបចោលនូវលក្ខខណ្ឌរដ្ឋបាលមួយចំនួន និងបានរៀបចំវេទិកាពិគ្រោះយោបល់ជាទៀងទាត់ជាមួយអង្គការសង្គមស៊ីវិលនិងបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីដោះស្រាយសំណើនិងកង្វល់របស់ពួកគេ។

រាជរដ្ឋាភិបាលកម្ពុជាមានផែនការៈ

បញ្ចូលមេរៀនប្រឆាំងអំពើពុករលួយក្នុងកម្មវិធីសិក្សាអប់រំចំណេះទូទៅទាំង៣កម្រិត គឺថ្នាក់បឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ។ ការយកចិត្តទុកដាក់ផ្សព្វផ្សាយ អប់រំ បំផុសចលនាស្រលាញ់ភាពស្អាតស្អំ រួមគ្នាប្រឆាំងអំពើពុករលួយគ្រប់មជ្ឈដ្ឋាន មន្ត្រីរាជការ វិស័យឯកជន សិល្បៈ

មហាជន ទីក្រុង និងជនបទ។ ការផ្សព្វផ្សាយច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយច្រើនរូបភាព បានធ្វើឱ្យមានការប្រែប្រួលឥរិយាបថរស់នៅ ឥរិយាបថការងារក្នុងសង្គម គួរឱ្យកត់សម្គាល់ ។

ទប់ស្កាត់អំពើពុករលួយ តាមរយៈវិធានការបង្ការ ដោយរួមបញ្ចូលទាំងការប្រកាសទ្រព្យសម្បត្តិ និងបំណុល ដាក់ចេញនូវបទប្បញ្ញត្តិផ្ទៃក្នុង គោលការណ៍ សារាចរណ៍ និងការណែនាំ។ លិខិតបទដ្ឋាននិងច្បាប់ដែលបានដាក់ចេញ និងបានអនុវត្តជាបន្តបន្ទាប់ សុទ្ធតែបានរួមចំណែកទប់ស្កាត់កុំឱ្យមានការប្រព្រឹត្តិអំពើអសកម្ម និងពុករលួយ ហើយបានលើកកម្ពស់ភាពស្អាតស្អំ តម្លាភាព និងគណនេយ្យភាព។ ការងារលទ្ធកម្ម ការប្រឡងប្រជែងដែលកាន់តែមានតម្លាភាព ការលើកកម្ពស់សេវាសាធារណៈរបស់គ្រប់ស្ថាប័នគ្រប់ថ្នាក់ ការបង្វិតរដ្ឋបាលឱ្យទៅកៀកប្រជាពលរដ្ឋ និងការដោះស្រាយពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋ ក៏ជាយន្តការរបស់រាជរដ្ឋាភិបាលផងដែរ ក្នុងការទប់ស្កាត់អំពើពុករលួយ។ ការព្រមានមន្ត្រីរាជការដែលខកខានក្នុងការអនុវត្តច្បាប់ បទប្បញ្ញត្តិ តួនាទី ភារកិច្ចឱ្យបានពេញលេញ ក៏បានចូលរួមចំណែកបង្ការ និងទប់ស្កាត់មុខសញ្ញាទាំងនោះ មិនឱ្យប្រព្រឹត្តិអំពើពុករលួយផងដែរ។

រាជរដ្ឋាភិបាលកម្ពុជា បានអនុវត្តការរៀបចំរបាយការណ៍ស្វ័យត្រួតពិនិត្យ តាមអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការប្រឆាំងអំពើពុករលួយ (UNCAC) សម្រាប់ជុំទី១ (២០១៣-២០១៥) ហើយកំពុងដំណើរការជុំទី២ បន្តទៀត (២០១៨-២០២០)។

អង្គភាពប្រឆាំងអំពើពុករលួយ បានអនុវត្តយ៉ាងសកម្មក្នុងការផ្សព្វផ្សាយវិធានការប្រឆាំងអំពើពុករលួយ និងវិធានការផ្សេងទៀតនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងនៅតាមសាកលវិទ្យាល័យ វិទ្យាស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈ វិទ្យាល័យ និងវិស័យឯកជន។ បន្ថែមលើការផ្សព្វផ្សាយច្បាប់ប្រឆាំងអំពើពុករលួយ អង្គភាពប្រឆាំងអំពើពុករលួយក៏បានសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសាម៉ីក្រសួងជាច្រើន ក្នុងការរៀបចំការផ្តល់សេវាសាធារណៈឱ្យមានប្រសិទ្ធភាព និងតម្លាភាព លើកកម្ពស់ការជឿទុកចិត្តរបស់សាធារណៈជនមកលើស្ថាប័នរដ្ឋ។ ដើម្បីចូលរួមក្នុងការកាត់បន្ថយអំពើអសកម្មនានា និងរួមចំណែកទប់ស្កាត់អំពើពុករលួយ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ក៏បានចូលរួមយ៉ាងសកម្ម តាមរយៈការចុះធ្វើអធិការកិច្ច ការតាមដានអនុវត្តច្បាប់ ការដោះស្រាយពាក្យបណ្តឹង និងបានផ្សព្វផ្សាយច្បាប់ពាក់ព័ន្ធនឹងការបង្ការទប់ស្កាត់អំពើពុករលួយ ទៅដល់គ្រប់រាជធានី-ខេត្តផងដែរ។

គួរកត់សម្គាល់ផងដែរថា សមាមាត្រនៃមន្ត្រីជាស្ត្រីនៅក្នុងក្រសួង ស្ថាប័ន បានកើនឡើងពី ៤០% ក្នុងឆ្នាំ២០១៦ ដល់ ៤១% ក្នុងឆ្នាំ២០១៩។ រាជរដ្ឋាភិបាលកម្ពុជា បានចុះបញ្ជីអត្រានុកូលដ្ឋាន តាមរយៈការចេញលិខិតបញ្ជាក់កំណើតដោយឥតគិតថ្លៃ និងបានផ្តល់ជំនួយផ្នែកច្បាប់ដោយឥតគិតថ្លៃសម្រាប់ប្រជាជនក្រីក្រ។ ក្រសួងមហាផ្ទៃដែលមានអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មជាសេនាធិការ បានរៀបចំនូវផែនការយុទ្ធសាស្ត្រជាតិស្តីពីអត្តសញ្ញាណកម្ម ឆ្នាំ២០១៧-២០២៦ ដែលត្រូវបានអនុមតិជាផ្លូវការ ដោយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីជាទស្សនវិស័យយុទ្ធសាស្ត្ររយៈពេលវែង ក្នុងការដឹកនាំតម្រង់ទិស

លើការងារគ្រប់គ្រងទិន្នន័យអត្តសញ្ញាណប្រជាជនតាមប្រព័ន្ធព័ត៌មានវិទ្យាទំនើប និងប្រើប្រាស់ទិន្នន័យអត្តសញ្ញាណកម្ម សម្រាប់លើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈនានា ជូនប្រពលរដ្ឋ។

សេវាច្រកចេញចូលតែមួយ កំពុងត្រូវបានដាក់ចេញនាពេលបច្ចុប្បន្ន និងជាយន្តការអភិបាលកិច្ចដ៏មានប្រសិទ្ធភាពមួយ ដែលត្រូវបានបង្កើតឡើងដើម្បីសម្រួលដល់ដំណើរការរដ្ឋបាល និងធានាដល់ការផ្តល់សេវាសាធារណៈទាន់ពេលវេលា ដល់ប្រជាពលរដ្ឋគ្រប់រូបរួម ទាំងអ្នកជំនួញ និងសហគ្រិនខ្នាតតូចផងដែរ។

រាជរដ្ឋាភិបាលកម្ពុជាក៏កំពុងអនុវត្តកំណែទម្រង់សំខាន់ៗ រួមមាន (១) ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ (២) កំណែទម្រង់រដ្ឋបាលសាធារណៈ (៣) កំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ (៤) កំណែទម្រង់កងយោធពលខេមរភូមិន្ទ (៥) កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនិង (៦) កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ។ ការចូលរួមរបស់អ្នកមានចំណែកពាក់ព័ន្ធទាំងអស់ ត្រូវបានធានាតាមរយៈការបង្កើតក្រុមការងារបច្ចេកទេសចម្រុះ។

ដោយឡែក ការងារនៅថ្នាក់ក្រោមជាតិ ស្រុក ខណ្ឌ គោលដៅចំនួន១២៣ នៃរាជធានី ខេត្តចំនួន២១ នឹងត្រូវដាក់ឱ្យអនុវត្តការងារគណនេយ្យភាពសង្គម ដោយមានការគាំទ្រពីលេខាធិការដ្ឋាន គ.ជ.អ.ប. និងរដ្ឋបាល រាជធានី ខេត្តសាមីទាំង២១ ដែលក្នុងនោះរួមមាន រដ្ឋបាលឃុំ សង្កាត់ ចំនួន ១ ០៧៨ សាលាបឋមសិក្សាចំនួន៥ ១០៧ និង មណ្ឌលសុខភាពចំនួន៨២២។ ក្នុងការពង្រឹងយន្តការសម្រុះសម្រួលដោះស្រាយបណ្តឹងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ការិយាល័យប្រជាពលរដ្ឋនៅថ្នាក់រាជធានីខេត្តទាំង២៥ និងការិយាល័យប្រជាពលរដ្ឋនៅថ្នាក់ក្រុង ស្រុក ខណ្ឌថ្មីចំនួន៣២ នឹងត្រូវដាក់ឱ្យដំណើរការ និងបានរៀបចំវគ្គបណ្តុះបណ្តាលចំនួន៥វគ្គ ដែលអ្នកចូលរួមមានចំនួនសរុប១៨៨។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលនឹងបង្កើតការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋាននៅថ្នាក់ ក្រុង ស្រុក ក្នុងគោលបំណងពង្រឹងការផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ការផ្តល់ប្រឹក្សាយោបល់ផ្លូវច្បាប់ និងសម្រុះសម្រួលវិវាទដល់ប្រជាពលរដ្ឋ នៅមូលដ្ឋាន។

## បញ្ហាប្រឈម

ប្រជាពលរដ្ឋប្រមាណ ១៥% នៅពុំទាន់ទទួលបានព័ត៌មាន ឬទទួលបានតិចតួច ជាពិសេសប្រជាជនក្រីក្ររស់នៅក្នុងតំបន់ដាច់ស្រយាល មនុស្សចាស់ជរា ជនពិការ ស្ត្រី និងកុមារ។ ផែនការកសាងលិខិតបទដ្ឋានគតិយុត្តិ (អនុក្រឹត - ច្បាប់) សម្រាប់គ្រប់គ្រងវិស័យព័ត៌មាន និងសោតទស្សន៍កំពុងស្ថិតក្នុងដំណើរការសិក្សាស្រាវជ្រាវនៅឡើយ ដោយខ្វះអ្នកជំនាញប្រកបដោយបទពិសោធន៍។ ការកសាងស្ថានីយវិទ្យុ និងទូរទស្សន៍ថ្មីនៅថ្នាក់ក្រោមជាតិមានភាពយឺតយ៉ាវ។ មូលដ្ឋានសម្ភារៈបច្ចេកទេសសម្រាប់ប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ(វិទ្យុជាតិ ទូរទស្សន៍ជាតិ ទីភ្នាក់ងារសារព័ត៌មានកម្ពុជា) បានឈានដល់

ដំណាក់កាលដែលត្រូវផ្លាស់ប្តូរនិងធ្វើទំនើបកម្ម ជាពិសេស ការត្រៀមលក្ខណៈផ្លាស់ប្តូរពីប្រព័ន្ធអាណាឡូក ទៅប្រព័ន្ធបច្ចេកវិទ្យាឌីជីថល ដើម្បីឆ្លើយតបនឹងគម្រោងផ្លាស់ប្តូររបស់អាស៊ាននិងពិភពលោក។

ការងារប្រយុទ្ធប្រឆាំងអំពើពុករលួយ ជាកិច្ចការមួយដែលត្រូវការពេលវេលា ហើយនៅក្នុងដំហាននីមួយ រាជរដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងប្រែងអនុវត្តយ៉ាងទាន់ពេលវេលា ស្របតាមយុទ្ធសាស្ត្រច្បាស់លាស់របស់ខ្លួន ហើយបង្កើនធនធាន សមត្ថភាព និងយន្តការប្រឆាំងអំពើពុករលួយជាបន្តបន្ទាប់។

បញ្ហាប្រឈមមួយដ៏សំខាន់គឺ ការចលនាការប្រយុទ្ធប្រឆាំងអំពើពុករលួយ នៅមិនទាន់ស្រុះគ្នា ព្រមគ្នា គ្រប់ទីកន្លែង និងគ្រប់ពេលវេលានៅឡើយ។ ការយល់ដឹងអំពីច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ នៅមិនទាន់បានគ្រប់គ្រាន់ ហើយចាំបាច់ត្រូវបន្តផ្សព្វផ្សាយ អប់រំតាមរូបភាពដ៏មានប្រសិទ្ធភាពបន្ថែមទៀត ការកែប្រែឥរិយាបទ ទម្លាប់ការងារចាស់មួយចំនួន នៅមិនបានទាន់ពេលវេលា និងមិនទាន់បានតាមសំណូមពរ ដែលទាមទារនូវភាពច្នៃប្រឌិតបន្ថែមទៀត ដើម្បីផ្តល់នូវការផ្លាស់ប្តូរប្រកបដោយប្រសិទ្ធភាព។

បញ្ហាមួយពាក់ព័ន្ធនឹងការចុះបញ្ជីអត្រានុកូលដ្ឋានគឺ ប្រជាជនកម្ពុជាមួយចំនួនតូច មិនសហការជាមួយអាជ្ញាធរមូលដ្ឋាន ក្នុងការចុះបញ្ជីអត្រានុកូលដ្ឋាន ដោយមិនបានផ្តល់ដំណឹង ឬទៅចុះឈ្មោះ នៅពេលកូនកើតឡើង ឬមានសមាជិកគ្រួសារទទួលមរណភាព ដែលជាហេតុឱ្យមានការខ្វះចន្លោះតួលេខ។

## គោលនយោបាយឬយុទ្ធសាស្ត្រសំខាន់ៗ

រាជរដ្ឋាភិបាលកម្ពុជា នឹងធានាថាគ្មាននរណាម្នាក់នៅកម្ពុជាត្រូវបានគេបោះបង់ចោល និងមិនទទួលបានសិទ្ធិសេរីភាពរបស់ខ្លួនដោយគ្មានការរើសអើងឡើយ ដូចជាការរើសអើង ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើត ស្ថានភាពសង្គម ទ្រព្យសម្បត្តិ ឬស្ថានភាពផ្សេងៗទៀត។ ក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលកម្ពុជានឹងបន្តជំរុញប្រព័ន្ធផ្សព្វផ្សាយរបស់ជាតិ និងលើកទឹកចិត្តប្រព័ន្ធផ្សព្វផ្សាយឯកជនឱ្យខិតខំពង្រីកសក្តានុពលប្រសិទ្ធភាព និងវិសាលភាពនៃការផ្សាយ ឱ្យគ្របដណ្តប់បានទូលំទូលាយទាំងក្នុងប្រទេស ក្នុងតំបន់ និងទ្វីបនានា ដើម្បីផ្តល់នូវព័ត៌មាន ការអប់រំ ការកំសាន្តប្រកបដោយគុណភាព និងសមធម៌ ជូនប្រជាពលរដ្ឋខ្មែរនៅគ្រប់ច្រកល្ហកនៃមាតុប្រទេស និងផ្សព្វផ្សាយឆ្ពោះទៅកាន់ពិភពលោកខាងក្រៅ ដើម្បីរួមចំណែកលើកតម្កើងអត្តសញ្ញាណ និងមោទនភាពជាតិខ្មែរ និងកិត្យានុភាពនៃព្រះរាជាណាចក្រកម្ពុជានៅលើឆាកអន្តរជាតិ។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលនឹងកសាងផែនការទំនើបនីយកម្មមូលដ្ឋានសម្ភារៈបច្ចេកទេស សម្រាប់អង្គភាពផ្សព្វផ្សាយថ្នាក់ជាតិ (វិទ្យុនិងទូរទស្សន៍ជាតិ និងទីភ្នាក់ងារសារព័ត៌មានកម្ពុជា) ដើម្បីឆ្លើយតបនឹងសំណូមពរចាំបាច់នៃការផ្សព្វផ្សាយជាសម្លេងផ្លូវការរបស់ជាតិ។ ជំរុញការអនុវត្តច្បាប់ស្តីពីរបបសារព័ត៌មាន និងរៀបចំលិខិតបទដ្ឋានគតិយុត្តថ្មី សម្រាប់គ្រប់គ្រងវិស័យព័ត៌មាន និងសោតទស្សន៍ ឱ្យស្ថិតក្នុងក្របខ័ណ្ឌនីតិរដ្ឋ។ បន្ថែមលើនេះ ក៏នឹងបន្តលើកទឹកចិត្ត និងបើកទូលាយ នូវការចូលរួមរបស់វិស័យឯកជន អង្គការសង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងវិស័យព័ត៌មាន និងសោតទស្សន៍។

រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តធ្វើកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយការរៀបចំក្របខ័ណ្ឌច្បាប់មួយដែលមាននិរន្តរភាព ដើម្បីទទួលបានទំនុកចិត្តពីសាធារណជន ដោយរួមបញ្ចូលទាំង ការកសាងសមត្ថភាពដើម្បីធានាឯករាជ្យភាពនិងភាពមិនលំអៀងរបស់តុលាការ ការពង្រឹងនីតិរដ្ឋ ការធានាដាច់ដោយឡែកអំណាចនានា ការគោរពសិទ្ធិបុគ្គលនិងយុត្តិធម៌សម្រាប់ប្រជាជនទូទៅ។ រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តបង្កើតច្បាប់ថ្មីៗ ដោយផ្អែកលើតម្រូវការនៃអភិបាលកិច្ចជាតិ ដែលធានាដល់ការការពារសិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ។

រាជរដ្ឋាភិបាលកម្ពុជា នឹងពង្រឹងការអនុវត្តច្បាប់ដែលមានស្រាប់ឱ្យកាន់តែមានប្រសិទ្ធភាព ដោយការបង្កើនការផ្សព្វផ្សាយព័ត៌មាននិងកម្មវិធីបណ្តុះបណ្តាល សម្រាប់មន្ត្រីអនុវត្តច្បាប់និងការអភិវឌ្ឍសមត្ថភាពស្តីពីច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

រាជរដ្ឋាភិបាលកម្ពុជា បាននិងកំពុងព្យាយាមរក្សាសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម លើកកម្ពស់កម្រិតជីវភាពរស់នៅ និងសុខុមាលភាពរបស់ប្រជាជន តាមរយៈការអនុវត្តវិធានការចាំបាច់ ការលើកកម្ពស់ និងការការពារសិទ្ធិជាមូលដ្ឋាន និងសេចក្តីថ្លៃថ្នូររបស់មនុស្ស។

រាជរដ្ឋាភិបាលកម្ពុជានឹងបង្កើនការផ្សព្វផ្សាយច្បាប់និងលិខិតបទដ្ឋានគតិយុត្ត និងបង្កើនការទទួលបានព័ត៌មាន ប្រព័ន្ធយុត្តិធម៌ ការសម្រេចចិត្តនានា និងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត ដើម្បីធានាការយល់ដឹងជាសាធារណៈផ្នែកច្បាប់និងការអនុវត្តច្បាប់ រួមទាំង ការសម្រេចរបស់តុលាការ នីតិវិធីរបាយការណ៍រដ្ឋបាលជាទៀងទាត់ ព័ត៌មានរដ្ឋបាលទាក់ទងនឹងស្ថានភាពសំណុំរឿងដែលមិនទាន់សម្រេច និងកាលវិភាគព័ត៌មាន។

រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តចាត់វិធានការដើម្បីប្រយុទ្ធប្រឆាំងអំពើពុករលួយ តាមរយៈការពង្រឹងគណនេយ្យភាពនិងការកសាងសមត្ថភាពស្ថាប័នដោយមានការគាំទ្រ និងការចូលរួមពីសាធារណជន ការចូលរួមពីវិស័យឯកជន និងការពង្រឹងការអនុវត្តច្បាប់។ ជាមួយគ្នានេះ ក្រសួងទំនាក់ទំនងជាមួយនឹងរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ក៏បានចូលរួមយ៉ាងសកម្មក្នុងការកាត់បន្ថយអំពើអសកម្មនានា ដើម្បីរួមចំណែកទប់ស្កាត់អំពើពុករលួយផងដែរ តាមរយៈ ការចុះធ្វើអធិការកិច្ច ការតាមដានអនុវត្តច្បាប់ ការដោះស្រាយពាក្យបណ្តឹង និងបានផ្សព្វផ្សាយច្បាប់ពាក់ព័ន្ធនឹងការបង្ការទប់ស្កាត់អំពើពុករលួយទៅដល់គ្រប់រាជធានី-ខេត្តផងដែរ។

**ករណីសិក្សាទី២៖ មេធាវីនិងគ្រូពេទ្យសម្រាប់ប្រជាជនក្រីក្រ**

*មេធាវីស្ម័គ្រចិត្ត*

ដើម្បីធានាដល់ការទទួលបានយុត្តិធម៌សង្គមកាន់តែទូលំទូលាយ រាជរដ្ឋាភិបាលកម្ពុជានៅខែកុម្ភៈ ឆ្នាំ២០១៩ បានបញ្ជាឱ្យបង្កើតក្រុមមេធាវីស្ម័គ្រចិត្ត ដើម្បីការពារស្ត្រីក្រីក្រ ដែលមិនអាចមានលទ្ធភាពបង់ប្រាក់សម្រាប់តំណាងរបស់ខ្លួនក្នុងតុលាការ។ ការបង្កើតក្រុមការងារផ្នែកច្បាប់ថ្មីនេះនឹងមិនប្រើប្រាស់ថវិកាជាតិនោះទេ ប៉ុន្តែការផ្តល់មូលនិធិដំបូងចំនួន ៥០០ ០០០ដុល្លារអាមេរិក នឹងចេញមកពីថវិកាផ្ទាល់ខ្លួនរបស់សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ហើយនឹងគ្របដណ្តប់លើការចំណាយលើការរស់នៅនិងម្ហូបអាហារ ដោយមានប្រាក់បន្ថែមសម្រាប់មេធាវីលើបេសកកម្មនៅតំបន់ជនបទ។ ស្ត្រីគោលដៅ ដែលទទួលជំនួយផ្នែកច្បាប់ពីក្រុមមេធាវីស្ម័គ្រ

ចិត្តនេះ រួមមាន ស្ត្រីក្រីក្រដែលជាជនរងគ្រោះដោយការរំលោភយកដីធ្លីដោយអ្នកមានអំណាច និងប្រជាជនទន់ខ្សោយដែលត្រូវបានប្ដឹងដោយបុគ្គលដែលមានអំណាច។

*ក្រុមគ្រូពេទ្យស្ម័គ្រចិត្ត*

ស្របជាមួយនឹងការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងកាត់បន្ថយភាពក្រីក្រ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតឡើងនូវសមាគមវេជ្ជបណ្ឌិតយុវជនស្ម័គ្រចិត្ត នៅឆ្នាំ២០១២ ហើយចាប់តាំងពីពេលនោះមក វេជ្ជបណ្ឌិតនិងគ្រូពេទ្យចំនួន ៣ ៦០០នាក់បានក្លាយជាអ្នកស្ម័គ្រចិត្ត។ វេជ្ជបណ្ឌិត យុវជនស្ម័គ្រចិត្ត ត្រូវបានបង្កើតឡើងដោយមានគោលបំណងសំខាន់៣ គឺ (១) រួមចំណែកជាមួយស្ថាប័នជាតិ ជាពិសេស ក្រសួងសុខាភិបាលក្នុងការផ្ដល់សេវាសុខភាពសាធារណៈជូនប្រជាជនដោយឥតគិតថ្លៃ មិនគិតពីពូជសាសន៍ ពណ៌សម្បុរ ឬការជាប់ពាក់ព័ន្ធនយោបាយឡើយ (២) រួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជាដើម្បីកាត់បន្ថយភាពក្រីក្រ តាមរយៈ ការផ្ដល់សេវាសុខភាពតាមផ្ទះដល់ជនក្រីក្រ ជាពិសេស ប្រជាជនក្រីក្រដែលរស់នៅតំបន់ជនបទ និង (៣) រួមចំណែកដល់ធនធានមនុស្សក្នុងវិស័យសុខាភិបាល ក៏ដូចជាផ្ដល់ឱកាសដល់គ្រូពេទ្យ យុវជន និងនិស្សិតស្ម័គ្រចិត្ត ក្នុងការចូលរួមចំណែកក្នុងការងារសប្បុរសធម៌នៅក្នុងសង្គម។

សមាគមវេជ្ជបណ្ឌិតយុវជនស្ម័គ្រចិត្ត ផ្ដល់សេវាសុខភាពដល់ប្រជាជនដោយគ្មានការរើសអើងនិន្នាការនយោបាយ។ ចាប់តាំងពីការបង្កើតឡើង មានមនុស្ស២៤០ ០០០នាក់បានទទួលប្រយោជន៍ពីសេវាសុខភាពដោយឥតគិតថ្លៃ។ ដោយសារតែសារសំខាន់របស់ខ្លួន អនុស្សារណៈនៃការយោគយល់មួយត្រូវបានចុះហត្ថលេខារវាងរបបសន្តិសុខសង្គម ជាមួយសមាគមវេជ្ជបណ្ឌិតយុវជនស្ម័គ្រចិត្ត ដើម្បីផ្ដល់សេវាព្យាបាលឥតគិតថ្លៃដល់កម្មករនិងប្រជាជននៅតាមរាជធានី ខេត្ត។ សមាគមវេជ្ជបណ្ឌិតយុវជនស្ម័គ្រចិត្ត បានផ្ដល់ជូននូវរោគវិនិច្ឆ័យ និងសេវាព្យាបាល រួមទាំងជំងឺទូទៅ ជំងឺមាត់ធ្មេញ ការវះកាត់តិចតួច ជំងឺមហារីកសុដន់ ជំងឺសរសៃឈាម ជំងឺសរសៃប្រសាទ ការធ្វើតេស្តឈាម ជំងឺថ្លើម ជំងឺសួត ជំងឺ ពោះវៀនធំ ជំងឺស្បែក និងជំងឺផ្សេងៗទៀត។

## គោលដៅទី១៧៖ ពង្រឹងមធ្យោបាយអនុវត្តនានានិងបង្កើតភាពរស់រវើកនៃភាពជាដៃគូសាកលសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព

### វឌ្ឍនភាព

នៅក្នុងស្ថានភាពនៃការអភិវឌ្ឍក្នុងបរិការណ៍សាកល ដែលមានការប្រែប្រួលយ៉ាងឆាប់រហ័ស រាជរដ្ឋាភិបាលកម្ពុជាបានបង្ហាញឱ្យឃើញនូវកិច្ចខិតខំប្រឹងប្រែង និងការប្ដេជ្ញាចិត្ត ក្នុងការបន្តកសាងភាពជាដៃគូ ដើម្បីការអភិវឌ្ឍប្រកបដោយប្រសិទ្ធភាព តាមរយៈ ការធ្វើឱ្យមានវឌ្ឍនភាពក្នុងការអនុវត្ត *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤* និង *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ*។ រាជរដ្ឋាភិបាលកម្ពុជាបានទទួលជោគជ័យគួរឱ្យកត់សម្គាល់ ក្នុងការកៀរគរធនធាន ស្របតាមអាទិភាពជាតិ ការធ្វើឱ្យប្រសើរឡើងកិច្ចសហប្រតិបត្តិការនិងភាពជាដៃគូជាមួយដៃគូអភិវឌ្ឍ តាមរយៈ ការបន្តការកសាងសមត្ថភាពដើម្បីអនុវត្តយន្តការនិងគោលនយោបាយអាទិភាព តាមតម្រូវការអភិវឌ្ឍន៍ជាតិ។ រាជរដ្ឋាភិបាលកម្ពុជាក៏បានទទួលជោគជ័យផងដែរ ក្នុងការអនុវត្ត *យុទ្ធសាស្ត្រស្ដីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ២០១៤-២០១៨* កន្លងមក។ យុទ្ធសាស្ត្រថ្មី សម្រាប់អាណត្តិកាល ២០១៩-២០២៣ កំពុងបន្តរៀបចំនិងសម្របសម្រួលភាពជាដៃគូ និងផ្ដល់កាលានុវត្តភាពក្នុងការកៀរគរធនធានសហប្រតិបត្តិការអភិវឌ្ឍន៍ និងពង្រឹងភាពជាដៃគូជាមួយភាគីដែលមានចំណែកពាក់ព័ន្ធ ដើម្បីគាំទ្រដល់ការអនុវត្ត *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤* និង *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.) ២០១៩-២០២៣* ដែលមានការបញ្ជ្រាបពីក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា

(គ.អ.ច.ក.) ក្នុងគោលដៅធ្វើឱ្យសម្រេចបាន កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាប័ន្ន ដែលនឹងធ្វើឱ្យមានការអភិវឌ្ឍសង្គមនិងបរិស្ថាន ហើយនឹងផ្តល់ផងដែរនូវមូលដ្ឋានគ្រឹះសម្រាប់អនុវត្តការតាមដានត្រួតពិនិត្យនិងវាយតម្លៃ និងការរៀបចំរបាយការណ៍។

បន្ថែមលើនេះ វឌ្ឍភាពគួរឱ្យកត់សម្គាល់ ពាក់ព័ន្ធនឹងការបង្កើតនិងការគ្រប់គ្រង *យន្តការភាពជាដៃគូ* ដែលជាផ្នែកនៃការអនុវត្ត *យុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍និងភាពជាដៃគូ ២០១៩-២០២៣* ត្រូវបានធ្វើឱ្យកើតមានឡើង។ ដូចបានបង្ហាញពីសារសំខាន់ពី ភាពជាដៃគូជាមួយអ្នកដែលមានចំណែកពាក់ព័ន្ធចម្បុះ ក្នុងការធ្វើឱ្យសម្រេចបាន គ.អ.ច.ក. *យុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍និងភាពជាដៃគូ ២០១៩-២០២៣* ផ្តល់នូវយន្តការពិគ្រោះយោបល់ថ្មី ជាមួយអង្គការសង្គមស៊ីវិល និងជាមួយតួអង្គអភិវឌ្ឍនានា នៅកម្រិតវិស័យនិងថ្នាក់ក្រោមជាតិ។ ការកែសម្រួលគោលការណ៍ណែនាំស្តីពីក្រុមការងារបច្ចេកទេសចម្រុះ រួមបញ្ចូលទាំងការរៀបចំសូចនាករត្រួតពិនិត្យរួមគ្នាសម្រាប់ឆ្នាំ២០១៩-២០២៣ និង គោលការណ៍ណែនាំផ្សេងទៀតស្តីពីយន្តការភាពជាដៃគូ ដូចជាការពិគ្រោះយោបល់រវាងរាជរដ្ឋាភិបាលជាមួយអង្គការមិនមែនរដ្ឋាភិបាល ការពិគ្រោះយោបល់រវាងអ្នកដែលមានចំណែកពាក់ព័ន្ធចម្រុះនៅកម្រិតវិស័យ និងថ្នាក់ក្រោមជាតិ បានធ្វើឱ្យប្រសើរឡើងនូវភាពជាដៃគូប្រកបដោយ បរិយាប័ន្ន តម្លាភាព គណនេយ្យភាព នៅក្នុងការអភិវឌ្ឍប្រកបដោយប្រសិទ្ធភាពនៅគ្រប់កម្រិត។ គោលការណ៍ដែលបានកែសម្រួលនេះ នឹងផ្តល់នូវយន្តការសម្រាប់ពិគ្រោះយោបល់និងតាមដានត្រួតពិនិត្យ ការបញ្ជ្រាប គ.អ.ច.ក. ទៅក្នុងអាទិភាពនិងសកម្មភាពរបស់ក្រសួង ស្ថាប័នតាមវិស័យ ក៏ដូចជា ការផ្តល់នូវការកសាងមូលដ្ឋានដ៏ទូលំទូលាយក្នុងភាពជាដៃគូប្រកបដោយបរិយាប័ន្ន។

ប្រព័ន្ធនិងសមត្ថភាពស្ថាប័ន ក៏ត្រូវបានពង្រឹងផងដែរ ដើម្បីធានានូវការដឹកនាំការកៀរគរនិងគ្រប់គ្រងធនធាន សម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍។ ដោយផ្អែកលើសមត្ថភាពនិងកិច្ចខិតខំប្រឹងប្រែង របស់គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍកម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលជាស្ថាប័នស្នូលរបស់រដ្ឋាភិបាល សម្រាប់សម្របសម្រួលនិងគ្រប់គ្រងការកៀរគរជំនួយអភិវឌ្ឍន៍ផ្លូវការ រាជរដ្ឋាភិបាលបានរក្សាបាននូវកិច្ចសហប្រតិបត្តិការល្អ និងធ្វើការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍនានា ដើម្បីគាំទ្រនិងតម្រង់ទិសដៅជំនួយអភិវឌ្ឍន៍ផ្លូវការ ឆ្ពោះទៅអាទិភាពជាតិ សំដៅសម្រេចបានគោលដៅអភិវឌ្ឍន៍ជាតិនៅកម្ពុជា។ ជាក់ស្តែង ការផ្តល់មូលនិធិតាមរយៈជំនួយអភិវឌ្ឍន៍ផ្លូវការឆ្នាំ២០១៩ មានចំនួន១ ៨៨៨លានដុល្លារ ដែលស្របគ្នានឹងតម្រូវការធនធានពីក្រៅប្រទេសសម្រាប់អនុវត្ត ផ.យ.អ.ជ.។ ភាពជោគជ័យគួរឱ្យកត់សម្គាល់នេះ បានបង្ហាញពីលទ្ធផលនៃភាពម្ចាស់ និងការដឹកនាំប្រកបដោយប្រសិទ្ធភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការកៀរគរធនធានឱ្យអស់លទ្ធភាព និងការធានានូវការផ្សារភ្ជាប់ធានធាននេះ ជាមួយនឹងអាទិភាពជាតិដែលបានកំណត់ក្នុង *ផ.យ.អ.ជ. ២០១៩-២០២៣*។ យោងតាមវឌ្ឍនភាពខាងលើ បរិមាណសរុបនៃការគាំទ្រដល់វិស័យឬអនុវិស័យ បានបង្ហាញពីការកើនឡើងខ្ពស់ជាងចំណុចដៅដែលបានកំណត់ នៅក្នុងក្របខ័ណ្ឌ គ.អ.ច.ក. ២០១៦-២០៣០។

រាជរដ្ឋាភិបាលកម្ពុជា ក៏ទទួលស្គាល់ផងដែរថា ទិន្នន័យប្រជាជនគឺជាមូលដ្ឋានគ្រឹះសម្រាប់រៀបចំគោលនយោបាយនិងកម្មវិធីជាតិ។ កម្ពុជាបានបង្កើនថវិកាជាតិសម្រាប់អង្កេតថ្នាក់ជាតិនិងជំរឿនទូទៅនៃប្រជាជនកម្ពុជាឆ្នាំ២០១៩ ឱ្យស្របតាមអនុសាសន៍និងស្តង់ដាអន្តរជាតិ។ ការងារនេះ

នឹងជំរុញដល់ការរាប់ប្រជាជនគ្រប់រូប និងកសាងសមត្ថភាពសម្រាប់ការប្រើប្រាស់ទិន្នន័យប្រកបដោយប្រសិទ្ធភាព ដើម្បីតាមដានវឌ្ឍនភាពធៀបនឹងគោលដៅនិងសូចនាករនានារបស់ គ.អ.ច.ក.។ ការងារជំរឿនត្រូវបានផ្សព្វផ្សាយតាមរយៈអនុក្រុមទិន្នន័យសម្រាប់អភិវឌ្ឍន៍ របស់ក្រុមការងារបច្ចេកទេសផែនការនិងការកាត់បន្ថយភាពក្រីក្រ ដើម្បីជានាគុណភាពនិងការបញ្ចេញទិន្នន័យបំបែកតាមទីកន្លែងនិងពេលវេលាកំណត់។

## តារាង ៤.១៧៖ វឌ្ឍនភាពគោលដៅទី១៧ នៃ គ.អ.ច.ក.

| | ចំណុចដៅ/សូចនាករ | ឯកតា | ២០១៥ | ចំណុចដៅ គ.អ.ច.ក. | | | | ជាក់ស្តែង | | | | វឌ្ឍនភាព |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | |
| ១៧.៣ | កៀរគរធនធានហិរញ្ញវត្ថុបន្ថែមទៀតពីប្រភពចម្រុះ សម្រាប់ផ្តល់ដល់បណ្តាប្រទេសកំពុងអភិវឌ្ឍ។ | | | | | | | | | | | លើសចំណុចដៅ |
| ១៧.៣.១ | សមាមាត្រនៃហិរញ្ញប្បទានចម្រុះធៀបនឹងផលិតផលក្នុងស្រុកសរុប។ | % នៃ ផ.ស.ស. | ៧,៧៣ | ៧,៣៥ | ៦,៨៧ | ៦,៤២ | ៦,០០ | ៦,៤៣ | ៦,៨៦ | ៦,១២ | ៧,០៥ | លើសចំណុចដៅ |
| ១៧.៦ | លើកកម្ពស់កិច្ចសហប្រតិបត្តិការជើង-ត្បូង កិច្ចសហប្រតិបត្តិការត្បូង-ត្បូង កិច្ចសហប្រតិបត្តិការតំបន់ត្រីកោណ និងកិច្ចសហប្រតិបត្តិការអន្តរជាតិស្តីពីការទទួលបានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និង លើកកម្ពស់ការចែករំលែកការយល់ដឹងស្តីពីទម្រង់នៃការឯកភាពទាំងសងខាង តាមរយៈការធ្វើឱ្យប្រសើរឡើង ការសម្របសម្រួលក្នុងចំណោមយន្តការដែលមានស្រាប់ ជាពិសេស ក្នុងកម្រិតសហប្រជាជាតិ និងតាមរយៈយន្តការសម្របសម្រួលបច្ចេកវិទ្យាសកល។ | | | | | | | | | | | លើសចំណុចដៅ |
| ១៧.៦.១ | ភាគរយនៃប្រជាជនប្រើប្រាស់អ៊ីនធឺណិតអចល័តល្បឿនលឿន (ល្បឿន ≥1Mbps)។ | % | ០,៦ | ០,៦៤ | ០,៧៤ | ១,០០ | ១,០៦ | ០,៦២ | ០,៨៦ | ០,៩៤ | ១,៣៥ | លើសចំណុចដៅ |
| ១៧.៨ | ត្រឹមឆ្នាំ២០២៧ ធ្វើប្រតិបត្តិការពេញលេញធនាគារបច្ចេកវិទ្យានិងវិទ្យាសាស្ត្រ និងយន្តការកសាងសមត្ថភាពពីបច្ចេកវិទ្យានិងនវានុវត្តន៍ សម្រាប់បណ្តាប្រទេសដែលមានការអភិវឌ្ឍតិចតួច និងលើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាដែលមានសមត្ថភាព ជាពិសេសបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន | | | | | | | | | | | លើសចំណុចដៅ |
| ១៧.៨.១ | សមាមាត្រនៃប្រជាជនប្រើប្រាស់សេវាទូរសព្ទ។ | % | ១៣៧,៣៥ | ១២៩,៣០ | ១១៥,៩៩ | ១១៦,៣៦ | ១១៧,៦០ | ១២៨,៩០ | ១១៨,០៣ | ១២១,៣៨ | ១៣៣,៤២ | លើសចំណុចដៅ |
| | ១) ទូរសព្ទចល័ត | % | ១៣៥,០០ | ១២៧,៤៥ | ១១៤,៧៤ | ១១៥,៨៩ | ១១៧,០៥ | ១២៧,៤៥ | ១១៧,១៩ | ១២០,៨៣ | ១៣៣,០៧ | លើសចំណុចដៅ |
| | ២) ទូរសព្ទអចល័ត | % | ២,៣៥ | ១,៨៥ | ១,២៥ | ០,៥៧ | ០,៥៥ | ១,៤៥ | ០,៨៤ | ០,៥៥ | ០,៣៥ | ទាបជាងចំណុចដៅ |
| ១៧.៩ | លើកកម្ពស់ការគាំទ្រពីអន្តរជាតិ សម្រាប់ការអនុវត្តការកសាងសមត្ថភាពដែលបានកំណត់ចំណុចដៅនិងមានប្រសិទ្ធភាព ក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍ ដើម្បីគាំទ្រផែនការជាតិ ក្នុងការអនុវត្តនូវគ្រប់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព រួមទាំងតាមរយៈ កិច្ចសហប្រតិបត្តិការជើង -ត្បូង កិច្ចសហប្រតិបត្តិការត្បូង -ត្បូង និងកិច្ចសហប្រតិបត្តិការតំបន់ត្រីកោណ។ | | | | | | | | | | | លើសចំណុចដៅ |
| ១៧.៩.១ | ទំហំហិរញ្ញប្បទានកិច្ចសហប្រតិបត្តិការបច្ចេកទេស (រួមទាំងកិច្ចសហប្រតិបត្តិការជើងត្បូង ត្បូង-ត្បូង និងកិច្ចសហប្រតិបត្តិការត្រីកោណ) ដែលបានសន្យាផ្តល់ដល់កម្ពុជា | % នៃ ផ.ស.ស. | ១,៣១ (២០១៦) | ១,៣១ | ១,២៣ | ១,១៥ | ១,០៧ | ១,៥៣ | ១,៨៧ | ១,៤៥ | ១,៨៥ | លើសចំណុចដៅ |
| ១៧.៩.២ | ទំហំហិរញ្ញប្បទានសហប្រតិបត្តិការដែលគាំទ្រគោលនយោបាយផ្នែកកិច្ចនិងការអភិវឌ្ឍដែលបានប្តេជ្ញាផ្តល់ ឱ្យកម្ពុជាធៀបនឹង ផ.ស.ស.។ | % នៃ ផ.ស.ស. | ០,០៣ (២០១៦) | ០,០៣ | ០,០២ | ០,០២ | ០,០២ | ០,០៤ | ០,០៥ | ០,០៤ | ០,០៤ | លើសចំណុចដៅ |
| ១៧.១០ | លើកកម្ពស់ប្រព័ន្ធពាណិជ្ជកម្មចម្រុះ ដែលមានលក្ខណៈជាសកលមានមូលដ្ឋានច្បាប់ បើកទូលាយនិងសមធម៌ក្រោម អង្គការពាណិជ្ជកម្មពិភពលោក រួមទាំងតាមរយៈការសន្និដ្ឋាននៃការចរចាក្រោម របៀបវារៈ ទីក្រុងដាហាស្តីពីការអភិវឌ្ឍ។ | | | | | | | | | | | លើសចំណុចដៅ |
| ១៧.១០.១ | អត្រាកើននៃចំនួនច្បាប់និងបទដ្ឋានគតិយុត្តពាណិជ្ជកម្ម ដែលបានរៀបចំឡើងដើម្បីសម្រួលដល់អ្នកវិនិយោគនិងធុរជនក្នុងស្រុកក្នុងការធ្វើពាណិជ្ជកម្ម។ | % | ៧ | ៧ | ៧ | ៨ | ៨ | ២៥ | ២០ | ១៧ | ១៤ | លើសចំណុចដៅ |
| ១៧.១៧ | លើកទឹកចិត្តនិងលើកកម្ពស់ភាពជាដៃគូប្រកបដោយប្រសិទ្ធភាពក្នុងផ្នែក សាធារណៈ រវាងផ្នែកសាធារណៈនិងផ្នែកឯកជន និងជាមួយសង្គមស៊ីវិល កសាងភាពជាដៃគូផ្អែកលើបទពិសោធន៍ និងយុទ្ធសាស្ត្រផ្តល់ធនធាននៃភាពជាដៃគូ។ | | | | | | | | | | | លើសចំណុចដៅ |
| ១៧.១៧.១ | ទំហំហិរញ្ញប្បទានសហប្រតិបត្តិការដែលត្រូវបានសន្យាផ្តល់ដល់ភាពជាដៃគូសង្គមស៊ីវិល ធៀបនឹង ផ.ស.ស។ | % នៃ ផ.ស.ស. | ០,០១ | ០,០១ | ០,០១ | ០,០១ | ០,០១ | ០,០៣ | ០,០៣ | ០,០៤ | ០,០៥ | លើសចំណុចដៅ |
| ១៧.១៨ | ត្រឹមឆ្នាំ២០២០ លើកកម្ពស់ការគាំទ្រការកសាងសមត្ថភាពដល់បណ្តាប្រទេសកំពុងអភិវឌ្ឍ រួមទាំងដល់បណ្តាប្រទេសដែលមានការអភិវឌ្ឍតិចតួច និងបណ្តារដ្ឋដែនកោះតូចៗកំពុងអភិវឌ្ឍ ដើម្បីបង្កើនឱ្យបានច្រើន ភាពអាចរកបានទាន់ពេលនៃទិន្នន័យដែលមានគុណភាពខ្ពស់ និងជឿជាក់បាន បំបែកតាមចំណូល យេនឌ័រ អាយុ ជាតិ សាសន៍ ជនពិការ តិច ស្ថានភាពនៃការផ្លាស់ប្តូរទីលំនៅ ការបាត់បង់សមត្ថភាពពលកម្មទីតាំងភូមិសាស្ត្រ និងលក្ខណៈផ្សេងទៀតដែលពាក់ព័ន្ធក្នុងបរិការណ៍ជាតិ។ | | | | | | | | | | | ស្ថិតលើគន្លងទៅសម្រេច |
| ១៧.១៨.១ | សមាមាត្រនៃសូចនាករអភិវឌ្ឍប្រកបដោយចីរភាពដែលបានបង្កើតឡើងនៅថ្នាក់ជាតិបំបែកទៅតាមចំណុចដៅដោយផ្អែកលើមូលដ្ឋានស្ថិតិផ្លូវការ។ | | - | - | - | ៩៤ | | - | - | ៩៤ | ៩៤ | ស្ថិតលើគន្លងទៅសម្រេច |
| ១៧.១៨.២ | សមាមាត្រនៃចំណាយថវិកាសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រជាតិសម្រាប់អភិវឌ្ឍស្ថិតិ។ | % | ០,២ | - | - | - | | - | - | - | | គ្មានទិន្នន័យ |
| ១៧.១៩ | ត្រឹមឆ្នាំ២០៣០ កសាងដោយផ្អែកលើការផ្តួចផ្តើមដែលមានស្រាប់ ដើម្បីអភិវឌ្ឍមធ្យោបាយ វាស់វែងពីវឌ្ឍនភាពនៃការអភិវឌ្ឍប្រកបដោយចីរភាព ដែលបំពេញផលិតផលក្នុងស្រុកសរុប និងគាំទ្រការកសាងសមត្ថភាព ស្ថិតិនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍ។ | | | | | | | | | | | ស្ថិតលើគន្លងទៅសម្រេច |
| ១៧.១៩.១ | ជំរឿនប្រជាជនរៀងរាល់១០ឆ្នាំម្តង។ | ចំនួនដង | ១ | - | - | - | ១ | - | - | - | ១ | ស្ថិតលើគន្លងទៅសម្រេច |

*ប្រភព៖ ក្របខ័ណ្ឌ គ.អ.ច.ក. និង ក្រសួង ស្ថាប័ន*

ដោយមានបំណងពង្រឹងកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ ច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានប្រកាសឱ្យប្រើប្រាស់នាខែសីហា ឆ្នាំ២០១៥ ហើយកិច្ចប្រជុំពិគ្រោះយោបល់ជាមួយអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិក៏ត្រូវបានរៀបចំឡើង ដើម្បីកំណត់បញ្ហាប្រឈមរួមគ្នា និងកំណត់ដំណោះស្រាយសមស្រប ដើម្បីពង្រឹងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្ត។

## បញ្ហាប្រឈម

ទោះបីជាការសម្រេចបានចំណុចដៅនានា ក្នុងគោលដៅទី១៧ នៃ គ.អ.ច.ក. មានកម្រិតគួរឱ្យកត់សម្គាល់ក៏ដោយ ក៏នៅមានបញ្ហាប្រឈមមួយចំនួនបានកើតមានឡើង នៅក្នុងអំឡុងពេលនៃការអនុវត្ត។ ដោយសារការរីកចម្រើនយ៉ាងឆាប់រហ័សនៃការអភិវឌ្ឍ ហើយកម្ពុជាបាននិងកំពុងធ្វើដំណើរឆ្ពោះទៅរកការចាកចេញពីស្ថានភាពនៃប្រទេសដែលមានការអភិវឌ្ឍតិចតួច នៅក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខ ដៃគូអភិវឌ្ឍហាក់ដូចជាកំពុងកែប្រែវិធីសាស្ត្រនៃការគាំទ្ររបស់ខ្លួនចំពោះកម្ពុជា ដោយបង្កើនសមាមាត្រនៃកម្ចីជៀបនឹងបរិមាណជំនួយអភិវឌ្ឍន៍ផ្លូវការ និងបង្កើនការរួមចំណែករបស់ថវិការដ្ឋនៅក្នុងគម្រោងនីមួយៗ ដែលគាំទ្រហិរញ្ញវត្ថុដោយដៃគូអភិវឌ្ឍ។ ក្នុងន័យនេះ ភាពជាដៃគូនិងធនធានអភិវឌ្ឍន៍ថ្មី ត្រូវសម្របសម្រួលនិងកៀរគរដើម្បីធានាថា ការគាំទ្រត្រូវបានរក្សានិងអាចព្យាករណ៍បានដើម្បីផ្តល់ហិរញ្ញប្បទានគ្រប់គ្រាន់សម្រាប់ការធ្វើឱ្យសម្រេចបាន គ.អ.ច.ក. និងដើម្បីត្រៀមសម្រាប់កម្ពុជាចាកចេញស្ថានភាពនៃប្រទេសដែលមានការអភិវឌ្ឍតិចតួច នាពេលអនាគត។ តម្រូវការនៃការកៀរគរធនធាននេះ មានកម្រិតស្មុគ្រស្មាញជាងមុន ហើយកម្រិតនៃធនធានក៏មានការកើនឡើងផងដែរ សម្រាប់ទាំងផ្នែកឯកជន និងផ្នែកសាធារណៈ ដើម្បីជាការរួមចំណែកធ្វើឱ្យសម្រេចបាន គ.អ.ច.ក. និងគោលដៅអភិវឌ្ឍន៍ផ្សេងទៀត។

សមត្ថភាពស្ថាប័ន ក៏ទាមទារឱ្យមានការពង្រឹងបន្ថែមទៀតផងដែរ ដើម្បីធានាពីការកៀរគរនិងការគ្រប់គ្រងធនធានសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍។ បញ្ហាប្រឈមមួយទៀតគឺ ត្រូវធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃដោយផ្អែកលើលទ្ធផល សម្រាប់ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ និងការរៀបចំរបាយការណ៍ដែលពាក់ព័ន្ធនឹងការសម្រេចបាន គ.អ.ច.ក. តាមរយៈ ការប្រមូលទិន្នន័យស្ថិតិ ដែលនឹងផ្តល់នូវបច្ចុប្បន្នភាពទិន្នន័យដែលមានគុណភាពខ្ពស់ អាចជឿជាក់បាន សម្រាប់ប្រើប្រាស់នៅក្នុងការតាមដានត្រួតពិនិត្យគោលដៅ និងសូចនាករអភិវឌ្ឍន៍នៅក្នុងប្រទេស និងសម្រាប់រៀបចំគោលនយោបាយនានា។

## គោលនយោបាយឬយុទ្ធសាស្ត្រសំខាន់ៗ

វឌ្ឍនភាពជាក់លាក់និងទាន់ពេលវេលា អាចបន្តសម្រេចទៅបាន គឺអាស្រ័យដោយការរួមបញ្ចូលគ្នារវាងភាពខ្លាំងនៃការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា និងការប្តេជ្ញាចិត្តធ្វើការងាររួមគ្នាក្នុង

ភាពជាដៃគូ និងការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ បច្ចុប្បន្ន ការយកចិត្តទុកដាក់ ត្រូវការផ្តោតលើ ការអនុវត្តប្រកបដោយប្រសិទ្ធភាពនិងការបន្តធ្វើការងារក្នុងភាពជាដៃគូ ដើម្បីធានាការអនុវត្តប្រកបដោយប្រសិទ្ធភាព នូវរបៀបវារៈគោលនយោបាយ រួមទាំង គ.អ.ច.ក. (២០១៦-២០៣០) ផ.យ.អ.ជ. (២០១៩-២០២៣) ផែនការយុទ្ធសាស្ត្រតាមវិស័យ និងគោលនយោបាយកែទម្រង់ផ្សេងទៀត។ ក្នុងន័យនេះ តួអង្គអភិវឌ្ឍទាំងអស់ត្រូវបានលើកទឹកចិត្តឱ្យធ្វើការប្រកបដោយភាពច្នៃប្រឌិត ជាមួយរាជរដ្ឋាភិបាលកម្ពុជា ខណៈពេលដែលកំពុងស្វែងរកការច្នៃប្រឌិត និងបង្កើតភាពជាដៃគូថ្មី ដែលអាចកៀរគរនិងតម្រង់ទិសធនធានដែលមានការកើនឡើង ដើម្បីគាំទ្រដល់ សង្គម សេដ្ឋកិច្ចដែលមានការប្រែប្រួល។

ការបន្តពង្រឹងការអនុវត្ត *យុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍និងភាពជាដៃគូ ២០១៩-២០២៣* ក៏មានសារសំខាន់ណាស់ ដើម្បីជំរុញកិច្ចសហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព ពង្រឹងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងពង្រឹងភាពជាដៃគូជាមួយតួអង្គអភិវឌ្ឍទាំងអស់ ដោយគោរពភាពជាម្ចាស់ ការដឹកនាំ របស់រាជរដ្ឋាភិបាលកម្ពុជា និងស្របតាមអាទិភាពជាតិ។ ដោយសារតែតួនាទីរបស់ជំនួយអភិវឌ្ឍន៍ផ្លូវការ នៅតែជាអាទិភាពខ្ពស់សម្រាប់របៀបវារៈអភិវឌ្ឍន៍សង្គមសេដ្ឋកិច្ចជាតិ និងដើរតួជាកាតាលីករក្នុងការប្រើប្រាស់ប្រភពហិរញ្ញវត្ថុអភិវឌ្ឍន៍ (ទាំងឯកជននិងសាធារណៈ) ដើម្បីជំរុញកំណើនសេដ្ឋកិច្ចនិងការអភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជា គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលជាស្ថាប័នស្នូលរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការសម្របសម្រួលនិងការកៀរគរធនធានឈានមុខគេ មានមុខងារសំខាន់ៗសម្រាប់ការគ្រប់គ្រងយុទ្ធសាស្ត្រជំនួយអភិវឌ្ឍន៍ផ្លូវការ។ ការបង្កើតប្រព័ន្ធតាមដានត្រួតពិនិត្យជាតិ និងការពង្រឹងការអនុវត្តប្រព័ន្ធតាមដានត្រួតពិនិត្យនិងរាយការណ៍ដែលមានស្រាប់ បានបង្ហាញឱ្យឃើញនូវភស្តុតាងដែលមានលក្ខណៈបរិមាណនិងគុណភាព នូវលទ្ធផលនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍និងវឌ្ឍនភាពជាក់លាក់។

ក្នុងនាមជាប្រទេសដែលមានស្ថានភាពចំណូលមធ្យមកម្រិតទាប និងជាប្រទេសដែលកំពុងឆ្ពោះទៅរកការចាកចេញពីប្រទេសដែលមានការអភិវឌ្ឍតិចតួចក្នុងពេលអនាគត រាជរដ្ឋាភិបាលកម្ពុជាកំពុងស្វែងរកការរួមបញ្ចូល និងរក្សាកំណត់ត្រាវឌ្ឍនភាពសង្គមសេដ្ឋកិច្ច តាមរយៈ ការពង្រឹងស្ថាប័នសាធារណៈ ប្រព័ន្ធនិងសមត្ថភាពដែលនឹងជួយទ្រទ្រង់ដល់កំណើនសេដ្ឋកិច្ចនិងការប្រកួតប្រជែងក្នុងពេលបច្ចុប្បន្ន និងក្នុងពេលអនាគតរយៈពេលវែង។ ដើម្បីសម្រេចបាននូវមហិច្ឆតាឈានដល់ឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ ជាប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០ និងដើម្បីអនុវត្តឱ្យបានពេញលេញនូវរបៀបវារៈអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ២០៣០ គឺតម្រូវឱ្យមានគោលនយោបាយសហប្រតិបត្តិការហិរញ្ញប្បទាននិងភាពជាដៃគូ សម្រាប់ការអភិវឌ្ឍទាំងមូល។

រាជរដ្ឋាភិបាលកម្ពុជាប្តេជ្ញាបន្តធ្វើការក្នុងភាពជាដៃគូ ដើម្បីទទួលបានជោគជ័យក្នុងការអនុវត្តរបៀបវារៈគោលនយោបាយរបស់ខ្លួន រួមមាន *គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា (គ.អ.ច.ក.) ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ.)* ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ និងកំណែទម្រង់អភិបាលកិច្ចសំខាន់ៗ។ យុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍនិងភាពជាដៃគូ របស់រាជរដ្ឋា

ភិបាលកម្ពុជា បានរួមចំណែកដ៏សំខាន់ដល់កិច្ចខិតខំប្រឹងប្រែងភាពជាដៃគូអភិវឌ្ឍ តាមរយៈការបង្កើតគោលការណ៍ ការកំណត់គោលដៅ និងការកំណត់ឧបករណ៍ ដើម្បីជំរុញកិច្ចសហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព។

អាទិភាពសំខាន់ៗសម្រាប់ពង្រឹងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍និងភាពជាដៃគូ ក្នុងនីតិកាលទី៦ នៃរដ្ឋសភា មានដូចខាងក្រោម៖

- បន្តពង្រឹងភាពជាដៃគូប្រកបដោយបរិយាប័ន្នជាមួយគ្រប់ដៃគូអភិវឌ្ឍ ដើម្បីកៀរគរធនធានហិរញ្ញវត្ថុសម្រាប់ការអនុវត្ត គ.អ.ច.ក. ដោយអនុលោមតាមគោលការណ៍ភាពជាអ្នកដឹកនាំ និងភាពជាម្ចាស់របស់រាជរដ្ឋាភិបាល។
- បន្តចូលរួមយ៉ាងសកម្មក្នុងកិច្ចការសាកលនិងតំបន់ ដើម្បីជំរុញកាលានុវត្តភាពការអភិវឌ្ឍ ជាពិសេស លើកកម្ពស់សន្តិភាព សន្តិសុខ និងកាលានុវត្តភាពវិនិយោគនៅកម្ពុជា។
- បន្តអនុវត្តការប្តេជ្ញាចិត្តទាំងអស់ដែលកម្ពុជាបានប្តេជ្ញាចិត្តនៅវេទិកាកម្រិតខ្ពស់ស្តីពី ប្រសិទ្ធភាពអភិវឌ្ឍន៍ រួមទាំងការពង្រឹងការប្រើប្រាស់យន្តការដែលមានស្រាប់សម្រាប់ការពិភាក្សាលើភាពប្រឈមនានាពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍។
- បន្តពង្រឹងភាពជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាល តាមរយៈការពង្រឹងការអនុវត្តច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីលើកកម្ពស់ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពរបស់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍។

## គោលដៅទី១៨៖ បញ្ចប់ផលប៉ះពាល់ជាវិជ្ជមានរបស់មីន/សំណល់ជាតិផ្ទុះពីសង្គ្រាម និងជំរុញការសង្គ្រោះជនរងគ្រោះ

### វឌ្ឍនភាព

កម្ពុជាសម្រេចបានវឌ្ឍនភាពល្អពាក់ព័ន្ធនឹងសកម្មភាពកម្ចាត់មីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម ទោះបីសមិទ្ធផលដែលសម្រេចបាននៅទាបជាងចំណុចដៅក៏ដោយ។ កម្ពុជាប្តេជ្ញាបោសសម្អាតគ្រាប់មីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម ឱ្យអស់នៅឆ្នាំ២០២៥។ ក្នុងឆ្នាំ២០១៦ កម្ពុជាសម្រេចបានការបោសសម្អាតគ្រាប់មីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម (ស.ផ.ស.) លើផ្ទៃដីទំហំ១៣ ២២៨ហិកតា ក្នុងគម្រោងផែនការ១៩ ០៨៧ហិកតា។ ក្នុងឆ្នាំ២០១៧ សម្រេចបាន១៤ ៦៧២ហិកតា នៃគម្រោងផែនការ១៩ ៦៥៩ហិកតា ក្នុងឆ្នាំ២០១៨ សម្រេចបាន១២ ៤៣២ហិកតា ក្នុងគម្រោងផែនការចំនួន២០ ០៤៩ហិកតា។ ក្នុងឆ្នាំ២០១៩ នេះ កម្ពុជាសម្រេចបាន១៣ ០០៨ហិកតា ធៀបនឹងគម្រោងផែនការចំនួន២០ ៨៥៧ហិចតា។

កម្ពុជាសម្រេចបានការកាត់បន្ថយបណ្តើរៗ នូវគ្រោះថ្នាក់របស់ប្រជាជនដោយសារគ្រាប់មីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម។ គ្រោះថ្នាក់ដោយសារគ្រាប់មីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម មានចំនួនតែ ៨៣ករណី ធៀបនឹងការព្យាករណ៍ ក្នុងឆ្នាំ២០១៦ ចំនួន១០០ករណី។ ចំពោះឆ្នាំ២០១៩នេះ ប្រជាជនរងគ្រោះដោយសារគ្រាប់មីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម មានចំនួន៧៧ករណី ធៀបនឹងការ

ព្យាករណ៍ចំនួន៧៣ករណី។ សារអប់រំស្តីពីហានិភ័យដោយសារគ្រាប់មីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម ត្រូវបានអនុវត្តតាមផែនការដែលបានគ្រោងទុក។ ចំនួនភូមិដែលបានទទួលសារនេះ មានការកើនឡើង ពី៣១៥ភូមិ ក្នុងឆ្នាំ២០១៦ ទៅដល់៣៦៤ភូមិនៅឆ្នាំ២០១៩។ ចំនួនជនរងគ្រោះដែលទទួលបានការ លើកកម្ពស់សិទ្ធិនិងគុណភាពជីវិត មានចំនួន២៩៦នាក់ ក្នុងឆ្នាំ២០១៦ និងកើនឡើងដល់៣៣៧នាក់ ក្នុងឆ្នាំ២០១៩។ ទោះបីជាស្ថិតនៅទាបជាងចំណុចដៅដែលកំណត់ក្នុង គ.អ.ច.ក. ប៉ុន្តែវឌ្ឍនភាពនេះ រំពឹងថានឹងឈានទៅសម្រេចបានគោលដៅតាមការគ្រោងទុក។ ចំនួនជនរងគ្រោះដោយសារមីននិង សំណល់ជាតិផ្ទុះពីសង្គ្រាម ទទួលបានការស្តារនីតិសម្បទានិងការឆ្លើយតបភ្លាមៗមានចំនួនតិចជាង ផែនការតិចតួច ដែលយើងរំពឹងថានឹងសម្រេចបានតាមគោលដៅផងដែរ។

ផែនការយុទ្ធសាស្ត្រជាតិពិការភាព ២០១៩-២០២៣ បានដាក់ចេញនូវគោលនយោបាយ អាទិភាពក្នុងការអនុវត្តកម្មវិធីកំណែទម្រង់ក្នុងវិស័យពិការភាព ដោយមានគោលបំណងពង្រឹងសមត្ថភាព ស្ថាប័ន និងពង្រឹងហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច សង្គមកិច្ចសម្រាប់បង្កើតឱកាសការងារសម្រាប់ជនពិការ ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍការងារចាំបាច់សម្រាប់វិស័យពិការភាពនៅកម្ពុជា។ បញ្ហាពិការ ភាពក៏ត្រូវបានដាក់បញ្ចូលក្នុង ផ.យ.អ.ជ. ២០១៩-២០២៣ យុទ្ធសាស្ត្រជាតិស្តីពីសកម្មភាពមីន ២០១៨-២០២៥ និងគោលនយោបាយនិងកម្មវិធីផ្សេងៗរបស់ក្រសួង ស្ថាប័ន និងអាជ្ញាធរគ្រប់កម្រិត។

## តារាង ៤.១៨÷ វឌ្ឍនភាពគោលដៅទី១៨ នៃ គ.អ.ច.ក.

| | ចំណុចដៅ/សូចនាករ | ឯកតា | ២០១៥ | ចំណុចដៅ គអ.ច.ក. | | | | ជាក់ស្តែង | | | | វឌ្ឍនភាព |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | ២០១៦ | ២០១៧ | ២០១៨ | ២០១៩ | |
| ១៨.១ | បោសសម្អាតផ្ទៃដីចម្ការមីន/ស.ផ.ស.ដែលបានដឹងឱ្យអស់ត្រឹមឆ្នាំ២០៣០ | | | | | | | | | | | ទាបជាងចំណុចដៅ |
| ១៨.១.១ | ផ្ទៃដីសរុបនៃការបោសសម្អាតមីននិងសំណល់ជាតិ ផ្ទុះពីសង្គ្រាមប្រចាំឆ្នាំ | ហ.ត. | ១៨ ៥៣១ | ១៩ ០៨៧ | ១៩ ៦៥៩ | ២០ ០៤៩ | ២០ ៨៥៧ | ១៣ ២២៨ | ១៤ ៦៧២ | ១២ ៤៣២ | ១៣ ០០៨ | ទាបជាងចំណុចដៅ |
| ១៨.២ | កាត់បន្ថយគ្រោះថ្នាក់ដោយសារមីនស.ផ.ស. នៅតិចជាង១០នាក់ក្នុងមួយឆ្នាំ ត្រឹមឆ្នាំ២០៣០ | | | | | | | | | | | ស្ថិតលើគន្លង ទៅសម្រេចបាន |
| ១៨.២.១ | ចំនួននៃជនរងគ្រោះថ្នាក់ (ស្លាប់និងរបួស) ដោយគ្រាប់មីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម | នាក់ | ១១១ | ១០០ | ៩០ | ៨១ | ៧៣ | ៨៣ | ៥៨ | ៥៨ | ៧៧ | ស្ថិតលើគន្លង ទៅសម្រេចបាន |
| ១៨.២.២ | ចំនួនភូមិដែលរងការគំរាមកំហែងដោយសារមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាមទទួលបានសារអប់រំគ្រោះថ្នាក់ដោយសារមីននិងសំណល់ជាតិផ្ទុះ ពីសង្គ្រាម | ភូមិ | ៣០០ | ៣១៥ | ៣៣០ | ៣៤៧ | ៣៦៤ | ៣១៥ | ៣៣០ | ៣៤៧ | ៣៦៤ | ស្ថិតលើគន្លង ទៅសម្រេចបាន |
| ១៨.៣ | លើកកម្ពស់សិទ្ធិ និងគុណភាពជីវិតរបស់ជនពិការដោយសារមីនសំណល់ជាតិផ្ទុះពីសង្គ្រាម ឱ្យបានកាន់តែប្រសើរឡើង | | | | | | | | | | | ស្ថិតលើគន្លង ទៅសម្រេចបាន |
| ១៨.៣.១ | ចំនួនជនពិការដោយសារមីន/សំណល់ជាតិផ្ទុះ ពីសង្គ្រាមទទួលបានការលើកកម្ពស់សិទ្ធិនិងគុណភាពជីវិត។ | នាក់ | ២៨០ | ២៩៦ | ៣០៩ | ៣២៤ | ៣៤០ | ២៩៦ | ៣១៤ | ៣២០ | ៣៣៧ | ស្ថិតលើគន្លង ទៅសម្រេចបាន |
| ១៨.៣.២ | ចំនួនជនរងគ្រោះដោយសារមីន/សំណល់ជាតិ ផ្ទុះពីសង្គ្រាមទទួលបានសេវាស្តារលទ្ធភាពពលកម្ម | នាក់ | ១ ៥០០ | ២ ៣០០ | ៣ ៥៧៧ | ៣ ៦៤៨ | ៣ ៧៣១ | ២ ៣០០ | ៣ ២៤៦ | ៣ ៥៨២ | ៣ ៤០៩ | ស្ថិតលើគន្លង ទៅសម្រេចបាន |
| ១៨.៣.៣ | ចំនួនជនរងគ្រោះដោយសារមីន/សំណល់ជាតិផ្ទុះពីសង្គ្រាមទទួលបានសេវាឆ្លើយតបបន្ទាន់និងធាប់របើសពីអាជ្ញាធរមីន | នាក់ | ១០១ | ១២៣ | ១៣៧ | ១៣៩ | ១៤២ | ១២៣ | ១២៨ | ១២៤ | ១៥៦ | ស្ថិតលើគន្លង ទៅសម្រេចបាន |

*ប្រភព÷ ក្របខ័ណ្ឌ គ.អ.ច.ក. និង ក្រសួង ស្ថាប័នពាក់ព័ន្ធ*

## បញ្ហាប្រឈម

ផ្ទៃដីដែលមានផ្ទុកគ្រាប់មីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម មានចំនួន១ ៩៧០គីឡូម៉ែត្រការ៉េ គិតត្រឹមខែធ្នូ ឆ្នាំ២០១៨។ លើសពីនេះទៀត ហិរញ្ញប្បទានសម្រាប់ដោះស្រាយបញ្ហាគ្រាប់មីននិងសំណល់ជាតិផ្ទុះពីសង្គ្រាមមានការថយចុះច្រើន ដោយសារកម្ពុជាបានក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប ដែលតម្រូវឱ្យប្រើប្រាស់ថវិកាជាតិ។ បញ្ហាប្រឈមផ្សេងទៀត មានដូចខាងក្រោម៖

- ផ្លូវចូលទៅទីតាំងមានស្ថានភាពមិនល្អ ប្រតិបត្តិករនិងក្រុមគ្រប់គ្រងគុណភាពរបស់អាជ្ញាធរមិនត្រូវដើរឆ្ងាយ ដើម្បីវាស់វែងទីតាំង។
- កង្វះអ្នកផ្តល់ព័ត៌មានដែលអាចជឿទុកចិត្តបាន និងចំណាយពេលវេលាច្រើនសម្រាប់កំណត់ទិន្នន័យដើមគ្រានៅតាមភូមិ ក្នុងតំបន់ដាច់ស្រយាល។
- តំបន់ហាមឃាត់ ជាពិសេសនៅតាមបណ្តោយព្រំដែន ដែលមិនអាចឱ្យក្រុមការងារនិងប្រតិបត្តិករចូលធ្វើការនៅទីនោះបាន។
- អ្នកផ្តល់ព័ត៌មានមួយចំនួនមិនមានពេលវេលាអមដំណើរក្រុមការងារដោយសារការងារប្រមូលផល។
- លក្ខខណ្ឌអាកាសធាតុនិងភូមិសាស្ត្រ៖ នៅរដូវវស្សា ក្រុមការងារមិនអាចចូលទៅដល់ភូមិឬទីតាំងដែលមានគ្រាប់មីននិងសំណល់ជាតិផ្ទុះពីសង្គ្រាមបានទេ។
- តំបន់ដែលបានបោសសម្អាតរួច នៅតែមានហានិភ័យខ្លះក្នុងសកម្មភាពកម្ចាត់មីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម ដែលអាចបណ្តាលមកពីគ្រាប់មីនមួយចំនួនស្ថិតនៅជ្រៅជាងជម្រៅដែលបានកំណត់សម្រាប់ធ្វើការបោសសម្អាត ។

## គោលនយោបាយឬយុទ្ធសាស្ត្រសំខាន់ៗ

កម្ពុជាបន្តអនុវត្តសកម្មភាពបោសសម្អាតគ្រាប់មីន ដោយផ្តោតលើតំបន់អាទិភាពនានា ដូចមានបញ្ជាក់នៅក្នុងយុទ្ធសាស្ត្រជាតិសកម្មភាពមីន ២០១៨-២០២៥ ថា បង្កើនល្បឿនបោសសម្អាតគ្រាប់មីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម និងសម្រេចឱ្យបានចក្ខុវិស័យកម្ពុជាមិនមានគ្រាប់មីននៅឆ្នាំ២០២៥។ យុទ្ធសាស្ត្រជាតិសកម្មភាពមីន ២០១៨-២០២៥ មានគោលដៅចំនួន៨ (១) រំដោះផ្ទៃដីដែលដឹងថាមានមីនឱ្យអស់នៅត្រឹមឆ្នាំ២០២៥ (២) រំដោះផ្ទៃដីដែលដឹងថាមានគ្រាប់បែកចង្កោមជាអាទិភាពនៅត្រឹមឆ្នាំ២០២៥ (៣) ដោះស្រាយបញ្ហាគំរាមកំហែងបណ្តាលមកពី សំណល់ជាតិផ្ទុះពីសង្គ្រាម (ស.ផ.ស.) ផ្សេងទៀត (៤) កាត់បន្ថយចំនួនគ្រោះថ្នាក់ដោយសារមីន និង ស.ផ.ស. ផ្សេងទៀត ឱ្យនៅកម្រិតអប្បបរមា ព្រមទាំងលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់អ្នករស់រានមានជីវិត និងសហគមន៍ដែលរងផលប៉ះពាល់ដោយសារគ្រាប់មីន និង ស.ផ.ស. (៥) រួមចំណែកដល់កំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ (៦) ជំរុញនិសព្វាវុធការ និងកិច្ចសហប្រតិបត្តិការនៅក្នុងតំបន់ និងអន្តរជាតិពាក់ព័ន្ធនឹង

សកម្មភាពមីន (៧) បង្កើតសមត្ថភាពជាតិប្រកបដោយនិរន្តរភាព ដើម្បីដោះស្រាយបញ្ហាគំរាមកំហែងដែលនៅសេសសល់ក្រោយឆ្នាំ២០២៥ (៨) ធានាថាសកម្មភាពមីនត្រូវបានគាំទ្រដោយប្រព័ន្ធគ្រប់គ្រងគុណភាពដែលមានភាពល្អប្រសើរ ការគ្រប់គ្រងព័ត៌មានដែលមានប្រសិទ្ធភាព ដោយមានការយកចិត្តទុកដាក់ខ្ពស់អំពីយេនឌ័រ និងការការពារបរិស្ថាន។

# ជំពូកទី៥

# មធ្យោបាយនិងការអនុវត្តបន្តសម្រាប់ការសម្រេចបានគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា(គ.អ.ច.ក.) ២០១៦-២០៣០

ជំពូកនេះ នឹងពិភាក្សាអំពីវិធីសាស្ត្រដែលអាចធ្វើឱ្យសម្រេចបាន គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា (គ.អ.ច.ក.) និងវិធីសាស្ត្រសម្រាប់ជម្នះបណ្តាបញ្ហាប្រឈមនានានៅក្នុងអំឡុងពេលនៃការអនុវត្ត គ.អ.ច.ក.។ វិធីសាស្ត្រទាំងនេះ ត្រូវបានបញ្ជាក់យ៉ាងច្បាស់ នៅក្នុងក្របខ័ណ្ឌ គ.អ.ច.ក. ដែលបានផ្តល់នូវសំណើសម្រាប់ការរៀបចំស្ថាប័ន និងជម្រើសសម្រាប់ធ្វើឱ្យមានវឌ្ឍនភាពឆ្ពោះសម្រេចបានគោលដៅនានា។ គោលដៅនេះ ក៏នឹងពិនិត្យមើលពីវិធីសាស្ត្រនៃការធ្វើសមាហរណកម្ម គ.អ.ច.ក. ទៅក្នុងប្រព័ន្ធផែនការនិងគោលនយោបាយដែលមានស្រាប់របស់កម្ពុជា ដូចនេះ ក្នុងពេលតែមួយនឹងអាចជំរុញការសម្រេចបានគោលដៅរបស់ជាតិ និងគោលដៅនានារបស់ គ.អ.ច.ក.។

ជំពូកនេះ បែងចែកជា៦ផ្នែកតូចៗ។ **ទី១** ពិចារណាមើលពីកាលានុវត្តភាព និងបញ្ហាប្រឈមនៅក្នុងការធ្វើសមាហរណកម្ម គ.អ.ច.ក. ទៅក្នុងប្រព័ន្ធផែនការនិងគោលនយោបាយជាតិ។ **ទី២** ដោះស្រាយពីបញ្ហានានាពាក់ព័ន្ធនឹងការប្រមូលធនធាន និងសកម្មភាពនានាសម្រាប់អនុវត្តឱ្យសម្រេចបានគោលដៅនានា។ **ទី៣** ពិនិត្យមើលឡើងវិញ ពីការរៀបចំការងារតាមដានត្រួតពិនិត្យនិងវាយតម្លៃ និងវិធីសាស្ត្រសម្រាប់ធានាការទទួលបានលទ្ធផលនិងការឆ្លើយតបបានទូលំទូលាយជាងមុន ពីការអនុវត្តទាំងនេះ។ **ទី៤** ពិភាក្សាពីមូលហេតុដែលត្រូវបានចាត់ទុកថា ការយល់ដឹងដែលមានសារសំខាន់សម្រាប់ការអនុវត្ត គ.អ.ច.ក.។ **ទី៥** ផ្តោតជាសំខាន់លើការកសាងសមត្ថភាពបុគ្គលនិងស្ថាប័ន សម្រាប់អនុវត្តឱ្យ សម្រេចបានគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា **និង ផ្នែកចុងក្រោយ**នៃជំពូកនេះ នឹងបញ្ចប់ដោយការពិភាក្សាជាមួយដៃគូពហុភាគី។

## ៥.១ ការធ្វើសមាហរណកម្ម គ.អ.ច.ក. ទៅក្នុងប្រព័ន្ធផែនការនិងគោលនយោបាយជាតិ

ការធ្វើសមាហរណកម្ម គ.អ.ច.ក. ទៅក្នុងគោលនយោបាយនិងប្រព័ន្ធផែនការ ជាចម្បងពាក់ព័ន្ធនឹងការបង្កប់ក្របខ័ណ្ឌនេះ នៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងការរៀបចំការងាររដ្ឋបាលនាពេលបច្ចុប្បន្ន។ បញ្ហាប្រឈមចម្បង២ ដែលបានជួបប្រទះនៅក្នុងដំណើរការនេះ រួមមាន **ទី១** តម្រូវការក្នុងការធានាសង្គតិភាពនិងភាពស៊ីសង្វាក់គ្នារវាង គ.អ.ច.ក. ផែនការ និងសកម្មភាព និង **ទី២** តម្រូវការក្នុងការធ្វើអាទិភាពរវាងចំណុចដៅចំណុចដៅនានារបស់ គ.អ.ច.ក. នៅក្នុងការរៀបចំគោលនយោបាយនិងជម្រើសធនធាន។

### សង្គតិភាពនិងភាពស៊ីចង្វាក់គ្នា

នៅកម្រិតថ្នាក់ជាតិ ភាពស៊ីចង្វាក់គ្នានឹងអាចកើតមានតាមរយៈទិដ្ឋភាពពីរ គឺ **ទី១** ដំណើរការរៀបចំ ផ.យ.អ.ជ. ដែលដំណាក់កាលនេះ *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤* និង *ក្របខ័ណ្ឌ*

*គ.អ.ច.ក.* គឺជាធាតុចូលយ៉ាងសំខាន់ និង **ទី២** ការគ្រប់គ្រងនៅក្នុងក្រសួង ស្ថាប័ន ជាពិសេស នៅក្នុងការអនុវត្តថវិការយៈពេលច្រើនឆ្នាំ ដោយផ្អែកលើលទ្ធផលដែលបានផ្តល់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកា។ សក្តានុពលទាំង២នេះ ដែលផ្សារភ្ជាប់នៅក្នុងការរៀបចំផែនការនិងដំណើរការផ្តល់ថវិកា មានបង្ហាញនៅក្នុង រូបភាពទី៥.១ ខាងក្រោម។

**រូបភាព ៥.១÷ ចំណុចផ្សារភ្ជាប់រវាង ក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា និង ដំណើរការនៃការរៀបចំផែនការនិងថវិកា**




*ប្រភព÷ គ.អ.ច.ក. ២០១៦-២០៣០*

ទី១៖ ដំណើរការនៃការរៀបចំ *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ* (ប្រអប់ទី១ នៃរូបភាព ៥.១) ត្រូវបានរំពឹងទុកថា នឹងមានភាពស្របគ្នាជាមួយនឹង គ.អ.ច.ក. រួមជាមួយគោលដៅរយៈពេលមធ្យមរបស់ *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤* ក្នុងការកំណត់វិធីសាស្ត្រគោលនយោបាយនានា នៅក្នុងផែនការជាតិ ហើយ គ.អ.ច.ក. នឹងដើរតួនាទីដ៏សំខាន់ក្នុងការបង្កើតក្របខ័ណ្ឌតាមដានត្រួតពិនិត្យនិងវាយតម្លៃ ផ.យ.អ.ជ.។ បន្ថែមលើនេះទៀត ទំនាក់ទំនងទាំងនេះ នឹងត្រូវពង្រីកទៅដល់កម្មវិធីវិនិយោគសាធារណៈ (ក.វ.ស.)។

ទី២៖ គ.អ.ច.ក. អាចដើរតួយ៉ាងច្បាស់លាស់ នៅក្នុងដំណើរការតាមដានត្រួតពិនិត្យនិងការអនុវត្តថវិកា ដែលកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានបង្កើតគម្រោងថវិកា ៣ឆ្នាំរំកិលភ្ជាប់ជាមួយនឹងផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង ស្ថាប័ន ដែលមានទំនាក់ទំនងរវាងថវិកាជាមួយនឹងលក្ខខណ្ឌគោលនយោបាយ។ ចំណុចដៅនិងសូចនាកររបស់ គ.អ.ច.ក. មានលក្ខណៈសមស្របទៅនឹងភារកិច្ចក្នុងការវាស់វែងប្រសិទ្ធភាពនៃឥទ្ធិពលរបស់ថវិកា តាមរយៈការផ្តល់នូវតារាងម៉ាទ្រីសនៃសំណុំរង្វាស់លទ្ធផលដ៏ទូលំទូលាយមួយ (តម្លៃចំណុចដៅតាមឆ្នាំ) ដែលត្រូវបានឯកភាពដោយក្រសួង ស្ថាប័ន ពាក់ព័ន្ធ។

ក្រសួងផែនការ បានបង្កើតចេញនូវការតភ្ជាប់និងការរៀបចំនេះ និងធានាថា ដំណើរការនៃការរៀបចំ ផ.យ.អ.ជ. ផ្តោតការយកចិត្តទុកដាក់លើលទ្ធផលដែលបានអនុវត្តផែនការនេះ និងសម្រាប់ជាមូលដ្ឋាននៃការរៀបចំរបាយការណ៍វឌ្ឍនភាពនៃការសម្រេចបាន គ.អ.ច.ក. ជាមួយគ្នានេះ ប្រធានបទសំខាន់ៗទាំងនោះ ក៏នឹងផ្តល់ជូនតាមរយៈកម្មវិធីវិនិយោគសាធារណៈដែរ។ បន្ថែមលើនេះទៀត តារាងសូចនាករស្នូល សម្រាប់ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ផ.យ.អ.ជ. បានបញ្ចូលសូចនាករ គ.អ.ច.ក. ក្នុងសមាមាត្រខ្ពស់ និងធ្វើបច្ចុប្បន្នភាពជាប្រចាំ ដើម្បីធានាសង្គតិភាព រវាង គ.អ.ច.ក. និងអាទិភាពនៃការរៀបចំផែនការជាតិ។ ក្រសួងផែនការក៏នឹងធ្វើការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័ន ដែលអនុវត្តផែនការយុទ្ធសាស្រ្តថវិកា ដើម្បីអនុវត្តក្របខ័ណ្ឌនៃការរៀបចំថវិកាផ្អែកលើការអនុវត្ត ដែលតម្រូវឱ្យមានការវាយតម្លៃដោយផ្តោតលើចំណុចដៅដែលពាក់ព័ន្ធនឹង គ.អ.ច.ក.។ ការងារនេះ នឹងផ្តល់នូវការផ្សារភ្ជាប់ គ.អ.ច.ក. ដោយផ្ទាល់ ទៅនឹងលទ្ធផលនៃការផ្តល់សេវា។

ទោះជាដូចនេះក្តី នៅតែទាមទារឱ្យមានកិច្ចខិតខំប្រឹងប្រែង និងការច្នៃប្រឌិតជាក់លាក់ថ្មីៗបន្ថែមទៀត ដើម្បីធានាសង្គតភាពនិងផ្សារភ្ជាប់ពេញលេញរវាង គ.អ.ច.ក. ជាមួយនឹងផែនការនិងសកម្មភាពរបស់រាជរដ្ឋាភិបាល។ ទិដ្ឋភាពចំនួន៣ ដែលត្រូវពិនិត្យពិចារណា គឺ៖

- សង្គតិភាពនៃពេលវេលា - អន្តរកាលរវាង លទ្ធផលយុទ្ធសាស្រ្តរយៈពេលវែង ជាមួយនឹង លទ្ធផលគោលនយោបាយរយៈពេលមធ្យម និង លទ្ធផលនៃការអនុវត្តរយៈពេលខ្លី។
- សង្គតិភាពតាមវិស័យ - អនុវត្តគោលដៅ នៅក្នុង និងនៅទូទាំងមុខងារ។ ចំណុចនេះត្រូវបានផ្តល់សារសំខាន់លើ ការបញ្ចូលលក្ខណៈទូទៅនៃ គ.អ.ច.ក. និងការបំពេញបន្ថែមដែលបានផ្តោតការយកចិត្តទុកដាក់។ និង
- សង្គតិភាពភូមិសាស្រ្ត - ធានាឱ្យផែនការនៅថ្នាក់ជាតិ ថ្នាក់វិស័យ និងថ្នាក់មូលដ្ឋាន ត្រូវបានផ្សារភ្ជាប់នឹងទំនាក់ទំនងធ្វើការជាមួយគ្នាដើម្បីទទួលបានលទ្ធផលជាអតិបរមា។

## ការធ្វើអាទិភាព គោលដៅ ចំណុចដៅ និង សកម្មភាព

ការកំណត់អាទិភាព គឺជាការគិតគូរដ៏សំខាន់ សម្រាប់ការអនុវត្តឱ្យទទួលបានជោគជ័យ និងផ្តល់នូវទំហំនិងមហិច្ឆតារបស់របៀបវារៈ គ.អ.ច.ក.។ ជាការចាំបាច់ ដែលគោលដៅមួយចំនួនត្រូវបានផ្តល់អាទិភាពខ្ពស់ជាងគោលដៅផ្សេងទៀត។ តម្រូវការនេះ គឺជាផ្នែកបន្ថែមនៃដំណើរការមូលដ្ឋាននីយកម្ម ប៉ុន្តែ នៅតែត្រូវការភាពជាក់លាក់បន្ថែមទៀត ហើយរាជរដ្ឋាភិបាលកម្ពុជា តាមរយៈដំណើរការរៀបចំផែនការជាតិនិងរចនាសម្ព័ន្ធដែលបានកំណត់ស្នើឡើងខាងលើ នឹងស្វែងរកការកំណត់គោលដៅសំខាន់ៗ

និងបញ្ហាផ្សេងទៀត ដែលចាំបាច់ត្រូវដោះស្រាយ។ ក្រសួងផែនការបានកំណត់អាទិភាពនានា ដែលជាផ្នែកនៃការរៀបចំ ផ.យ.អ.ជ. តាមការណែនាំ៣ចំណុច ដូចខាងក្រោម៖

- ការពិចារណាជាចម្បងលើគោលការណ៍ "គ្មាននរណាម្នាក់ត្រូវបានទុកឱ្យនៅឯកោ" និងតម្រូវការនៃការដោះស្រាយគោលដៅ (ផ្នែកឬក្រុមប្រជាជនគោលដៅ) ដែលកម្រិតជីវភាពខ្សត់ខ្សោយជាងក្រុមប្រជាជនផ្សេងទៀត។ គោលដៅដែលមិនទាន់បានសម្រេច និងបញ្ហាដែលមិនទាន់បានដោះស្រាយរួច នៅក្នុងក្របខ័ណ្ឌគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (គ.អ.ស.ក.) ក៏ស្ថិតនៅក្នុងអាទិភាពនេះផងដែរ ហើយកម្ពុជានឹងផ្តោតការយកចិត្តទុកដាក់លើការធ្វើឱ្យប្រសើរឡើងលើផ្នែកមួយចំនួនដែលមានវឌ្ឍនភាពមិនគ្រប់គ្រាន់ (បញ្ជីចំណុចដៅ គ.អ.ស.ក. ដែលមិនទាន់សម្រេចបាន នៅផ្នែកទី២)។ ជាបន្តបន្ទៀត គម្លាតនិងវិសមភាពដែលកើតមានឡើង គឺជាចំណុចសំខាន់ក្នុងការកំណត់អាទិភាព។
- ការបន្សីគ្នារវាងចំណុចដៅរបស់ គ.អ.ច.ក. និងគោលដៅជាតិដែលមានស្រាប់និងបង្កើតថ្មី ត្រូវតែបង្កើតជាមូលដ្ឋានគ្រឹះសម្រាប់វិធីសាស្ត្រអាទិភាពទូទៅរបស់កម្ពុជា។ ការប្រើប្រាស់ក្របខ័ណ្ឌ គ.អ.ច.ក. និងយុទ្ធសាស្ត្រចតុកោណ ជាធាតុចូលរួមគ្នាសម្រាប់ ផ.យ.អ.ជ. នឹងផ្តល់នូវការកំណត់អាទិភាពសម្រាប់ការអនុវត្ត។
- តាមការគូសបញ្ជាក់ពីបទពិសោធន៍និងការណែនាំរបស់សាកលលោក ត្រូវផ្តល់អាទិភាពលើការអនុវត្តគោលនយោបាយដែលជា "កត្តាជំរុញ" វឌ្ឍនភាពក្នុងរបៀបវារៈទាំងមូលរបស់ គ.អ.ច.ក.។ បទពិសោធន៍នេះ ត្រូវបានគាំទ្រដោយទ្រឹស្តីអន្តរជាតិ និងបទពិសោធន៍នានាក្នុងប្រទេស ដែលគូសបញ្ជាក់ពីសារសំខាន់នៃការយល់ដឹង និងការកំណត់ការតភ្ជាប់អន្តរកម្មក្នុងក្របខ័ណ្ឌ គ.អ.ច.ក.។

ការយល់ដឹងពីបញ្ហាទាំងនេះ រួមជាមួយនឹង គោលដៅនិងគោលបំណងរបស់ជាតិ នឹងផ្តល់នូវមូលដ្ឋានយ៉ាងជាក់លាក់ សម្រាប់ការកំណត់អាទិភាព ហើយក្រសួងផែនការនឹងកំណត់ការអភិវឌ្ឍសមត្ថភាពក្នុងការវិភាគស៊ីជម្រៅបន្ថែមទៀត នៅពេលដែលកម្ពុជាមានការរីកចម្រើនក្នុងការអនុវត្តគោលនយោបាយនិងសកម្មភាព ក្នុងការជំរុញការសម្រេចបាន គ.អ.ច.ក.។

## ៥.២ ការផ្តល់ធនធាន និង ការធ្វើឱ្យសម្រេចបានគោលដៅ

ផ្នែកនេះ នឹងពិចារណាពីការកំណត់និងប្រមែប្រមូលធនធានដែលត្រូវការ រួមជាមួយនឹងការកំណត់សកម្មភាពសម្រាប់អនុវត្តដើម្បីឱ្យសម្រេចបាន គ.អ.ច.ក.។ ការកៀរគរធនធានសម្រាប់គោលដៅថ្មីទាំងនេះ ក៏ត្រូវផ្តោតលើថវិការបស់ជាតិនិងធនធានក្នុងស្រុក។

ការសម្រេចបាន គ.អ.ច.ក. គឺមិនមែនតែជាការងារនិងការទទួលខុសត្រូវរបស់រាជរដ្ឋាភិបាលកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែ គ្រប់តួអង្គទាំងអស់ រួមទាំងផ្នែកឯកជន សង្គមស៊ីវិល និងប្រជាជនខ្លួនឯងផងដែរ ត្រូវតែចូល។ យើងត្រូវទទួលស្គាល់ថា កម្ពុជាមានបញ្ហាប្រឈមនឹងការខ្វះខាតធនធាន ធៀបនឹងមហិច្ឆតាដែលបានបង្ហាញនៅក្នុង គ.អ.ច.ក. រួមជាមួយនឹងទស្សនវិស័យរបស់កម្ពុជា ឆ្នាំ២០៥០។ ដើម្បីធ្វើឱ្យសម្រេចបានគោលដៅទាំងនេះ ទាមទារឱ្យមានការវិនិយោគលើផ្នែកសំខាន់ៗ ជាមួយនឹងការពង្រីកលំហូរធនធាន។

តាមការធ្វើចំណោលពី*ការវាយតម្លៃហិរញ្ញវត្ថុសម្រាប់អភិវឌ្ឍន៍* ដែលបានធ្វើឡើងដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងឆ្នាំ២០១៧ បញ្ជាក់ថា ភាពខ្លាំងនៃសេដ្ឋកិច្ចនិងការអនុវត្តសារពើពន្ធរបស់កម្ពុជា នឹងនៅតែបន្ត រួមទាំងការកើនឡើងយ៉ាងឆាប់រហ័សនៃការកៀរគរធនធាន ប៉ុន្តែបញ្ហាប្រឈមផ្នែកហិរញ្ញវត្ថុនៅតែបន្ត។ រូបភាព ៥.២ បង្ហាញថា ទោះបីជាចំណូលរបស់រាជរដ្ឋាភិបាល (បច្ចុប្បន្នមាន២០% នៃផ.ស.ស.)[2] ស្ថិតនៅក្នុងគន្លងកំណើនសេដ្ឋកិច្ចខ្លាំង និងត្រូវបានកំណត់ថានឹងបន្តកំណើនខ្ពស់ក្តី ក៏លំហូរជំនួយអភិវឌ្ឍន៍ផ្លូវការ និងជំនួយនានាដល់ អង្គការមិនមែនរដ្ឋាភិបាល ហាក់មាននិន្នាការថយចុះ ខណៈពេលដែលកម្ពុជាមានការរីកចម្រើនបន្ថែមទៀតក្នុងនាមជាប្រទេសដែលមានស្ថានភាពចំណូលមធ្យមកម្រិតទាប ហើយនឹងមានភាពជឿនលឿនខ្លាំងនៅក្នុងដំណើរការនៃការចាកចេញពីក្រុមប្រទេសដែលមានការអភិវឌ្ឍតិចតួចនៅទសវត្សរ៍ខាងមុខ។ ទោះជាដូចនេះក្តី លំហូរនេះ នៅតែបញ្ជាក់ពីចំណែកជាក់លាក់នៃថវិកាវិនិយោគសាធារណៈ។ នៅពេលខាងមុខ ចំណូលសាធារណៈ នឹងត្រូវរងសម្ពាធកាន់តែខ្លាំងលើថវិកាចរន្ត ដែលបណ្តាលមកពីការកើនឡើងនៃចំណាយ ដែលមិនមានការរំពឹងទុកលើការផ្តល់សេវាសាធារណៈ ការកើនឡើងនៃប្រាក់បៀវត្សរ៍ក្នុងវិស័យសាធារណៈ ការបំពេញបន្ថែមលើគម្លាតដែលបន្សល់ទុកដោយការគាំទ្រពីជំនួយអភិវឌ្ឍន៍ផ្លូវការ ការពង្រីកការចំណាយ និងតម្រូវការលើចំណាយវិនិយោគសាធារណៈ។

ការងារនេះ ទាមទារឱ្យមានការធ្វើឱ្យប្រសើរឡើងនូវសមត្ថភាព និងការពង្រឹងប្រព័ន្ធនៃដំណើរការរៀបចំ ផ.យ.អ.ជ. ហើយក្រសួងផែនការនឹងលើកកម្ពស់ការវិភាគនិងព្យាករលំហូរហិរញ្ញវត្ថុ និងលំហូរផ្សេងទៀត តាមរយៈការរៀបចំស្ថាប័នសម្រាប់វាយតម្លៃហិរញ្ញវត្ថុសម្រាប់អភិវឌ្ឍន៍ និងអភិវឌ្ឍសមត្ថភាពលើការវិភាគរបស់មន្ត្រីក្នុងស្ថាប័ននោះ។ ក្រសួងផែនការ ក៏នឹងពង្រឹងកម្មវិធីវិនិយោគសធារណៈ (ក.វ.ស.) និងរៀបចំឱ្យដំណើរការបានល្អប្រសើរ ដូចជាកម្មវិធីមូលធនរបស់រាជរដ្ឋាភិបាល ជាដើម។ ការងារនេះក៏ទាមទារផងដែរ ឱ្យមានកិច្ចខិតខំប្រឹងប្រែងបន្តទៀតដើម្បីធានាឱ្យមានការផ្សារភ្ជាប់

[2] ផ្អែកលើរបាយការណ៍ប៉ាន់ស្មាន ឆ្នាំ២០១៩

កាន់តែរឹងមាំរវាង ក.វ.ស. និងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ផែនការយុទ្ធសាស្រ្តថវិកា ដែលដឹកនាំដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីឈានទៅអនុវត្តការរៀបចំថវិកាដោយផ្អែកលើកម្មវិធី និងការធ្វើសមាហរណកម្មថវិកាចរន្តនិងថវិកាមូលធន។

**រូបភាព ៥.២៖ ចំណោលលំហូរហិរញ្ញវត្ថុ ដល់ឆ្នាំ២០២៥ (សេណារីយ៉ូកម្រិតទាបនិងខ្ពស់)**




| | |
|---|---|
| ចំណូលក្នុងស្រុក | កិច្ចសហប្រតិបត្តិការត្បូង-ត្បូង |
| ការវិនិយោគឯកជនក្នុងស្រុក | ការផ្ទេរប្រាក់ពីបរទេស |
| ការវិនិយោគផ្ទាល់ពីបរទេស | អង្គការមិនមែនរដ្ឋាភិបាល |
| ជំនួយអភិវឌ្ឍន៍ផ្លូវការ | ហិរញ្ញវត្ថុការប្រែប្រួលអាកាសធាតុ |

*ប្រភព៖ ការវាយតម្លៃហិរញ្ញវត្ថុអភិវឌ្ឍន៍ រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០១៧*

បន្ថែមពីនេះ ដូចការបញ្ជាក់ពីការធ្វើចំណោល *ការវាយតម្លៃហិរញ្ញវត្ថុសម្រាប់អភិវឌ្ឍន៍* ទោះបីជាការវិនិយោគផ្នែកឯកជន ទាំងពីក្នុងស្រុកនិងពីបរទេស នឹងមានការកើនឡើងស្របគ្នាជាមួយសេដ្ឋកិច្ចក្តី តែចំណែករបស់វានៅក្នុង ផ.ស.ស. ទំនងជានៅស្ថិរភាព។ ទោះជាដូចនេះក្តី លំហូរវិនិយោគនេះ នៅតែមានសារសំខាន់ណាស់សម្រាប់រក្សានិចលភាពសេដ្ឋកិច្ច និងជានាជំរុញឱ្យកម្ពុជាផ្លាស់ប្តូរទៅរកផលិតកម្មដែលមានតម្លៃបន្ថែមខ្ពស់។ កំណើនសេដ្ឋកិច្ចខ្ពស់ នៅតែជាកត្តានាំមុខសម្រាប់កាត់បន្ថយភាពក្រីក្រ និងបរិយាប័ន្នសេដ្ឋកិច្ច ហើយកំណើននេះ ផ្តល់នូវមធ្យោបាយដែលផ្តល់ប្រាក់ចំណូលពន្ធខ្ពស់ ដែលចាំបាច់សម្រាប់លើកកម្ពស់ការផ្តល់សេវាសាធារណៈ។

ការបង្កើនកម្រិតនៃការវិនិយោគពីប្រភពទាំងនេះ ទន្ទឹមនឹងការពង្រឹងការផ្សារភ្ជាប់វិស័យនេះ ទៅវិស័យសេដ្ឋកិច្ចផ្សេងទៀត គឺជាគោលដៅចម្បងរបស់ គ.អ.ច.ក. និងសង្គតិភាពជាមួយគោលនយោបាយនានារបស់រាជរដ្ឋាភិបាលកម្ពុជា ដូចជា គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ ជាដើម។ ដូចនេះ រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តលើកកម្ពស់ការវិនិយោគដែលមិនប៉ះពាល់ដល់អាកាសធាតុ ទន្ទឹមនឹងការបន្តធ្វើឱ្យប្រសើរឡើងប្រសិទ្ធភាពនៃប្រព័ន្ធប្រមូលពន្ធ។ រាជរដ្ឋាភិបាល

កម្ពុជាទទួលស្គាល់ពីសារសំខាន់នៃការរួមវិភាគទានដាច់ដោយឡែករបស់ផ្នែកឯកជន ហើយរាជរដ្ឋាភិបាលកម្ពុជាក៏នឹងផ្តល់នូវមធ្យោបាយសម្រាប់ផ្នែកឯកជនធ្វើអាជីវកម្ម សង្គមស៊ីវិល និងប្រជាជន ធ្វើសកម្មភាពដើម្បីរួមចំណែកធ្វើឱ្យសម្រេចបាន គ.អ.ច.ក.។ ការផ្តល់នូវមធ្យោបាយទាំងនេះ រួមទាំងការជំរុញនិងការលើកទឹកចិត្តឱ្យមានការផ្លាស់ប្តូរឥរិយាបទ ក្នុងការផលិតនិងប្រើប្រាស់ ដើម្បី "សេដ្ឋកិច្ចពណ៌បៃតង" រាជរដ្ឋាភិបាលកម្ពុជានឹងពិចារណាអនុវត្តនូវការយកពន្ធសមស្រប និងការលើកទឹកចិត្តផ្សេងទៀត។ បន្ថែមលើនេះ រាជរដ្ឋាភិបាលកម្ពុជានឹងអនុវត្តការងារបន្ថែមទៀត ដើម្បីជួយសម្រួលដល់ភាពជាដៃគូ រវាងរដ្ឋនិងឯកជន ក្នុងគោលដៅសម្រេចឱ្យបានគោលដៅនានារបស់ គ.អ.ច.ក.។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំគោលនយោបាយជាតិស្តីពី ភាពជាដៃគូរវាងរដ្ឋនិងឯកជន ហើយនឹងរៀបចំការកែប្រែច្បាប់ចាំបាច់នានា ដើម្បីលើកកម្ពស់ភាពជោគជ័យនៃភាពជាដៃគូរវាងរដ្ឋនិងឯកជន ដោយផ្អែកលើគោលការណ៍រក្សាទុកប្រាក់ចំណេញ (ដូចជា នីតិវិធី សាងសង់ ដំណើរការ និង សាងសង់ ដំណើរការ ផ្ទេរ)។

ចំណុចពិភាក្សាចុងបញ្ចប់ យើងទទួលស្គាល់ថា ការពិភាក្សានិងការឆ្លើយតបគោលនយោបាយដែលបានស្នើឡើង បានគ្របដណ្តប់តែលើលំហូរនិងការប្រើប្រាស់ហិរញ្ញវត្ថុប៉ុណ្ណោះ។ ក្នុងបរិការណ៍នេះ ទាមទារឱ្យមានការអភិវឌ្ឍធនធាននិងមធ្យោបាយនានា ដើម្បីវិភាគនិងប៉ាន់ស្មានពីចំណាយ ក៏ដូចជាការកំណត់ពីតម្រូវការហិរញ្ញវត្ថុសម្រាប់ធ្វើឱ្យសម្រេចបាន គ.អ.ច.ក. ដូចនេះ វិធីសាស្ត្រទាំងនេះ អាចត្រូវបានបញ្ចូលក្នុងការអនុវត្តថវិកាជាតិ។

ទោះជាដូចនេះក្តី បទពិសោធន៍ពីអតីតកាលក្នុងការប៉ាន់ស្មានចំណាយសម្រាប់ធ្វើឱ្យសម្រេចបាន គ.អ.ស.ក. បានបង្ហាញពីចំណុចខ្វះខាតពីការប៉ាន់ស្មានចំណាយលម្អិតរយៈពេលវែង ពាក់ព័ន្ធនឹងការងារអន្តរវិស័យ។ បទពិសោធន៍នេះ បានផ្តល់ជាទូទៅនូវចំហាក (សេណារីយ៉ូ) នៃចំណាយមិនត្រឹមត្រូវ និងមានតម្លៃកំណត់ សម្រាប់ធនធាននិងការរៀបចំផែនការសារពើពន្ធ។ បន្ថែមលើនេះទៀត បញ្ហាប្រឈមទាំងនេះ ទំនងជាត្រូវបានសង្កត់ធ្ងន់ ដោយការពង្រីកនៅក្នុងគោលដៅ និងការបញ្ចូលគោលដៅនៃការអភិវឌ្ឍឱ្យបានទូលំទូលាយ។ ទោះជាដូចនេះក្តី ការគ្រប់គ្រងនិងការព្យាករសម្ពាធសារពើពន្ធ នៅតែជាបញ្ហាសំខាន់ដែលត្រូវពិចារណាដោះស្រាយ ហើយបច្ចេកទេសនិងវិធីសាស្ត្រនានា កំពុងត្រូវបានប្រើប្រាស់ដោយប្រទេសមួយចំនួន ដូចជាប្រទេស បង់ក្លាដេស អេត្យូពី និងប៉ាគីស្ថាន ជាដើម។ ក្រសួងផែនការនឹងព្យាយាមស្វែងយល់ពីម៉ូដែលទាំងនេះ និងពិនិត្យភាពសមស្របដើម្បីជ្រើសរើស រួមទាំងការប្រើប្រាស់សម្រាប់ការវាយតម្លៃផ្នែកសារពើពន្ធដែលមិនមានមហិច្ឆតាខ្លាំង និងការវាយតម្លៃតាមវិស័យលើពេលវេលាកំណត់ ដោយការផ្សារភ្ជាប់រវាងការរៀបចំថវិកាដោយផ្អែកលើកម្មវិធី និងផែនការយុទ្ធសាស្ត្រថវិកា។

## ៥.៣ ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ និង មតិយោបល់គោលនយោបាយ

ផ្នែកនេះ កំណត់ចេញនូវសមាសភាគសំខាន់ៗនៃការរៀបចំការតាមដានត្រួតពិនិត្យនិងវាយតម្លៃ និងសង្ខេបពីបញ្ហាដែលនៅសេសសល់មិនទាន់បានដោះស្រាយ។ រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ពីសារសំខាន់នៃវិធីសាស្ត្ររាយការណ៍ទំនើប និងដែលបានបង្ហាញថា គ.អ.ច.ក. សម្រេចបានលើសពីការកំណត់របស់រាជរដ្ឋាភិបាល។ ផ្នែកនេះ ក៏ពិភាក្សាពីការធ្វើឱ្យប្រសើរឡើងនូវការងារតាមដានត្រួតពិនិត្យនិងវាយតម្លៃ លើប្រព័ន្ធអេកូឡូស៊ី។ ដូចនេះ ការងារនេះផ្តោតលើ ការគិតគូឯករាជ្យ ក្នុងការបញ្ចូលធាតុចូលផ្សេងៗ ពីផ្នែកឯកជននិងសង្គមស៊ីវិល ពាក់ព័ន្ធនឹងវឌ្ឍនភាពនិងការផ្តល់អនុសាសន៍ដែលមានអត្ថប្រយោជន៍ដល់អ្នកធ្វើសេចក្តីសម្រេចចិត្ត និងគាំទ្រដល់ការពិគ្រោះយោបល់ថ្នាក់ជាតិស្តីពី គ.អ.ច.ក.។

### សមាសភាគសំខាន់ៗនៃការរៀបចំការតាមដានត្រួតពិនិត្យនិងវាយតម្លៃ

ក្រសួងផែនការជាស្ថាប័នដែលទទួលខុសត្រូវ លើដំណើរការជាទូទៅនៃការតាមដានត្រួតពិនិត្យនិងវាយតម្លៃ និងការរក្សានូវមូលដ្ឋានទិន្នន័យសម្រាប់សូចនាករ គ.អ.ច.ក. និងទទួលខុសត្រូវក្នុងការធ្វើសកម្មភាពក្នុងនាមជាស្ថាប័នទំនាក់ទំនងផ្នែកបច្ចេកទេសពាក់ព័ន្ធនឹង គ.អ.ច.ក.។ ភារកិច្ចកន្លងទៅ រួមបញ្ចូលទាំងការចងក្រងទិន្នន័យដែលទទួលបាននិងផ្តល់នូវការធ្វើបច្ចុប្បន្នភាពប្រចាំឆ្នាំ និងរៀបចំរបាយការណ៍ សម្រាប់ផ្តល់ជូនទៅរាជរដ្ឋាភិបាលកម្ពុជាពិនិត្យ។

ការទទួលខុសត្រូវផ្នែកបច្ចេកទេសរបស់ក្រសួងផែនការ នឹងត្រូវរួមបញ្ចូលទាំង ការផ្តល់ការណែនាំដល់ភាគីពាក់ព័ន្ធរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការរៀបចំប៉ាន់ស្មាន និងគណនាតម្លៃចំណុចដៅរបស់សូចនាករ ការប្រមូលទិន្នន័យ និង និតិវិធីនៃការរាយការណ៍និងការសន្ទត។ ជាមួយគ្នានេះ ក៏មានការទទួលខុសត្រូវសម្រាប់ការបញ្ជាក់ពីសូចនាករនិងការផ្តល់ទិន្នន័យ ជាមួយក្រសួង ស្ថាប័ននានា។ សមត្ថភាពនិងប្រព័ន្ធទិន្នន័យត្រូវបានពង្រឹង តាមរយៈ យុទ្ធសាស្ត្រជាតិអភិវឌ្ឍស្ថិតិ ដែលជាគំនិតផ្តួចផ្តើមដ៏សំខាន់សម្រាប់បំពេញបន្ថែម ក្នុងការរៀបចំនិងការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ការសម្រេចបាន គ.អ.ច.ក.។ ជំពូកទី៣ នៃផ្នែកទី១ និង តារាងទី១និងទី២ នៃផ្នែកទី២ នៃ ក្របខ័ណ្ឌ គ.អ.ច.ក. ផ្តល់នូវសូចនាករ ប្រភពទិន្នន័យ និងវដ្តនៃទិន្នន័យ សម្រាប់ប្រើប្រាស់ក្នុងការតាមដានត្រួតពិនិត្យនិងវាយតម្លៃ។ ស្ថាប័នទទួលខុសត្រូវធ្វើឱ្យសម្រេចបានចំណុចដៅរបស់សូចនាករនីមួយៗ មានតួនាទីផ្តល់នូវទិន្នន័យបច្ចុប្បន្នភាព ដល់ក្រសួងផែនការ ឱ្យបានទាន់ពេលវេលា តាមពេលវេលាកំណត់ ដើម្បីរៀបចំរបាយការណ៍ជាប្រចាំ។ ក្រសួង ស្ថាប័ន នឹងត្រូវផ្តល់ផងដែរនូវ ការវាយតម្លៃពីវឌ្ឍនភាព ដែលជាផ្នែកមួយនៃដំណើរការត្រួតពិនិត្យមើលឡើងវិញការអនុវត្ត ផ.យ.អ.ជ. និងការសម្រេចបាន គ.អ.ច.ក.។

របាយការណ៍នេះ ក៏បានផ្តល់នូវគណនេយ្យភាពដែលគូសបញ្ជាក់ពីបញ្ហា និងផ្តល់នូវសំណើដើម្បីដោះស្រាយនូវចំណុចអសកម្មនានា។ ក្រសួងផែនការនឹងប្រើប្រាស់វិធីសាស្ត្រដែលប្រើប្រាស់នូវតារាងគ្រប់គ្រងក្នុងរបាយការណ៍នៅកម្រិតគោលដៅនិងចំណុចដៅ ដើម្បីអនុញ្ញាតឱ្យមានការវាយតម្លៃយ៉ាងឆាប់រហ័សពីវឌ្ឍនភាព (ការកំណត់ពិន្ទុចំណុចដៅទៅតាមកម្រិតនៃទិន្នន័យរបស់សូចនាករ)។ សំណើណាមួយដើម្បីកែសម្រួលតម្លៃគ្រាដើម ចំណុចដៅ ឬតម្លៃចុងក្រោយ ទាមទារឱ្យមានការពិនិត្យមើល និងឯកភាពដោយថ្នាក់ដឹកនាំរបស់ក្រសួងផែនការ ដែលជាការបញ្ជាក់ថា ចំណុចដៅមិនអាចប្រែប្រួលជាប្រចាំបានទេ ហើយតម្លៃត្រូវបង្កើតឡើងយ៉ាងហ្មត់ចត់ និងត្រូវផ្សារភ្ជាប់គោលដៅគោលនយោបាយ គ.អ.ច.ក. ដែលបានកំណត់។

ក្របខ័ណ្ឌ គ.អ.ច.ក ក៏បានកំណត់ចំនួនសូចនាករ ដែលមានបញ្ហាទិន្នន័យ ដែលត្រូវការដោះស្រាយ ជាមួយនឹងការគាំទ្រពីដៃគូអភិវឌ្ឍ។ ក្រសួងផែនការនឹងធ្វើការពិនិត្យមើល គ.អ.ច.ក. ឡើងវិញនៅក្នុងរយៈពេល១២ខែបន្ទាប់ ដោយពិនិត្យសូចនាករតាមគោលដៅនីមួយៗ ដើម្បីធានាពីគុណភាព។ ក្រសួងផែនការក៏នឹងរៀបចំវគ្គបណ្តុះបណ្តាលសមត្ថភាពជាសេរីពាក់ព័ន្ធនឹង គ.អ.ច.ក. ដល់មន្ត្រីរបស់ក្រសួង ស្ថាប័ន និងពិចារណាប្រមូលទិន្នន័យគាំទ្រដល់សូចនាករដែលមានមានទិន្នន័យគាំទ្រ។ បន្ទាប់ពីនេះ នឹងធ្វើការកំណត់អាទិភាពសូចនាករដែលត្រូវបានចាត់ទុកថាសំខាន់ តែមិនត្រូវបានដាក់បញ្ចូលនៅក្នុងបញ្ជីសូចនាក គ.អ.ច.ក. និងផ្សារភ្ជាប់ជាមួយផែនការមេស្ថិតិ របស់វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ។

## ការធ្វើឱ្យប្រសើរឡើងប្រព័ន្ធអេកូឡូស៊ីសម្រាប់ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ

ចំពោះវិសាលភាពនិងការធ្វើឱ្យសម្រេចបាន គ.អ.ច.ក. ទាមទារឱ្យមានការចូលរួមពីគ្រប់ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ និងភាគីដែលពាក់ព័ន្ធ។ រាជរដ្ឋាភិបាលកម្ពុជាក៏ព្យាយាម កសាងនូវប្រព័ន្ធអេកូឡូស៊ី ដោយមានការគាំទ្រពីមតិយោបល់ដ៏ទូលំទូលាយ និងមានការចូលរួមចំណែកពីផ្នែកឯកជន សង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ។ ប្រព័ន្ធអេកូឡូស៊ីនេះ សំដៅលើបរិស្ថាន ដែលទិន្នន័យត្រូវបានបង្កើតឡើង និងប្រើប្រាស់ ដោយតួអង្គផ្លូវការ និងមិនផ្លូវការ ដែលគាំទ្រដល់ការធ្វើសេចក្តីសម្រេចចិត្តលើការធ្វើឱ្យសម្រេចបាន គ.អ.ច.ក.។ ប្រព័ន្ធនេះ ការរួមចំណែកជាមូលដ្ឋានលើការប្រមូលទិន្នន័យដែលបង្កើតដោយរាជរដ្ឋាភិបាលកម្ពុជា និងស្ថាប័នប្រឹក្សាឯករាជ្យ ដើម្បីជួយដល់ការរៀបចំរបាយការណ៍ និងដល់អ្នកធ្វើសេចក្តីសម្រេចចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា និងភាគីពាក់ព័ន្ធ។

ដោយកសាងលើបទពិសោធន៍នៃការអនុវត្ត គ.អ.ស.ក. ក្រសួងផែនការ ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍ នឹងអនុវត្តនូវសកម្មភាពមួយចំនួន ដូចខាងក្រោម៖

- យុទ្ធនាការជាតិ ដើម្បីលើកទឹកចិត្តអ្នកដែលមានចំណែកពាក់ព័ន្ធ ស្តីពី គ.អ.ច.ក. ជាមួយនឹងការផ្តួចផ្តើម ការធ្វើទំនាក់ទំនងសម្រាប់ការអភិវឌ្ឍ ដើម្បីលើកទឹកចិត្តឱ្យមានការតាមដានត្រួតពិនិត្យលទ្ធផលនៃការអនុវត្ត គ.អ.ច.ក. ជាពិសេស គោលដៅដែលធ្វើឱ្យប្រសើរឡើងឥរិយាបថអ្នកផលិតនិងអ្នកប្រើប្រាស់។ ការអនុវត្តសកម្មភាពនេះ គួរប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយទាំងពីរប្រភេទ គឺ បែបប្រពៃណី និងបែបទំនើប។
- ធ្វើឱ្យមានការពាក់ព័ន្ធជាពិសេស ជាមួយ តំណាងអាជីវករនិងផ្នែកឯកជន ដើម្បីទាក់ទាញការយកចិត្តទុកដាក់ និងលើកទឹកចិត្តឱ្យមានការចូលរួមក្នុងការធ្វើឱ្យសម្រេចបាន គ.អ.ច.ក.។
- អភិវឌ្ឍវេទិកាគោលនយោបាយនិងប្រព័ន្ធ នៃ គ.អ.ច.ក. លើប្រធានបទតាមវិស័យ ជាមួយនឹង អ្នកផ្តល់យោបល់ និងតួអង្គសង្គមស៊ីវិលផ្សេងទៀត ដោយផ្តោតអាទិភាពជាសំខាន់លើវិស័យដែលបានកំណត់ខាងលើ។
- ចែករំលែកទិន្នន័យផ្លូវការ និងកសាងគេហទំព័រអ៊ិនធឺណិត ដើម្បីប្រើប្រាស់សម្រាប់ជូនដំណឹងដល់អ្នកប្រើប្រាស់ រួមទាំង ប្រជាជនទូទៅ ដើម្បីរួមចំណែកក្នុងការ តាមដានត្រួតពិនិត្យនិងវាយតម្លៃ ស្រាវជ្រាវ និងចូលរួមក្នុងការពិគ្រោះយោបល់ជាតិស្តីពី គ.អ.ច.ក.។

## ៥.៤ ការលើកកម្ពស់ចំណេះដឹង

រាជរដ្ឋាភិបាលកម្ពុជានឹងកសាងនូវចំណេះដឹងស្តីពីប្រធានបទ គ.អ.ច.ក. ដល់គ្រប់តួអង្គទាំងអស់ ដើម្បីជំរុញការធ្វើឱ្យមានការពាក់ព័ន្ធរបស់សង្គមស៊ីវិល ផ្នែកឯកជន សាកលវិទ្យាល័យ និងប្រជាជនទូទៅ ក្នុងការអនុវត្តនិងការតាមដានត្រួតពិនិត្យនិងវាយតម្លៃ គ.អ.ច.ក.។ យុទ្ធនាការទាំងនេះ នឹងអនុវត្តទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីកៀរគរនិងកសាងភាពជាដៃគូ ឱ្យចូលរួមជាមួយគ្នាពីគ្រប់វិស័យនៃសង្គម និងបង្កើនការចូលរួម។

ដោយសារតែរដ្ឋបាលថ្នាក់មូលដ្ឋាន មានកម្រិតស្ថិតនៅកៀកជិតទៅនឹងប្រជាជនជាងគេ ដូចនេះ រដ្ឋបាលនេះ ត្រូវបានលើកទឹកចិត្តជាងគេ ក្នុងការទទួលបានការលើកម្ពស់ចំណេះដឹង ដែលពាក់ព័ន្ធនឹង គ.អ.ច.ក.។ អាជ្ញាធរថ្នាក់ក្រោមជាតិ គឺជាស្ពានចម្លង រវាងរដ្ឋាភិបាលនៅថ្នាក់ជាតិ ជាមួយនឹងប្រជាជនទូទៅ និងដើរតួនាទីដ៏សំខាន់ ក្នុងការជំរុញឱ្យមានការចូលរួមពីសង្គមស៊ីវិល ផ្នែកឯកជន សាកលវិទ្យាល័យ និងអង្គការផ្សេងទៀតដែលមានទីតាំងនៅក្នុងមូលដ្ឋានរបស់ខ្លួន។ ថ្នាក់ដឹកនាំនៅមូលដ្ឋានដែលត្រូវបានជ្រើសរើស តាមអាណត្តិជ្រើសរើសតាមបែបប្រជាធិបតេយ្យ ត្រូវដឹកនាំការអភិវឌ្ឍនៅមូលដ្ឋាន និងជួយឱ្យមានគណនេយ្យភាពក្នុងសង្គម។

សម្មភាពលើកកម្ពស់ចំណេះដឹង នឹងមានគោលដៅបង្កើនការចូលរួមរបស់ប្រជាជននិងសហគមន៍មូលដ្ឋាន ក្នុងគោលដៅដើម្បីលើកកម្ពស់ភាពជាម្ចាស់នៅក្នុងការចូលរួមធ្វើឱ្យសម្រេចបាន

គ.អ.ច.ក. នៅកម្រិតមូលដ្ឋាន។ អាញ្ញាធរថ្នាក់ក្រោមជាតិ នឹងត្រូវបានគាំទ្រដើម្បីទទួលស្គាល់របៀបវារៈឆ្នាំ២០៣០ ថា ជាក្របខ័ណ្ឌមួយសម្រាប់ធ្វើសកម្មភាពនិងបង្កើតចេញនូវយន្តការ ដែលបើកផ្លូវឱ្យមានការចូលរួមពីរបស់ប្រជាជនប្រកបដោយគណនេយ្យភាព។

## ៥.៥ ការកសាងសមត្ថភាព

គំនិតផ្តួចផ្តើមក្នុងការអភិវឌ្ឍ ឬក្នុងការទទួលបានជំនាញនិងចំណេះដឹងរបស់មន្ត្រីរាជការមានសារសំខាន់ណាស់ ដើម្បីឱ្យការអនុវត្ត គ.អ.ច.ក. ដែលមានបញ្ហាប្រឈមដោយសារកង្វះសមត្ថភាពត្រូវបានដោះស្រាយទាំងនៅកម្រិតជាតិ វិស័យ និងនៅកម្រិតរដ្ឋបាលមូលដ្ឋាន។ ការកសាងសមត្ថភាពដល់មន្ត្រីរាជរដ្ឋាភិបាល ដើម្បីជំរុញការអភិវឌ្ឍប្រកបដោយចីរភាព អាចពាក់ព័ន្ធនឹងការកែទម្រង់យ៉ាងទូលំទូលាយនិងពង្រឹងប្រព័ន្ធអន្តររដ្ឋាភិបាល និងធ្វើឱ្យអភិបាលកិច្ចមានភាពល្អប្រសើរឡើង។ វិធានការនេះរួមបញ្ចូលទាំង ការលើកកម្ពស់សមត្ថភាពសម្រាប់ការអភិវឌ្ឍនិងការអនុវត្តយុទ្ធសាស្ត្រ តាមរយៈការធ្វើឱ្យប្រសើរការរៀបចំផែនការ ការរៀបចំថវិកានិងប្រព័ន្ធគ្រប់គ្រងថវិកានិងហិរញ្ញវត្ថុ និងសំខាន់ជាងនេះទៀតគឺ សមត្ថភាពប្រមូលទិន្នន័យដែលពាក់ព័ន្ធនឹង គ.អ.ច.ក.។

វិទ្យាស្ថានជាតិស្ថិតិ ដែលជាអង្គភាពមួយស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងផែនការកំពុងអនុវត្តសកម្មភាពជាច្រើន ដើម្បីបង្កើតនិងអនុវត្តប្រព័ន្ធទិន្នន័យសម្រាប់ការតាមដានត្រួតពិនិត្យ គ.អ.ច.ក. រួមទាំងការបង្កើតផែនការអនុវត្តជាតិ សម្រាប់វាស់ស្ទង់និងក្របខ័ណ្ឌប្រមូលទិន្នន័យរបស់ គ.អ.ច.ក.។ ការងារនេះរួមទាំង ការធ្វើឱ្យប្រសើរឡើងការប្រមូលទិន្នន័យរដ្ឋបាលជាប្រព័ន្ធ ក៏ដូចជាដើម្បីកំណត់វិធីសាស្ត្រល្អៗ សម្រាប់ការបញ្ចូលទិន្នន័យពីប្រភពផ្សេងគ្នា។

ពិសេសជាងនេះទៅទៀត វិទ្យាស្ថានជាតិស្ថិតិ បានធ្វើការងារយ៉ាងជិតស្និទជាមួយអង្គការសហប្រជាជាតិ និងស្ថាប័នអន្តរជាតិផ្សេងទៀត ដើម្បីពិនិត្យមើលពីសក្តានុពលប្រមូលទិន្នន័យនៅពេលអនាគត សម្រាប់សូចនាករ គ.អ.ច.ក. ដែលមិនមានក្នុងបញ្ជី និងត្រូវបានចាត់ថ្នាក់ថា ងាយស្រួលនិងរកទិន្នន័យគាំទ្រ ជាមួយអង្កេតជាតិសំខាន់ៗដែលមានស្រាប់ ដូចជា អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា និងអង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជា។ ជាមួយគ្នានេះ ម៉ូដែលនៃការអង្កេតថ្មី នឹងត្រូវបានរៀបចំនិងអនុវត្ត។ បន្ថែមលើនេះទៀត វិទ្យាស្ថានជាតិស្ថិតិ ដែលជាស្ថាប័នសម្របសម្រួលប្រព័ន្ធស្ថិតិជាតិ នឹងពិនិត្យមើលឡើងវិញនូវជម្រើសសម្រាប់ក្របខ័ណ្ឌប្រមូលទិន្នន័យ (ឧ. ជំរឿន អង្កេត ទិន្នន័យរដ្ឋបាល) សម្រាប់ការប្រៀបធៀបនិងគុណតម្លៃនៃចំណាយ។

រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តស្វែងរកជម្រើសសម្រាប់ផ្តល់ការគាំទ្របន្ថែមដល់ប្រព័ន្ធស្ថិតិជាតិសម្រាប់ការប្រមូលទិន្នន័យប្រកបដោយគុណភាព។ ការស្វែងរកជម្រើសនេះ រួមទាំងការចូលរួមពីសំណាក់ដៃគូអភិវឌ្ឍ ជាពិសេសប្រព័ន្ធអង្គការសហប្រជាជាតិនៅកម្ពុជា តាមរយៈកិច្ចប្រជុំរបស់គណៈកម្មាធិការសម្របសម្រួលស្ថិតិ (SCC) និងអនុក្រុមការងារទិន្នន័យសម្រាប់ការអភិវឌ្ឍនៃក្រុម

ការងារបច្ចេកទេសផែនការនិងកាត់បន្ថយភាពក្រីក្រ ក្នុងការពិភាក្សាពីតម្រូវការជំនួយបច្ចេកទេស និងហិរញ្ញវត្ថុសម្រាប់ការកសាងសមត្ថភាពមន្ត្រីវិទ្យាស្ថានជាតិស្ថិតិ និងមន្ត្រីស្ថិតិរាជធានី-ខេត្ត ក៏ដូចសម្រាប់ប្រព័ន្ធស្ថិតិជាតិទាំងមូល។

បន្ថែមលើនេះទៀត វិទ្យាស្ថានជាតិស្ថិតិបានបង្កើតនិងកំពុងប្រើប្រាស់ឧបករណ៍សម្រាប់ផ្លាស់ប្តូរទិន្នន័យ រួមទាំងទិន្នន័យស្ថិតិពីការអង្កេត ជំរឿន និងប្រភពរដ្ឋបាលថ្មីៗ ដោយផ្អែកលើកម្មវិធីដត់ស្តាតស៊្វីត(.Stat Suite) ដែលជាប្រព័ន្ធកម្មវិធីសម្រាប់រាយការណ៍និងផ្សព្វផ្សាយទិន្នន័យស្ថិតិតាមថ្នាលបច្ចេកវិទ្យាព័ត៌មានវិទ្យា ឬហៅថាខេមស្តាត "CamStat" (Cambodia Statistical Data Dissemination Platform) ដែលអនុញ្ញាតឱ្យអ្នកប្រើប្រាស់ទូទៅទទួលបានទិន្នន័យងាយស្រួល ជាពិសេសសម្រាប់គាំទ្រដល់ដំណើរការតាមដានត្រួតពិនិត្យនិងវាយតម្លៃការសម្រេចបាន គ.អ.ច.ក ឱ្យកាន់តែមានភាពទាន់ពេលវេលា និងមានប្រសិទ្ធភាព។ ប្រព័ន្ធកម្មវិធីថ្មីនេះរួមបញ្ចូលទាំង៖

- ប្រព័ន្ធអេកូទិន្នន័យស្ថិតិមានលក្ខណៈបើកចំហ ដោយភ្ជាប់ទៅនឹងកម្មវិធីថ្នាលផ្សព្វផ្សាយទិន្នន័យសូចនាករ គ.អ.ច សកល ដែល៖ (ក) មានមុខងារជាឧបករណ៍ទម្រង់សម្រាប់ ផ្ទេរ បញ្ជូន និងចែករំលែកទិន្នន័យ ដោយផ្អែកប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យា ប្រកបដោយភាពអាចជឿទុកចិត្តបាន មានគុណភាព និងទាន់ពេលវេលា (ខ) លើកម្ពស់គណនេយ្យភាព និងទិន្នន័យមានលក្ខណៈបើកចំហសម្រាប់អ្នកផលិតទិន្នន័យ និង (គ) បង្កើនការយល់ដឹងដល់ភាគីពាក់ព័ន្ធដទៃផ្សេងទៀតដែលមិនមែនរដ្ឋាភិបាល អំពីសារសំខាន់នៃទិន្នន័យ ដែលជាផ្នែកមួយនៅក្នុងដំណើរការតាមដានត្រួតពិនិត្យនិងវាយតម្លៃនិងអនុវត្ត គ.អ.ច.។
- គាំទ្រការទទួលយកមកអនុវត្ត និងការធ្វើមូលដ្ឋាននីយកម្មនៃការអនុវត្ត ឱ្យស្របតាមស្តង់ដាអន្តរជាតិ តាមរយៈការអភិវឌ្ឍពិធីសារស្ថិតិ (ទស្សន វិធីសាស្ត្រ ចំណាត់ថ្នាក់ ការថែរក្សានៃការចុះបញ្ជីស្ថិតិ និងគោលការណ៍ណែនាំសម្រាប់ការផលិត ការវិភាគ ការផ្លាស់ប្តូរទិន្នន័យនិងការផ្សព្វផ្សាយ) និងគាំទ្រដល់ការកសាងសមត្ថភាពក្នុងការប្រើប្រាស់ពិធីសារស្ថិតិ និងគោលការណ៍ណែនាំស្ថិតិ សំដៅលើកកម្ពស់ការសម្របសម្រួលនៅក្នុងប្រព័ន្ធស្ថិតិជាតិ និងការចែករំលែកទិន្នន័យរវាងក្រសួង-ស្ថាប័នពាក់ព័ន្ធនៅក្នុងរាជរដ្ឋាភិបាលកម្ពុជា។
- វាយតម្លៃឡើងវិញនូវសមត្ថភាពនៃប្រព័ន្ធស្ថិតិកម្ពុជា ក្នុងការចងក្រងសូចនាករ គ.អ.ច សាកល និងសូចនាករ គ.អ.ច.ក និងដើម្បីរៀបចំផែនការអនុវត្តថ្នាក់ជាតិ សម្រាប់ការវាស់វែងសូចនាករទាំងនេះ ឆ្ពោះទៅគាំទ្រដំណើរការតាមដានវឌ្ឍនភាពនៃការសម្រេចបាន គ.អ.ច.ក ឱ្យកាន់តែមានប្រសិទ្ធភាព។

## ៥.៦ ការលើកកម្ពស់ភាពជាដៃគូពហុភាគី

រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ថា ភាពជាដៃគូសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា គឺជាការផ្តួចផ្តើមរបស់ភាគីពាក់ព័ន្ធចម្រុះ ដោយស្ម័គ្រចិត្តអនុវត្តដោយភាគីរាជរដ្ឋាភិបាល អង្គការ

អន្តររដ្ឋាភិបាល អង្គការសង្គមស៊ីវិលសំខាន់ៗ និង ភាគីដែលមានចំណែកពាក់ព័ន្ធផ្សេងទៀត។ នៅកម្ពុជា ប្រភេទនៃភាពជាដៃគូនេះ ត្រូវបានចែករំលែកសម្រាប់ការអនុវត្តគោលដៅអភិវឌ្ឍន៍ និងការប្តេជ្ញាចិត្ត ដែលបានឯកភាពរួចហើយ និង បានបញ្ចូលក្នុងរបៀបវារៈទី២១ ការអនុវត្តផែនការចនណេសស្បើក សេចក្តីប្រកាសសហស្សវត្សរ៍ ឯកសារស្តីពីលទ្ធផលនៃមហាសន្និបាតអង្គការសហប្រជាជាតិស្តីពីការអភិវឌ្ឍ ប្រកបដោយចីរភាព (រីយ៉ូ +២០) និងមហាសន្និបាតលើកទី៣ស្តីពីរដ្ឋដែនកោះតូចៗកំពុងអភិវឌ្ឍន៍។

រាជរដ្ឋាភិបាលកម្ពុជាជឿជាក់ថា ភាពជាដៃគូទាំងនេះ អាចរួមចំណែកយ៉ាងច្រើនដល់ របៀបវារៈ ឆ្នាំ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និងធ្វើឱ្យសម្រេចបាន គ.អ.ច.ក.។ នៅ ក្នុងគោលដៅទី១៧ "ការពង្រឹងមធ្យោបាយអនុវត្តនានា និងការបង្កើនភាពរស់រវើកនៃភាពជាដៃគូ សាកល សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព" រាជរដ្ឋាភិបាលកម្ពុជា បានប្តេជ្ញាចិត្តយ៉ាងមុតមាំ ក្នុង ការធ្វើការក្នុងភាពជាដៃគូ ជាមួយនឹងដៃគូអភិវឌ្ឍដែលមានចំណែកពាក់ព័ន្ធទាំងអស់ ដើម្បីធានាឱ្យ សម្រេចបានរបៀបវារៈគោលនយោបាយ និង គ.អ.ច.ក. តាមរយៈការអនុវត្ត ផ.យ.អ.ជ. ២០២៩-២០២៣។

ដោយមានទំនាក់ទំនងជាក់លាក់ក្នុងភាពជាដៃគូរវាងតួអង្គនានាក្នុងរាជរដ្ឋាភិបាល"យុទ្ធសាស្ត្រ សម្រាប់ភាពជាដៃគូនិងសហប្រតិបត្តិការអភិវឌ្ឍន៍" ដែលបានបង្កើតឡើងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និង ដើរតួនាទីយ៉ាងសំខាន់ក្នុងកិច្ចខិតខំប្រឹងប្រែងនិងការធ្វើទំនាក់ទំនងពាក់ព័ន្ធជាមួយនឹង ជំនួយអភិវឌ្ឍន៍ ផ្លូវការ និងជំនួយផ្សេងៗទៀត។ តាមជាតុចូលពីរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍទាំងអស់ គោលបំណងនៃ ភាពជាដៃគូនេះ គឺកៀរគរនិងគ្រប់គ្រងគ្រប់ទម្រង់ទាំងអស់នៃហិរញ្ញវត្ថុអភិវឌ្ឍន៍ ដូចនេះ ធនធាននានាត្រូវ បានបន្ស៊ីជាអតិបរមា ជាមួយនឹងអាទិភាពនៃការអភិវឌ្ឍជាតិ និងសម្រេចបាននូវលទ្ធផលល្អបំផុត[3]។

[3] សូមមើលគេហទំព័ររបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា៖ http://www.cdc-crdb.gov.kh/dcps/dcps_2019_2023/default.htm

# ជំពូកទី៦

# សេចក្តីសន្និដ្ឋាន

ការអនុមតិ គ.អ.ច. នៅកម្ពុជា គឺជាដំណើរការដ៏ទូលំទូលាយនិងហ្មត់ចត់ និងបានចូលរួមពីភាគីដែលមានការពាក់ព័ន្ធជាច្រើន។ ដំណើរការនៃការរៀបចំជាផ្លូវការរបស់ គ.អ.ច.ក. បានចាប់ផ្តើមបន្ទាប់ពីកិច្ចប្រជុំពិភាក្សាជាច្រើនលើកច្រើនសារជាមួយភាគីដែលមានចំណែកពាក់ព័ន្ធ រួមទាំងអ្នករៀបចំគោលនយោបាយ ក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ស្ថាប័នពាក់ព័ន្ធ និងសាធារណៈជន។ ក្របខ័ណ្ឌ គ.អ.ច.ក. ត្រូវបានបង្កើតឡើងយ៉ាងពេញលេញ ក្រោយពីកិច្ចខិតខំប្រឹងប្រែងរួមគ្នារយៈពេល២ឆ្នាំ ដែលធ្វើឡើងដោយក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជា ដៃគូអភិវឌ្ឍនិងភាគីដែលមានចំណែកពាក់ព័ន្ធ ដឹកនាំដោយក្រសួងផែនការ។ ក្របខ័ណ្ឌនេះ រួមបញ្ចូលទាំងការស្នើឡើងពីវិធីសាស្រ្តនៃការធ្វើសមាហរណកម្មទៅក្នុងគោលនយោបាយ និងប្រព័ន្ធផែនការជាតិ។

ដំណើរការនៃការធ្វើមូលដ្ឋាននីយកម្ម គ.អ.ច. បានចាប់ផ្តើមពីការធ្វើការវាយតម្លៃ ការសម្រេចបាននិងការមិនសម្រេចបានបណ្តាចំណុចដៅនានារបស់ គ.អ.ស.ក. និងការវិភាគពីភាពរងគ្រោះថ្នាក់នៃក្រុមជនដែលត្រូវបានបោះបង់ចោល។ ក្នុងដំណើរធ្វើមូលដ្ឋាននីយកម្មនេះ ការតម្រឹមតម្រង់រវាង គ.អ.ច. ជាមួយយុទ្ធសាស្រ្តអភិវឌ្ឍនានានៅថ្នាក់ជាតិ ដូចជា *យុទ្ធសាស្រ្តចតុកោណ ដំណាក់កាលទី៤ ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣* ត្រូវបានផ្តល់អាទិភាព។ ការវាយតម្លៃទាំងនេះ បានជួយដល់ការស្វែងរកពីគម្លាត និងកំណត់ពីផែនការនិងគោលនយោបាយទាំងឡាយណាដែលមិនផ្សារភ្ជាប់ជាមួយ ចំណុចដៅនានារបស់ គ.អ.ច.ក.។

រាជរដ្ឋាភិបាលកម្ពុជាពិចារណាចាត់ទុក របាយការណ៍ត្រួតពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្តជាការរៀនសូត្រ និងដំណោះការចែករំលែកបទពិសោធន៍និងលទ្ធផល និងក៏ជាមូលដ្ឋានយ៉ាងសំខាន់សម្រាប់ការរៀបចំរបាយការណ៍វឌ្ឍនភាពនេះផងដែរ។ ដូចនេះ ប្រធានបទសម្រាប់វេទិកានយោបាយកម្រិតខ្ពស់របស់អង្គការសហប្រជាជាតិ ឆ្នាំ២០១៩ ដែលស្តីពី "ការផ្តល់អំណាចដល់ប្រជាជននិង ធានាបរិយាប័ន្ន និងសមភាព" ត្រូវបានដាក់បញ្ចូលជាខ្លឹមសារស្នូល នៅក្នុងការរៀបចំសេចក្តីព្រាងរបាយការណ៍វឌ្ឍនភាពនេះដែរនេះ។ របាយការណ៍ត្រួតពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្ត ផ្តោតជាសំខាន់លើគោលដៅចំនួន៦ប៉ុណ្ណោះ និងបង្ហាញដោយសង្ខេបពីគោលដៅផ្សេងទៀត។ ដោយឡែក របាយការណ៍វឌ្ឍនភាពឆ្នាំ២០១៩ នេះ បានពិនិត្យមើលនិងវាយតម្លៃលម្អិត នៅគ្រប់គោលដៅ ចំណុចដៅ និងសូចនាកររបស់ គ.អ.ច.ក.។ នៅក្នុងការបោះជំហានទៅមុខនៃការអនុវត្តរបៀបវារៈ ឆ្នាំ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព របាយការណ៍វឌ្ឍនភាពឆ្នាំ២០១៩ នេះ នឹងក្លាយជាឯកសារមូលដ្ឋាន

ដ៏សំខាន់សម្រាប់តម្រង់ទិសអ្នករៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ជាពិសេស សម្រាប់រាជរដ្ឋាភិបាលកម្ពុជាពិនិត្យមើលពីវឌ្ឍនភាពរបស់ប្រទេស និងកំណត់ទិសដៅដែលត្រូវសម្រេចឱ្យបាននូវគោលដៅរហូតដល់ឆ្នាំ២០៣០ នៅក្នុងអាណត្តិកាលដែលនៅសល់របស់ ក្របខ័ណ្ឌ គ.អ.ច.ក.។

ការពិនិត្យមើលពីលទ្ធផលនេះ គឺផ្អែកលើវិធីសាស្ត្រស្រាវជ្រាវចម្រុះ ដែលរួមមាន ការកំណត់ពីស្ថានភាពបច្ចុប្បន្ន ការស្រាវជ្រាវឯកសារដែលមានស្រាប់ ការសម្ភាសន៍ជាមួយអ្នកដែលមានចំណែកពាក់ព័ន្ធសំខាន់ៗ ដើម្បីទទួលព័ត៌មានសម្រាប់វាយតម្លៃពីវឌ្ឍនភាព បញ្ហាប្រឈម និង គោលនយោបាយសំខាន់ៗសម្រាប់ជំរុញការធ្វើឱ្យសម្រេចបាន គ.អ.ច.ក.។ ឯកសារសំខាន់ៗ ដែលបានពិនិត្យមើលនិងដាក់បញ្ចូល រួមមាន *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ ក្របខ័ណ្ឌ គ.អ.ច.ក. ២០១៦-២០៣០* និង ខ្លឹមសារមួយចំនួនពី *ផ.យ.អ.ជ. ២០១៩-២០២៣* ក៏ដូចជា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យផ្សេងទៀត។ ឯកសារទាំងនេះ ត្រូវបានពិនិត្យមើលយ៉ាងហ្មត់ចត់ ដើម្បីទទួលបានការយល់ដឹងកាន់តែច្បាស់ពីវឌ្ឍនភាពនិងបញ្ហាប្រឈមស្តីពីគោលដៅនិងចំណុចដៅនីមួយៗរបស់ គ.អ.ច.ក.។ ព័ត៌មាននិងទិន្នន័យដែលទទួលបានពីគ្រប់ភាគីទាំងអស់ ជាពិសេស ពីប្រភពអង្កេតនិងជំរឿនានា បានផ្តល់ជាឧបករណ៍សម្រាប់វាយតម្លៃយ៉ាងល្អ។ ទោះជាដូចនេះក្តី សូចនាករមួយចំនួន នៅតែមិនមានទិន្នន័យគាំទ្រ ដោយសារតែសូចនាករទាំងនោះ ពុំមានវដ្តទិន្នន័យ ឬពុំទាន់អាចផលិតបាននៅឆ្នាំ២០១៩នេះ។ ចំណែកឯសូចនាករមួយចំនួនទៀត មិនមានប្រភពទិន្នន័យគាំទ្រតែម្តង ដែលក្រសួងផែនការនឹងផ្តួចផ្តើមឱ្យមានការពិភាក្សាកម្រិតអន្តរក្រសួង នៅពេលខាងមុខ ដើម្បីពិចារណាវាយតម្លៃលើវត្តមានរបស់សូចនាករទាំងនោះ នៅក្នុងបញ្ជីសូចនាករ គ.អ.ច.ក.។

ទោះបីជាការអនុវត្តនេះ គឺជាឆ្នាំដំបូងក្តី ប៉ុន្តែលទ្ធផលដែលទទួលបាន បានបង្ហាញថា កម្ពុជាបានធ្វើឱ្យមានវឌ្ឍនភាពយ៉ាងល្អនៅលើផ្នែកជាច្រើន ហើយភាគច្រើននៃចំណុចដៅនៃគោលដៅទាំងអស់ សម្រេចបានទៅតាមគន្លងឬលើសពីកម្រិតដែលបានកំណត់។ របាយការណ៍នេះ ក៏បានបង្ហាញពីលទ្ធផលតាមរយៈរូបភាពមានគំនូសពណ៌សំខាន់ៗ សម្រាប់បង្ហាញដោយសង្ខេបពីកម្រិតនៃការសម្រេចបាននេះដែរ។ នៅក្នុងវិស័យអប់រំ អត្រាបញ្ចប់ការសិក្សានៅកម្រិតបឋមសិក្សាបានកើនឡើងពី៨០,០% នៅឆ្នាំ២០១៥ ដល់៨៦,២% នៅឆ្នាំ២០១៩ អត្រាបញ្ចប់ការសិក្សានៅកម្រិតមធ្យមសិក្សាបឋមភូមិបានកើនឡើងពី៣៩,០% នៅឆ្នាំ២០១៥ ដល់៤៧,៥% នៅឆ្នាំ២០១៩ ហើយសមាមាត្រនៃសិស្សរៀននៅថ្នាក់ទី១ដែលបានឆ្លងកាត់គ្រប់កម្មវិធីនៃការអប់រំកុមារតូច បានកើនឡើងពី៦២,០% ដល់៧១,៣% នៅឆ្នាំ២០១៩។ ដូចគ្នានេះដែរ កម្ពុជាបានសម្រេចយុត្តភាពយេនឌ័រក្នុងវិស័យអប់រំ និងកំពុងចាប់ផ្តើមមានលម្អៀងទៅរកក្មេងស្រី នៅក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ។ កម្ពុជាក៏សម្រេចបានស្ថិរភាពកំណើនសេដ្ឋកិច្ចជាមធ្យមក្នុងរង្វង់៧,៧% ក្នុងមួយឆ្នាំ ក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ និងបានក្លាយជាប្រទេសដែលមានស្ថានភាពសេដ្ឋកិច្ចចំណូលមធ្យមកម្រិតទាប នៅឆ្នាំ២០១៥ ហើយកំពុងឈាន

ទៅរកប្រទេសដែលមានស្ថានភាពសេដ្ឋកិច្ចចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ ជាមួយគ្នានឹងអត្រានៃភាពក្រីក្រ បានបន្តធ្លាក់ចុះក្នុងកម្រិត ប្រមាណ១% ក្នុងមួយឆ្នាំ។

រាជរដ្ឋាភិបាលកម្ពុជាក៏បានប្តេជ្ញាចិត្តក្នុងការបញ្ជ្រាបបញ្ហាបរិស្ថាន និងស្ថេរភាពធនធានធម្មជាតិ ទៅក្នុងក្របខ័ណ្ឌអភិវឌ្ឍន៍ជាតិ។ ការប្តេជ្ញាចិត្តនេះ អាចបង្ហាញចេញតាមរយៈការបង្កើតក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ចីរភាព និងការអនុមតិផែនការយុទ្ធសាស្ត្រការប្រែប្រួលអាកាសធាតុកម្ពុជា ២០១៤-២០២៣។ ឯកសារគោលនយោបាយជាតិ មិនត្រឹមតែបង្ហាញពីការធ្វើអាទិភាពពីវិធានការរបស់កម្ពុជាក្នុងការបន្សាំអាកាសធាតុកាសធាតុប៉ុណ្ណោះទេ ប៉ុន្តែ ក៏បានផ្តល់នូវការចង្អុលបង្ហាញសម្រាប់កាត់បន្ថយឧស្ម័នកាបូនអុកស៊ីតនៅក្នុងវិស័យសេដ្ឋកិច្ចមួយចំនួន និងការលើកកម្ពស់បង្កើនអាកាបូន។ បន្ថែមលើនេះទៀត កម្ពុជាបានបង្កើតគោលនយោបាយកំណើនបៃតងនិងផែនទីបង្ហាញផ្លូវ ដែលកំណត់ផ្លូវដើម្បីជំរុញសេដ្ឋកិច្ច តាមរយៈជម្រើសកាបូនទាប ការសន្សំនិងបង្កើតការងារ ការការពារក្រុមងាយរងគ្រោះ និងធ្វើឱ្យប្រសើរឡើងចីរភាពបរិស្ថាន។

គុណភាពនិងការគ្រប់គ្រងទិន្នន័យ គឺជាបញ្ហាប្រឈមចម្បងនៅក្នុងការវាយតម្លៃការអនុវត្ត គ.អ.ច.ក.។ ប្រព័ន្ធទិន្នន័យរដ្ឋបាលនៃគោលដៅតាមវិស័យជាច្រើនចាំបាច់ត្រូវការពង្រឹង។ ខណៈពេលដែលរាជរដ្ឋាភិបាលកម្ពុជាបានបោះជំហានទៅមុខជាមួយការអនុវត្ត គ.អ.ច.ក. និងផែនការអភិវឌ្ឍន៍ជាតិ (ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ និងផែនការយុទ្ធសាស្ត្រតាមវិស័យ) ចាំបាច់ទាមទារឱ្យមានការគាំទ្របន្ថែម ដើម្បីពង្រឹងប្រព័ន្ធព័ត៌មានរបស់ក្រសួង ស្ថាប័ន ជាពិសេស នៅក្នុងវិស័យដែលមិនទាន់អាចផលិតទិន្នន័យគ្រប់គ្រាន់ និងបំបែកសម្រាប់សូចនាករ គ.អ.ច.ក.។

រាជរដ្ឋាភិបាលកម្ពុជា កំពុងអនុវត្ត គ.អ.ច.ក. តាមរយៈ *ផ.យ.អ.ជ. ២០១៩-២០២៣* ដោយប្រើប្រាស់ប្រភពធនធានហិរញ្ញវត្ថុខុសៗគ្នា ដែលបានកំណត់តាមរយៈការវាយតម្លៃដែលកំពុងដំណើរការ។ ការអនុវត្តនេះ ទាមទារឱ្យមានការលើកកម្ពស់សមត្ថភាព និងពង្រឹងប្រព័ន្ធដំណើរការ ផ.យ.អ.ជ. ហើយក្រសួងផែនការ (ជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា) នឹងធ្វើឱ្យប្រសើរឡើងការវិភាគនិងការព្យាករហិរញ្ញវត្ថុ និងលំហូរផ្សេងទៀត ដោយធ្វើការការរៀបចំស្ថាប័នជំនួយហិរញ្ញវត្ថុសម្រាប់ការអភិវឌ្ឍ និងការអភិវឌ្ឍសមត្ថភាពវិភាគរបស់មន្ត្រីសំខាន់ៗនៃស្ថាប័ននេះ។ ក្រសួងផែនការក៏នឹងពង្រឹងកម្មវិធីវិនិយោគសាធាណៈ ដែលអាចឱ្យដំណើរការបានល្អប្រសើរនូវកម្មវិធីមូលធនជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល។ ការពង្រឹងនេះ នឹងទាមទារឱ្យមានកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីធានាការផ្សារភ្ជាប់កាន់តែល្អប្រសើរជាងមុនរវាងកម្មវិធីវិនិយោគសាធារណៈ ជាមួយនឹងការកែទម្រង់ការគ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈ/ផែនការយុទ្ធសាស្ត្រថវិកា ហើយការងារនេះនឹងត្រូវបានដឹកនាំដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីផ្លាស់ប្តូរទៅជាការរៀបចំថវិកាដោយផ្អែកលើការអនុវត្ត និងដើម្បីធ្វើសមាហរណកម្មថវិកាចរន្តនិងមូលធន។

ការប្តេជ្ញាចិត្តដ៏ខ្លាំងក្លារបស់រាជរដ្ឋាភិបាលកម្ពុជា ទៅនឹងរបៀបវារៈ ឆ្នាំ២០៣០ បានជំរុញដំណើរការរៀបចំរបាយការណ៍វឌ្ឍនភាពនេះ។ ការប្តេជ្ញាចិត្តនេះ គាំទ្រដល់ការរៀបចំស្ថាប័ន ដែលកំណត់សម្រាប់ គ.អ.ច.ក. ក៏ដូចជា ការធ្វើសមាហរណកម្មទៅក្នុងក្របខ័ណ្ឌផែនការជាតិ។ ជាបន្តទៀត រាជរដ្ឋាភិបាលកម្ពុជា នឹងបន្តចូលរួមជាមួយអ្នកដែលមានចំណែកពាក់ព័ន្ធ ដើម្បីដោះស្រាយបញ្ហាប្រឈមដែលបានកំណត់នៅក្នុងរបាយការណ៍នេះ រៀនសូត្របទពិសោធន៍ពីអតីតកាល និងរួមបញ្ចូលសមិទ្ធផលនានានៅក្នុងប្រទេស ដើម្បីឈានឆ្ពោះទៅមុខដើម្បីសម្រេចបានគោលដៅជាតិដែលបានកំណត់ក្នុង *ផ.យ.អ.ជ. ២០១៩-២០២៣* គោលដៅនានារបស់ គ.អ.ច.ក. និង ទស្សនទានកម្ពុជាឆ្នាំ ២០៥០។

# ឧបសម្ព័ន្ធ ១

## ឯកសារយោង


អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកម្ចាត់មីននិងសង្គ្រោះជនពិការដោយសារមីន(២០១៨) *យុទ្ធសាស្ត្រជាតិសកម្មភាពមីន ២០១៨-២០២៥ ភ្នំពេញ*

គណៈកម្មាធិការនីតិសមម្បទានិងអភិវឌ្ឍន៍កម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (២០១៣) *យុទ្ធសាស្ត្រភាពជាដៃគូនិងសហប្រតិបត្តិការអភិវឌ្ឍន៍ ២០១៤-២០១៨ ភ្នំពេញ*

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (២០១០) *ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យនេសាទ ២០១០-២០១៩ ភ្នំពេញ*

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ(២០១០) *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៤-២០១៨ ភ្នំពេញ*

ក្រសួងមហាផ្ទៃ (២០១៧*) ផែនការយុទ្ធសាស្ត្រកំណត់អត្តសញ្ញាណជាតិ ២០១៧-២០២៦ ភ្នំពេញ*

ក្រសួងបរិស្ថាន(២០១៤) *ផែនការយុទ្ធសាស្ត្រស្តីពីការប្រែប្រួលអាកាសធាតុនៅកម្ពុជា ២០១៤-២០២៣ ភ្នំពេញ*

ក្រសួងបរិស្ថាន (២០១៥) *គោលនយោបាយជាតិបរិស្ថាន ២០១៥-២០២៥ ភ្នំពេញ*

ក្រសួងបរិស្ថាន (២០១៦) *យុទ្ធសាស្ត្រជាតិបរិស្ថាន និងផែនការសកម្មភាព ២០១៦-២០២៣ ភ្នំពេញ*

ក្រសួងផែនការ (២០១៨) *ក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា ភ្នំពេញ*

ក្រសួងបរិស្ថាន (២០១៧) *ផែនការជាតិគ្រប់គ្រងតំបន់អភិរក្ស ២០១៧-២០៣១ ភ្នំពេញ*

ក្រសួងអប់រំ យុវជន និងកីឡា (២០១៤) *ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ ភ្នំពេញ*

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (២០១៩) *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឆ្នាំ២០១៩-២០២៣* ភ្នំពេញ

ក្រសួងអប់រំ យុវជន និងកីឡា (២០១៦) *ស្ថិតិនិងសូចនាករអប់រំសាធារណៈ ២០១៦-២០១៧ ភ្នំពេញ*

ក្រសួងអប់រំ យុវជន និងកីឡា (២០១៧) *ស្ថិតិនិងសូចនាករអប់រំសាធារណៈ ២០១៧-២០១៨ ភ្នំពេញ*

ក្រសួងសុខាភិបាល (២០១៦) *ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៦-២០២០ ភ្នំពេញ*

រាជរដ្ឋាភិបាលកម្ពុជា (២០១១) *យុទ្ធសាស្ត្រជាតិស្តីពីទឹកស្អាតនិងអនាម័យ នៅជនបទ ២០១១-២០២៥ ភ្នំពេញ*

រាជរដ្ឋាភិបាលកម្ពុជា (២០១៤) *យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ២០១៤-២០១៨ ភ្នំពេញ*

រាជរដ្ឋាភិបាលកម្ពុជា (២០១៦) *ការវាយតម្លៃការបញ្ចូលគ្នាយ៉ាងឆាប់រហ័ស ភ្នំពេញ*

រាជរដ្ឋាភិបាលកម្ពុជា (២០១៧) *ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥ ភ្នំពេញ*

រាជរដ្ឋាភិបាលកម្ពុជា (២០១៨) *ក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា ២០១៦-២០៣០ ភ្នំពេញ*

រាជរដ្ឋាភិបាលកម្ពុជា (២០១៤) *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ ភ្នំពេញ*

រាជរដ្ឋាភិបាលកម្ពុជា (២០១៥) *គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥ ភ្នំពេញ*

រាជរដ្ឋាភិបាលកម្ពុជា (២០១៥) *គោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ឆ្នាំ២០១៥-២០២៥ ភ្នំពេញ*

រាជរដ្ឋាភិបាលកម្ពុជា (២០១៧) *គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឆ្នាំ២០១៧-២០២៥ ភ្នំពេញ*

រាជរដ្ឋាភិបាលកម្ពុជា (២០១៩) *កម្មវិធីការងារសមរម្យសម្រាប់ប្រទេសកម្ពុជា ឆ្នាំ២០១៩-២០២៣ ភ្នំពេញ*

រាជរដ្ឋាភិបាលកម្ពុជា (២០១៨) *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ ភ្នំពេញ*

រាជរដ្ឋាភិបាលកម្ពុជា (២០១៨) *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ ភ្នំពេញ*

# ឧបសម្ព័ន្ធ ២

## បញ្ជីប្រភពទិន្នន័យ សម្រាប់ចំណុចដៅ គ.អ.ច.ក.

| | ចំណុចដៅ | ប្រភពទិន្នន័យ |
|---|---|---|
| **គោលដៅទី១៖ បញ្ចប់ភាពក្រីក្រគ្រប់ទម្រង់នៅគ្រប់ទីកន្លែង** | | |
| ១.២ | កាត់បន្ថយយ៉ាងតិចពាក់កណ្តាលនូវសមាមាត្រនៃ បុរស ស្ត្រី និងកុមារ គ្រប់អាយុ ដែលរស់នៅក្នុងភាពក្រីក្រ គ្រប់សមាសភាព ដោយផ្អែកលើនិយមន័យរបស់កម្ពុជា នៅត្រឹមឆ្នាំ២០៣០។ | វ.ជ.ស. |
| ១.៣ | អនុវត្តប្រព័ន្ធជាតិគាំពារសង្គម និងវិធានការផ្សេងៗ ឱ្យបានទូទាំងប្រទេស និង សម្រេចឱ្យបានភាគច្រើននូវភាពគ្របដណ្តប់នៃប្រព័ន្ធនេះ ដល់ប្រជាជនក្រីក្រ និង ប្រជាជនងាយរងគ្រោះ នៅត្រឹមឆ្នាំ២០៣០។ | ក.ស.អ.យ.<br>ក.ផ.ក. |
| ១.៤ | ត្រឹមឆ្នាំ២០៣០ ធានាថា បុរសស្ត្រីគ្រប់រូប ជាពិសេស ប្រជាជនក្រីក្រនិងប្រជាជនងាយរងគ្រោះ មានសិទ្ធិស្មើគ្នាក្នុងការប្រើប្រាស់ធនធានសេដ្ឋកិច្ចនិងក្នុងការទទួលបានសេវាមូលដ្ឋាន ភាពជាម្ចាស់ និង ការគ្រប់គ្រងដីនិងកម្មសិទ្ធិផ្សេងទៀត ធនធានធម្មជាតិ បច្ចេកវិទ្យាថ្មីៗសមស្រប និង សេវាហិរញ្ញវត្ថុ រួមទាំងមីក្រូហិរញ្ញវត្ថុ។ | MAPP |
| **គោលដៅទី២៖ បញ្ចប់ភាពអត់ឃ្លាន សម្រេចឱ្យបានសន្តិសុខស្បៀង ធ្វើឱ្យប្រសើរឡើងស្ថានភាពអាហារូបត្ថម្ភ និងលើកកម្ពស់កសិកម្មប្រកបដោយចីរភាព** | | |
| ២.២ | ត្រឹមឆ្នាំ២០៣០ បញ្ចប់គ្រប់ទម្រង់នៃកង្វះអាហារូបត្ថម្ភ រួមទាំង ការសម្រេចបាននៅឆ្នាំ២០២៥ នូវ ចំណុចដៅដែលបានឯកភាពក្នុងកម្រិតអន្តរជាតិស្តីពីភាពក្រិននិងភាពស្គមស្គាំងរបស់កុមារអាយុក្រោមអាយុ៥ឆ្នាំ និងដោះស្រាយនូវតម្រូវការអាហារូបត្ថម្ភរបស់កុមារីវ័យជំទង់ ស្ត្រីមានផ្ទៃពោះ ស្ត្រីកំពុងបំបៅដោះកូន និងស្ត្រីវ័យចាស់។ | CARD |
| ២.៣ | ត្រឹមឆ្នាំ២០៣០ ទទួលបានកំណើនទ្វេដងនៃផលិតភាពក្នុងវិស័យកសិកម្ម និង ចំណូលរបស់ ផលិតករធុនតូច ជាពិសេស ស្ត្រីក្នុងគ្រួសារទុរគត គ្រួសារកសិករ អ្នកគង្វាលនិងអ្នកនេសាទ រួមទាំងតាមរយៈការធានានិងការទទួលបានស្មើភាពគ្នានូវដីធ្លី ធនធានផលិតកម្មផ្សេងទៀតនិងធាតុចូល ចំណេះដឹង សេវាហិរញ្ញវត្ថុ ទីផ្សារនិងកាលានុវត្តភាពសម្រាប់តម្លៃបន្ថែម និងការងារក្នុងផ្នែកមិនមែនកសិកម្ម។ | ក.ក.រ.ន. |
| ២.៤ | ត្រឹមឆ្នាំ២០៣០ ធានានូវប្រព័ន្ធផលិតកម្មស្បៀងអាហារដែលមានចីរភាព អនុវត្តសកម្មភាពកសិកម្មដោយមានការឆ្លើយតបនឹងការប្រែប្រួលអាសធាតុដែល ជួយឱ្យមានការកើនឡើងនូវផលិតកម្មនិងផលិតផល ជួយថែរក្សាប្រព័ន្ធអេកូឡូស៊ី ជួយពង្រឹងសមត្ថភាពសម្រាប់ធន់នឹងការប្រែប្រួលអាកាសធាតុអាក្រក់ ភាពរាំងស្ងួត ទឹកជំនន់ និងគ្រោះមហន្តរាយផ្សេងទៀត និងធ្វើឱ្យប្រសើរឡើងជាបន្តបន្ទាប់គុណភាពដី។ | ក.ក.រ.ន. |

| | | |
|---|---|---|
| ២.៥ | ត្រឹមឆ្នាំ២០២០ រក្សាការធ្វើពិពិធកម្មហ្សែននៃគ្រាប់ពូជការធ្វើកសិកម្មនិងចំការ ការផ្សាំពូជសត្វ និងប្រភេទសត្វព្រៃដែលពាក់ព័ន្ធ រួមទាំងតាមរយៈការគ្រប់គ្រងសមស្រប ការធ្វើពិពិធកម្ម និងរក្សាគ្រាប់ពូជ នៅកម្រិតជាតិ តំបន់ និងអន្តរជាតិ និងលើកកម្ពស់ការទទួលបានចំណែកប្រកបដោយយុត្តិធម៌ និងសមធម៌នៃផលប្រយោជន៍ពីការប្រើប្រាស់ធនធានហ្សែននិងចំណេះដឹងប្រពៃណីដែលពាក់ព័ន្ធ ដូចការឯកភាពជាអន្តរជាតិ។ | ក.ក.រ.ន.<br>ក.ប.ស. |
| ២.a | បង្កើនការវិនិយោគ រួមទាំងតាមរយៈការលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងផ្នែកហេដ្ឋារចនាសម្ព័ន្ធជនបទ ការស្រាវជ្រាវនិងសេវាផ្សព្វផ្សាយកសិកម្ម ការអភិវឌ្ឍបច្ចេកវិជ្ជានិងធនាគារហ្សែនរុក្ខជាតិនិងសត្វ ដើម្បីលើកកម្ពស់សមត្ថភាពផលិតក្នុងប្រទេសកម្ពុជា។ | គ.ជ.ទា./<br>ក.អ.ក. |
| **គោលដៅទី៣៖** | **ធានាឱ្យជីវភាពរស់នៅរបស់ប្រជាជនប្រកបដោយសុខភាពល្អ និងលើកកម្ពស់សុខមាលភាពរបស់មនុស្សគ្រប់រូបនិងគ្រប់វ័យ** | |
| ៣.១ | កម្រិតនៃការអភិវឌ្ឍនៃប្រទេសកម្ពុជា សុខភាពនិងសុខមាលភាពរបស់ប្រជាពលរដ្ឋ និងបង្ការហានិភ័យហិរញ្ញវត្ថុ។ | ក.ស.ភ. |
| ៣.២ | ត្រឹមឆ្នាំ២០៣០ កាត់បន្ថយអត្រាមរណភាពមាតានៅកម្រិតសាកល ឱ្យនៅកម្រិតទាបជាង ៧០ក្នុងចំណោម ១០០ ០០០កំណើតរស់។ | ក.ស.ភ. |
| ៣.៣ | ត្រឹមឆ្នាំ២០៣០ បញ្ចប់ការស្លាប់ដែលអាចការពារបាន នៃទារកទើបកើតនិងកុមារអាយុក្រោម៥ឆ្នាំ ដោយគ្រប់ប្រទេសទាំងអស់មានគោលដៅកាត់បន្ថយមរណភាពទារកទើបកើត ដល់ត្រឹម ១២ ក្នុង១ ០០០កំណើតរស់ និងមរណភាពកុមារក្រោមអាយុ៥ឆ្នាំ យ៉ាងហោចណាស់ដល់ត្រឹម ២៥ ក្នុងចំណោម១ ០០០កំណើតរស់។ | ក.ស.ភ. |
| ៣.៤ | ត្រឹមឆ្នាំ២០៣០ បញ្ចប់ការរីករាលដាលមេរោគអេដស៍ ជំងឺរបេង គ្រុនចាញ់ ជំងឺមិនត្រូវបានយកចិត្តទុកដាក់នៅតំបន់ត្រូពិច ជំងឺថ្លើម ជំងឺឆ្លងតាមទឹក និងជំងឺឆ្លងផ្សេងទៀត។ | ក.ស.ភ. |
| ៣.៥ | ត្រឹមឆ្នាំ២០៣០ កាត់បន្ថយឱ្យបានមួយភាគបីនៃមរណភាពមុនអាយុកាលរំពឹងទុកពីជំងឺមិនឆ្លង តាមរយៈការការពារនិងការព្យាបាល និងលើកកម្ពស់សុខភាពផ្លូវចិត្ត និងសុខុមាលភាព។ | ក.ស.ភ. |
| ៣.៦ | ពង្រឹងការបង្ការនិងការព្យាបាលការសេពសារធាតុរួមទាំងការសេពគ្រឿងញៀននិងការប្រើប្រាស់ជាតិស្រវឹងដែលនាំឱ្យគ្រោះថ្នាក់។ | ក.ស.ភ. |
| ៣.៧ | ត្រឹមឆ្នាំ២០២០ កាត់បន្ថយឱ្យបានពាក់កណ្ដាលនៃចំនួនមនុស្សស្លាប់ដោយគ្រោះថ្នាក់ចរាចរនៅទូទាំងពិភពលោក។ | ក.ស.ភ. |
| ៣.៨ | ត្រឹមឆ្នាំ២០៣០ ធានាថា ការទទួលបានជាសាកលនូវសេវាថែទាំសុខភាពផ្លូវភេទ និងសេវាសុខភាពបន្តពូជ រួមទាំងផែនការគ្រួសារ ព័ត៌មាននិងការអប់រំ និងការធ្វើសមាហរណកម្មសុខភាពបន្តពូជទៅក្នុងកម្មវិធីនិងយុទ្ធសាស្ត្រជាតិ។ | ក.ស.ភ. |
| ៣.៩ | សម្រេចឱ្យបាននូវសុខភាពល្អជាសកល រួមទាំងការបង្ការហានីភ័យផ្នែកហិរញ្ញវត្ថុ ការទទួលបាននូវសេវាថែទាំសុខភាពចាំបាច់ដែលមានគុណភាព និងការទទួលបានថ្នាំពេទ្យនិងថ្នាំបង្ការចាំបាច់ដែលមានគុណភាព មានប្រសិទ្ធភាពនិងសុវត្ថិភាព សម្រាប់ប្រជាជនគ្រប់រូប។ | ក.ស.ភ. |

| | | |
|---|---|---|
| ៣.a | ពង្រឹងការអនុវត្តក្របខ័ណ្ឌអនុសញ្ញារបស់អង្គការសុខភាពពិភពលោក ស្តីពីការត្រួតពិនិត្យថ្នាំជក់ ឱ្យបានហ្មត់ចត់នៅក្នុងគ្រប់ប្រទេស។ | ក.ស.ភ. |
| ៣.c | បង្កើនជាបន្តបន្ទាប់ការវិភាជថវិកាលើវិស័យសុខាភិបាល និងជ្រើសរើសការអភិវឌ្ឍ ការបណ្តុះ បណ្តាល និងការជួលបុគ្គលិកផ្នែកសុខាភិបាល នៅក្នុងប្រទេសកម្ពុជា។ | ក.ស.ភ. |
| **គោលដៅទី៤៖ ធានាការអប់រំប្រកបដោយគុណភាព បរិយាបន្ន និងសមធម៌ និងលើកកម្ពស់កាលានុវត្តភាពសិក្សាពេញមួយជីវិតសម្រាប់ប្រជាជនគ្រប់រូប** | | |
| ៤.១ | ត្រឹមឆ្នាំ២០៣០ ធានាថា កុមារានិងកុមារីទទួលបានការអប់រំពេញលេញប្រកបដោយសមធម៌និងគុណភាព នៅកម្រិតបឋមសិក្សានិងមធ្យមសិក្សា ដោយមិនមានការបង់ថ្លៃឈ្នួល ដែលនឹងធ្វើឱ្យលទ្ធផលនៃការសិក្សាមានប្រសិទ្ធភាព។ | ក.អ.យ.ក. |
| ៤.២ | ត្រឹមឆ្នាំ២០៣០ ធានាថា កុមារានិងកុមារីគ្រប់រូបនឹងទទួលបាននូវការអភិវឌ្ឍក្នុងភាពជាកុមារតូច ទាំងការថែទាំ និងការអប់រំនៅមត្តេយ្យ សិក្សា ប្រកបដោយគុណភាព សម្រាប់ត្រៀមខ្លួនគ្រប់គ្រាន់សិក្សានៅកម្រិតបឋមសិក្សា។ | ក.អ.យ.ក. |
| ៤.៣ | ត្រឹមឆ្នាំ២០៣០ ធានាការទទួលបានស្មើភាពគ្នាសម្រាប់បុរសនិងស្ត្រីគ្រប់រូប នូវការបណ្តុះបណ្តាលបច្ចេកទេសមុខវិជ្ជាជីវៈនិងការសិក្សានៅកម្រិតឧត្តមសិក្សា រួមទាំងសាកលវិទ្យាល័យ។ | ក.អ.យ.ក. |
| ៤.៥ | ត្រឹមឆ្នាំ២០៣០ លុបបាត់កម្លាតយេនឌ័រនៅក្នុងវិស័យអប់រំ និងធានាការទទួលបានភាពស្មើភាពគ្នាក្នុងការអប់រំគ្រប់កម្រិត និងនៅក្នុងការបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់ក្រុមជនងាយរងគ្រោះ រួមទាំងក្រុមជនដែលបាត់បង់សមត្ថភាពពលកម្ម ប្រជាជននិងកុមារដែលរស់នៅក្នុងស្ថានភាពងាយរងគ្រោះ។ | ក.អ.យ.ក. |
| ៤.៦ | ត្រឹមឆ្នាំ២០៣០ ធានាថា យុវវ័យគ្រប់រូប និងភាគច្រើននៃប្រជាជនពេញវ័យ ទាំងបុរសនិងស្ត្រី សម្រេចបាននូវលក្ខខណ្ឌអក្ខរភាព។ | ក.អ.យ.ក. |
| ៤.a | កសាងនិងធ្វើឱ្យប្រសើរឡើងសម្ភារៈបរិក្ខារអប់រំ ដែលធ្វើឱ្យមានភាពប្រែប្រួលដល់កុមារអ្នកបាត់បង់សមត្ថភាពពលកម្មនិងយេនឌ័រ និងផ្តល់នូវសុវត្ថិភាព គ្មានអំពើហិង្សា មានបរិស្ថាននៃការសិក្សាប្រកបដោយ បរិយាបន្ននិងមានប្រសិទ្ធភាពសម្រាប់ប្រជាជនគ្រប់រូប។ | ក.អ.យ.ក.<br>ក.អ.ជ. |
| ៤.c | ត្រឹមឆ្នាំ២០៣០ បង្កើនឱ្យបានច្រើនការផ្គត់ផ្គង់គ្រូបង្រៀនដែលមានគុណភាព រួមទាំងតាមរយៈកិច្ចសហប្រតិបត្តិការអន្តរជាតិសម្រាប់ការបណ្តុះបណ្តាលគ្រូបង្រៀននៅក្នុងប្រទេសកម្ពុជា។ | ក.អ.យ.ក. |
| **គោលដៅទី៥៖ សម្រេចឱ្យបានសមភាពយេនឌ័រនិងពង្រឹងភាពអង់អាចរបស់ស្ត្រីនិងកុមារីគ្រប់រូប** | | |
| ៥.១ | បញ្ចប់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីនិងកុមារី នៅគ្រប់ទីកន្លែង។ | ក.ក.ន. |
| ៥.២ | លុបបំបាត់រាល់ទម្រង់នៃអំពើហិង្សាលើស្ត្រីនិងកុមារី នៅទីសាធារណៈនិងទីកន្លែងឯកជននានា រួមទាំងការជួញដូរ ការធ្វើអាជីវកម្មផ្លូវភេទនិងអាជីវកម្មផ្សេងទៀត។ | ក.ក.ន. |
| ៥.៣ | លុបបំបាត់រាល់ ទង្វើដែលមានគ្រោះថ្នាក់ ដូចជាការបង្ខំកុមារឱ្យរៀបអាពាហ៍ពិពាហ៍ និងការធ្វើឱ្យមានរបួសស្នាមប្រដាប់បន្តពូជ។ | ក.ក.ន. |

| | | |
|---|---|---|
| ៥.៤ | ទទួលស្គាល់និងផ្តល់តម្លៃដល់ការងារផ្ទះដែលមិនទទួលកម្រៃ តាមរយៈការផ្តល់សេវាសាធារណៈ ហេដ្ឋារចនាសម្ព័ន្ធ និងគោលនយោបាយគាំពារសង្គម និងលើកកម្ពស់ការរួមចំណែកទទួលខុសត្រូវឱ្យបានសមរម្យ នៅក្នុងសង្គមគ្រួសារនិងសង្គមជាតិ។ | ក.ក.ន. |
| ៥.៥ | ធានាការចូលរួមពេញលេញនិងមានប្រសិទ្ធភាពរបស់ស្ត្រី និងមានឱកាសដូចគ្នាក្នុងភាពជាអ្នកដឹកនាំនៅគ្រប់កម្រិតនៃការធ្វើសេចក្តីសម្រេចក្នុងវិស័យនយោបាយ សេដ្ឋកិច្ច និងជីវិតជាសាធារណៈ។ | ក.ក.ន. |
| ៥.៦ | ធានាការទទួលបានសុខភាពផ្លូវភេទនិងសុខភាពបន្តពូជ និងសិទ្ធិបន្តពូជជាសាកលដូចបានឯកភាពដោយផ្អែកលើកម្មវិធីសកម្មភាពរបស់សន្និសីទអន្តរជាតិស្តីពីប្រជាជននិងការអភិវឌ្ឍ និងផែនការ សកម្មភាពទីក្រុងប៉េកាំង និងឯកសារពាក់ព័ន្ធនានា | ក.ក.ន. |
| ៥.c | អនុម័តនិងពង្រឹងគោលនយោបាយនិងបទដ្ឋានគតិយុត្តនានាសម្រាប់លើកកម្ពស់សមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រីនិងកុមារី នៅគ្រប់កម្រិត។ | ក.ក.ន.<br>ក.ម.ស. |
| **គោលដៅទី៦៖ ធានាឱ្យមានទឹកនិងអនាម័យនិងការគ្រប់គ្រងទឹកនិងអនាម័យប្រកបដោយចីរភាពសម្រាប់ប្រជាជនគ្រប់រូប** | | |
| ៦.១ | ត្រឹមឆ្នាំ២០៣០ សម្រេចនូវការទទួលបានសាកលកម្មនិងសមធម៌នូវទឹកបរិភោគដែលមានសុវត្ថិភាពនិងតម្លៃសមរម្យ សម្រាប់ប្រជាជនទាំងអស់។ | ក.អ.ជ. |
| ៦.២ | ត្រឹមឆ្នាំ២០៣០ សម្រេចនូវការទទួលបានគ្រប់គ្រាន់និងសមធម៌នូវអនាម័យសម្រាប់ប្រជាជនគ្រប់រូប និងបញ្ចប់ការបន្ទោរបង់នៅក្រៅបង្គន់ ផ្តោតការយកចិត្តទុកដាក់លើតម្រូវការរបស់ស្ត្រី និងកុមារី និងប្រជាជនដែលរស់នៅក្នុងស្ថានភាពងាយរងគ្រោះ។ | ក.អ.ជ. |
| ៦.៣ | ត្រឹមឆ្នាំ២០៣០ ធ្វើឱ្យប្រសើរឡើងគុណភាពទឹក ដោយកាត់បន្ថយការបំពុល លុបបំបាត់ការបោះបង់សំរាមនិងកាត់បន្ថយឱ្យនៅកម្រិតទាបបំផុតនៃការបោះបង់ចោលសម្ភារៈនិងសារធាតុជាតិគីមីដែលមានគ្រោះថ្នាក់ កាត់បន្ថយឱ្យនៅពាក់កណ្តាលសមាមាត្រនៃសំណល់រាវដែលមិនបានសម្អាត និងបង្កើនឱ្យបានច្រើនវត្ថុធាតុដើមកកើតឡើងវិញ និងការប្រើប្រាស់ឡើងវិញប្រកបដោយសុវត្ថិភាពជាសកល។ | ក.ប.ស. |
| ៦.៤ | ត្រឹមឆ្នាំ២០៣០ បង្កើនឱ្យបានច្រើននូវប្រសិទ្ធភាពនៃទឹកដែលប្រើប្រាស់នៅគ្រប់វិស័យ និងធានានូវការបូមនិងផ្គត់ផ្គង់ទឹកសាប ដើម្បីដោះស្រាយការខ្វះខាតទឹក និងកាត់បន្ថយឱ្យបានច្រើននូវចំនួនប្រជាជនដែលរងគ្រោះដោយសារការខ្វះខាតទឹក។ | ក.ឧ.ស. |
| ៦.a | ត្រឹមឆ្នាំ២០៣០ ពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិ និងគាំទ្រការកសាងសមត្ថភាពដល់ បណ្តាប្រទេសកំពុងអភិវឌ្ឍ ក្នុងកម្មវិធីនិងសកម្មភាពពាក់ព័ន្ធនឹងទឹកនិងអនាម័យ រួមទាំងបច្ចេកវិជ្ជា ប្រមូលទឹក បន្សាបទឹកប្រៃប្រសិទ្ធភាពទឹកសម្អាត សំណល់រាវ កែច្នៃនិងប្រើប្រាស់ឡើងវិញ។ | គ.ជ.ទ./<br>ក.អ.ក. |
| **គោលដៅទី៧៖ ធានាឱ្យទទួលបានថាមពលដែលមានលក្ខណៈបច្ចេកទេសទំនើប ប្រកបដោយចីរភាពអាចជឿជាក់បាន និងមានតម្លៃសមរម្យ សម្រាប់ប្រជាជនគ្រប់រូប** | | |
| ៧.១ | ត្រឹមឆ្នាំ២០៣០ ធានាការទទួលបានជាសាកលនូវសេវាថាមពលទំនើប អាចទុកចិត្តបាន និងតម្លៃសមរម្យ។ | ក.រ.ថ. |

| | | |
|---|---|---|
| ៧.២ | ត្រឹមឆ្នាំ២០៣០ បង្កើនចំណែកនៃថាមពលកកើតឡើងវិញក្នុងថាមពលចម្រុះជាសាកល។ | ក.រ.ថ. |
| ៧.៣ | ត្រឹមឆ្នាំ២០៣០ បង្កើនទ្វេដងនៃអត្រាធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាពថាមពលជាសាកល។ | ក.រ.ថ. |
| **គោលដៅទី៨៖** | **ធានាកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពនិងបរិយាបន្ន មានមុខរបរពេញលេញ និង ផលិតភាព និងមានការងារសមរម្យ សម្រាប់ប្រជាជនគ្រប់រូប** | |
| ៨.១ | ធ្វើឱ្យមានស្ថិរភាព កំណើនសេដ្ឋកិច្ចសម្រាប់មនុស្សម្នាក់ឱ្យស្របតាមលក្ខខណ្ឌជាតិ ជាពិសេសកំណើនផលិតផលក្នុងស្រុកសរុបប្រចាំឆ្នាំយ៉ាងតិច ៧% នៅកម្ពុជា។ | ក.ផ.ក.<br>ក.ស.ហ. |
| ៨.២ | សម្រេចឱ្យបានផលិតភាពសេដ្ឋកិច្ចកម្រិតខ្ពស់ជាងមុនតាមរយៈ ការធ្វើពិពិតកម្ម ការបង្កើនកម្រិតបច្ចេកវិទ្យានិងនវានុវត្តន៍ រួមទាំងតាម រយៈការផ្តោតការយកចិត្តទុកដាក់លើតម្លៃបន្ថែមខ្ពស់ និងវិស័យនានាដែលផ្តល់ការងារច្រើន។ | ក.ព.ក. |
| ៨.៣ | លើកកម្ពស់គោលនយោបាយតម្រង់ទិសការអភិវឌ្ឍ ដែលគាំទ្រសកម្មភាពផលិតកម្មបង្កើតការងារសមរម្យ សហគ្រិនភាព ការច្នៃប្រឌិតនិងនវានុវត្តន៍ និងលើកទឹកចិត្តក្នុងការចុះបញ្ជីជាផ្លូវការ និងកំណើនសហគ្រាសមីក្រូតូច និងមធ្យម រួមទាំង តាមរយៈការទទួលបានសេវាហិរញ្ញវត្ថុ ។ | ក.ព.ក. |
| ៨.៩ | ត្រឹមឆ្នាំ២០៣០ បង្កើតនិងអនុវត្តគោលនយោបាយ សម្រាប់លើកកម្ពស់ទេសចរណ៍ប្រកបដោយចីរភាព ដែលបង្កើតការងារនិងលើកកម្ពស់វប្បធម៌និងផលិតផលក្នុងស្រុក។ | ក.ទ.ច. |
| ៨.a | បង្កើនហិរញ្ញប្បទានសម្រាប់គាំទ្រវិស័យ ពាណិជ្ជកម្មសម្រាប់ ប្រទេសកម្ពុជា រួមទាំងតាមរយៈក្របខ័ណ្ឌលើកកម្ពស់ការធ្វើសមាហរណកម្មសម្រាប់ជំនួយបច្ចេកទេសពាក់ព័ន្ធនឹងពាណិជ្ជកម្ម | គ.ជ.ទ./<br>ក.អ.ក. |
| **គោលដៅទី៩៖** | **កសាងហេដ្ឋារចនាសម្ព័ន្ធដែលធន់នឹងបម្រែបម្រួលអាកាសធាតុ លើកកម្ពស់ឧស្សាហូប- នីយកម្មប្រកបដោយចីរភាពនិងបរិយាបន្ននិងលើកកម្ពស់នវានុវត្តន៍** | |
| ៩.១ | អភិវឌ្ឍហេដ្ឋរចនាសម្ព័ន្ធដែលមានគុណភាព អាចជឿជាក់បាន ធន់នឹងការប្រែប្រួលអាកាសធាតុ និងចីរភាព រួមទាំង ហេដ្ឋារចនាសម្ព័ន្ធតំបន់និងឆ្លងកាត់ព្រំដែនប្រទេស ដើម្បីគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចនិងលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជន ជាមួយនឹងការផ្តោតការយកចិត្តទុកដាក់លើការទទួលបានដោយសមរម្យនិងសមធម៌ សម្រាប់ប្រជាជនគ្រប់រូប។ | ក.ស.ដ. |
| ៩.២ | លើកកម្ពស់ឧស្សាហូបនីយកម្មប្រកបដោយបរិយាប័ន្ននិងចីរភាព និងត្រឹមឆ្នាំ២០៣០ បង្កើនឱ្យបានច្រើន ឧស្សាហកម្មដែលរួមចំណែក បង្កើតការងារនិងផលិតផលក្នុងស្រុកសរុប ឱ្យស្របតាមកាលៈទេសៈជាតិ និងបង្កើនការរួមចំណែកនេះទ្វេដង នៅក្នុងបណ្តាប្រទេសដែលមានការអភិវឌ្ឍតិចតួច។ | ក.ឧ.វ.ប.ន |

| | | |
|---|---|---|
| ៩.៥ | លើកកម្ពស់ការស្រាវជ្រាវវិទ្យាសាស្ត្រ បង្កើនសមត្ថភាពបច្ចេកវិទ្យារបស់វិស័យឧស្សាហកម្មនៅគ្រប់ប្រទេស ជាពិសេស បណ្តាប្រទេសកំពុងអភិវឌ្ឍ ក្នុងនោះ ត្រឹមឆ្នាំ២០៣០ លើកទឹកចិត្តនវានុវត្តន៍និងបង្កើនចំនួននៃពលករស្រាវជ្រាវនិងការអភិវឌ្ឍក្នុងប្រជាជន១លាននាក់ និងការចំណាយដល់ការស្រាវជ្រាវនិងការអភិវឌ្ឍផ្នែកសាធារណៈនិងឯកជន។ | អ.ល.-ក.ជ.វ.ប./ក.ផ.ក. |
| ៩.a | សម្របសម្រួលឱ្យមានការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដែលមានភាពបន្សាំ និងប្រកបដោយចីរភាព នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍ តាមរយៈការលើកកម្ពស់ការគាំទ្រហិរញ្ញវត្ថុ បច្ចេកវិទ្យានិងបច្ចេកទេស ដល់បណ្តាប្រទេសនៅទ្វីបអាហ្វ្រិក បណ្តាប្រទេសដែលមានការអភិវឌ្ឍតិចតួច បណ្តាប្រទេសដែលពុំមានព្រំដែនជាប់សមុទ្រកំពុងអភិវឌ្ឍន៍ និងបណ្តារដ្ឋដែនកោះតូចៗកំពុងអភិវឌ្ឍ។ | គ.ជ.នា./ក.អ.ក. |
| ៩.c | បង្កើនឱ្យបានច្រើនការទទួលបានសេវាទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន និងខិតខំប្រឹងប្រែងផ្តល់នូវការទទួលបានសមរម្យនិងជាសាកលនូវសេវាអ៊ិនធឺណិតនៅប្រទេសកម្ពុជាត្រឹមឆ្នាំ២០២០។ | ក.ប.ទ. |
| **គោលដៅទី១០៖ កាត់បន្ថយវិសមភាពនៅក្នុងប្រទេសនិងក្នុងចំណោមបណ្តាប្រទេសនានា** | | |
| ១០.១ | ត្រឹមឆ្នាំ២០៣០សម្រេចឱ្យបានចំណូលរបស់ប្រជាជនចំនួន ៤០% នៃប្រជាជនទាំងអស់ ដែលមានចំណូលទាបជាងគេនូវកំណើនជាបន្តបន្ទាប់និងដោយចីរភាពក្នុងអត្រាខ្ពស់ជាងកម្រិតមធ្យមរបស់ជាតិ។ | ក.ផ.ក. |
| ១០.២ | ត្រឹមឆ្នាំ២០៣០ ផ្តល់ភាពអង់អាចនិងជំរុញបរិយាបន្នសង្គម សេដ្ឋកិច្ច និងនយោបាយ សម្រាប់ប្រជាជនគ្រប់រូប ដោយមិនគិតពីស្ថានភាព អាយុ ភេទ ការបាត់បង់សមត្ថភាពពលកម្ម ពូជសាសន៍ ជនជាតិភាគតិច ជនជាតិដើម សាសនា ឬសេដ្ឋកិច្ច ឬស្ថានភាពផ្សេងទៀត។ | ក.ផ.ក. |
| ១០.៤ | ឯកភាពលើគោលនយោបាយនានា ជាពិសេស គោលនយោបាយស្តីពីសារពើពន្ធ ប្រាក់បៀវត្សរ៍ ការគាំពារសង្គម និង សម្រេចឱ្យបានជាបន្តបន្ទាប់សមភាពច្រើនជាងមុន។ | ក.ស.អ.យ. |
| ១០.a | អនុវត្តគោលការណ៍និងប្រព្រឹត្តកម្មពិសេសនិងដោយឡែកសម្រាប់បណ្តាប្រទេសកំពុងអភិវឌ្ឍ ជាពិសេស បណ្តាប្រទេសដែលមានការអភិវឌ្ឍតិចតួច ឱ្យស្របតាមកិច្ចព្រមព្រៀងពាណិជ្ជកម្មពិភពលោក។ | ក.ព.ក. |
| ១០.b | លើកទឹកចិត្តចំពោះជំនួយអភិវឌ្ឍផ្លូវការ និងលំហូរហិរញ្ញវត្ថុ រួមទាំងការវិនិយោគផ្ទាល់ពីបរទេស ដល់បណ្តារដ្ឋដែលមានតម្រូវការជាងគេ ជាពិសេសបណ្តាប្រទេសដែលមានការអភិវឌ្ឍតិចតួច បណ្តាប្រទេសនៅក្នុងទ្វីបអាហ្វ្រិក បណ្តារដ្ឋដែនកោះតូចៗដែលកំពុងអភិវឌ្ឍ និងបណ្តាប្រទេសដែលពុំមានព្រំប្រទល់ជាប់សមុទ្រកំពុងអភិវឌ្ឍ ឱ្យស្របតាម ផែនការនិងកម្មវិធីជាតិនានារបស់ប្រទេសនីមួយៗ។ | គ.ជ.នា./ក.អ.ក. |
| **គោលដៅទី១១៖ ធ្វើឱ្យទីក្រុងនិងកន្លែងតាំងទីលំនៅថ្មីសម្រាប់ប្រជាជន មានលក្ខណៈបរិយាបន្ន សុវត្ថិភាព ធន់នឹងការប្រែប្រួលអាកាសធាតុនិងចីរភាព** | | |
| ១១.៦ | ត្រឹមឆ្នាំ២០៣០ កាត់បន្ថយការបំពុលបរិស្ថានក្នុងមនុស្សម្នាក់នៅទីក្រុង រួមទាំងតាមរយៈការផ្តោតការយកចិត្តទុកដាក់លើគុណភាពខ្យល់ និងការគ្រប់គ្រងសំណល់នៅទីក្រុង និងតំបន់ផ្សេងទៀត។ | ក.ប.ស. |

| | | |
|---|---|---|
| **គោលដៅទី១២៖ ធានាឱ្យមានចីរភាពក្នុងទម្រង់នៃការប្រើប្រាស់និងផលិតកម្ម** | | |
| ១២.៤ | ត្រឹមឆ្នាំ២០២០ សម្រេចឱ្យបានការគ្រប់គ្រងបរិស្ថានល្អ ពាក់ព័ន្ធនឹងការបោះបង់ចោលសារធាតុគីមីនិងសំណល់គ្រប់ប្រភេទ តាមរយៈ ការកែច្នៃឡើងវិញ ឱ្យស្របតាមក្របខ័ណ្ឌកិច្ចព្រមព្រៀងអន្តរជាតិ និងកាត់បន្ថយឱ្យបានច្រើននូវការបញ្ចេញសំណល់ទាំងនោះទៅក្នុងបរិយាកាស ក្នុងទឹក និងក្នុងដី ដើម្បីកាត់បន្ថយឱ្យនៅទាបបំផុតនូវផលប៉ះពាល់អវិជ្ជមានលើសុខភាពប្រជាជននិងបរិស្ថាន។ | ក. ប. ស. |
| ១២.៥ | ត្រឹមឆ្នាំ២០៣០ កាត់បន្ថយឱ្យបានច្រើន ការបង្កើតសំណល់ តាមរយៈការការពារ ការកាត់បន្ថយ ការកែច្នៃឡើងវិញ និងការប្រើប្រាស់ឡើងវិញ។ | ក. ប. ស. |
| **គោលដៅទី១៣៖ ចាត់វិធានការជាបន្ទាន់ ដើម្បីប្រយុទ្ធប្រឆាំងនឹងបម្រែបម្រួលអាកាសធាតុ និងផលប៉ះពាល់របស់វា** | | |
| ១៣.១ | ពង្រឹងសមត្ថភាពធន់ទ្រាំនិងភាពបន្សាំទៅនឹងគ្រោះធម្មជាតិនិងគ្រោះមហន្តរាយពាក់ព័ន្ធនឹងអាកាសធាតុ សម្រាប់គ្រប់ប្រទេស។ | ក. ប. ស. |
| ១៣.២ | បញ្ជ្រាបវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ក្នុងគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការជាតិ។ | ក.ជ.អ.ច.<br>អ.ល.អ.ច. |
| ១៣.៣ | លើកកម្ពស់ការអប់រំ ការលើកម្ពស់ការយល់ដឹង និងលើកកម្ពស់សមត្ថភាពមនុស្ស និងស្ថាប័ន ស្ដីពីការបន្ធូរបន្ថយការប្រែប្រួលអាកាសធាតុការបន្សាំ ការកាត់បន្ថយ ផលប៉ះពាល់ និងការផ្ដល់នូវការក្រើនរំលឹកឱ្យប្រយ័ត្នជាមុន។ | ក.ជ.អ.ច.<br>អ.ល.អ.ច.<br>ក.ក.រ.ន. |
| **គោលដៅទី១៤៖ អភិរក្សនិងប្រើប្រាស់ប្រកបដោយចីរភាពនូវ មហាសមុទ្រ សមុទ្រ និងធនធានសមុទ្រ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព** | | |
| ១៤.១ | ត្រឹមឆ្នាំ២០២៥ ការពារ និងកាត់បន្ថយឱ្យបានច្រើនការបំពុលគ្រប់ប្រភេទនៅក្នុងសមុទ្រ ជាពិសេស ពីបណ្ដាសកម្មភាពនានាដែលផ្ដើមចេញពីលើដីរួមទាំងការបំពុលដោយសំណល់ក្នុងសមុទ្រ និងអាហារបំប៉ន។ | ក.ប.ស. |
| ១៤.២ | ត្រឹមឆ្នាំ២០២០ គ្រប់គ្រងឱ្យបានច្រើន និងការពារប្រព័ន្ធអេកូឡូស៊ីនៅក្នុងសមុទ្រតាមឆ្នេរនិងទឹកសាបដើម្បីចៀសវាងផលប៉ះពាល់អវិជ្ជមាននានា រួមទាំង តាមរយៈការពង្រឹងភាពធន់របស់វា និងដំណើរការសកម្មភាពសម្រាប់ធ្វើឱ្យមានភាពដូចដើមវិញ ដើម្បីសម្រេចឱ្យបាននូវមហាសាគរនិងដែនទឹកសាបដែលមានផលិតភាពនិងសុខភាព។ | ក.ប.ស.<br>ក.ក.រ.ន. |
| ១៤.៥ | ត្រឹមឆ្នាំ២០២០ អភិរក្សយ៉ាងតិច ១០%នៃតំបន់ឆ្នេរតំបន់ក្នុងសមុទ្រ ស្របតាមច្បាប់ជាតិនិងអន្តរជាតិ និងផ្អែកលើព័ត៌មានវិទ្យាសាស្ត្រ។ | ក.ក.រ.ន. |
| ១៤.៧ | ត្រឹមឆ្នាំ២០៣០ បង្កើនផលប្រយោជន៍ពីសេដ្ឋកិច្ចដល់បណ្ដារដ្ឋដែនកោះតូចៗកំពុងអភិវឌ្ឍ និងបណ្ដាប្រទេសដែលមានការអភិវឌ្ឍតិចតួច ពីការប្រើប្រាស់ធនធានក្នុងសមុទ្រ ប្រកបដោយចីរភាព រួមទាំងតាមរយៈ ការគ្រប់គ្រងប្រកបដោយចីរភាពនូវការនេសាទ ជលវប្បកម្ម និងទេសចរណ៍។ | ក.ក.រ.ន. |
| ១៤.b | ផ្ដល់នូវការទទួលបានធនធានសមុទ្រនិងទីផ្សារ ចំពោះអ្នកនេសាទទ្រង់ទ្រាយតូច។ | ក.ក.រ.ន. |

| | | |
|---|---|---|
| **គោលដៅទី១៥៖ ការពារ ស្តារ និងជំរុញការប្រើប្រាស់ប្រកបដោយចីរភាពនូវប្រព័ន្ធអេកូឡូស៊ីនៅលើដែនគោក គ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព ប្រយុទ្ធប្រឆាំងនឹងឱនភាពដី បញ្ឈប់និងបង្វែរទិសនៃការសឹករេចរឹលគុណភាពដី និងបញ្ឈប់កុំឱ្យបាត់បង់ជីវជាតិដីនិងជីវៈចម្រុះ** | | |
| ១៥.១ | ត្រឹមឆ្នាំ២០២០ ធានាការអភិរក្ស ការស្តារនិងការប្រើប្រាស់ប្រកបដោយចីរភាពនូវប្រព័ន្ធអេកូឡូស៊ីក្នុងទឹកសាបនៅដែនគោកនិងនៅលើគោក និងសេវា ជាពិសេស ព្រៃឈើ ដីសើម ភ្នំ និងដីស្ងួត ឱ្យស្របតាមកតព្វកិច្ចក្រោមកិច្ចព្រមព្រៀងអន្តរជាតិ។ | ក.ក.រ.ន.<br>ក.ប.ស. |
| ១៥.២ | ត្រឹមឆ្នាំ២០២០លើកកម្ពស់ការអនុវត្តការគ្រប់គ្រងប្រកបដោយចីរភាព នូវព្រៃឈើគ្រប់ប្រភេទ កាត់បន្ថយឱ្យបានពាក់កណ្តាលនូវការបំផ្លាញព្រៃឈើព្រៃឈើដែលបាត់បង់ និងបង្កើនឱ្យបានច្រើនជាសកលការដាំដើមឈើនិងការដាំព្រៃឈើឡើងវិញ។ | ក.ក.រ.ន.<br>ក.ប.ស. |
| ១៥.៣ | ត្រឹមឆ្នាំ២០៣០ ប្រយុទ្ធប្រឆាំងនឹងការបំផ្លាញព្រៃឈើ ធ្វើឱ្យដូចដើមឡើងវិញដីដែលបាត់បង់ជីជាតិ រួមទាំង ដីដែលទទួលផលប៉ះពាល់ពី វាលរហោដ្ឋានកម្មភាព រាំងស្ងួត និងទឹកជំនន់ធ្វើឱ្យប្រសើរឡើងនូវពិភពលោកដែលមានដីមិនមានការខូចខាត។ | ក.ក.រ.ន. |
| ១៥.៥ | អនុវត្តចំណាត់ការចាំបាច់និងជាបន្ទាន់ដើម្បីកាត់បន្ថយផលប៉ះពាល់ អវិជ្ជមានលើលំនៅឋានធម្មជាតិ កាត់បន្ថយឱ្យបានពាក់កណ្តាលនូវការបាត់បង់ជីវៈចម្រុះ និងត្រឹមឆ្នាំ២០២០ ការពារនិងបង្ការការបាត់បង់ផុតពូជនូវប្រភេទរុក្ខជាតិ/សត្វដែលរងការគំរាមកំហែងជិតផុតពូជ។ | ក.ក.រ.ន. |
| ១៥.៧ | អនុវត្តសកម្មភាពជាបន្ទាន់ដើម្បីបញ្ចប់ការបរបាញ់និងជួញដូរប្រភេទពូជ រុក្ខជាតិ និងពពួកសត្វដែលត្រូវបានការពារ និងដោះស្រាយទាំងតម្រូវការនិងការផ្គត់ផ្គង់ខុសច្បាប់នៃផលិតផលសត្វព្រៃ។ | ក.ក.រ.ន. |
| ១៥.៩ | ត្រឹមឆ្នាំ២០២០ បញ្ចូលតម្លៃប្រព័ន្ធអេកូឡូស៊ីនិងជីវៈចម្រុះ ទៅក្នុងផែនការជាតិនិងផែនការមូលដ្ឋាន ដំណើរការនៃការអភិវឌ្ឍយុទ្ធសាស្ត្រនិងគណនេយ្យភាពសម្រាប់កាត់បន្ថយភាពក្រីក្រ។ | ក.ជ.អ.ច./<br>អ.ល.អ.ច.<br>ក.ប.ស.<br>ក.ក.រ.ន. |
| ១៥.b | កៀរគរធនធានឱ្យបានច្រើនពីគ្រប់ប្រភពនិងនៅគ្រប់កម្រិត ដើម្បីផ្តល់ហិរញ្ញវត្ថុសម្រាប់គ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព និងផ្តល់នូវការឧបត្ថម្ភគ្រប់គ្រាន់ដល់ប្រទេសកម្ពុជា ដើម្បីអនុវត្តការគ្រប់គ្រងបានល្អប្រសើរ រួមទាំងសម្រាប់ការអភិរក្ស និងការដាំព្រៃឈើឡើងវិញ។ | គ.ជ.នា./<br>ក.អ.ក. |
| **គោលដៅទី១៦៖ លើកកម្ពស់សង្គមដែលមានសន្តិភាពប្រកបដោយបរិយាបន្ន ដើម្បីការអភិវឌ្ឍប្រកបដោយ ចីរភាព ផ្តល់នូវការទទួលបានយុត្តិធម៌សម្រាប់ប្រជាជនគ្រប់រូប និងកសាងស្ថាប័នដែលមានប្រសិទ្ធភាព គណនេយ្យភាព និងបរិយាបន្ន នៅគ្រប់កម្រិត** | | |
| ១៦.៣ | លើកកម្ពស់វិធានការច្បាប់ នៅកម្រិតជាតិនិងអន្តរជាតិ និងធានាការទទួលបានយុត្តិធម៌ស្មើភាពគ្នា សម្រាប់ប្រជាជនគ្រប់រូប។ | ក.ទ.រ.ព.អ. |
| ១៦.៧ | ធានានូវការធ្វើសេចក្តីសម្រេច ដោយមានការចូលរួមពីគ្រប់តំណាង ដោយមានការទទួលខុសត្រូវប្រកបដោយបរិយាបន្ននៅគ្រប់កម្រិត។ | ក.ម.ស. |

| | | |
|---|---|---|
| ១៦.៩ | ត្រឹមឆ្នាំ២០៣០ ផ្ដល់អត្តសញ្ញាណផ្លូវច្បាប់ដល់ប្រជាជនគ្រប់រូប រួមទាំងការចុះបញ្ជីកំណើត។ | ក.ម.ផ. |
| **គោលដៅទី១៧៖ ពង្រឹងមធ្យោបាយអនុវត្តនានានិងបង្កើតភាពរស់រវើកនៃភាពជាដៃគូសកល សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព** | | |
| ១៧.៣ | កៀរគរធនធានហិរញ្ញវត្ថុបន្ថែមទៀតពីប្រភពចម្រុះ សម្រាប់ផ្ដល់ដល់បណ្ដាប្រទេសកំពុងអភិវឌ្ឍ។ | គ.ជ.នា./ក.អ.ក. |
| ១៧.៦ | លើកកម្ពស់កិច្ចសហប្រតិបត្តិការជើង-ត្បូង កិច្ចសហប្រតិបត្តិការត្បូង-ត្បូង កិច្ចសហប្រតិបត្តិការតំបន់ត្រីកោណ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ស្តីពីការទទួលបានវិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍ និង លើកកម្ពស់ការចែករំលែកការយល់ដឹងស្តីពីទម្រង់នៃការឯកភាពទាំងសងខាង តាមរយៈការធ្វើឱ្យប្រសើរឡើង ការសម្របសម្រួលក្នុងចំណោមយន្តការដែលមានស្រាប់ ជាពិសេស ក្នុងកម្រិតសហប្រជាជាតិ និងតាមរយៈយន្តការសម្របសម្រួល បច្ចេកវិទ្យាសកល។ | ក.ប.ទ. |
| ១៧.៨ | ត្រឹមឆ្នាំ២០២៧ធ្វើប្រតិបត្តិការពេញលេញ ធនាគារបច្ចេកវិទ្យានិងវិទ្យាសាស្ត្រ និងយន្តការកសាងសមត្ថភាពពីបច្ចេកវិទ្យានិងនវានុវត្តន៍សម្រាប់បណ្ដាប្រទេសដែលមានការអភិវឌ្ឍតិចតួច និងលើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាដែលមានសមត្ថភាពជាពិសេស បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន។ | ក.ប.ទ. |
| ១៧.៩ | លើកកម្ពស់ការគាំទ្រពីអន្តរជាតិ សម្រាប់ការអនុវត្តការកសាងសមត្ថភាពដែលបានកំណត់ចំណុចដៅនិងមានប្រសិទ្ធភាពក្នុងបណ្ដាប្រទេសកំពុងអភិវឌ្ឍ ដើម្បីគាំទ្រផែនការជាតិ ក្នុងការអនុវត្តនូវគ្រប់គោលដៅអភិវឌ្ឍប្រកបដោយចីរភាព រួមទាំងតាមរយៈ កិច្ចសហប្រតិបត្តិការជើង-ត្បូង កិច្ចសហប្រតិបត្តិការត្បូង-ត្បូង និងកិច្ចសហប្រតិបត្តិការតំបន់ត្រីកោណ។ | គ.ជ.នា./ក.អ.ក. |
| ១៧.១០ | លើកកម្ពស់ប្រព័ន្ធពាណិជ្ជកម្មចម្រុះ ដែលមានលក្ខណៈជាសកលមានមូលដ្ឋានច្បាប់បើកទូលាយនិងសមធម៌ក្រោមអង្គការពាណិជ្ជកម្មពិភពលោក រួមទាំងតាមរយៈការសន្និដ្ឋាននៃការចរចាក្រោមរបៀបវារៈទីក្រុងដាហា ស្តីពីការអភិវឌ្ឍ។ | ក.ព.ក. |
| ១៧.១៧ | លើកទឹកចិត្តនិងលើកកម្ពស់ភាពជាដៃគូប្រកបដោយប្រសិទ្ធភាពក្នុងវិស័យសាធារណៈរវាងផ្នែកសាធារណៈនិងផ្នែកឯកជន និងជាមួយសង្គមស៊ីវិល កសាងភាពជាដៃគូផ្អែកលើបទពិសោធនិងយុទ្ធសាស្ត្រ ផ្តល់ធនធាននៃភាពជាដៃគូ។ | គ.ជ.នា./ក.អ.ក. |
| ១៧.១៨ | ត្រឹមឆ្នាំ២០២០ លើកកម្ពស់ការគាំទ្រការកសាងសមត្ថភាពដល់បណ្ដាប្រទេសកំពុងអភិវឌ្ឍ រួមទាំងដល់បណ្ដាប្រទេសដែលមានការអភិវឌ្ឍតិចតួច និងបណ្ដារដ្ឋដែនកោះតូចៗកំពុងអភិវឌ្ឍដើម្បីបង្កើនឱ្យបានច្រើន ភាពអាចរកបានទាន់ពេលនៃទិន្នន័យដែលមានគុណភាពខ្ពស់ និងជឿជាក់បាន បំបែកតាមចំណូល យេនឌ័រ អាយុ ជាតិសាសន៍ ជនជាតិភាគតិច ស្ថានភាពនៃការផ្លាស់ប្តូរទីលំនៅ ការបាត់បង់សមត្ថភាពពលកម្ម ទីតាំងភូមិសាស្ត្រ និងលក្ខណៈផ្សេងទៀតដែលពាក់ព័ន្ធ ក្នុងបរិការណ៍ជាតិ។ | ក.ផ.ក. |

| | | |
|---|---|---|
| ១៧.១៩ | ត្រឹមឆ្នាំ២០៣០ កសាងដោយផ្អែកលើការផ្តួចផ្តើមដែលមានស្រាប់ដើម្បីអភិវឌ្ឍមធ្យោបាយវាស់វែងពីវឌ្ឍនភាពនៃការអភិវឌ្ឍប្រកបដោយចីរភាព ដែលបំពេញផលិតផលក្នុងស្រុកសរុប និងគាំទ្រការកសាងសមត្ថភាពស្ថិតិនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍ។ | វ.ជ.ស. |
| **គោលដៅទី ១៨៖ បញ្ចប់ផលប៉ះពាល់ជាអវិជ្ជមានរបស់មីន/សំណល់ជាតិផ្ទុះពីសង្គ្រាម និងជំរុញការសង្គ្រោះជនរងគ្រោះ** | | |
| ១៨.១ | បោសសម្អាតផ្ទៃដីចម្ការមីននិងសំណល់ជាតិ ផ្ទុះពីសង្គ្រាម ដែលបានដឹងឱ្យអស់ ត្រឹមឆ្នាំ២០៣០។ | អ.ធ.ម. |
| ១៨.២ | កាត់បន្ថយគ្រោះថ្នាក់ដោយសារមីន/ស.ផ.ស. នៅតិចជាង១០នាក់ក្នុងមួយឆ្នាំ ត្រឹមឆ្នាំ២០៣០។ | អ.ធ.ម. |
| ១៨.៣ | លើកកម្ពស់សិទ្ធិ និងគុណភាពជីវិតរបស់ជនពិការដោយសារមីន/សំណល់ជាតិផ្ទុះពីសង្គ្រាមឱ្យបានកាន់តែប្រសើរឡើង។ | អ.ធ.ម. |